ទស្សនាវដ្តីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរកការពិត



- យើងមិនអាចគ្មានគុណូបការ
- ខ្ញុំនិទានរឿងប្រាប់ចៅៗ

លេខ០៣៩ ខែ មីនា ឆ្នាំ២០០៣

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣៩ ខែមីនា ឆ្នាំ២០០៣


## មាតិកា


- សំបុត្រៈ យើងមិនអាចគ្មានតុលាការ ..................................១

**ផ្នែកឯកសារ**

- អ្វីដែលមិនបដិវត្តន៍ ត្រូវតែកម្ចាត់.......................................៣
- សំឡេង ប៉ុល ពត នៅក្នុងត្រចៀកចិន...............................៧
- បញ្ជីឈ្មោះជនរងគ្រោះបរទេស.......................................១១
- ទស្សនៈបដិវត្តចំពោះសិទ្ធិសេរីភាពប្រជាធិបតេយ្យ................ ១២
- ជម្រាបបងជាទីស្នេហា(ឯកសារទូរលេខ) ...........................១៥
- បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ..........១៦
- សារាចរលេខ១០៦របស់បក្សភូមិភាគ...............................១៧
- ទំនាក់ទំនងនយោបាយរវាងប្រទេសថៃនិងប្រទេសកម្ពុជា..........១៨

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

- ខ្ញុំនិទានរឿងប្រាប់ចៅៗ ...........................................................២១
- បដិវត្តដែលគ្មានខ្លឹមសារ............ ...................................២៦
- ដោគវាសនារបស់អតីតយុទ្ធជនតំបន់៣១ ...........................២៨

**ផ្នែកច្បាប់**

- កម្ពុជាៈតុលាការដែលមានអំណាច.....................................៣១

**វេទិកាពិភាក្សាសាធារណៈ**

- ឱកាសចុងក្រោយសម្រាប់កម្ពុជា.......................................៣៦
- នីតិរដ្ឋនិងកេរដំណែលនៃជម្លោះ........................................ ៣៧
- កម្ពុជាត្រូវបង្ហាញនូវការតាំងចិត្តរបស់ខ្លួន............................៤៤
- សន្តិភាពនិងការផ្សះផ្សាជាតិ............................................៤៥
- កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា..............៥៤

**ទំព័រស្រាវជ្រាវរកគ្រួសារ**

- នៅតែមិនអស់ចិត្ត.......................................................៥៥

**សិល្បៈខ្មែរក្រហម**

- រូបថតខ្មែរក្រហម..............................................ក្របក្រោយ




យាយ គឹម មីន


## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះៈ*** *យិន នាន, ថ៉ាង ពីរ័ន, ឡុង ដានី, អៀ ម៉េងទ្រី, ហម ឆាយលី, ហ៊ុយ វណ្ណៈ* ***អ្នកនិពន្ធនិងស្រាវជ្រាវៈ*** *លី សុផល, សើ សាយព្រាណា* ***ជំនួយការ*** ***និពន្ធនាយកៈ*** *សាន់ កល្យាណ* ***និពន្ធនាយករងៈ*** *សួ ប៊ុនសូ៊* ***អ្នកបកប្រែៈ*** *អេង កុកថាយ* ***និពន្ធនាយកទូទៅៈ*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រៈ*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយៈ*** *មាស ប៊ុនថាន*

*សំបុត្រៈ*

# យើងមិនអាចគ្មានតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមបានទេ

១០ មីនា...

គ្រប់ពេលវេលាដែលមានការវិវឌ្ឍន៍សំខាន់ៗទាក់ទងនឹងបញ្ហាកាត់ទោសមេដឹកនាំខ្មែរក្រហម ខ្ញុំតែងតែគិតទៅដល់បងស្រីរបស់ខ្ញុំនិងប្រជាជនកម្ពុជាជិតពីរលាននាក់ដែលបានស្លាប់បាត់បង់ជីវិតក្នុងរបបខ្មែរក្រហម ។ ខ្ញុំបានគិតទៅដល់អ្នកទាំងនោះកាលពី២ខែមុន ពោលគឺនៅខែមករា ក្នុងពេលដែលអង្គការសហប្រជាជាតិបន្តការចរចាសាជាថ្មីជាមួយរាជរដ្ឋាភិបាលកម្ពុជាស្តីអំពីការបង្កើតឲ្យមានតុលាការមួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ មកដល់ខែមីនានេះ ខ្ញុំចាប់ផ្តើមគិតដល់បងស្រីរបស់ខ្ញុំនិងអ្នកដែលបានស្លាប់យ៉ាងវេទនាទាំងនោះម្តងទៀត ពីព្រោះជិតដល់ពេលមានកិច្ចប្រជុំយ៉ាងសំខាន់មួយរវាងអង្គការសហប្រជា-ជាតិនិងរដ្ឋាភិបាលនៅទីក្រុងភ្នំពេញ ។ មរណភាពដ៏គួរឲ្យព្រឺព្រួចរបស់បងស្រីខ្ញុំនិងប្រជាជនកម្ពុជារាប់លាននាក់ដែលត្រូវបានយកទៅសម្លាប់និងបង្អត់អាហារក្រោមស្នាដៃខ្មែរក្រហមបាននិងកំពុងតែអន្ទោលតាមប្រាណសង្គមកម្ពុជាអស់រយៈពេលជាងម្ភៃឆ្នាំមកហើយ ។ ខ្ញុំចង់ឲ្យព្រលឹងបងស្រីខ្ញុំនិងជនរងគ្រោះទាំងអស់ទៅកាន់សុគតិភព ។




ខ្ញុំអាចត្រឹមតែសង្ឃឹមថា ការចរចាដែលនឹងចាប់ផ្តើមនៅថ្ងៃទី១៣ ខែមីនា នឹងនាំឲ្យមានយុត្តិធម៌ជាមិនខាន ពីព្រោះខ្ញុំក៏ដូចជាប្រជាជនកម្ពុជាជាច្រើនសែននាក់មិនដែលបោះបង់ក្តីសង្ឃឹមនេះម្តងណាសោះឡើយ ។ ការទាមទារយុត្តិធម៌ត្រូវតែបន្តរហូតដល់យើងបានឈានដល់គោលដៅ ។

នេះប្រហែលគឺជាឱកាសចុងក្រោយបង្អស់សម្រាប់អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាល ក្នុងការបង្ហាញឲ្យឃើញថាភាគីទាំងពីរពិតជាមានសុឆន្ទៈចង់រកយុត្តិធម៌ឲ្យជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ខ្មែរក្រហម ។ អង្គការសហប្រជា-ជាតិ (ដែលទទួលស្គាល់ខ្មែរក្រហមជាផ្លូវការយ៉ាងយូរក្រោយពេលដែលពិភពលោកដឹងថាខ្មែរក្រហមបានប្រព្រឹត្តអំពើប្រល័យពូជសាសន៍) និងរាជរដ្ឋាភិបាលកម្ពុជា (ដែលអះអាងថាខ្លួនចង់កាត់ទោសមេដឹកនាំខ្មែរក្រហម ហើយមិនបានធ្វើឲ្យគ្រប់ជ្រុងជ្រោយតាមផ្លូវច្បាប់នោះ)គឺសុទ្ធតែមានកាតព្វកិច្ចជាប្រវត្តិសាស្ត្រធានាឲ្យមានយុត្តិធម៌ដល់ជនរងគ្រោះរាប់លាននាក់ ។ ប៉ុន្តែការខ្វែងគំនិតគ្នារបស់ភាគីទាំងពីរកំពុងតែធ្វើឲ្យរាំងស្ទះដល់កិច្ចព្រមព្រៀងរួមគ្នាមួយ ។

ការខ្វែងគំនិតគ្នាទីមួយគឺពាក់ព័ន្ធទៅនឹងបញ្ហាបទដ្ឋានយុត្តិធម៌អន្តរជាតិ ។ អ្នកជំនាញការមួយចំនួននិយាយថា តុលាការនៅក្នុង

ប្រទេសមួយដែលមានកម្រិតអភិវឌ្ឍដូចប្រទេសកម្ពុជាបច្ចុប្បន្ននេះ មិនអាចមានសង្ឃឹមថានឹងឈានសម្រេចបាននូវបទដ្ឋានយុត្តិធម៌ដែលមានលក្ខណៈអន្តរជាតិពេញលេញបានឡើយ ។ ប៉ុន្តែប្រទេសសេរ៉ាឡេអូននិងរ៉្វាន់ដាកំពុងមានតុលាការបទដ្ឋានអន្តរជាតិ ។ ហេតុអ្វីក៏មិនអាចកើតមាននៅកម្ពុជា? តើទ្វីបអាហ្វ្រិកមានបទដ្ឋានយុត្តិធម៌ខ្ពស់ជាងអាស៊ីឬយ៉ាងដូចម្តេច?

ការខ្វែងគំនិតគ្នាទីពីរគឺ ទាក់ទងទៅនឹងបញ្ហាបទដ្ឋានតុលាការ ពោលគឺបញ្ហាថាតើអ្នកណាគួរតែគ្រប់គ្រងតុលាការ ។ តើការផ្ទប់ទៅលើមោទកភាពជាតិធ្វើឲ្យយើងមិនអាចទទួលបាននូវយុត្តិធម៌ឬមួយយ៉ាងណា ប្រសិនបើយើងអនុញ្ញាតឲ្យអង្គការសហប្រជា-ជាតិគ្រប់គ្រងតុលាការ? តើហេតុអ្វីបានជាតុលាការចាំបាច់ត្រូវតែមានភាគីម្ខាងគ្រប់គ្រងលើភាគីម្ខាងទៀត? តើអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលមិនអាចធ្វើការរួមគ្នាដើម្បីរកយុត្តិធម៌ជូនដល់ជនរងគ្រោះទេឬយ៉ាងដូចម្តេច?

អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលត្រូវតែអនុវត្តតាមបទបញ្ញត្តិទាំងឡាយ ចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិដែលនាំឲ្យយើងមានការតាំងចិត្តសម្រេចឲ្យបាននូវលក្ខខណ្ឌនានាដើម្បីរក្សាការគោរពសិទ្ធិមនុស្ស ភាពថ្លៃថ្នូររបស់បុគ្គល យុត្តិធម៌ និងការគោរពកាតព្វកិច្ចកើតឡើងដោយច្បាប់អន្តរជាតិ ។

ទន្ទឹមគ្នានេះដែរ ក៏នៅមានបញ្ហាសំខាន់មួយទៀតដែលចាំបាច់ត្រូវតែដោះស្រាយ ។ នៅពេលដែលមេដឹកនាំខ្មែរក្រហមដែលត្រូវបានចោទប្រកាន់ជាសាធារណៈថាជាមេឃាតករប្រល័យពូជសាសន៍ធ្វើដំណើរយ៉ាងសេរីដោយគ្មានអ្នកណាអាចប៉ះពាល់បាន នេះគឺពិតជាការដែលមិនអាចទទួលយកបាន និងធ្វើឲ្យអ្នកដែលមានវាសនារួចចាកផុតពីអំពើប្រល័យពូជសាសន៍កាន់តែឈឺចាប់ខ្លាំងឡើង ។ មេដឹកនាំទាំងនោះចេះតែបន្តភាពត្រេកត្រអាលជាមួយនឹងនិទណ្ឌភាព(ភាពរួចទោស)របស់ខ្លួន ហើយក៏មិនខុសពី ប៉ុល ពត និង កែ ពក នោះឡើយ មេដឹកនាំដែលនៅរស់ទាំងប៉ុន្មានសង្ឃឹមថានឹងស្លាប់ដោយសុខស្រួលនៅលើដំណេករបស់ខ្លួនក្នុងខណៈដែលជនរងគ្រោះចេះតែបន្តឈឺចាប់ឥតស្រាកស្រាន្ត ។

រាជរដ្ឋាភិបាលគួរតែមានការចាប់ផ្តើមស៊ើបអង្កេតតាមនីតិវិធីព្រហ្មទណ្ឌទៅលើករណីបទល្មើសរបស់មេដឹកនាំខ្មែរក្រហម ក្នុងនោះរួមមាន អៀង សារី, នួន ជា, ខៀវ សំផន និង អៀង ធីរិទ្ធ ដែលត្រូវបានចោទថាជាអ្នកទទួលខុសត្រូវចំពោះបទឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ។ កម្ពុជានឹងមិនមានយុត្តិធម៌ពិតប្រាកដទេ ប្រសិនបើឃុំខ្លួន ម៉ុក និង ឌុច ដោយមិនបានទាំងធ្វើការស៊ើបអង្កេតអំពីសកម្មភាពនិងធ្វើការវិនិច្ឆ័យក្តីផងនោះ ។ មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមទាំងឡាយគួរតែត្រូវឃុំខ្លួនដូច ម៉ុក និង ឌុច ដែរ ចំណែកឯចៅក្រមស៊ើបអង្កេតត្រូវចុះធ្វើការស៊ើបអង្កេតឲ្យបានហ្មត់ចត់ ។

អ្វីដែលអង្គការសហប្រជាជាតិគួរតែធ្វើនៅក្នុងកិច្ចចរចានេះ គឺត្រូវតែស្មោះត្រង់ចំពោះប្រជាជនកម្ពុជា និងបើកចំហឲ្យនិយាយត្រង់ៗអំពីអ្វីដែលខ្លួនកំពុងតែធ្វើដើម្បីស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះ ។ អង្គការសង្គមស៊ីវិលកម្ពុជានានាបានសុំ ហើយសុំទៀតចង់ឲ្យមានតម្លាភាពនៅក្នុងកិច្ចចរចា ។ មកទល់នឹងពេលនេះនៅតែមិនច្បាស់ថា តើអង្គការសហប្រជាជាតិកំពុងតែពិភាក្សាអំពីរឿងអ្វីឡើយ ។ សហរដ្ឋអាមេរិក បារាំង ជប៉ុន និងឥណ្ឌា ថ្មីៗនេះ ក៏បានសុំឲ្យអង្គការសហប្រជាជាតិពន្យល់ពីបញ្ហានេះដែរ ។ បរិយាកាសអាថ៌កំបាំងដែលត្រឹមតែធ្វើឲ្យគេឯងចង់ដឹងនោះបានធ្វើឲ្យជនរងគ្រោះនៃរបបខ្មែរក្រហមកាន់តែអស់សង្ឃឹមទៅៗ ។ យើងត្រូវការឲ្យមានតម្លាភាពនៅក្នុងការចរចានេះ ។

រដ្ឋាភិបាលកម្ពុជាអាចទទួលបាននូវធម្មនុញ្ញរូបដែលខ្លួនចង់បាន ចំណែកឯអង្គការសហប្រជាជាតិអាចទទួលបាននូវបទដ្ឋានយុត្តិធម៌អន្តរជាតិដែលខ្លួនចង់បាន ប្រសិនបើភាគីទាំងពីរបង្ហាញចេញឲ្យឃើញនូវសុឆន្ទៈពិតប្រាកដ ។ អង្គការសហប្រជាជាតិនិងរដ្ឋាភិបាលត្រូវតែរកវិធីដោះស្រាយនៅក្នុងកិច្ចចរចាខាងមុខនេះប្រកបដោយឆន្ទៈនិងតម្លាភាព ចង់ទទួលបានជោគជ័យដែលប្រការទាំងនេះធ្វើឲ្យយើងយល់ច្បាស់ថាតើមានការរីកចម្រើនអ្វីខ្លះដែលបានសម្រេចដើម្បីឈានដល់គោលដៅរួមរបស់យើងទាំងអស់គ្នា ។ នៅពេលដែលការចរចាចាប់ផ្តើម ខ្ញុំនឹកគិតដល់បងស្រីខ្ញុំដែលស្លាប់យ៉ាងវេទនា ។ ដើម្បីបងស្រីខ្ញុំនិងជនរងគ្រោះរាប់លាននាក់នៃរបបខ្មែរក្រហមយើងមិនអាចគ្មានតុលាការបានទេ ។

**ឆាំង យុ**

*(អត្ថបទសង្ខេបចេញពីឯកសារចម្លើយសារភាព)*

# អ្វីដែលមិនបដិវត្ត ត្រូវតែកម្ចាត់

អ៊ីវ សេនារក្ស មានស្រុកកំណើតនៅក្នុងសង្កាត់លេខ៤ ទីក្រុងភ្នំពេញ ។ នៅក្នុងសម័យសង្គមរាស្ត្រនិយម(ឆ្នាំ១៩៦២) សេនារក្ស បានមកធ្វើការនៅក្រសួងការបរទេសភ្នំពេញ ក្រោយមកធ្វើជាអនុពន្ធនៅស្ថានទូតរុស្ស៊ីនៅទីក្រុងមូស្គូ ។ អ៊ីវ សេនារក្ស និងមន្ត្រីទូតកម្ពុជាមួយចំនួនបានវិលត្រឡប់មកកម្ពុជាវិញ ដើម្បីអនុវត្តផែនការរបស់សូវៀតដែលបានដាក់ឲ្យធ្វើ ។ នៅពេលមកដល់កម្ពុជា សេនារក្ស ត្រូវបានអង្គការឃាត់ខ្លួននិងសួរចម្លើយ ។ សេនារក្ស បានរៀបរាប់នូវសកម្មភាពការងារយ៉ាងលម្អិតជាមួយខ្សែបណ្តាញរបស់ខ្លួន ហើយខាងក្រោមនេះជាអត្ថបទដកស្រង់ចេញពីចម្លើយសារភាពរបស់គាត់÷

ឆ្នាំ១៩៦២ អ៊ីវ សេនារក្ស បានចូលធ្វើការនៅក្រសួងការបរទេសភ្នំពេញ ។ នៅពេលនោះ ទ្រី សេងហួត លេខាធិការក្រសួងការបរទេសជាអ្នកនាំ សេនារក្ស ចូលជាសេ.អ៊ី.អាដោយមាន សារិន ឆាក ជាអ្នកទទួលស្គាល់ ។ ញឹក ជូឡុង ដែលជារដ្ឋមន្ត្រីគឺជាអ្នកឧបត្ថម្ភប្រាក់ខែចំនួន៣៥០០រៀលក្នុងមួយខែ ។ កម្មវិធីនៃការចូលសេ.អ៊ី.អា គឺដំបូង សេនារក្ស ត្រូវមកបង្ហាញខ្លួនវេលាម៉ោង៩ព្រឹកនៅការិយាល័យរបស់ ញឹក ជូឡុង ដែលមាន ទ្រី សេងហួត ជាអ្នកឧទ្ទេសនាមនិងសូត្រពាក្យសម្បថនៅចំពោះមុខមេសេ.អ៊ី.អា ។ ខ្លឹមសារនៃសម្បថនោះមានអត្ថន័យថា "ស្មោះត្រង់ចំពោះសេ.អ៊ី.អាជានិច្ចក្នុងបេសកកម្មប្រឆាំងពួកកុម្មុយនិស្ត" ។ សេនារក្ស មានតួនាទីឃ្លាំមើលគ្រប់សកម្មភាពរបស់បុគ្គលិកក្រសួងការបរទេសក្រែងមានសកម្មភាពនយោបាយផ្សេងៗដែលប៉ះពាល់ដល់អាយុជីវិតក្រុមខ្សែសេ.អ៊ី.អា រួចហើយរាយការណ៍ពត៌មានទាំងនោះទៅឲ្យ សារិន ឆាក អគ្គលេខាធិការក្រសួងការបរទេស ។ ខែឧសភា ឆ្នាំ១៩៦៤ សារិន ឆាក ត្រូវទៅបំពេញបេសកកម្មនៅប្រទេសបារាំង ដូច្នេះតំណែងរបស់ សារិន ឆាក ត្រូវធ្លាក់មកលើ អ៊ុង ស៊ុយដេត វិញ ។

ឆ្នាំ១៩៦៥ សេនារក្ស និងភ្នាក់ងារ៤នាក់ឈ្មោះ ១) ស៊ីន សួប អតីតអធិបតីក្រសួងការបរទេស ២) គីម សាគុណ អតីតប្លង់តុងនៅក្រសួងការបរទេស ៣) ហាក់ អេង និង៤) ស៊ុម ម៉ានិត អតីតលេខាធិការក្រសួងការបរទេស បានទទួលផែនការមួយដើម្បីតាមដានសកម្មភាពការងាររបស់បុគ្គលិកនិងភ្ញៀវដែលមកទាក់ទងធ្វើការនៅក្រសួងការបរទេស ។ ហាក់ អេង (មេក្រុម) បានចាប់បុគ្គលិកពីរនាក់ឈ្មោះ អ៊ុំ សួន និង កែវ ជុន ពីបទសង្ស័យថា បានធ្វើសកម្មភាពបំផុសបុគ្គលិកដែលធ្វើការនៅក្រសួងការបរទេស ។ អ្នកទោសទាំងពីរត្រូវបានបញ្ជូនទៅដាក់ឃុំឃាំងនៅអគ្គសេនាធិការកងយោធពលខេមរភូមិន្ទ ។

ឆ្នាំ១៩៦៦ សេនារក្សនិងសមាជិក៤នាក់ទៀតបានចូលរួមប្រជុំការងារមួយដែលរៀបចំឡើងដោយ អ៊ុង ស៊ុយដេត ។ អ៊ុង ស៊ុយដេត បានលើកឡើងពីភាពមិនប្រក្រតីថា "សព្វថ្ងៃនេះចលនាខ្មែរក្រហមចេះតែរីកធំគ្រប់ទីកន្លែង ។ ដូច្នេះខ្សែសេ.អ៊ី.អារបស់យើងត្រូវធ្វើការយ៉ាងណាតាមដានកម្ចាត់ខ្មែរក្រហមឲ្យអស់ពីក្រសួងដើម្បីជាវិភាគទានមួយជួយរាជរដ្ឋាភិបាលក្នុងការថែរក្សារបបសព្វថ្ងៃឲ្យនៅគង់វង្ស" ។ ហាក់ អេង គឺជាអ្នកដឹកនាំសកម្មភាពនេះ ។ ភោគ ឆាយ អតីតលេខាធិការក្រសួងការបរទេស ត្រូវបានសង្ស័យថា ជាកម្មាភិបាលខ្មែរក្រហម(ព្រោះមានភ្នាក់ងារខ្មែរក្រហមតាមការពារ) ។ ភោគ ឆាយ បានលាលែងតំណែងក្រោយពីដឹងថាគ្រោះថ្នាក់នឹងកើតមានដល់ខ្លួន ។

ខែកុម្ភៈ ឆ្នាំ១៩៦៧ អ៊ុង ស៊ុយដេត និងក្រុមរបស់សេនារក្ស បានជួបប្រជុំនៅក្រសួងការបរទេសដើម្បីផ្លាស់ប្តូរសមាសភាពមេក្រុមសេ.អ៊ី.អា ពីព្រោះថា ហាក់ អេង ត្រូវចេញទៅបំពេញបេសកកម្មនៅបរទេស ហើយម្យ៉ាងទៀតដើម្បីស្វែងរកឬសគល់នៃបរាជ័យក្នុងបេសកកម្មចាប់ខ្មែរក្រហមម្នាក់ឈ្មោះ ភោគ ឆាយ ។ ស៊ុម ម៉ានិត ជាអ្នកមើលការខុសត្រូវជំនួស ហាក់ អេង ប៉ុន្តែឋិតនៅក្រោមបញ្ជារបស់ អ៊ុង ស៊ុយដេត ដដែល ។ សេនារក្សនិងក្រុមការងារបានបន្តធ្វើសកម្មភាពឆែកឆេរនៅក្នុង

ក្រសួងការបរទេស ហើយបានប្រទះឃើញខិត្តប័ណ្ណនិងឯកសារមួយចំនួនរបស់ភ្នាក់ងារបក្សប់ខ្មែរក្រហម ។ ប៉ុកដឹកុមារ(ស្លាប់) និង រស់ ដេតថូ បានគេចខ្លួន ។ នៅក្នុងឆ្នាំ១៩៦៧នេះ សេនារក្ស បានចូលរួមប្រជុំផែនការចំនួន៣លើក ។

ឆ្នាំ១៩៦៨ អ៊ីង ស៊ុយដេត ត្រូវទៅបំពេញបេសកកម្មនៅឯប្រទេសជប៉ុន ដូច្នេះតំណែងនេះត្រូវបានជំនួសដោយឆាយត្រី វិញ ។ មុននឹងចាកចេញ អ៊ីង ស៊ុយដេត បានហៅសមាជិក៥នាក់ចូលរួមប្រជុំ ជាពិសេសមេសេ.អ៊ី.អា ប្រចាំក្រសួងការបរទេស ១)ស៊ុម ម៉ានិត ២)ថ្វី សេងហួត ៣)ហុង សារេត ៥)គីម សាគុណ និង ៥) សេនារក្ស ដើម្បីរៀបចំឲ្យបុគ្គលិកនៅក្នុងក្រសួងការបរទេសធ្វើប្រវត្តិរូបផ្ទាល់ខ្លួនឲ្យបានច្បាស់អំពីអតីតភាពនិងសហការជាមួយទាហាន២នាក់ដែលយាមប្រចាំការនៅក្រសួងនេះ ។ ក្រោយពីអនុវត្តតាមផែនការប្រជុំហើយ សេនារក្ស បានធ្វើតេស្តជាប់ជានាយកបណ្ណាល័យនៅក្នុងស្ថានទូតខ្មែរប្រចាំនៅទីក្រុងម៉ូស្គូ ។ សេនារក្ស ក៏ត្រូវបាន ចាន់ សូរី ខទ្វេសនាមចូលជាសមាជិកកា.ហ្វេ.បេ នៅពេលនោះដែរ ។

ឆ្នាំ១៩៧០ ក្រុមកា.ហ្វេ.បេ របស់ សេនារក្ស នៅទីក្រុងម៉ូស្គូ មាន ចាន់ សូរី, ប្រាក់ សាឯម និង សឹន សួប ។ នៅក្នុងឆ្នាំនេះ សេនារក្ស បានចូលរួមប្រជុំចំនួន៥លើក ដោយមាន បូរីស ប៉ូស្នែតនីក អ្នកបកប្រែប្រចាំស្ថានទូតកម្ពុជានៅទីក្រុងម៉ូស្គូជាអ្នកដាក់ផែនការ ។ ផែនការរួមនៅក្នុងឆ្នាំនេះ បូរីស ប៉ូស្នែតនីក បានប្រាប់អំពីគោលបំណងរបស់សូវៀតថា សូវៀតតែងតែនៅជិតអ្នកស្នេហាជាតិខ្មែរដែលធ្វើការតស៊ូក្រោមទិវាទរណសិរ្សរួបរួមជាតិកម្ពុជា ។ សូវៀតចង់ឲ្យកម្ពុជាទទួលជោគជ័យទាំងស្រុងក្នុងពេលឆាប់ៗ ។ សេនារក្ស បានរាយការណ៍ផែនការទាំងនេះទៅឲ្យ ជា សាន ដើម្បីសុំយោបល់ក្នុងការអនុវត្តផែនការឲ្យមានប្រសិទ្ធភាព ។ ជា សាន និង សេនារក្ស បានទៅទំនាក់ទំនងការងារជាមួយសូវៀត ។ លុកស៊ីន លេខាធិការគណៈកម្មាធិការសូវៀតផ្នែកសន្តិសុខបានស្នើសុំ ជា សាន នូវឯកសារមួយចំនួនដែលទាក់ទងនឹងអ្នកស្នេហាជាតិខ្មែរ ។ នៅខែសីហា សេនារក្ស និង គុយជា បានអនុវត្តតាមផែនការរបស់ បូរីស ប៉ូស្នែតនីក ដោយបញ្ចុះបញ្ចូលបាននិស្សិតខ្មែរ១៨នាក់ បញ្ជូនទៅទីក្រុងប៉េកាំងដើម្បីចូលរួមជាមួយរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលកំពុងតែត្រូវការកម្លាំង ។

ខែមីនា ឆ្នាំ១៩៧១ ជា សាន បានផ្តល់បទសម្ភាសន៍មួយប្រាប់អ្នកកាសែតថា សម្តេច សីហនុ អាចមានលទ្ធភាពត្រឡប់ទៅមាតុប្រទេសវិញក្នុងករណីដែលអាមេរិកយល់ព្រមបញ្ឈប់សង្គ្រាមនៅកម្ពុជា ។ ខែឧសភា ឆ្នាំដដែល ជា សាន បានធ្វើដំណើរទៅទីក្រុងប៉េកាំង ។ ជា សាន បានដឹងថា គណៈប្រតិភូរណសិរ្សរួបរួមជាតិកម្ពុជាមួយក្រុមដែលដឹកនាំដោយ ដួង សំអុល អតីតសមាជិកការិយាល័យនយោបាយរណសិរ្សរួបរួមជាតិនិងជាអតីតរដ្ឋមន្ត្រីខាងដឹកនាំសម្ភាររបស់រដ្ឋាភិបាលរួបរួមជាតិកម្ពុជានឹងមកទស្សនកិច្ចនៅសហភាពសូវៀតតាមសេចក្តីអញ្ជើញរបស់គណៈកម្មការខាងសាមគ្គីធម៌អាស៊ី-អាហ្វ្រិករបស់សូវៀត ដែលនឹងប្រារព្ធធ្វើឡើងនៅខែកញ្ញា ឆ្នាំ១៩៧១ ។ ជា សាន ក៏ត្រូវបានអញ្ជើញជាផ្លូវការឲ្យចូលរួមក្នុងពិធីនោះដែរ ។ ប្រតិភូខាងកម្ពុជាដែលត្រូវចូលរួមមានចំនួនប្រាំនាក់គឺ ជា សាន, ហាក់សៀង ឡាយនី, បាន យ៉ាន, សួរ គីមហុង ដឹកនាំដោយ ដួង សំអុល ។ គោលបំណងនៃការពិភាក្សានេះគឺខាងកម្ពុជាចង់ឲ្យសូវៀតទទួលស្គាល់រាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជាដែលទើបបង្កើតថ្មីនិងឲ្យសូវៀតដកស្ថានទូតចេញពីកម្ពុជា ហើយផ្លាស់ប្តូរដំហររបស់ខ្លួនមកទាក់ទង ជា សាន ដែលកំពុងកាន់កាប់ស្ថានទូតខ្មែរប្រចាំនៅម៉ូស្គូវិញ ។ ប៉ុន្តែជាលទ្ធផល គឺសូវៀតជាអ្នកចំណេញទាំងស្រុង ។ សូវៀតមិនព្រមផ្លាស់ប្តូរដំហររបស់ខ្លួនឡើយ ។

ឆ្នាំ១៩៧២ ក្នុងឱកាសខួបលើកទី២នៃកំណើតរណសិរ្សនិងកំណើតកងទ័ពប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ដែលរៀបចំឡើងដោយអង្គការមហាជនសូវៀតនានា ដូចជាគណៈកម្មការសូវៀតខាងសាមគ្គីធម៌អាស៊ី-អាហ្វ្រិក គណៈកម្មការសូវៀតខាងសន្តិភាព គណៈកម្មការខាងស្ត្រីសូវៀត សមាគមមិត្តភាពសូវៀត-កម្ពុជានិងគណៈកម្មការយុវជនសូវៀត ។ ក្នុងឱកាសនោះតំណាងគណៈកម្មការនីមួយៗបានឡើងថ្លែងសុន្ទរកថាគាំទ្រម្តងម្នាក់ៗ ។ នៅខែឧសភា ជា សាន បានសម្រេចបញ្ជូន សេនារក្ស ទៅទីក្រុងប៉េកាំងដើម្បីបំពេញបេសកកម្មមួយចំនួនជួយអន្តរាគមន៍ឲ្យអតីតនិស្សិតម្នាក់ឈ្មោះ ព្រហ្ម ភឿន និងប្រពន្ធមករស់នៅនិង

ធ្វើការនៅប៉េកាំង ហើយភារកិច្ចមួយទៀតគឺទាក់ទងសម្តេច សីហនុ ដោយសុំឲ្យ ប៉ែន នុត ជួយធ្វើអន្តរាគមន៍ឲ្យ ជា សាន ទៅធ្វើជាឯកអគ្គរដ្ឋទូតកម្ពុជាប្រចាំប្រទេសរូម៉ានី ។ ខែមិថុនា សេនារក្ស បានមកដល់ប៉េកាំង ហើយចាប់ផ្តើមធ្វើការជាមួយខ្មែរកា.ហ្សេ.បេ មួយចំនួនដូចជាឈ្មោះ ហាក់ សៀងឡាយនី, ប៊ូច មាគបូរី, រឿមម៉ាច និង ជិន ឈុនលៀង ជាដើម ។ បន្ទាប់ពីបំពេញកិច្ចការរួច សេនារក្ស បានត្រឡប់មកបន្តការងារជាមួយក្រុមកា.ហ្សេ.បេ នៅមូស្គូវិញ ។

ឆ្នាំ១៩៧៣ សេនារក្ស បានចូលរួមប្រជុំចំនួន៣លើក ។ តាមរយៈការប្រជុំនេះ ប៉ូរីស ប៉ូស្នែតនីក បានចាត់តាំងឲ្យ ជា ខន ចូលបង្រ្គប់ក្នុងជួររណសិរ្សនៅប៉េកាំងដើម្បីពង្រីកខ្មែរកា.ហ្សេ.បេ បន្ថែម ។ តាមសេចក្តីរៀបរាប់របស់ សេនារក្ស បានឲ្យដឹងថា «ដោយឃើញថាសង្រ្គាមនៅកម្ពុជាកាន់តែរីករាលដាលធំឡើងៗ ប្រជាជននៅលើពិភពលោកបានធ្វើមិទ្ទីងគ្រប់ប្រទេស ។ ប្រជាជនសូវៀតបាននាំគ្នាចូលរួមប្រជុំក្រោមពាក្យស្លោកថា "សប្តាហ៍សាមគ្គីធម៌ជាមួយអ្នកស្នេហាជាតិខ្មែរ» ។ ខែកញ្ញា ប៉ូរីស ប៉ូស្នែតនីក បានប្រជុំសម្រេចបញ្ចូលអ្នកស្រី សេនារក្ស នាមដើមឈ្មោះ គីមវី ឲ្យចូលជាសមាជិកកា.ហ្សេ.បេខ្មែរម្នាក់ទៀត ។

នៅឆ្នាំ១៩៧៤ សេនារក្ស, ជា គុយ និងអ្នកស្រី គីមវី បាននាំគ្នាធ្វើសកម្មភាពជាបន្តបន្ទាប់ ដោយទំនាក់ទំនងការងារជាមួយ ជា សាន, ហាក់ សៀងឡាយនី, រឿម ម៉ាច, ហេង ពេជ្រ, គ្រិន លាន, ជា ខន និង ប៊ូច មាគបូរី (អ្នកទាំងនេះសុទ្ធតែមានតួនាទីសំខាន់ៗក្នុងរាជរដ្ឋាភិបាលរួបរួមជាតិកម្ពុជា) តាមរយៈសំបុត្រស្តីពីរឿងសូវៀតចង់ចូលតំបន់រំដោះ ។ ខែកញ្ញា រដ្ឋាភិបាលប៉េកាំងបានបញ្ជូន នូ ពេជ ទៅកាន់តំណែងជាភារធារីស្តីទីស្ថានទូតកម្ពុជានៅមូស្គូដែលគាំទ្រដោយសូវៀត ។ ក្រៅពីនេះ នូ ពេជ មានមុខតំណែងជាមេកា.ហ្សេ.បេ ។ នូ ពេជ ក៏បានសំណូមពរឲ្យសូវៀតជួយសម្តេចចូលស្រុកនិងមានអំណាចពេញដៃខ្លាំងជាងខ្មែរក្រហមផង ។ ចំណែក សេនារក្ស និងក្រុមការងារ បានទទួលបញ្ជាពី នូ ពេជ អនុវត្តផែនការពីរគឺ ១) ទាមទារឲ្យរដ្ឋាភិបាលកម្ពុជាបញ្ឈប់សង្រ្គាមនៅកម្ពុជា ដោយសុខចិត្តទទួលយកជ័យជម្នះដែលចក្រពត្តិអាមេរិកយល់ព្រមប្រគល់ឲ្យ ២) សុំឲ្យរដ្ឋាភិបាលលើកលែងទោសពួកកងទ័ពដែលស៊ីឈ្នួលឲ្យចក្រពត្តិ ។ ក្រោយពេលដឹងថាកងទ័ពរណសិរ្សកម្ពុជានឹងធ្វើយុទ្ធនាការវាយសម្រុកផ្តាច់ព្រ័ត្រសហភាពសូវៀត បានចាត់វិធានការជាបន្ទាន់ឲ្យពួក កា.ហ្សេ.បេ ដែលដឹកនាំដោយ នូ ពេជ ទាមទាររដ្ឋាភិបាលកម្ពុជាឲ្យបញ្ឈប់សង្រ្គាមតាមការស្នើសុំរបស់ចក្រពត្តិអាមេរិក ដោយសូវៀតសន្យាថានឹងប្រគល់សន្តិភាពមួយរយភាគរយដល់កម្ពុជាក្នុងរយៈពេលមួយសប្តាហ៍ ។

ខែមករា ឆ្នាំ១៩៧៥ ជា គុយ បានលាលែងពីតំណែងជាអនុពន្ធស្ថានទូតទៅធ្វើជាអ្នកកាសែតវិញ ហើយមកបន្តសកម្មភាពជាមួយ សេនារក្ស, អ្នកស្រី គីមវី, ឡាំ វ៉ារី និង នរោត្តម នរិន្ទ្រាពង្ស ទាក់ទងនឹងខ្មែរកា.ហ្សេ.បេនៅប៉េកាំងដដែល ។ ក្រុមកា.ហ្សេ.បេ បានបញ្ជូន ហេង ពេជ្រ, គ្រិន លាន និង ហាក់ សៀងឡាយនី ដែលជាខ្មែររបស់ខ្លួនទៅកាន់តំបន់រំដោះ ។ អ្នកទាំងបីនាក់នេះត្រូវបានចាត់តាំងឲ្យដើរផ្សព្វផ្សាយគ្រប់តំបន់នៅក្នុងប្រទេសកម្ពុជាឲ្យអបអរសាទរនិងទទួលសន្តិភាពថ្មីដែលស្ថិតក្រោមការគ្រប់គ្រងរបស់សូវៀត ។ ខែមីនា សេនារក្ស, ជា គុយ, អ្នកស្រី គីមវី និង អ៊ុយ ឡេន បានរាយការណ៍ទៅស្ថានទូតថាផែនការដែលសូវៀតដាក់ឲ្យ ស្តីពីការបញ្ឈប់សង្រ្គាមនៅកម្ពុជានោះបានផ្សព្វផ្សាយគ្រប់ភ្នាក់ងារកា.ហ្សេ.បេរួចហើយ ។

ថ្ងៃ១៧ មេសា ១៩៧៥ គឺជាថ្ងៃជោគជ័យរបស់ពួកខ្មែរក្រហម ។ នៅមូស្គូ ហ្សូប៊ីន អនុរដ្ឋមន្ត្រីក្រសួងការបរទេសសូវៀតបានអញ្ជើញ សេនារក្ស និង នូ ពេជ ចូលរួមបរិភោគអាហារថ្ងៃត្រង់ក្នុងគោលបំណងចង់ឲ្យភ្នាក់ងារកា.ហ្សេ.បេ ជួយបញ្ជូនអ្នកការទូតសូវៀត២០០នាក់ទៅកម្ពុជាដើម្បីបើកស្ថានទូតឡើងវិញ ។ ដើម្បីជាការដោះដូរគ្នា ហ្សូប៊ីន រដ្ឋមន្ត្រីក្រសួងការបរទេសសូវៀតក៏បានផ្ញើសារមួយច្បាប់ជូនរដ្ឋាភិបាលកម្ពុជាតាមរយៈ នូ ពេជ ។ សារនោះមានខ្លឹមសារថា «១) សូមប៉ាន់ប្រមាណមើលសម្ភារត្រូវការពីសូវៀតដើម្បីផ្តល់ឲ្យបញ្ហាជនដែលខ្វះខាតបន្ទាប់ពីសង្រ្គាម ។ ២) រដ្ឋាភិបាលសូវៀតស្នើបើកទ្វារស្ថានទូតឡើងវិញ ដោយមានអ្នកការទូតសូវៀតចំនួន២០០នាក់មកធ្វើការជាបន្ទាន់ ។ ៣) សូមរក្សាការពារស្ថានទូតសូវៀតកុំឲ្យមានអ្នកណាប៉ះពាល់ ។ ៤) សូមរក្សាការពារសន្តិសុខដល់ជនជាតិសូវៀត

៤នាក់ដែលជាប់នៅភ្នំពេញ ។ អស់រយៈពេល៧ខែ ផែនការនេះនៅតែមិនទាន់មានការឆ្លើយតប ។ នៅក្នុងចន្លោះពេលនោះ បូរីស ប៉ូស្ទែតនីក បានប្រជុំជាមួយសមាជិកកា.ហ្វេ.បេ ដើម្បីស្វែងយល់ពីអាថ៌កំបាំងរបស់កម្ពុជានិងអ្នកគ្រប់គ្រងថ្មី។ បូរីស ប៉ូស្ទែតនីក បាននិយាយទៀតថាៈ កម្ពុជាមានអាថ៌កំបាំងច្រើនណាស់ ត្រូវរកឲ្យឃើញ ក្រៅពី ប៉ុល ពត, អៀង សារី និង ខៀវ សំផន តើមានអ្នកណាទៀតដែលជាមនុស្សខ្លាំងនៅក្នុងអង្គការបដិវត្តកម្ពុជា ។

នរោត្តម ទិន្រ្ទាពង្ស និង អ្នកស្រី គីមវី ត្រូវបានប្រធានកា.ហ្វេ.បេបញ្ជូនឲ្យមកស៊ើបការណ៍នៅកម្ពុជា ។ ប៉ុន្តែលទ្ធផលនៅតែអវិជ្ជមាន ។ ប្រធានកា.ហ្វេ.បេ បានបញ្ជូន ឡាំវ៉ារី, អ៊ុយ ឡុន, ជា សាន និងអ្នកផ្សេងទៀតមកកម្ពុជាជាបន្តបន្ទាប់ ។ ឡាំវ៉ារី បានមកដល់កម្ពុជានៅខែកញ្ញា ឆ្នាំ១៩៧៦ ។ ចំណែក សេនារក្ស នៅតែបន្តការងាររហូតជាមួយសូវៀត ដោយចូលរួមប្រជុំជាមួយសមាជិកកា.ហ្វេ.បេមួយចំនួនដើម្បីចាត់វិធានការរកដំណោះស្រាយអំពីអាថ៌កំបាំងរបស់កម្ពុជាដែលមិនព្រមឆ្លើយតបតាមការស្នើសុំរបស់សូវៀត។ នៅទីបញ្ចប់ បូរីស ប៉ូស្ទែតនីក បានចាត់តាំងឲ្យ សេនារក្ស មកប្រទេសកម្ពុជាដើម្បីទាក់ទង ជា សាន និង ហាក់ សៀងឡាយនី ដែលបានមកដល់កម្ពុជាមុន ។ សេនារក្ស បានធ្វើដំណើរមកដល់កម្ពុជានៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ១៩៧៧ ។ មកដល់បានតែពីរថ្ងៃប៉ុណ្ណោះ សេនារក្ស ត្រូវអង្គការចាប់ខ្លួន ។

## អំពីក្រុមគ្រួសារ

ឪពុកឈ្មោះ អ៊ីវ សេន ធ្វើគយនៅភ្នំពេញ ម្តាយស្លាប់ ។ អ៊ីវសេនារក្ស មានបងប្អូន៣នាក់÷

អ៊ីវ អេងសេង ស្រី អាយុ៤៥ឆ្នាំ គ្មានគ្រួសារ

អ៊ីវ សេនារី ស្រី អាយុ៣៩ឆ្នាំ មានគ្រួសារឈ្មោះ ឌី ចំរុង លេខាក្រសួងសាធារណការភ្នំពេញ ។

អ៊ី សេនានី អាយុ៣១ នៅលីវ រៀននៅប្រទេសបារាំង ។

**រសី សាយ្យាណា**

---

បងឌុច

### វិធាការសួរចម្លើយVIII ថ្ងៃទី២៦ កញ្ញា ១៩៧៦

១) យើងខ្ញុំជំរុញដោយមាត់ទទេឲ្យសារភាពអំពីខ្សែក្បត់សំខាន់ៗដែលទាក់ទងវៀតណាម ហើយដែលអាចអនុវត្តផែនការក្បត់បាន តែកុំប៉ាតណាប៉ាណីច្របូកច្របល់ទៀត ។

ជំរុញថា ខ្សែក្បត់នៅបូព៌ានិយាយពុំទាន់ច្បាស់និយាយតែមនុស្សដែលបែកមុខ ហើយដែលពុំមានលទ្ធភាពធ្វើអ្វីបាន ។

២) យើងខ្ញុំកំញើញថា នឹងធ្វើទារុណកម្មនៅព្រឹកថ្ងៃ២៧ កញ្ញា ១៩៧៦ ។

៣) VIII ចាប់ផ្តើមសរសេរការវិវត្តសតិអារម្មណ៍របស់ផ្ទាល់ខ្លួន ។ រួចហើយសរសេរសំបុត្រតាមរយៈ យើងខ្ញុំ(ប៉ុន) ស្នើសូមជួប បងឌុច ថ្ងៃណា ពេលណាក៏បាន តាមយើងខ្ញុំអនុញ្ញាត ។ យើងខ្ញុំស្មានតែសាមីខ្លួនរកប្រតិកម្ម(ឯកសារសរសេរយើងខ្ញុំពុំដឹងថាសាមីខ្លួនមានសរសេរទេ) យើងខ្ញុំហែកសំបុត្រនោះចោល ហើយឡើងទៅស្តីឲ្យថា “យើងខ្ញុំអាចមានសមត្ថភាព ពាំនាំបញ្ហាអស់នោះរាយការណ៍ជូន បងឌុច បានដែរទេ” ។ សូមបញ្ជាក់លិខិតផ្ញើតាមមិត្ត អុន ដែលយាម ។

៤) VIII ផ្តល់ឯកសារសតិអារម្មណ៍ផ្ទាល់មកយើងខ្ញុំហើយ និយាយអំពីការវិវត្តសតិអារម្មណ៍ផ្ទាល់ខ្លួន យើងខ្ញុំបានពន្យល់អំពី “យើងម្នាក់ៗធ្វើបដិវត្តន៍ដើម្បីឧត្តមគតិមិនធ្វើខ្ញុំកញ្ជះគេ ព្រោះវាថ្លៃថ្នូរ...” ។

៥) ទទួលក្រដាសហើយ សាមីខ្លួនរាយការណ៍បន្ថែមអំពីខ្សែសផ្ទាក់និងផែនការក្បត់ដែលយើងខ្ញុំសរុបខាងលើនេះ ។ រួចយើងខ្ញុំណែនាំឲ្យសរសេរសេរី ។

២៦ កញ្ញា ១៩៧៦ ប៉ុន

*(ឯកសារដកស្រង់ចេញពីវិទ្យុផ្សាយសំឡេងកម្ពុជាប្រជាធិបតេយ្យ)*

# សំឡេង ប៉ុល ពត នៅក្នុងក្រចៀកចិន

ដោយវិទ្យុផ្សាយសំឡេងកម្ពុជាប្រជាធិបតេយ្យបានផ្សាយពីលើកមុន កាលពីថ្ងៃទី១១ ខែធ្នូ ឆ្នាំ១៩៧៨ វេលាព្រឹក សមមិត្ត ប៉ុល ពត លេខាគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនិស្តកម្ពុជា រដ្ឋមន្ត្រីទី១នៃរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យបានទទួលជួបសន្ទនាជាមួយសមមិត្ត លីន ណាន នាយករងអន្តរជាតិនៃទីភ្នាក់ងារសារពត៌មាន ស៊ិន ហ៊័រ និងគណៈប្រតិភូទីភ្នាក់ងារសារពត៌មាន ស៊ិន ហ៊័រ ដែលសមមិត្តដឹកនាំ ។

ក្នុងឱកាសនោះ សមមិត្ត ប៉ុល ពត បានជម្រាបសមមិត្តនៃទីភ្នាក់ងារសារពត៌មាន ស៊ិន ហ៊័រ អំពីសភាពការណ៍របស់កម្ពុជាប្រជាធិបតេយ្យ សមមិត្តលេខាបក្សយើងបានរំឭកអំពីគោលគំនិតយួនចង់យកកម្ពុជាធ្វើជាផ្នែកមួយរបស់វាតាមរយៈយុទ្ធ-សាស្ត្រសហព័ន្ធឥណ្ឌូចិនរបស់វា សមមិត្តលេខាបក្សយើងមានប្រសាសន៍ថា បក្សកុម្មុយនិស្តឥណ្ឌូចិនរបស់យួនបានកំណត់ថាធ្វើសហព័ន្ធឥណ្ឌូចិនដែលមានបក្សតែមួយ ប្រជាជនតែមួយ ប្រទេសតែមួយ គឺបក្សប្រជាជនតែមួយ ប្រទេសតែមួយរបស់យួន ដូច្នេះឈរលើយុទ្ធសាស្ត្រនេះ យួនបានធ្វើសកម្មភាពគ្រប់បែបយ៉ាងដើម្បីយកកម្ពុជា ប៉ុន្តែតាំងពីឆ្នាំ១៩៣០ មកដល់ឥឡូវគឺ៤៨ឆ្នាំហើយ យួនយកកម្ពុជាមិនបាន យួនវាបានធ្វើឧបាយកលគ្រប់បែបយ៉ាងទាំងអស់ តែវាសម្រេចទិសដៅវាមិនបាន។ សមមិត្តលេខា ប៉ុល ពត មានប្រសាសន៍ទៀតថា ក្រោយពីវារំដោះហើយ សរុបប្រទេសវាខាងជើងនិងខាងត្បូងរួចហើយ យួនចាប់ផ្តើមអនុវត្តយុទ្ធសាស្ត្រសហព័ន្ធឥណ្ឌូចិន និងអាស៊ីអាគ្នេយ៍ភ្លាម ។ កាលៈទេសៈដែលយួនអនុវត្តយុទ្ធសាស្ត្រនេះស្របនឹងកាលៈទេសៈដែលវាតទីនិយមសូវៀតអនុវត្តយុទ្ធសាស្ត្រវានៅអាហ្វ្រិក ។

នៅឆ្នាំ១៩៧៥,១៩៧៦ នៅអាហ្វ្រិក គុយបាបានដើរតួជាកងទ័ពស៊ីឈ្នួលឲ្យវាតទីនិយមសូវៀត ឯយួននៅអាស៊ីអាគ្នេយ៍នេះ វាក្រអើតក្រទមដាក់គេឯង ។ យួននិងសូវៀតសង្ឃឹមថា វាមានលក្ខណៈសម្បត្តិវាយយកកម្ពុជាដោយងាយ ហើយក្តាប់ប្រទេសឯទៀតនៅអាស៊ីអាគ្នេយ៍នេះដោយស្រួលបាន កម្ពុជាជាជំហានដំបូងធ្វើជាឈ្នាន់ ហើយពួកវាឈានទៅយកអាស៊ីអាគ្នេយ៍ ហើយពីអាស៊ីអាគ្នេយ៍ ពួកវាចង់ឈានទៅយកសកលលោកទាំងមូល ។ ប៉ុន្តែ យួនអនុវត្តផែនការជាយុទ្ធសាស្ត្រនេះមិនបានសម្រេចទេ នេះគឺមកពីប្រជាជនកម្ពុជាមិនអនុញ្ញាតឲ្យវាមិនចុះសារភាព ហើយទប់ទល់វាជាប់ សមមិត្តលេខា ប៉ុល ពត បញ្ជាក់ថា ដោយវាបរាជ័យជាបន្តបន្ទាប់ ដូច្នេះបានតែយួនវាយលុកឈ្លានពានកម្ពុជាដោយទ្រង់ទ្រាយធំនៅចុងឆ្នាំ១៩៧៧ ការវាយដោយទ្រង់ទ្រាយធំនេះ ជារូបភាពមួយដែលវាធ្វើឡើងដោយទ័លច្រក ។ យួនវាចង់វាយយកកម្ពុជាតែមួយព្រឹបតាមយុទ្ធសាស្ត្រវាយរហ័សឈ្នះរហ័ស យកបានកម្ពុជាក្នុងមួយព្រឹប វាអាចដោះស្រាយបញ្ហានយោបាយ យោធា សេដ្ឋកិច្ច និងទូតរបស់វាគ្មានអ្នកណាថាអីវាបានទេ ។ ប៉ុន្តែ យួនវាប៉ាន់ប្រមាណកម្លាំងវាហួសហេតុ យុទ្ធសាស្ត្រវាយរហ័សឈ្នះរហ័សត្រូវបរាជ័យជាមូលដ្ឋាន មូលហេតុ វាជាកងទ័ពឈ្លានពាន វាគ្មានមូលដ្ឋានអីនៅលើទឹកដីកម្ពុជាទេ វាគ្មានប្រជាជន គ្មានសេដ្ឋកិច្ចកងទ័ព១៤កងពលរបស់វាមកកន្លែងប្រហោង សមមិត្តលេខាបក្សយើងមានប្រសាសន៍ថាវាគ្មានស្អីជាកម្លាំងជួយឧបត្ថម្ភវាទេ វាត្រូវដឹកគ្រាប់ស្បៀងនិងទាហានវាមកពីខាងក្រោយ ក្នុងសភាពនេះវាមិនខ្លាំងទេ គឺវាចូលក្នុងវង្វង់យើងខ្ញុំ យើងខ្ញុំខ្លាំងជាងវា ពីព្រោះយើងខ្ញុំមានកងទ័ពជាទឹកដីយើងខ្ញុំ យើងខ្ញុំស្គាល់ភូមិសាស្ត្រ យើងខ្ញុំមានប្រជាជន មានស្បៀង ក្នុងលក្ខណៈសម្បត្តិនេះ យើងខ្ញុំវាយឈ្នះ វាយធំក៏បាន វាយតូចក៏បាន វាយពេលណាក៏បាន វាយពីមុខក៏បាន វាយពីក្រោយក៏បាន កាំភ្លើងតូចក៏ប្រើបាន កាំភ្លើងធំក៏ប្រើបាន ថ្មើរជើងប្រមូលផ្តុំក៏វាយបាន ឈ្លបក៏វាយបាន យើងខ្ញុំ

វាយមិនគ្រប់កន្លែងទាំងអស់ សមមិត្តលេខា ប៉ុល ពត មានប្រសាសន៍ថា កាលសង្គ្រាមលោកលើកទី២ ពួកឈ្លានពានចូលដល់ប្រទេសខ្លះ វាមានកន្លែងស៊ីផឹក រាំរែក ហ៊ោកញ្ជ្រៀវ ឯកងទ័ពយួន បើចូលក្នុងទឹកដីកម្ពុជាហើយ គ្មានកន្លែងរាំសប្បាយទេ វាត្រូវនៅក្នុងវាលដី វាត្រូវត្រៀមជាប់ ភ័យជាប់ ដូច្នេះវាមិនគ្រាន់តែមានមូលដ្ឋានសេដ្ឋកិច្ចនិងនយោបាយប៉ុណ្ណោះទេ វាឋិតក្នុងបរិយាកាសឯកោទាំងស្រុងទៀត ចាំតែពេលត្រូវកម្ទេច សមមិត្តលេខា ប៉ុល ពត មានប្រសាសន៍ថា កម្មាភិបាលដឹកនាំខាងយោធាកម្ពុជាក្តាប់ជាប់សភាពទំនាស់ខ្លាំង ពេលខ្មាំងយួនប្រមូលផ្តុំនៅលើទឹកដីវាហើយ វាបុកមួយព្រឹបមក វាសម្តែងឫទ្ធិ តែដល់វាចូលដល់ដីកម្ពុជាវាត្រូវពង្រាយ ដូច្នេះ វាចាញ់ វារុលទៅមុខទៀត វាកាន់តែស្តើងទៀត លូនកាន់តែឆ្ងាយវាលំបាកខាងដឹកជញ្ជូនគ្រាប់ស្បៀងនិងទាហានបន្ថែម ដូច្នេះកងទ័ពបដិវត្តកម្ពុជាអាចកាត់វាជាកង់ៗ ហើយកម្ទេចវាៗ សមមិត្តលេខា ប៉ុល ពត មានប្រសាសន៍ប្រាប់អ្នកយកពត៌មាននៃទីភ្នាក់ងារសារពត៌មាន ស៊ិនហ៊័រ ថា ក្នុងសង្គ្រាមប្រឆាំងយួនដើម្បីការពារប្រទេសក្រោមការដឹកនាំរបស់បក្សកុម្មុយនិស្តកម្ពុជា យើងខ្ញុំគិតគូរកត្តាយោធានយោបាយ ស្បៀងនិងមិត្តភក្តិលើសកលលោកៗ ក្នុងមួយឆ្នាំកន្លងទៅនេះ តាំងពីរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យប្រកាសប្រាប់ពិភពលោកពីអំពើឈ្លានពានវាតទីលេបទឹកដីរបស់យួនមកលើកម្ពុជាប្រជាធិបតេយ្យ កត្តាទាំងនេះប្រែប្រួលជាខ្លាំងៈ

១) នៅលើឆាកអន្តរជាតិពីឆ្នាំ១៩៧៧ យួនវាឃោសនាបោកប្រាស់ វាយប្រហារកម្ពុជាប្រជាធិបតេយ្យ និងបដិវត្តកម្ពុជា ពេលនោះ វានៅមានឈ្មោះបោះសំឡេង វានៅបន្លំគេបាន ឥឡូវសភាពការណ៍ក្រឡាប់ចាក់ យួនវាមានតែបួនដប់ទេ នៅខាងវា វាឯកោដល់កម្រិតខ្ពស់ អាស៊ីអាគ្នេយ៍ខាងកម្ពុជាត្រូវការខាងកម្ពុជាឯករាជ្យ កម្ពុជាឯករាជ្យជាប្រយោជន៍ប្រទេសអាស៊ីនិងសកលលោក យួនវាលែងបន្លំបាន បានជាវារត់ទៅឱបជើងវាតទីនិយមសូវៀត នេះជាសភាពទ័លច្រក យួនវាឱបជើងសូវៀតដើម្បីឲ្យសូវៀតជួយ តែវាត្រូវឯកោថែម គេកាន់តែឃើញមុខមាត់កាន់តែច្បាស់ សកលលោកទាំងមូលផ្អើលអំពីរឿងនេះ យួនវាបរាជ័យនិងឯកោកម្រិតខ្ពស់យ៉ាងនេះ សូវៀតម្នាក់ឯងក៏ជួយវាមិនរួចទេ ហេតុនេះបានជាវាតទីនិយមសូវៀតត្រូវទៅប្រមូលជើងក្នុងបក្សសម្ព័ន្ធយោធាវ៉ាសូវីមកជួយ ។ បើវាតទីនិយមសូវៀតជួយយួនបាន វាមិនទៅប្រមូលជើងក្នុងបក្សសម្ព័ន្ធយោធាវ៉ាសូវីទេ តែដល់សូវៀតទៅសុំដល់បក្សសម្ព័ន្ធយោធាវ៉ាសូវី ជួយយួន យួនកាន់តែឯកោទៀត កម្លាំងនៅក្នុងបក្សសម្ព័ន្ធវ៉ាសូវី ក៏ប្រឆាំងដែរ បើសូវៀតយកបក្សសម្ព័ន្ធយោធា វ៉ាសូវីមកអាស៊ីទៀត តើសភាពការណ៍យ៉ាងម៉េច ប្រទេសឯទៀតក៏ត្រូវគិតគូរដែរ ទិន្នាការស្អប់យួន ទិន្នាការផ្តន្ទាទោសយួន ទិន្នាការមិនជួយយួន ចេះតែវិវឌ្ឍទៅមុខទៀត បើសកលលោកឈប់ឲ្យអង្ករនិងស្បៀង យួនវារកអីដោះស្រាយមិនបានទេ ទិសវិវឌ្ឍយួនមួយឆ្នាំ ពីរឆ្នាំទៀត យួនមុខជាហិនហោចវិនាសអន្តរធានមែនទែន បក្សសម្ព័ន្ធសេដ្ឋកិច្ចសូវៀតកូមេកុង(*COMECON*)



ម៉ៅ សេទុង ប៉ុល ពត

ដោះស្រាយមិនរួចទេ ជួយបណ្តោះអាសន្នបានតែជួយជាបន្ទុក ហើយពយួនធ្វើសង្គ្រាមយូរអង្វែងប្រឆាំងកម្ពុជាមិនបានទេ ។ ប្រជាជនអឺរ៉ុបខាងកើតមុខតែក្រោកឈរឡើងប្រឆាំង ប្រភពដែលយួនពឹងពាក់មានតែមួយនេះហើយប្រភពឥតរឹងប៉ឹងទៅជួយយួនបានទេ ដូច្នេះក្នុងមួយឆ្នាំនេះ មតិសកលលោកមានការប្រែប្រួលខ្លាំងដែលនាំឲ្យយួនឯកោដល់កម្រិតនេះជាកត្តាអន្តរជាតិ ។

២) អំពីបញ្ហាសេដ្ឋកិច្ចនិងស្បៀង ប្រៀបធៀបកម្ពុជានិងយួន យួនអត់បាយ កម្ពុជាមានបាយហូប ដូច្នេះកម្ពុជាខ្លាំងជាងយួនខាងស្បៀងគូសត្រូវរបស់កម្ពុជាវាខ្សោយជាងកម្ពុជាខាងស្បៀង ហើយវាដោះស្រាយខ្លួនវាមិនរួច វាទៅពឹងពាក់សកលលោក សកលលោកឥឡូវមានតែផ្នែកសូវៀតទេដែលនៅជួយវា ដូចនេះសភាពការណ៍នេះមិនល្អចំពោះយួនទេ បើសង្គ្រាមពន្យារពេលទៅទៀត យួនកាន់តែហិនហោច ។


អៀង សារី

៣) កត្តានយោបាយ សភាពការណ៍កម្ពុជានឹងនជាមូលដ្ឋាន ឯយួនលំបាកខាងនយោបាយផ្ទៃក្នុងបក្សវាមិនឯកភាពទេ ពេលដែលលើកដែនការវាយកម្ពុជាវាឯកភាពគ្នា តែដល់វាយមិនបានម្នាក់ៗត្រូវគិតគូរ ឥឡូវសង្គ្រាមនេះនៅជំពាក់ស្មុគស្មាញ ឥឡូវវារករឿងចិនទៀត នាំឲ្យបាក់បែកសាមគ្គីផ្ទៃក្នុងវាថែមទៀត វិបត្តិសេដ្ឋកិច្ចក៏នាំឲ្យផ្ទៃក្នុងវាស្មុគស្មាញថែមទៀត ប្រជាជនវៀតណាមក៏ប្រឆាំងវាភាគខាងត្បូងប្រឆាំងពួកកាន់អំណាចមកពីខាងជើង អសន្តិសុខមានជាប់ ពិសេសនៅភាគខាងត្បូង ។ ខាងត្បូងមានលេចចេញបីចលនាដែលប្រឆាំងវា÷

១) ខាងផ្នែកខ្មែរកម្ពុជាក្រោម

២) ជនជាតិនៅខ្ពង់រាប ដែលហៅថា ចលនា ហ៊ុលរ៉ូ ពីមុនគឺចលនាតស៊ូរំដោះជនជាតិភ្នំនៅវៀតណាម ។

៣) ចលនានៅក្នុងប្រជាជនវៀតណាមខាងត្បូង មានពួករដ្ឋការអាធីវ ពួកកាតូលិច ពួកហ្វាហាវ ពួកកៅដាយ ។

សមមិត្តលេខា ប៉ុល ពត មានប្រសាសន៍ថា យើងខ្ញុំពិនិត្យកត្តាទាំងបី កត្តាមិត្តអន្តរជាតិ កត្តាសេដ្ឋកិច្ច និងស្បៀង កត្តាយោធាឃើញថា យើងខ្ញុំមានប្រៀបលើវា យើងខ្ញុំមានមូលដ្ឋានដើម្បីបន្តសង្គ្រាមការពារប្រទេស ឯយួនមូលដ្ឋានទាំងបីនេះវាលំបាកខ្លាំង ចំពោះកត្តាឯទៀត សមមិត្តលេខា ប៉ុល ពត មានប្រសាសន៍ថា ក្នុងឆ្នាំ១៩៧៧ និងដើមឆ្នាំ១៩៧៨ យួនវាចាញ់ជាយុទ្ធសាស្ត្រខាងវាយរហ័ស ឈ្នះរហ័ស ហើយវាបន្តវាយកម្ពុជាយើងខ្ញុំក្នុងឆ្នាំ១៩៧៨ ។ ក្នុងឆ្នាំ១៩៧៨នេះ វាវាយតាមព្រំដែនចុះឡើងៗ ធ្វើឲ្យកម្លាំងរបស់វាខ្ទេចខ្ទីច្រើន វាត្រូវបរាជ័យធ្ងន់ វាយកកម្ពុជាមិនបាន វារត់ទៅពឹងពាក់វាតទីនិយមសូវៀតនិងបក្សសម្ព័ន្ធយោធាវ៉ាសូវី បើវាមានកម្លាំងគ្រប់គ្រាន់ខាងយោធា វាមិនទៅពឹងពាក់ទេ ពីមុនវាច្រើនប្រើពាក្យស្លោកថា ជម្លោះវៀតណាមកម្ពុជាជាបញ្ហាព្រំប្រទល់ដែនដើម្បីបោកបន្លំ ឥឡូវវាបោកបន្លំលែងបាន វាត្រូវសកលភាវូបនីយកម្ម វាត្រូវទៅប្រមូលសកលលោកមកជួយ នាំឲ្យផ្អើលគេឯង ហើយឥឡូវសង្គ្រាមនេះចូលក្នុងសកលភាវូបនីយកម្មច្បាស់ណាស់ ។ សមមិត្តលេខា ប៉ុល ពត បានវិភាគអំពីកម្លាំងបក្សសម្ព័ន្ធយោធា វ៉ាសូវី ដូចតទៅៈ

តើបក្សសម្ព័ន្ធវៀតណាមអាចប្រើកម្លាំងអ្វីខ្លះ តើថ្មើរជើងមកយ៉ាងម៉េច យើងខ្ញុំយល់ឃើញថា វាអាចប្រើថ្មើរជើងខ្លះ តែពួកវាលំបាកខាងថ្មើរជើងណាស់ ពីព្រោះមកធ្វើសង្គ្រាមនៅកម្ពុជា ឆ្ងាយពីអឺរ៉ុបខាងកើត បើថ្មើរជើងមក១០០០០(មួយម៉ឺន)នាក់ មុខជាចោទបញ្ហាដល់ពួកវា ២០០០០(ពីរម៉ឺន)នាក់កាន់តែជាបញ្ហាទៀត ពីព្រោះពួកវាមិនស៊ីបាយនេះឯណា វាត្រូវដឹកបាយមកជាមួយ ជាទស្សនៈបក្សយើងខ្ញុំត្រូវហ៊ានថា វាប្រថុយប្រថាន ប្រើថ្មើរជើង តែវាមានការលំបាកច្រើននៅមានលទ្ធភាពទី២ ដែលវាប្រើទីប្រឹក្សារាប់ពាន់រាប់ម៉ឺននាក់ ទន្ទឹមនឹងនេះបក្សសម្ព័ន្ធយោធាវៀតណាម ជួយយន្តហោះ កាំភ្លើងធំ រថក្រោះមួយរយៈ ដំបូងខ្ញុំប៉ាន់ប្រមាណថា ពួកវាអាចឲ្យយួនច្រើនដើម្បីដោះស្រាយឲ្យរហ័ស តែដល់សង្គ្រាមពន្យារទៅទៀត ជាបញ្ហាដល់ពួកវា ឯយន្តហោះ រថក្រោះ មិនមែនជាបញ្ហាដល់យើងខ្ញុំទេ វាអាចឲ្យយើងខ្ញុំលំបាកមួយរយៈ ពេលវាបុកអាចឆ្ងាយខ្លះ យើងខ្ញុំត្រូវប៉ាន់បញ្ហានេះជាមុន តែកត្តាកំណត់គឺត្រូវមានថ្មើរជើងច្រើន ហើយវាយនៅលើទឹកដីយើងខ្ញុំ មុខជាវាមានការលំបាកច្រើន ពីព្រោះវាអត់ប្រជាជន អត់ស្បៀង វាត្រូវដឹកអ្វីៗទាំងអស់មកផ្គត់ផ្គង់ វាយយូរៗទៅ វាកាន់តែខ្ទេចខ្ទីកម្លាំងរបស់វា យើងខ្ញុំនៅតែវាយតាមវិធីដដែល កាត់កណ្តាលនិងកាត់កន្ទុយវា ដូច្នេះត្រូវវាត្រៀមស្រេច ដើម្បីការពារផ្លូវមួយកំណាត់ប្រវែង៥គីឡូម៉ែត្រ វាត្រូវការមួយវរសេនាតូច បើកាន់តែវែងត្រូវប្រើកម្លាំងការពារកាន់តែច្រើន បើមួយកងពលវាវាយបុកចូល១០គីឡូម៉ែត្រ ត្រូវប្រើមួយវរសេនាធំដើម្បីការពារផ្លូវ ដូច្នេះវាគ្មានកម្លាំងមកការពារគ្រប់គ្រាន់វាយបុកយើងខ្ញុំឆ្ងាយទេ យើងខ្ញុំឈរលើសង្គ្រាមយូរអង្វែង ឈរលើសង្គ្រាមយូរអង្វែងនេះ យើងខ្ញុំជឿជាក់លើជ័យជម្នះ យើងខ្ញុំកំពុងតាមដាន តើបក្សសម្ព័ន្ធវៀតណាម វាប្រើកម្លាំងអ្វីខ្លះ ។ បើវាប្រើកម្លាំងច្រើនរបស់បក្សសម្ព័ន្ធយោធា វៀតណាម ហើយវាផុងខ្លួននៅកម្ពុជា តើវាប្រហោងទេនៅកន្លែងឯទៀត វាត្រូវគិតគូរ ។ សមមិត្តលេខា ប៉ុល ពត មានប្រសាសន៍ទៀតថា យើងទប់ទល់ជាមួយយួននិងបក្សសម្ព័ន្ធវៀតណាមៈ

១) ជាភារកិច្ចជាតិ

២) ក៏ជាភារកិច្ចអន្តរជាតិដែរ ក្នុងឋានៈជាអ្នកការពារទង់ឯករាជ្យជាតិ អធិបតេយ្យភាព បូរណភាពទឹកដីផង និងជាអ្នកការពារទង់បដិវត្តផង ជាយុទ្ធសាស្ត្រយើងខ្ញុំគ្មានព្រួយបារម្ភទេ ជាយុទ្ធវិធីយើងខ្ញុំត្រូវប្រុងប្រយ័ត្ន និងខំប្រឹងប្រែង ចំពោះអង្គការយួនដាក់ឈ្មោះខ្មែរ សមមិត្តលេខា ប៉ុល ពត មានប្រសាសន៍ថា យួនទ័លសុញវាហើយបានជាវាបង្កើតអង្គការនេះវាគ្មានផ្លូវណាដើរទៀត វាបរាជ័យធ្ងន់ណាស់ បានជាវាបញ្ចេញប៉ាយមួយទៀតដើម្បីបោកបន្លំ តែមិនទាន់ចេះប៉ាយផងគ្រាន់តែហាណូយឃោសនាមួយថ្ងៃពីរថ្ងៃមុនគេដឹងអស់ ដល់ចេញមក ហើយសកលលោកដឹងថាគឺយួនទាំងអស់ ។ យួនវាធ្វើទាំងអស់នាំឲ្យវាបែកមុខថែមទៀត តាមស្គាល់ធាតុយួនវានៅតែធ្វើតទៅទៀត ហើយវាត្រូវបែកមុខតទៅទៀត ។

ថ្ងៃក្រោយវាដាក់ឈ្មោះកម្ពុជាហើយធ្វើសន្និសីទកាសែតជាដើម ។ ឆាកល្ខោននេះ កម្ពុជាយើងខ្ញុំធ្លាប់ស្គាល់ច្បាស់ណាស់សកលលោកក៏ស្គាល់វាដែរ ។ សមមិត្តលេខា ប៉ុល ពត មានប្រសាសន៍ទៀតថា នេះជាសភាពការណ៍ដែលខ្ញុំសូមជម្រាបអំពីកាលយួនឈ្លានពានកម្ពុជាកន្លងមក និងអំពីប៉ាន់ប្រមាណទៅអនាគត យើងខ្ញុំត្រូវខំប្រឹងប្រែងដោយខ្លួនឯង ក្នុងការតស៊ូនេះរបស់យើងខ្ញុំ យើងខ្ញុំបានទទួលការឧបត្ថម្ភគាំទ្រជាច្រើនពីមិត្តភក្តិលើសកលលោក ហើយមិត្តភក្តិកាន់តែច្រើនគាំទ្រយើងខ្ញុំ បក្សប្រជាជន កងទ័ព និងរដ្ឋាភិបាលចិន បានជួយឧបត្ថម្ភគាំទ្រយើងខ្ញុំជាបន្តបន្ទាប់ ឆ្លៀតឱកាសនេះយើងខ្ញុំតាងនាមបក្សកុម្មុយនិស្តកម្ពុជា ប្រជាជនកម្ពុជា កងទ័ពបដិវត្តកម្ពុជានិងរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះបក្សកុម្មុយនិស្តចិន ប្រជាជន កងទ័ពនិងរដ្ឋាភិបាលចិននិងចំពោះសមមិត្តប្រធាន ហ្វា កូហ្វឹង និងមជ្ឈិមបក្សកុម្មុយនិស្តចិនកន្លងមកបច្ចុប្បន្ននេះនិងទៅអនាគត យើងរួមគ្នាដើម្បីបុព្វហេតុរួមដើម្បីយកជ័យជម្នះ ព្រមជាមួយនេះ យើងខ្ញុំក៏សូមសម្តែងនូវអំណរគុណចំពោះមិត្តភក្តិទាំងអស់លើសកលលោក ។ កិច្ចសន្ទនាបានប្រព្រឹត្តទៅក្នុងបរិយាកាសរាក់ទាក់ប្រកបដោយភាតរភាពបដិវត្តយ៉ាងកក់ក្តៅបំផុត ។

# បញ្ជីឈ្មោះជនរងគ្រោះជនបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

រៀបរៀងដោយៈ យិន ឆាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ២៩១ | ង្វៀង ធីហ៊ុិន (ស្រី) | យួន | ចារកិច្ចយួន | កំពង់សោម | ៦-៩-៧៨ | ១៤-១០-៧៨ |
| ២៩២ | ង្វៀង យ៉ាំងថាន់ | យួន | បីញញី | ភូមិភាគនិរតី | ៦-៩-៧៨ | ១៤-១០-៧៨ |
| ២៩៣ | ឡេ យ៉ាំងឡឹយ | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ១២-៩-៧៨ | ១៤-១០-៧៨ |
| ២៩៤ | ធិន ធឿង (ស្រី) | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-៩-៧៨ | ១៤-១០-៧៨ |
| ២៩៥ | ហា ហួយ (ស្រី) | យួន | ចារកិច្ចយួន | ស្វាយរៀង | ១៣-៩-៧៨ | ១៤-១០-៧៨ |
| ២៩៦ | វិន ង៉ុកឡឹង | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៩-៧៨ | ១៤-១០-៧៨ |
| ២៩៧ | វិញ យ៉ាំងថាញ់ | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៩-៧៨ | ១៤-១០-៧៨ |
| ២៩៨ | ដាម ធីហឿង (ស្រី) | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៩-៧៨ | ១៤-១០-៧៨ |
| ២៩៩ | ត្រឹង ធីធូ (ស្រី) | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៩-៧៨ | ១៤-១០-៧៨ |
| ៣០០ | ត្រឹង ស៊ាំងថុង | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៩-៧៨ | ១៤-១០-៧៨ |
| ៣០១ | ង្វៀង យ៉ាំងចូវ | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ២៨-១០-៧៨ | ២០-១១-៧៨ |
| ៣០២ | ដឺ ឡាយ | យួន | ចារកិច្ចយួន | ភូមិភាគនិរតី | ២៨-១០-៧៨ | ២០-១១-៧៨ |
| ៣០៣ | ថាយ ថាន់ធិន | យួន | បីញញឹក | ត្បូងសាន | ២២-៧-៧៨ | ២-១២-៧៨ |
| ៣០៤ | ឡេ វ៉ាន់ណាំ | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៥-៧-៧៨ | ២-១២-៧៨ |
| ៣០៥ | ង្វៀង វ៉ាន់ឡាយ | យួន | ដាយវុយធីវគី | ត្បូងសាន | ២៤-៨-៧៨ | ២-១២-៧៨ |
| ៣០៦ | ង្វៀង យ៉ាំងយឿ | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៧-៩-៧៨ | ២-១២-៧៨ |
| ៣០៧ | ឡេ ធីយុងកាម(ស្រី) | យួន | ចារកិច្ចយួន | ស្វាយរៀង | ២៧-៩-៧៨ | ២-១២-៧៨ |
| ៣០៨ | វ៉ី វ៉ាងយ៉ាវ(ស្រី) | យួន | ស័ក្តិ១ធីវគី | មណ្ឌលគិរី | ៩-១០-៧៨ | ២-១២-៧៨ |
| ៣០៩ | ដាម យ៉ាំងទី | យួន | ធីវវុយធីវគី | មណ្ឌលគិរី | ៩-១០-៧៨ | ២-១២-៧៨ |
| ៣១០ | ង្វៀង វ៉ាន់សាង | យួន | ស័ក្តិ១ធីវគី | មណ្ឌលគិរី | ៩-១០-៧៨ | ២-១២-៧៨ |
| ៣១១ | ដាម យ៉ាំងវន | យួន | ស័ក្តិ១ធីវគី | មណ្ឌលគិរី | ៩-១០-៧៨ | ២-១២-៧៨ |
| ៣១២ | ង្វៀង ស៊ុនហ្វា | យួន | ដុងវុយធីវគី | ក្រចេះស្នួល | ១៣-១០-៧៨ | ២-១២-៧៨ |
| ៣១៣ | ត្រឹង យ៉ាំលីង | យួន | ដុងវុយធីវគី | ស្វាយរៀង | ១៣-១០-៧៨ | ២-១២-៧៨ |
| ៣១៤ | តា ថាន់ទី | យួន | ធីវវុយធីវគី | មណ្ឌលគិរី | ៨-១១-៧៨ | ២-១២-៧៨ |
| ៣១៥ | វិន ធិន | យួន | ធីវវុយធីវគី | មណ្ឌលគិរី | ៨-១១-៧៨ | ២-១២-៧៨ |
| ៣១៦ | ង្វៀង កុងថាញ់ | យួន | ប្រជាជន | ស្វាយរៀង | ១៣-៥-៧៨ | ២៧-៥-៧៨ |
| ៣១៧ | ឌៀប គីងហុក | យួន | ប្រជាជន | កំពង់សោម | ២៨-៤-៧៨ | ២៧-៥-៧៨ |

(នៅមានត)

# ទស្សនៈបដិវត្តចំពោះសិទ្ធិសេរីភាពប្រជាធិបតេយ្យ

*នៅក្នុងវចនានុក្រមខ្មែរដែលបោះពុម្ពផ្សាយនៅឆ្នាំ១៩៦៧ បានឲ្យនិយមន័យ«**សិទ្ធិ**»ថា ផលសម្រេច សេចក្តីសម្រេច សេចក្តីសុខ សេចក្តីខ្លាំងពូកែ សេចក្តីសម្រេចតាមអំណាចច្បាប់ អំណាច សេចក្តីអង់អាច មុខការដែលត្រូវសម្រេចលើខ្លួន... ។*

*នៅក្នុងសៀវភៅ«លោកប្រជាធិបតេយ្យ»បោះពុម្ពនៅឆ្នាំ ១៩៩៤ រៀបរៀងដោយវិទ្យាស្ថានសាធារណរដ្ឋអន្តរជាតិនិងវិទ្យាស្ថានកម្ពុជាដើម្បីសិទ្ធិមនុស្សបានពន្យល់ថា សិទ្ធិមានពីរ÷ សិទ្ធិពីកំណើតនិងសិទ្ធិផ្តល់ឲ្យ ។ ១) សិទ្ធិពីកំណើត គឺជាសិទ្ធិដែលភ្ជាប់មកជាមួយយើង ទោះបីជាយើងមិនចង់បានក៏ដោយក៏យើងមិនអាចបដិសេធបានឡើយ ។ សិទ្ធិដែលយើងមិនអាចបំភ្លេចបាននោះ គឺសិទ្ធិមានជីវិតសិទ្ធិក្នុងការរស់នៅ ។ ជីវិត គឺជាទ្រព្យសម្បត្តិទីមួយរបស់មនុស្សនិងជាកម្មសិទ្ធិផ្តាច់មុខរបស់មនុស្សម្នាក់ៗ គ្មាននរណាម្នាក់លើលោកនេះអាចយកជីវិតរបស់យើងបានឡើយ ។ ២) សិទ្ធិផ្តល់ឲ្យគឺជាសិទ្ធិដែលមនុស្សមួយក្រុម ឬរដ្ឋាភិបាលបានផ្តល់ឲ្យ ។ ប្រជាធិបតេយ្យគឺជាអំណាច(សេចក្តីសម្រេចចិត្ត) កំពូលរបស់ប្រជាពលរដ្ឋក្នុងការសម្រេចចិត្តធ្វើអ្វីគ្រប់យ៉ាងដរាបណាសកម្មភាពនោះមិនត្រូវបានហាមឃាត់ដោយច្បាប់ដ៏ជាក់លាក់ណាមួយ ។ ដូចជានៅក្នុងពេលបោះឆ្នោត យើងមានសិទ្ធិសម្រេចជ្រើសរើសយកគណបក្សណាមួយតាមដែលយើងពេញចិត្ត និងយល់ថាជាមនុស្សស្មោះជាតិពិតប្រាកដ ។ សេរីភាព គឺជាអំណាចដែលអាចធ្វើអ្វីតាមអំពើចិត្តដែលឋិតក្រោមក្របខ័ណ្ឌនៃច្បាប់របស់រដ្ឋ ។ នៅក្នុងរបបកម្ពុជាប្រជា-ធិបតេយ្យក៏លើកយកទស្សនៈស្តីអំពីសិទ្ធិសេរីភាពប្រជា-ធិបតេយ្យមកណែនាំយុវជន-យុវនារីដែរ ។ តើសិទ្ធិសេរីភាពប្រជាធិបតេយ្យបានផ្តោតជាសំខាន់ទៅលើអ្វី?*

*ក្រោយពីជ័យជម្នះថ្ងៃ១៧ មេសា ១៩៧៥ កម្ពុជាប្រជា-ធិបតេយ្យបានសរសេរថា«យើងបន្តធ្វើបដិវត្តន៍និងកសាងសង្គមនិយមយ៉ាងសស្រាក់សស្រាំ ពិសេសយុវជនយុវនារីបដិវត្តបានបន្តធ្វើពលិកម្មនិងប្តេជ្ញាចិត្តលះបង់អ្វីៗទាំងអស់ដើម្បីសម្រេចគោលដៅបដិវត្តសង្គមនិយមឲ្យបានលឿនមហាលោតផ្លោះមហាអស្ចារ្យក្រោមការដឹកនាំដ៏ត្រឹមត្រូវរបស់បក្សកុម្មុយនិស្តកម្ពុជា ។ ក្រោមការដឹកនាំបំពាក់បំប៉នរបស់បក្សកុម្មុយនិស្តកម្ពុជា យុវជនយុវនារីបានបន្តប្រយុទ្ធធ្វើបដិវត្តន៍ខាងសតិអារម្មណ៍យ៉ាងជ្រាលជ្រៅ ដើម្បីវាយកម្ទេចគោលជំហរសតិអារម្មណ៍ កម្មសិទ្ធិខាងសតិអារម្មណ៍ កម្មសិទ្ធិខាងមនោសញ្ចេតនា កម្មសិទ្ធិខាងលោកទស្សនៈជីវទស្សន៍ សីលធម៌ និងវាយកម្ទេចទម្លាប់ចាស់ទាំងអស់ ។ យុវជន យុវនារីត្រូវយល់ឲ្យច្បាស់ថា បើគ្រាន់តែមានសេចក្តីប្តេជ្ញាចិត្តខ្ពស់ ហ៊ានធ្វើពលិកម្មគ្រប់បែបយ៉ាង តែបើនៅមានលោកទស្សនៈមិនត្រឹមត្រូវនោះក៏មិនអាចសម្រេចទិសដៅបដិវត្តសង្គមនិយមនិងកសាងសង្គមនិយមនៅកម្ពុជាបានជោគជ័យទាំងស្រុងនឹងឆាប់រហ័សដែរ ។ យុវជន យុវនារីត្រូវប្រយុទ្ធបំពាក់បំប៉នខ្លួននូវលោកទស្សនៈបដិវត្តដែលជាទស្សនៈត្រឹមត្រូវវិទ្យាសាស្ត្រនៃវណ្ណៈអធនឲ្យកាន់តែរឹងប៉ឹងខ្លាំងក្លាឡើង ។ បណ្តាលោកទស្សនៈទាំងអស់នេះ យុវជន យុវនារី ត្រូវតែមានលោកទស្សនៈត្រឹមត្រូវចំពោះសិទ្ធិសេរីភាពប្រជាធិបតេយ្យ» ។*

*នៅក្នុងសៀវភៅកំណត់ហេតុកម្ពុជាប្រជាធិបតេយ្យបានប្រៀបធៀបសិទ្ធិសេរីភាពប្រជាធិបតេយ្យនៅក្នុងរបបរបស់ខ្លួនទៅនឹងសិទ្ធិសេរីភាពរបស់វណ្ណៈនាយទុនដោយពន្យល់អំពីសិទ្ធិរបស់វណ្ណៈនាយទុនថា «សិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់វណ្ណៈនាយទុននៅក្រោមច្បាប់រដ្ឋធម្មនុញ្ញបានបើកសេរីភាពឲ្យប្រជាជនមានសិទ្ធិក្នុងការនិយាយស្តី មានមតិ សរសេរនិងដើរហើរតាមចិត្ត ។ ប៉ុន្តែជាក់ស្តែងពួកនេះបានក្តាប់អំណាចទាំងអស់ ។ សេរីភាពរបស់ពួកនាយទុនមានត្រឹមតែលើក្រដាសប៉ុណ្ណោះ នៅក្នុងការអនុវត្តជាក់ស្តែងគឺគ្មានទាល់តែសោះ ។ ជនណាដែលជាដៃជើងរបស់វា(ពួកនាយទុន) ការសរសេរនិយាយស្តីបញ្ចេញយោបល់សរសើររបបវា លើកឥទ្ធិពលវណ្ណៈវា ឬបម្រើ ឃោសនាអប់រំរបបវាគឺពួកនោះមានសិទ្ធិសេរីភាពនឹងធ្វើតាមចិត្តមែន ។ ប៉ុន្តែបើប្រជាជនណា ឬមហាជនណាហ៊ាននិយាយស្តី ហ៊ានមានមតិ*

ឬហ៊ានលិយាយ សរសេរការពិតជាក់ស្តែងក្នុងសង្គមនាយទុន ដែលជិះជាន់សង្កត់សង្កិនទីផពុករលួយអាវ៉ាសែ ឬហ៊ាននិយាយ បញ្ចេញយោបល់ការពារផលប្រយោជន៍ប្រទេសជាតិ ការពារផលប្រយោជន៍អ្នកដែលត្រូវពួកវាជិះជាន់ឆក់ប្លន់នោះ មុខជានឹងត្រូវពួកនាយទុនយកច្បាប់យករដ្ឋធម្មនុញ្ញរបស់ខ្លួនមកបកស្រាយ ដើម្បីចោទប្រកាន់ ចាប់ចង ដាក់គុកច្រវាក់ ធ្វើទារុណកម្មលើរូបរាងកាយយ៉ាងព្រៃផ្សៃរហូតដល់ប្រហារជីវិតយ៉ាងកំរោលទៀតផង ។ បើប្រៀបធៀបនឹងរបបសង្គមចាស់វិញ គ្មានអ្នកកាសែត ឬទស្សនាវដ្ដីណាហ៊ានសរសេរអំពីវីរភាព អំពីពលិកម្មនិងលើសរសើរអំពីទេពកោសល្យរបស់ប្រជាជន កម្មករ កសិករ និងពលករឡើយ ។ កាលពីសង្គមចាស់មានសៀវភៅជាច្រើនបានឃោសនាអប់រំនិងផ្សព្វផ្សាយតែអំពើអបាយមុខភូតកុហកកេងប្រវ័ញ្ចគ្រប់បែបយ៉ាង ។ ប្រជាជនដែលមានចំនួនច្រើនលើសលប់រហូតដល់ជាង៩០ភាគរយ មិនអាចរកស៊ីប្រណាំងប្រជែងជាពួកនាយទុនបានឡើយ ។ ហេតុដូច្នេះហើយបានជាប្រជាជន កម្មករ កសិករ ពលករ ដែលមានបាតដៃទទេធ្លាក់ខ្លួនកាន់តែក្រទៅៗ រហូតដល់លក់កម្លាំងពលកម្មទៅឲ្យពួកនាយទុនដែលរង់ចាំរឹបអូសជិះជាន់កម្លាំងពលកម្មប្រជាជនក្រីក្រប៉ុណ្ណោះ ។ ទាំងនេះគឺធាតុពិតក្លែងក្លាយរបស់ពួកនាយទុន ។ នៅក្នុងការឈរឈ្មោះបោះឆ្នោតជ្រើសតាំងប្រជាជនមានសិទ្ធិអាចទៅបោះឆ្នោះបានដោយសេរី ប៉ុន្តែការពិត ពួកនាយទុនបានធ្វើច្បាប់មួយដោយដាក់លក្ខខណ្ឌ សេដ្ឋកិច្ច ហិរញ្ញវត្ថុ នយោបាយ និងសីលធម៌មុនជាស្រេចដើម្បីរារាំងនិងបំបិទសិទ្ធិនេះទៅវិញ ។ ដូចជាការឈរឈ្មោះជាបេក្ខជនឲ្យគេបោះឆ្នោតគឺពួកវាតម្រូវឲ្យបង់ជាលុយកាក់ទ្រព្យសម្បត្តិយ៉ាងច្រើនសម្រាប់ធានា ហេតុនេះហើយបានជាប្រជាជន កម្មករ កសិក ពលករ ដែលក្រីក្រមិនអាចបំពេញតាមលក្ខខណ្ឌបានទេ មានតែពួកដៃជើងរបស់ខ្លួនប៉ុណ្ណោះដែលអាចមានលទ្ធភាពឈរឈ្មោះជាបេក្ខជនបាន ។ ដូច្នេះសិទ្ធិសេរីភាពប្រជាធិបតេយ្យ ដែលវណ្ណៈនាយទុនប្រកាសថាផ្ដល់ឲ្យប្រជាជន កម្មករ កសិករ ពលករ គឺគ្រាន់តែជាការបោកប្រាស់ បន្លំភ្នែកបំភ័ន្តមតិមហាជនប៉ុណ្ណោះ ។ ធាតុពិតក្លែងក្លាយ បោកប្រាស់នៃសិទ្ធិសេរីភាពរបស់វណ្ណៈពួកនាយទុនពិតប្រាកដ គឺសិទ្ធិសេរីភាពក្នុងការអត់ឃ្លានដាច់ពោះស្លាប់និងសិទ្ធិសេរីភាពក្នុងការធ្វើខ្ញុំកញ្ជះគេ» ។

តើទស្សនៈសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់បដិវត្តមានខ្លឹមសារពិតដូចម្ដេច?



រដ្ឋអំណាចបដិវត្តកម្ពុជាប្រជាធិបតេយ្យបានផ្ដល់សិទ្ធិជាអាទិភាពទៅលើប្រជាជន កម្មករ កសិករគឺជាម្ចាស់ប្រទេស ។ ដូច្នេះ ជ័យជម្នះដែលទទួលបាននៅថ្ងៃ១៧ មេសា ១៩៧៥ គឺថ្ងៃប្រវត្តិសាស្ត្ររបស់ប្រជាជនកម្ពុជាដែលបានមកពីការខិតខំប្រឹងប្រែងរបស់វណ្ណៈកម្មករ កសិករ ។ ស្ទើរតែគ្រប់ហេដ្ឋារចនាសម្ព័ន្ធចាស់ៗត្រូវបានបំផ្លាញចោល ហើយចាប់ផ្ដើមស្ថាបនាប្រទេសឡើងវិញពីកម្លាំងមនុស្សសុទ្ធសាធដោយយកវិស័យកសិកម្មជាមូលដ្ឋាន ដោយធ្វើស្រូវឲ្យបាន៣តោនក្នុង

១ហិកតាតាមទិសមហាលោតផ្លោះមហាអស្ចារ្យ ។ ប្រជាជនកម្ពុជាទាំងអស់ត្រូវបានរបបកម្ពុជាប្រជាធិបតេយ្យរៀបចំឲ្យមានសិទ្ធិស្មើៗគ្នា ។

រដ្ឋអំណាចបដិវត្តកម្ពុជាប្រជាធិបតេយ្យពន្យល់អំពីទស្សនៈសិទ្ធិសេរីភាពប្រជាធិបតេយ្យដល់យុវជនយុវនារីឲ្យយល់ច្បាស់អំពីសិទ្ធិនេះថា «*ទោះបីជាប្រទេសកម្ពុជាទើបងើបផុតពីសង្គ្រាមវិនាសកម្ម ខ្វះមុខខ្វះក្រោយយ៉ាងណាក្តី ក៏រដ្ឋអំណាចបដិវត្តខិតខំដោះស្រាយអស់លទ្ធភាពផ្គុងផ្គើមប្រជាជនឲ្យមានហូបគ្រប់ៗគ្នា ទោះបាយក្តី បបរក្តី ផលដែលយើងទទួលបាន យើងចេះចែករំលែកគ្នាហូបទាំងអស់គ្នា គ្មាននរណាម្នាក់ហូបតែម្នាក់ឯងសុខចិត្តឲ្យអ្នកដទៃដាច់ពោះស្លាប់នោះទេ ។ ប្រជាជន កម្មករ កសិករ មានសិទ្ធិបង្កបង្កើនផលចិញ្ចឹមជីវិតខ្លួនឯង និងរួមចំណែកកសាងប្រទេសទាំងអស់គ្នា ដោយគ្មាននរណា ជំពាក់បំណុលអ្នកណាឡើយ ។ ទាំងអស់គ្នាគឺជាម្ចាស់ប្រទេស ម្ចាស់បដិវត្ត ម្ចាស់លើវាសនាអនាគតរបស់ខ្លួនដូចៗគ្នា ។ ប្រជាជនកម្ពុជាទាំងអស់នាំគ្នាវាយសម្រុកបង្កបង្កើនផលកសាងនិងការពារប្រទេសឯករាជ្យម្ចាស់ការដោយគំនិតច្នៃប្រឌិតរស់រវើក គ្មានភ័យព្រួយបារម្ភអំពីរឿងជិះជាន់ទារបំណុល ឬត្រូវបង់ពន្ធអាករសព្ទសាពើពីរឿងម្ចាស់បំណុលរឹបអូសយកដីធ្លីទៀតឡើយ ។ ប្រជាជនមានសិទ្ធិសេរីភាពប្រជាធិបតេយ្យ មានសម្លៀកបំពាក់បិទបាំងកាយ មានជម្រករស់នៅគត់មត់ មានសិទ្ធិក្នុងការរៀនសូត្រ វប្បធម៌ នយោបាយ បច្ចេកទេសនិងវិទ្យាសាស្ត្រផ្សេងៗ ។ ថ្វីដ្បិតតែថា កម្ពុជាប្រជាធិបតេយ្យពុំទាន់បានបើកសាលាមធ្យមសិក្សា ឧត្តមសិក្សាជាខ្សែសង្វាក់ដូចពួកសក្តិភូមិ តែប្រជាជនយើងទាំងនៅទីក្រុង ជនបទនិងនៅព្រៃភ្នំចុងកាត់មាត់ញកសុទ្ធតែបានរៀនអក្សររៀននយោបាយ ហើយយកចំណេះទាំងនោះមកបម្រើ ការពារនិងកសាងប្រទេសបានយ៉ាងស័ក្តិសិទ្ធិ ។ ប្រជាជន កម្មករ កសិករ មានសិទ្ធិចូលរួមការបោះឆ្នោះជ្រើសរើសតំណាងរបស់ខ្លួន ហើយក៏អាចឈរឈ្មោះជាតំណាងឲ្យគេបោះឆ្នោតបានដែរ ក៏ប៉ុន្តែអ្នកទាំងនោះត្រូវតែមានលក្ខណៈសម្បត្តិបួនយ៉ាង÷ ១) មានស្មារតីស្នេហជាតិ ស្នេហាប្រជាជន បម្រើកម្មករ កសិករ ពលករ ឲ្យអស់ពីចិត្តពីថ្លើមនិងស្មោះស ។ ២) សកម្មប្រយុទ្ធក្នុងកិច្ចការពារនិងកសាងប្រទេសគ្រប់ពេលវេលា ។ ៣) មានគោលជំហរនយោបាយសតិអារម្មណ៍និងចាត់តាំងបដិវត្តរឹងប៉ឹងត្រឹមត្រូវល្អ ។ ៤) មានមហាជនស្រឡាញ់ជឿទុកចិត្តកក់ក្តៅ ។ បេក្ខជនដែលត្រូវឈរឈ្មោះអាចឃោសនាតាមចិត្ត ទោះជាចង់ឃោសនាក្រើកមេឃដីយ៉ាងណាក៏ដោយឲ្យតែការឃោសនានោះបម្រើនិងការពារផ្តល់ប្រយោជន៍ប្រជាជន កម្មករ កសិករ ភាគច្រើនលើសលប់ដាច់ខាតនោះមានន័យថា ប្រជាជនមានសិទ្ធិសេរីភាពពេញបរិបូរណ៍*» ។ ក្រៅពីលក្ខណៈសម្បត្តិខាងលើនេះ បក្សបានស្ទាបស្ទង់មតិ ស្តាប់យោបល់ពីប្រជាជន កម្មករ កសិករ យើងជាមុនថា ការជ្រើសរើសនេះពិតជាបានទទួលការស្រឡាញ់ពេញចិត្តពីប្រជាជន ហើយអ្នកនោះបានបម្រើផលប្រយោជន៍ឲ្យប្រជាជនយ៉ាងពិតប្រាកដមែន ។ កត្តាទាំងនេះ ហើយដែលរដ្ឋអំណាចកម្ពុជាប្រជាធិបតេយ្យចាត់ទុកថាសិទ្ធិសេរីភាពប្រជាធិបតេយ្យដែលរដ្ឋប្រគល់ជូនប្រជាជន កម្មករ កសិករ ពលករ ពិតជាប្រជាធិបតេយ្យមួយរយភាគរយ ។

ខ្មែរក្រហមបានផ្តល់សិទ្ធិទៅឲ្យប្រជាជន កម្មករ កសិករ ពលករ កម្ពុជាស្មើរតែគ្រប់យ៉ាង រហូតដល់ផលិតផលដែលបានមកពីការខិតខំប្រឹងប្រែងរបស់ប្រជាជនក៏ត្រូវយកមកដាក់រួមហូបរួមដែរ ពោលគឺរួមសុខរួមទុក្ខជាមួយគ្នាបើអត់ហូបគឺត្រូវអត់ទាំងអស់គ្នា ទាំងនេះហើយដែលពួកខ្មែរក្រហមគិតថាជាសិទ្ធិសេរីភាពប្រជាធិបតេយ្យមួយដែលខុសអំពីសិទ្ធិរបស់ពួកនាយទុន និងជាសិទ្ធិដែលខ្លួនផ្តល់ឲ្យប្រជាជនដោយពេញលេញ ។ ប៉ុន្តែខ្មែរក្រហមកំពុងមើលរំលងអំពីសកម្មភាពខ្លួនឯង ដែលបានរំលោភលើសិទ្ធិរបស់ប្រជាជនកម្ពុជាយ៉ាងធ្ងន់ធ្ងរ ។ សិទ្ធិនោះគឺសិទ្ធិមានជីវិត មិនថាមនុស្សចាស់ឬក្មេងត្រូវតែមានជីវិត វិញ្ញាណដូចៗគ្នា ។ ខ្មែរក្រហមពុំបានផ្តល់សិទ្ធិរស់រាន មកឲ្យប្រជាជនឡើយ កុំថាឡើយមនុស្សចាស់ សូម្បីតែទារកដែលកើតមកក៏ត្រូវទទួលរងនូវទារុណកម្មនិងសម្លាប់ដែរ ។ ក្នុងអំឡុង៣ឆ្នាំ៨ខែនិង២០ថ្ងៃក្រោមការគ្រប់គ្រងរបស់ខ្លួន សិទ្ធិរស់រានរបស់ប្រជាជនកម្ពុជារាប់សែននាក់ត្រូវបានរលត់បាត់ពីលោក ។ បច្ចុប្បន្ននេះនៅពុំទាន់មានមេដឹកនាំខ្មែរក្រហមណាម្នាក់ ព្រមទទួលខុសត្រូវចំពោះអំពើរបស់ខ្លួននៅឡើយទេ ។

**លី សុផល**

*(ឯកសារទូរលេខៈ លេខ២៥)*

# សូមជម្រាបបងជាទីគោរព

ថ្ងៃទី៦ ខែមីនា វេលារសៀលខាង៧ បានដំណើរមកដល់កន្លែងធ្វើការរបស់យើងតាមកំណត់ ។

១) សមាសភាពប្រតិភូមាន÷

ប្រតិភូយោធាភូមិភាគទី៥រួមមាន១៥នាក់ ក្នុងនេះមាន លីយ៉ាង ជាប្រធាន ក្នុងនេះកម្មាភិបាលទទួលខុសត្រូវខេត្តផ្ទេក្ង កង់ទុំ ៣នាក់ ខេត្តដាឡាក់២នាក់ និងកម្មាភិបាលយោធាភូមិភាគទី៥ចំនួន២នាក់ គឺ លីយ៉ាង និង អ៊ីបូ ។

ប្រតិភូរបស់វៀតណាម-កម្ពុជារួមមាន៨នាក់ដែលមាន ទឹកាម ប្រធាននិង បាតិន អនុប្រធាន ។

ក្រោពីនោះជំនួយការ ។ ក្នុងនេះ លីយ៉ាង ទទួលខុសត្រូវរួម ។

២) បានលើក«១»ប្រជុំនៅវេលាម៉ោង៣ ។...យើងខ្ញុំបាន...ទៅខាង៧(វៀតណាម) មានមតិមុន លីយ៉ាង បានខុទ្ទេសនាមអត្ថបទ...វាយម៉ាស៊ីន ។ យើងខ្ញុំសូមសរុបជូនអង្គការនូវខ្លឹមសារអត្ថបទនោះដូចតទៅ÷

ក) លើកសភាពការណ៍ភូមិមុន អូររ៉ាយ ថាមានការប៉ះទង្គិចបន្ទូរឈាមទាំងសងខាង ។ គេថា ត្រង់ចំណុចនោះជាទឹកដីរបស់គេ ។ល ។ ខ) លើបញ្ហាខាងកម្ពុជាប្រមូលនិងដកប្រជាជនភូមិសោប ។ គ) លើកសភាពការណ៍១០៥ ដែលមានការវាយគ្នាពីថ្ងៃ២៥ ខែ២ និងថ្ងៃ២៩ ខែ២នេះម្តងទៀត ។ គេថា ខាងកម្ពុជាបានចូលជ្រៅទៅខាងដី៧ ចម្ងាយពី៤-៥គ.ម យើងចូលខាងត្បូងជាកំហ៊ុត ។

**ជាបញ្ចប់គេលើកសំណូមពរ៣÷**

ក) ក្នុងពេលរង់ចាំបក្សទាំងពីរនិងរដ្ឋាភិបាលទាំងពីរសម្រេចដោះស្រាយបញ្ហាព្រំដែនពិតប្រាកដ ទាំងពីរខាងនូវខ្សែបន្ទាត់ព្រំដែនមួយបណ្តោះអាសន្នដើម្បីចៀសវាងការប៉ះទង្គិចគ្នានឹងដើម្បីងាយស្រួលដល់កិច្ចសហការផ្សេងៗតាមព្រំដែន ។ ទាំងរតគិរី និងមណ្ឌលគិរី ។ ខ) ស្នើខាងយើងដោះស្រាយប្រជាជនភូមិសោបឲ្យទៅខាងគេវិញ ។ គ) គេស្នើពិភាក្សាសម្រេចជាលក្ខការណ៍មួយចំនួនអំពីការទាក់ទងចេញចូលទៅមកតាមព្រំដែន ។ល ។ ដោយគេចាប់អារម្មណ៍ខ្លឹមសារទាក់ទងថ្នាក់ខេត្តដែលជាប់ព្រំដែនគ្នា ដូចជាផ្ទេក្ងនិងកង់ទុំ និងរតនគិរី ដាឡាត បានធ្លុកមណ្ឌលគិរីជាដើម ។

បរិយាកាសជួបគ្នា រីករាយស្និទ្ធស្នាល កក់ក្តៅ

អាកប្បកិរិយា ពាក្យសម្តីរាបសា មិនប្រងើងប្រងាងដូចលើកមុនទេ តាមមតិសង្កេតរបស់ស.ម ប៉ុត មិនមានប្រើពាក្យសម្តីថាឈ្លានពានដូចមុនទេ ។

លីយ៉ាង ខុទ្ទេសនាមចប់នៅវេលាម៉ោង៥កន្លះល្ងាច ។

ដោយការហត់នឿយក្នុងការធ្វើដំណើរវែង យប់ថ្ងៃ៦-៣ នេះសម្រាក ។ ព្រឹកថ្ងៃ៧ ខែ៣ ខាងយើងខុទ្ទេសនាម ។

៣) យើងខ្ញុំបានត្រៀមគម្រោង÷

ទីមួយៈ សម្រួលកសាងប្រទេសក្រោយរំដោះថ្ងៃ១៧ ខែ៤ ក្នុងក្របខ័ណ្ឌនិង១០៩ ។ ទីពីរៈ លក្ខណៈពិសេសរបស់១០៩ ដែលមានការទាក់ទងដល់បដិវត្តវៀតណាមខាងត្បូងពិសេសចាប់តាំងពី១៩៧០មកទល់ថ្ងៃរំដោះ ។ ទីបីៈ ការជួយឧបត្ថម្ភគ្នារវាងបក្សទាំងពីរប្រជាជនទាំង២ វៀតណាម-កម្ពុជាក្នុងសង្គ្រាមរំដោះជាតិ ។ ទីបួនៈ លើកព្រឹត្តិការណ៍តាមព្រំដែនមួយចំនួន«ក្រោយរំដោះ»,គួរឲ្យស្តាយ ◆ព្រឹត្តិការណ៍អូរតាបូក អូរតាកយ៉ាក អូរឡាពើង ពីខែ៩-៧ ចាត់តាំងមកទទួលនៅថ្ងៃទី១៦ ខែ៣នេះ ។ ◆ការចាត់តាំងគណៈទទួលរវាងខេត្តជាប់ព្រំដែនគ្នាយល់ព្រមជាគោល-ការណ៍ ។ ស្នើខាង៧ រៀបចំកម្មាភិបាលតាមខេត្តទាំងនោះ ហើយខុទ្ទេសនាមមកខាង១០៩តាមផ្លូវ១៩ ។ ខាងខ្ញុំនឹងរៀបចំនិងខុទ្ទេសនាមឲ្យទាំង២ខាងជួបគ្នាតាមជាក់ស្តែង ។ ខាងរតនគិរី យើងខ្ញុំត្រៀមសមមិត្ត ប៉ុត សមមិត្ត នា ខាង៨០១ និងម្នាក់ទៀតខាងតំបន់ ខាងសមមិត្ត ឡៅ ។ ឯខាងមណ្ឌល១០៥ នឹងពិភាក្សាជាមួយសមមិត្ត ឡាំង ក្រោយ ។ សូមបងណែនាំថែម ។

ដោយគោរព ភាតរភាពបដិវត្តយ៉ាងកក់ក្តៅបំផុត ។ **យ៉ា**

ថ្ងៃទី៧-៣-៧៥

**បន្ថែមៈ** បើអង្គភាពយល់ព្រមយើងខ្ញុំស្នើខាង៨៩ជួយណែនាំខាង៩២០ឲ្យបង្កង់សកម្មភាពប្រយុទ្ធសិន ។ ខាងយើងខ្ញុំទាក់ទង៩២០ មិនព្រួសោះអស់រយៈយូរដែរហើយ ។

**ចម្លងជូនៈ** បងប៉ុល បងនួន បងខៀវ បងវ៉ាន់ បងឿន ទុកឯកសារ ។

# បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

រៀបចំនិងចងក្រងដោយៈ យិន នាន

*(តពីលេខមុន)*

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច | |
|---|---|---|---|---|---|---|
| ៦៥៩ | សាម មុិញសិញ | ប្រជាជនថ្មី | កំពង់ឆ្នាំង | ១៧-២-៧៦ | ១១-៦-៧៦ | |
| ៦៦០ | ព្រុំ សុីណារុធ | ដាំស្ទូនៅអគ្គការអ៊ែអេស | ពោធិ៍សាត់ | ១-៣-៧៦ | ១១-៦-៧៦ | |
| ៦៦១ | ឃី យួន | ប្រជាជន | តំបន់២៥ | ១-៣-៧៦ | ១១-៦-៧៦ | |
| ៦៦២ | យុយ ង៉ិចសែ | បុគ្គលិកមន្ទីរ២៥ | តំបន់២៥ | ១-៣-៧៦ | ១១-៦-៧៦ | |
| ៦៦៣ | ពក ង៉ែត | កម្មករនេសាទ | កំពង់សោម | ១-៣-៧៦ | ១១-៦-៧៦ | |
| ៦៦៤ | នួប ទឹម | កម្មករនេសាទ | កំពង់សោម | ១-៣-៧៦ | ១១-៦-៧៦ | |
| ៦៦៥ | អ៊ុត ហ៊ាង | មេពួក | ចំការរដូង | ៥-១-៧៦ | ១១-៦-៧៦ | ឃើ |
| ៦៦៦ | អ៊ុង វន | អនុក្រុម | រោងចក្រកែវ | ១៨-១២-៧៥ | ១១-៦-៧៦ | ឃើ |
| ៦៦៧ | ដៃ ផល | យុទ្ធជន | វត្តបោ | ២៨-១២-៧៥ | ១១-៦-៧៦ | ឃើ |
| ៦៦៨ | ហៈ ឆុន | ធនាគារ | មុខកំពូល | ២៩-១-៧៦ | ១១-៦-៧៦ | ឃើ |
| ៦៦៩ | រស់ សាន | កសិដ្ឋាន | តំបន់២៥ | ៩-៥-៧៦ | ១១-៦-៧៦ | ឃើ |
| ៦៧០ | ដួង ទី | យុទ្ធជន | ពោធិ៍ចិន | ២៧-៣-៧៦ | ១១-៦-៧៦ | ឃើ |
| ៦៧១ | អឿង យាម | យុទ្ធជន | ស-២១យ | ៣០-៧-៧៦ | ១១-៦-៧៦ | |
| ៦៧២ | ពុំ ពិល | យុទ្ធជន | តាខ្មៅ | ២៧-៣-៧៦ | ១៣-៦-៧៦ | ឃើ |
| ៦៧៣ | យឹម សារឿន | យុទ្ធជន | រោងចក្រធ្វើកង់ | ?-៣-៧៦ | ១៤-៦-៧៦ | |
| ៦៧៤ | គាន់ ស៊ុម | កម្មករ | កំពង់ស្ពឺ | ២៨-៥-៧៦ | ១៤-៦-៧៦ | |
| ៦៧៥ | អេង ព្រិន | យុទ្ធជន | តាខ្មៅ | ១៧-៣-៧៦ | ១៦-៦-៧៦ | ឃើ |
| ៦៧៦ | សៀម ហោ ហៅ ម៉េង អ៊ីង | ព្រិទ្ធបាលទោ | ព្រែកក្ដាម | ៣-៤-៧៦ | ១៧-៦-៧៦ | |
| ៦៧៧ | ថាច់ ឃៀម | ពេទ្យទាហាន | តំបន់១៥ | ៣០-៣-៧៦ | ១៧-៦-៧៦ | |
| ៦៧៨ | ឈឹម សុភាព | ទាហាន | កំពង់សោម | ២៩-៥-៧៦ | ១៧-៦-៧៦ | |
| ៦៧៩ | ពេជ ចិន្ដា | សក្ដិ៣ | កំពង់សោម | ២៩-៥-៧៦ | ១៧-៦-៧៦ | |
| ៦៨០ | កៅ គឹមលី | ពលទោ | កំពង់សោម | ៧-៥-៧៦ | ១៧-៦-៧៦ | |
| ៦៨១ | ដាន់ ប្រាក់ | ពលទោ | កំពង់សោម | ៧-៥-៧៦ | ១៧-៦-៧៦ | |
| ៦៨២ | ប៉ែន ដុន | ពលទោម៉ារីន | កំពង់ស្ពឺ | ២៨-៥-៧៦ | ១៧-៦-៧៦ | |
| ៦៨៣ | អ៊ុក សឿន | ពលទោ | កំពង់ស្ពឺ | ២៨-៥-៧៦ | ១៧-៦-៧៦ | |
| ៦៨៤ | ទី យ៉េន | កុម្ម៉ង់ដូ | កំពង់ស្ពឺ | ២៨-៥-៧៦ | ១៧-៦-៧៦ | |

(នៅមានត)

# សារាចរលេខ១០៦ របស់បក្សភូមិភាគ

ចាប់តាំងពីថ្ងៃ១៧ មេសា ១៩៧៥ ជាថ្ងៃដែលយើងរំដោះក្រុងភ្នំពេញនិងទូទាំងប្រទេស សភាពការណ៍មានការប្រែប្រួលក្រឡាប់ចាក់លើគ្រប់វិស័យ ។

បក្សភូមិភាគចាប់អារម្មណ៍និងមានវិធានការអប់រំនិងណែនាំបន្តបន្ទាប់ដល់កងកម្លាំងប្រដាប់អាវុធយើងដើម្បីចៀសវាងនូវការវិវឌ្ឍន៍មិនល្អ ពិសេសដើម្បីទប់ទល់ចំពោះសតិអារម្មណ៍កម្មសិទ្ធិសួនតួនិងបាតុភាពមិនល្អផ្សេងៗគ្រប់បែបយ៉ាង ។

**១) បញ្ហាអាវុធៈ** ពេលធ្វើដំណើរត្រូវមានគ្នាតិច ទោះទៅធ្វើការដោយមានការចាត់តាំង ឬទៅសួរសុខទុក្ខគ្រួសារក៏ដោយដាច់ខាតមិនត្រូវយកអាវុធទៅតាមឡើយ ។ លើកលែងតែ÷

ក) កម្មាភិបាលដែលអង្គការកំណត់បំពាក់កាំភ្លើងខ្លីជូនទើបមានសិទ្ធិយកកាំភ្លើងខ្លីនោះតាមការពារខ្លួន ។

ខ) អង្គភាពដែលត្រូវទៅប្រតិបត្តិការទើបមានសិទ្ធិយកអាវុធជាចាំបាច់ទៅតាមខ្លួន ។

ដូច្នេះដើម្បីអនុវត្តសេចក្ដីកំណត់នេះបាន អង្គភាពនីមួយៗត្រូវម្ចាស់ការចាត់តាំងផ្នែកទទួលខុសត្រូវ ថែទាំទុកដាក់អាវុធឲ្យបានត្រឹមត្រូវនិងហ្មត់ចត់ ។

**២) បញ្ហាកសាងគ្រួសារ** សូមគណៈបញ្ជាការគ្រប់ថ្នាក់រៀនសូត្រណែនាំសារាចរលេខ១០៥ យោធា៧៥ដែលណែនាំពីបញ្ហាកសាងគ្រួសារនេះឡើងវិញ ។ ព្រមជាមួយនេះយើងខ្ញុំសូមបញ្ជាក់មួយចំនួនថែមទៀត÷

ក) បើចង់ស្នើកសាងជាមួយនារីណាមួយ ត្រូវស៊ើបសួរឲ្យដឹងជាសម្ងាត់នូវប្រវត្តិរូប ពិសេសពិនិត្យនិន្នាការនយោបាយនិងវណ្ណៈរបស់នារីសិន ។ បើឃើញថាសមស្របទើបរាយការណ៍ជូនអង្គការដើម្បីអង្គការស៊ើបពិនិត្យថែម បើសមស្របអង្គការនឹងគិតគូរស្ដីដណ្ដឹងជូន ។

ខ) ដើម្បីរក្សាប្រពៃណីល្អប្រសើររបស់ប្រជាជនយើងនិងរក្សាសីលធម៌បដិវត្តយើងឲ្យកាន់តែល្អផូរផង់ថែមទៀត សាមីខ្លួនមិនត្រូវស្នើនារីដោយផ្ទាល់ខ្លួនឯងឡើយ ។ សមមិត្តណាអនុវត្តល្មើសលើបញ្ហានេះ សូមចាត់ទុកជាល្មើសវិន័យយោធាហើយត្រូវទទួលវិន័យទៅតាមទោសកំហុស ។

គ) បញ្ហាសុំខបត្តម្ភពីប្រជាជនៈ ដោយបច្ចុប្បន្នប្រជាជនយើងកំពុងជួបប្រទះការលំបាកខាងជីវភាពកងទ័ពយើងត្រូវបញ្ឈប់ឲ្យបានដាច់ខាតនិងស្ដាពរនូវការសុំខបត្តម្ភពីប្រជាជន ។ លើកលែងតែមន្ទីរពេទ្យនានា ទើបអាចស្នើសុំការខបត្តម្ភពីប្រជាជនបានខ្លះដោយមានលិខិតបញ្ជាក់ច្បាស់លាស់ពីគណៈបញ្ជាការមន្ទីរពេទ្យ ។

បញ្ជាក់ៈ ដើម្បីកុំឲ្យប៉ះពាល់ដល់មនោសញ្ចេតនារបស់ប្រជាជនផ្ដល់ដោយការស្រឡាញ់រាប់អាន ។ តែដាច់ខាតយើងមិនត្រូវផ្ដើមគំនិតសុំឡើយ ។

ឃ) សីលធម៌បដិវត្តន៍ៈ ត្រូវមានអាកប្បកិរិយាសុភាពរាបសាបដិវត្តន៍ឲ្យបានកម្រិតខ្ពស់បំផុត ចំពោះប្រជាជននិងអង្គការគ្រប់ជាន់ថ្នាក់ ។ ចៀសវាងដាច់ខាតនូវអាកប្បកិរិយាប្អកញា សម្ដីអួតអាង ក្អឹតក្អើង ចំពោះប្រជាជននិងអង្គការមូលដ្ឋានអាកប្បកិរិយាទាំងអស់នេះ មិនអាចអធ្យាស្រ័យបានទៀតក៏ដោយ ។ បើមានបញ្ហាអ្វីកើតឡើងត្រូវដោះស្រាយតាមគោលជំហរបដិវត្តរឹងប៉ឹងថ្លៃថ្នូរ ។ បើដោះស្រាយមិនបានត្រូវនឹងនអត់ធ្មត់ ចៀសវាងនូវការប៉ះទង្គិច ហើយរាយការណ៍តាមខ្សែរយៈដើម្បីឲ្យថ្នាក់លើដោះស្រាយ ។

***(សៀវភៅកំណត់ហេតុលេខ D ២១៦៥៨)***

# ទំនាក់ទំនងនយោបាយរវាងប្រទេសថៃនិងប្រទេសកម្ពុជា

***(ឯកសារក្រសួងការបរទេសសាធារណរដ្ឋប្រជាមានិតកម្ពុជា ខែកញ្ញា ឆ្នាំ១៩៨៣)***

*មេដឹកនាំថៃបានឃុបឃិតជាមួយរដ្ឋាភិបាលទីក្រុងប៉េកាំង និង ប៉ុល ពត ដើម្បីប្រឆាំងនឹងប្រទេសនៅក្នុងឥណ្ឌូចិនទាំងបី ក្នុងគោលបំណងអនុវត្តនូវគោលនយោបាយវាតទីនិយមនិងត្រួតត្រានិយមទៅលើប្រទេសដទៃ ។*

*មនុស្សទាំងអស់ច្បាស់ជានៅចាំបានថា ក្នុងរយៈពេលប៉ុន្មានឆ្នាំដំបូងនៃរបប ប៉ុល ពត នៅគ្រាដែលគោលនយោបាយប្រតិកិរិយារបស់ចិនមិនទាន់បង្ហាញរូបរាង តាមរយៈការប្រឆាំងប្រទេសឥណ្ឌូចិនទាំងបីដោយចំហ អាជ្ញាធរថៃនៅតែអនុវត្តគោលនយោបាយបង្កជម្លោះប្រឆាំងប្រទេសចិននិងកម្ពុជា ។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ ប៉ុល ពត បានអនុវត្តនូវគោលនយោបាយដ៏សែនឃោរឃៅនិងប្រតិកិរិយាមួយ ។ ដោយទាញយកផលប្រយោជន៍ពីការទទួលជ័យជម្នះលើពួកបង្កជម្លោះអាមេរិកក្បត់គោលបំណងជាតិ បន ប៉ុល ពត បានប្រព្រឹត្តនូវការសម្លាប់មនុស្សជាទ្រង់ទ្រាយធំដ៏គួរឲ្យស្អប់ខ្ពើម ដែលជំរុញឲ្យប្រទេសជាតិទាំងមូលធ្លាក់ទៅក្នុងនរកនៃអំពើប្រល័យពូជសាសន៍ ហើយក្នុងពេលជាមួយគ្នានេះ ពួកវាបានបង្កឲ្យមានជម្លោះប្រដាប់អាវុធជាមួយប្រទេសជិតខាងទៀត ។ អាជ្ញាធរនិងសារព័ត៌មានថៃបានរាយការណ៍ម្តងហើយម្តងទៀតយ៉ាងទូលំទូលាយអំពីការប៉ះទង្គិចបង្ហូរឈាមគ្នានិងការទន្រ្ទានចូលទឹកដីថៃដោយកងទ័ពរបស់ ប៉ុល ពត នៅតាមព្រំដែន។ នៅក្នុងឆ្នាំ១៩៧៧ មានរបាយការណ៍ប្រភេទនេះចំនួនប្រមាណ៤០០ត្រូវបានរាយការណ៍បានសេចក្តីថាមានការប៉ះទង្គិចគ្នាលើសពីម្តងក្នុងមួយថ្ងៃ ហើយការប៉ះទង្គិចគ្នាភាគច្រើនមានការចូលរួមពីកងទ័ព ប៉ុល ពត រហូតដល់៦០០ទៅ៨០០នាក់ ។*

*ការបរិហារិះគន់ខាងក្រោមអាចរកឃើញនៅក្នុង «សៀវភៅស»ដែលបោះពុម្ពដោយក្រសួងការបរទេសថៃៈ*

*នៅវេលាម៉ោង១១យប់ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៧៧ កងប្រដាប់អាវុធធំៗជាច្រើនកងរបស់កម្ពុជាប្រជាធិបតេយ្យ ក្នុងនោះមានទាហានកងទ័ពប្រមាណ៣០០នាក់ បានឈ្លានពានចូលទឹកដីថៃ ហើយដោយគ្មានផ្តល់ដំណឹងជាមុន បានវាយលុកភូមិចំនួនបីរបស់ថៃ រួមមាន ភូមិបាននងដរ ភូមិបានក្លងកោរ និងភូមិបានណយប៉ារ៉ៃ នៃស្រុកអារញ្ញប្រាធេតខេត្តប្រាចាន់បូរីភាគអាគ្នេយ៍ ។ មានរបាយការណ៍ថា កងទ័ពខ្មែរក្រហមបានបាញ់មកលើប្រជាជនថៃស្លូតត្រង់ ហើយដុតកម្ទេចផ្ទះសម្បែងអស់ជាច្រើនខ្នង... ។ ការខាតបង់មានដូចខាងក្រោមៈ*

*១) នៅភូមិបាននងដរ ប្រជាជន២១នាក់ត្រូវបានសម្លាប់ ក្នុងនោះមានស្ត្រីមានផ្ទៃពោះម្នាក់ កុមារនិងទារកជាច្រើននាក់ដែលទទួលរងនូវការធ្វើកាយវិកលកម្មយ៉ាងធ្ងន់ធ្ងរ ។ ផ្ទះទាំងអស់ត្រូវដុតបំផ្លាញ ។*

*២) នៅភូមិបានក្លងកោរ ប្រជាជនថៃចំនួន៨នាក់ត្រូវបានសម្លាប់ ហើយផ្ទះសម្បែងទាំងអស់ត្រូវដុតបំផ្លាញ ។*

*៣) នៅភូមិបានណយប៉ារ៉ៃ ប្រជាជនចំនួន២០០នាក់ត្រូវបង្ខំចិត្តរត់ចេញពីផ្ទះ ហើយមួយចំនួនធំរងរបួសយ៉ាងធ្ងន់ធ្ងរ ។*

*...យោងតាមមូលហេតុខាងលើ រដ្ឋាភិបាលថៃបានទាមទារឲ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យទទួលខុសត្រូវចំពោះឧបទ្ទវហេតុនេះ ហើយផ្តល់ជាសំណងឲ្យបានសមរម្យជាបន្ទាន់ចំពោះការស្លាប់បាត់បង់ជីវិតប្រជាជននិងការខាតបង់ទៅលើទ្រព្យសម្បត្តិដែលបង្កឡើងដោយការវាយប្រហារនេះ ។*

*នៅអំឡុងពាក់កណ្តាលទីមួយនៃឆ្នាំ១៩៧៨ មានឧបទ្ទវហេតុប្រមាណ១០០ករណីបានកើតឡើង ដែលក្នុងនោះភូមិដ្ឋានរបស់ថៃជាច្រើនត្រូវបានដុតបំផ្លាញ ជនស៊ីវិលថៃជាច្រើននាក់ត្រូវបានចាប់ពង្រត់ ហើយប្រជាជនជាង១០០នាក់ត្រូវបានសម្លាប់ (ប្រភពៈ កាសែតថៃឈ្មោះដឹនេសិន ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ១៩៧៨) ។*

ឯកសារជាផ្លូវការរបស់អាជ្ញាធរថៃដែលបានចោទប្រកាន់ បន ប៉ុល ពត ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនថៃអាចរកឃើញ នៅក្នុងឯកសារពាក្យបណ្តឹងរបស់មហាសន្និបាទអគ្គការសហប្រជាជាតិ ។

ក្នុងការការពារកូនក្តី បន ប៉ុល ពត របស់ខ្លួន កឹង ពាវ បានផ្តល់របាយការណ៍នៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៩ ថា "ការប៉ះទង្គិចបង្ហូរឈាមគ្នា" ដែលបានកើតឡើងជាញឹកញយនៅតាមព្រំដែនកម្ពុជា-ថៃ គឺដោយសារការមិនគោរពវិន័យរបស់កងទ័ពប្រទេសកម្ពុជា(នៃប៉ុលពត) ...ជម្លោះទាំងនោះគ្រាន់តែជាលទ្ធផលអាក្រក់នៃការប្រកាន់បក្សនិយមនិងសកម្មភាពឯងឹតឯងល់របស់កងទ័ពកម្ពុជា(របស់ ប៉ុល ពត) ហើយវាមិនបង្កឲ្យមានការខូចខាតធ្ងន់ធ្ងរអ្វីដល់ប្រទេសថៃទេ (ដកស្រង់ចេញពីសៀវភៅ "ការសិក្សាអំពីចិនកុម្មុយនិស្ត" លេខ១០/៨០ បោះពុម្ពនៅតៃវ៉ាន់) ។

ពេលដែលប្រទេសចិនឃុបឃិតដោយចំហជាមួយចក្រពត្តិអាមេរិក ដើម្បីអនុវត្តនូវគោលនយោបាយវាតទីនិយមនិងត្រួតត្រានិយមនៅអាស៊ីភាគអាគ្នេយ៍ប្រឆាំងនឹងប្រទេសទាំងបីនៅក្នុងឥណ្ឌូចិន ដោយប្រើប្រាស់បន ប៉ុល ពត ជាមធ្យោបាយប្រទេសថៃក៏ងាកទៅរកការចងសម្ព័ន្ធភាពជាមួយប្រទេសចិន ដើម្បីប្រើប្រាស់ចិនជាឈ្នាន់ កេងប្រយោជន៍ពីការឃុបឃិតរបស់ចិននិងអាមេរិក ផ្សះផ្សាជាមួយបន ប៉ុល ពត ហើយប្រឆាំងនឹងប្រជាជនឥណ្ឌូចិនទាំងបីក្នុងគោលបំណងបន្តអនុវត្តនយោបាយវាតទីនិយមនិងត្រួតត្រានិយម ។

ប្រទេសថៃត្រូវបានផ្តល់នូវការធានាអះអាងពីចិនថា កម្ពុជាប្រជាធិបតេយ្យមិនមែនជាគ្រោះថ្នាក់សម្រាប់ប្រទេសថៃទេ ។ តាមរយៈកាសែតបាងកកប៉ុស្តិ៍ចុះថ្ងៃទី៨ ខែវិច្ឆិកា ឆ្នាំ១៩៧៧ អនុប្រធានាធិបតីចិន លី សៀននាន ក្នុងពេលទទួលរាក់ទាក់អ្នកកាសែតថៃនៅទីក្រុងប៉េកាំងបានធានាថា "ប្រទេសថៃនិងអាស៊ានគ្មានអ្វីដែលត្រូវខ្លាចកម្ពុជាប្រជាធិបតេយ្យទេ ម្យ៉ាងទៀតមិត្តកម្ពុជាបាននិយាយថា គេចង់បង្កើនចំណងមិត្តភាពជាមួយប្រទេសថៃ" ។ ក្រោយមកតាមរយៈរបាយការណ៍របស់ កឹង ពាវ សរសេរនៅថ្ងៃទី១៦ ខែមករា ឆ្នាំ១៩៧៩ ក្នុងដំណើរទស្សនកិច្ចទៅប្រទេសថៃ អនុប្រធានាធិបតី តេង សៀវ ពីង បានជម្រាបប្រាប់លោកនាយករដ្ឋមន្ត្រី ក្រាំងសាក់ ឆមម៉ាណាន់ ថា ប្រទេសកម្ពុជា(ប៉ុល ពត) គ្មានគោលបំណងចង់អនុវត្តនយោបាយពង្រីកទឹកដីទេ ។ ប្រទេសចិនអាចធានាបានថា ប្រទេសកម្ពុជាពិតជាចង់បង្កើតឲ្យមានទំនាក់ទំនងល្អជាមួយប្រទេសថៃ (ដកស្រង់ចេញពីសៀវភៅ "ការសិក្សាអំពីចិនកុម្មុយនិស្ត" លេខ១០/៨០ បោះពុម្ពនៅតៃវ៉ាន់) ។ បន្ថែមពីលើនេះ ថៃក៏បានមើលឃើញដែរថា របប ប៉ុល ពត អាចធ្វើឲ្យមានភាពកាន់តែងាយស្រួលដើម្បីឲ្យប្រទេសថៃបញ្ឆោកកម្ពុជាបានទាំងស្រុង តាមរយៈការប្រើប្រាស់ល្បិចកល"បង្កជម្លោះរវាងកម្ពុជានិងកម្ពុជា ឥណ្ឌូចិននិងឥណ្ឌូចិន" ។

នៅថ្ងៃទី៣០ ខែមករា ឆ្នាំ១៩៧៨ ក្នុងដំណើរទស្សនកិច្ចទៅទីក្រុងភ្នំពេញ រដ្ឋមន្ត្រីការបរទេសថៃ ឧបប៉ាឌិត មិនត្រឹមតែធ្វើមិនដឹងមិនឮចំពោះបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលបានប្រព្រឹត្តឡើងដោយបន ប៉ុល ពត ទៅលើប្រជាជនកម្ពុជាប៉ុណ្ណោះទេ ថែមទាំងបានព្យាយាមការពារ ប៉ុល ពត ពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងប្រជាជនថៃថែមទៀត ។ រដ្ឋមន្ត្រីរូបនេះបានបកស្រាយថា ការប៉ះទង្គិចគ្នានៅតាមបណ្តោយព្រំដែនកម្ពុជា-ថៃត្រូវបាន "បង្កឡើងដោយជនទីបី"(ដកស្រង់ចេញពីសុន្ទរកថារបស់រដ្ឋមន្ត្រីឧបប៉ាឌិក នៅក្នុងពិធីបដិសណ្ឋារកិច្ចទទួល អៀង សារី យូភីអាយ ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៨) ។ គាត់ក៏បានបញ្ជាក់ដែរថា "ថៃនិងកម្ពុជាមិនអាចបំបែកចេញពីគ្នាបានឡើយ" (អា.អែហ្វ.ប៉េ ទីក្រុងបាងកក ថ្ងៃទី៣១ ខែមករា ឆ្នាំ១៩៧៨) ។ តាមប្រភពដដែលនេះ ឧបប៉ាឌិត បានទទួលស្វាគមន៍ជាចំហចំពោះ"កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាប្រជាធិបតេយ្យក្នុងការអភិវឌ្ឍន៍ប្រទេស" ក្នុងខណៈដែលបន ប៉ុល ពត កំពុងដឹកនាំសង្គមកម្ពុជាទាំងមូលទៅក្នុងភាពច្របូកច្របល់និងការបង្ហូរឈាម ។

ចំពោះរដ្ឋាភិបាលថៃ ការធ្វើទស្សនកិច្ចរបស់ អៀង សារី មកទីក្រុងបាងកកនៅថ្ងៃទី១៨ ខែកក្កដា ឆ្នាំ១៩៧៨ ជាឱកាសដ៏ល្អមួយសម្រាប់ថៃក្នុងការធ្វើឲ្យប្រទេសចិនសប្បាយចិត្តនិងបញ្ចុះបញ្ចូលកម្ពុជាប្រជាធិបតេយ្យ តាមរយៈការផ្តល់នូវការទទួលរាក់ទាក់យ៉ាងកក់ក្តៅនិងមានកិត្តិយសបំផុតដល់តំណាងនៃរដ្ឋាភិបាលប្រល័យពូជសាសន៍រូបនេះ ។ រដ្ឋមន្ត្រីការបរទេសថៃបានធ្វើដំណើរទៅកាន់ព្រំដែនដើម្បីទទួល អៀង សារី ទៅទីក្រុង

បាងកក ។ ជាអំណោយមួយសម្រាប់ប្រទេសថៃមុនពេលចាកចេញពីកម្ពុជា អៀង សារី បានដាក់បញ្ជាដល់កងទ័ពរបស់ខ្លួន “កុំឲ្យប្រើអាវុធទៅលើភូមិដ្ឋានថៃនៅតាមព្រំដែន” (កាសែតថៃ ដឺនេសិន ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៧៨) ។

នៅក្នុងដំណើរទស្សនកិច្ចនេះ ភាគីទាំងសងខាងបានព្រមព្រៀងគ្នាទៅលើវិធានការដើម្បី “បញ្ចប់ការប៉ះទង្គិចគ្នានៅតាមព្រំដែនរវាងប្រទេសទាំងពីរ” ។ តាមការពិត កិច្ចព្រមព្រៀងនេះមិនត្រូវបានបង្កើតឡើងដើម្បីដោះស្រាយជម្លោះរវាងប្រទេសទាំងពីរដោយសន្តិវិធី ឬដើម្បីកាត់បន្ថយការឈឺចាប់និងការកាប់សម្លាប់ប្រជាជនកម្ពុជានិងថៃនៅតាមព្រំដែនទេ ប៉ុន្តែជាការដោះបន្ទុករបស់ ប៉ុល ពត ដើម្បីឲ្យ ប៉ុល ពត មានពេលនិងកម្លាំងគ្រប់ដើម្បីបន្តគាបសង្កត់ប្រជាជនកម្ពុជាដែលកំពុងតែក្រោកឈរឡើងប្រឆាំងនឹងរបប ប៉ុល ពត ហើយ ប៉ុល ពត អាចប្រមូលផ្តុំកងទ័ពទាំងអស់ទៅដាក់នៅតាមព្រំដែនខាងកើត ក្នុងគោលបំណងពង្រីកសង្គ្រាមឈ្លានពានទៅលើប្រទេសវៀត-ណាម ។ ក្រោយពីកិច្ចព្រមព្រៀងនេះត្រូវបានបង្កើតឡើងកងពលចំនួន១៩ ក្នុងចំណោមកងពល២៣របស់ប្រទេសកម្ពុជាត្រូវបានដាក់ពង្រាយនៅតាមតំបន់ជាប់ព្រំដែនវៀតណាម ហើយមានតែបីកងពលប៉ុណ្ណោះដែលនៅសល់តាមព្រំដែនថៃ ។ ដូចបានព្រមព្រៀងគ្នារួចជាស្រេចក្នុងដំណើរទស្សនកិច្ចរបស់ គេង សៀវ ពីង នៅទីក្រុងបាងកក នៅថ្ងៃទី៥ ខែវិច្ឆិកា ប្រទេសថៃបានអនុញ្ញាតឲ្យចិនដឹកអាវុធទៅកាន់ប្រទេសកម្ពុជាកាត់តាមផ្លូវអាកាសរបស់ខ្លួន... ។



# ខ្ញុំនិទានរឿងប្រាប់ចៅៗ

សាក្សីដែលមានវ័យចំណាស់នៅតាមភូមិស្រុកដាច់ស្រយាល ដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម តែងតែនិទានរឿងប្រាប់កូនចៅរបស់ខ្លួននិងញាតិមិត្តជិតខាង ។

យាយ គឹម មឹន អាយុ៧៥ឆ្នាំ រស់នៅភូមិកំពង់ក្ដី ឃុំកំពង់ចិនត្បូង ស្រុកស្ទោង ខេត្តកំពង់ធំ បានរៀបរាប់ប្រាប់ខ្ញុំអំពីខ្សែជីវិតរបស់យាយដែលឆ្លងកាត់ជាច្រើនជំនាន់មកថាៈ “ខ្ញុំមិនមែនអ្នកស្រុកស្ទោងទេ ខ្ញុំរត់ចោលស្រុកកំណើតមកនៅស្រុកស្ទោងនេះដោយសារតែឥស្សរៈតាមចាប់ខ្ញុំ ។ ខ្ញុំមកនៅស្រុកនេះក្បាលមួយគ្មានបងប្អូនមាមីងទេ រស់នៅតាំងពីបាតដៃទទេ រកស៊ីសន្សំរហូតដល់មានផ្ទះធំ មានដីស្រែ គោក្របី ប៉ុន្តែ ប៉ុលពត ធ្វើឲ្យខ្ញុំរលាយអស់ ដល់ពេលខ្លួនចាស់អ៊ីចេះហើយគ្មានបងប្អូននៅជិតទៀត” ។


យាយ គឹម មឹន

យាយមឹន មានស្រុកកំណើតនៅភូមិជើងអក ឃុំរំហាច ស្រុកអង្គស្នួល ខេត្តកណ្ដាល ។ យាយកើតនៅឆ្នាំរោង (ត្រូវនឹងឆ្នាំ១៩២៨) នៅក្នុងគ្រួសារមួយដែលមានបងប្អូន៨នាក់ (ប្រុស៤នាក់ ស្រី៤នាក់) ។ យាយគឺជាកូនទី៤ ។ ឪពុករបស់យាយឈ្មោះ ញូង គឹម ជាអតីតជំទប់លេខ១នៅក្នុងស្រុកអង្គស្នួល ។ ម្ដាយរបស់យាយឈ្មោះ កៅ ប៊ុល ដែលស្លាប់តាំងពីយាយមានអាយុ១៧ឆ្នាំ ។ ឪពុកម្ដាយរបស់យាយមានផ្ទះក្បឿងមួយខ្នង មានដីស្រែ៦ហិកតាដែលផ្ដល់ផលស្រូវក្នុងមួយឆ្នាំប្រមាណ២០០ថាំង មានដីចម្ការ១៣ហិកតា ដើមត្នោតប្រហែល៥០០ដើម និងមានគោប្រមាណ៤០ក្បាល ។ យាយប្រាប់ថា ក្រុមគ្រួសាររបស់យាយមិនដែលខ្វះខាតស្បៀងអាហារឡើយ មានតែហូបមិនអស់ សល់ចែកបងប្អូនញាតិសន្ដានទៀតផង ។

ប្រហែលក្នុងឆ្នាំ១៩៥០ នៅពេលយាយអាយុ២២ ឆ្នាំ បងប្រុសទីបីរបស់យាយឈ្មោះ គឹម ស៊ិន ត្រូវកងទ័ពឥស្សរៈសម្លាប់ចោលដោយចោទថាចូលខាងបារាំង ។ យាយបានឲ្យដឹងថា ពេលនោះបងរបស់យាយទើបនឹងលាចាកសិក្ខាបទ ហើយក្មួយម្នាក់ដែលធ្វើជាស្មៀនរាជការនៅទីក្រុងភ្នំពេញ ហៅគាត់ឲ្យចូលធ្វើការជាមួយ ។ ខាងក្រុមឥស្សរៈបានដឹងរឿងនេះ ក៏ចោទថា បងប្រុសរបស់យាយចូលខាងបារាំង ជាមនុស្សក្បាលពីរ ហើយចាប់គាត់យកទៅសម្លាប់ ។ យាយរៀបរាប់ថា “ពេលដែលកងទ័ពឥស្សរៈមកចាប់បងខ្ញុំ ខ្ញុំអត់នៅផ្ទះ ខ្ញុំរវល់ទៅឃ្វាលគោ ។ ប្អូនស្រីខ្ញុំរត់ទៅប្រាប់ខ្ញុំថា ឥស្សរៈចាប់បងយកទៅបាត់ហើយ ។ ខ្ញុំរត់តាមរកបងខ្ញុំគ្រប់ទិសទី សួរអ្នកស្រុកហូរហែថា ឃើញឥស្សរៈនាំបងខ្ញុំទៅតាមផ្លូវណា ។ ខ្ញុំវេចលុយមួយថ្នក់នៅជាយក្រមា គិតថាបើជួបគេនៅត្រង់ណានឹងសុំទិញជីវិតបងមកវិញ ។ ខ្ញុំដើររកបង៦-៧ថ្ងៃ រកអត់ឃើញ ។ ថ្ងៃមួយខ្ញុំរកឃើញ កន្លែងឥស្សរៈក៏សុំចូលជួបបង ។ ខ្ញុំទៅសុំគេ គេបង្វិលបន្តពីម្នាក់ទៅម្នាក់ ទម្រាំគេអនុញ្ញាតឲ្យខ្ញុំចូលមើលបង ។ ពេលខ្ញុំចូលទៅឃើញបងនៅក្នុងទ្រុង ខ្ញុំស្ទើរតែរលួយថ្លើមប្រមាត់អស់ហើយ ។ បងខ្ញុំត្រូវគេដាក់ខ្នោះដៃជើង

ជាប់ទាំងអស់ ។ គាត់ឃើញខ្ញុំ គាត់យំអង្វរខ្ញុំថា អូនអើយអូន បើអូនឯងជួយបងឲ្យរស់មួយពេលនេះ ដល់ទៅវិញបងនឹងបួសសងគុណអូនឯងមួយជីវិត ។ ប៉ុន្តែខ្ញុំជួយបងខ្ញុំអត់បាន ។ ប្រហែលពីរថ្ងៃក្រោយមក គេយកបងខ្ញុំទៅសម្លាប់នៅព្រៃខ្មោចក្បែរភូមិ ។ បងខ្ញុំទើបនឹងសឹកពីសង្ឃខែកត្តិក ហើយគាត់ត្រូវគេសម្លាប់នៅក្នុងខែកត្តិកឆ្នាំក្រោយ» ។ យាយបង្អង់បន្តិច រួចទាញក្រមាមកជូតទឹកភ្នែកហើយបន្តទៀតៈ «គេសម្លាប់បងខ្ញុំពីក្បាលព្រលប់ដល់សម្លាប់ហើយគេប្រើមនុស្សមកប្រាប់ឲ្យទៅយកខ្មោចកប់ ។ ព្រលឹមឡើងបងប្អូនមាមីងខ្ញុំ នាំគ្នាដើររកខ្មោចបងប្រុសខ្ញុំ ឃើញដេកស្តូកស្តឹងនៅលើដីកងទ័ពឥស្សរៈកាប់ដាច់កនៅជាប់ស្បែកតែបន្តិច ដៃទាំងសងខាងត្រូវកាប់ដាច់ត្រឹមកដៃ ។ ខ្ញុំអាណិតបងខ្ញុំណាស់» ។

បន្ទាប់ពីសម្លាប់ គឹម ស៊ិន កងទ័ពឥស្សរៈបានហៅយាយ គឹម មឹន ឲ្យទៅផ្តិតមេដៃសន្យាថានឹងមិនប្តឹងរាជការឡើយ ។ បើហ៊ានប្តឹងនឹងត្រូវស្លាប់ម្នាក់ទៀត ។ ក្រោយមក រាជការដឹងរឿងនេះក៏ចេញដីកាកោះហៅឪពុករបស់យាយឲ្យទៅផ្តល់ចម្លើយនៅសាលាដំបូង ប៉ុន្តែឪពុករបស់យាយមិនទៅបង្ហាញខ្លួន ព្រោះខ្លាចការគំរាមកំហែងរបស់កងទ័ពឥស្សរៈ ។ តុលាការចេញដីកាកោះហៅម្តងហើយម្តងទៀត ឪពុកយាយនៅតែមិនទៅបង្ហាញខ្លួន ។ ដោយហេតុដូច្នេះ តុលាការក៏ចេញលិខិតមួយច្បាប់ព្រមានថា បើខាងក្រុមគ្រួសាររបស់យាយមិនមកផ្តល់ចម្លើយទេនឹងត្រូវមានទោស ។ យាយ មឹន ក៏ចេញមុខជំនួសឪពុកទៅផ្តល់ចម្លើយនៅសាលាដំបូងក្នុងទីក្រុងភ្នំពេញ ។ ដំណឹងនេះក៏លេចឮដល់កងទ័ពឥស្សរៈ ។ កងទ័ពឥស្សរៈក៏តាមរកចាប់ខ្លួនយាយ មឹន ។ បងប្រុសជីដូនមួយម្នាក់របស់គាត់ដឹងរឿងនេះ ក៏មកប្រាប់យាយ មឹន ឲ្យភៀសខ្លួនចេញជាបន្ទាន់ ។ ដោយសារឪពុករបស់យាយមានបងប្អូនមកប្រកបរបរឡើងត្នោតនៅស្រុកស្ទោងខេត្តកំពង់ធំ យាយ មឹន ក៏ភៀសខ្លួនមករស់នៅទីនេះ ។

យាយ មឹន យំបណ្តើររៀបរាប់បណ្តើរទៀតថា «ពេលខ្ញុំចេញពីផ្ទះ ខ្ញុំយកខោអាវតែមួយបន្លាស់ប៉ុណ្ណោះ ។ ខ្ញុំយកប្រាក់តែ៥០០រៀល ហើយមានទំហូមួយគូជាប់នឹងត្រចៀកនិងចិញ្ចៀនមួយវង់ដែលពាក់ជាប់នឹងដៃមិនដែលដោះ ។ ប្រាក់កាសដែលខ្ញុំរកបានទាំងប៉ុន្មាន និងកេរអាកររបស់ម្តាយខ្ញុំ ខ្ញុំទុកជូនឪពុកខ្ញុំទាំងអស់ឲ្យគាត់ចិញ្ចឹមប្អូនៗ ។ ម្យ៉ាងអាណិតឪពុកដែលមិនធ្លាប់បែកគ្នា ។ ខ្ញុំថ្វាយបង្គំលាឪពុកចេញមក ទឹកភ្នែកឪពុកហូរជោកក្បាលខ្ញុំ ។ ខ្ញុំធ្វើដំណើរតែម្នាក់ឯង ចោលស្រុកកំណើតមករស់នៅស្រុកគេ» ។ តាំងពីចាកចេញពីស្រុកកំណើត យាយ មឹន មិនហ៊ានត្រឡប់ទៅវិញទេ រហូតដល់មានកូនពីរនាក់ ទើបគាត់ហ៊ានទៅលេងស្រុកកំណើត ព្រោះថាពេលនោះប្រទេសកម្ពុជាបានទទួលឯករាជ្យពីអាណានិគមបារាំង ហើយចលនាខ្មែរឥស្សរៈក៏ស្ងប់ស្ងាត់វិញ ។ ប៉ុន្តែនៅពេលនោះ ឪពុករបស់យាយបានទទួលអនិច្ចកម្មទៅហើយ ។

មកដល់ស្រុកស្ទោង ខេត្តកំពង់ធំ យាយ មឹន បានសុំស្នាក់អាស្រ័យនៅផ្ទះរបស់ស្ត្រីម្នាក់ឈ្មោះ ភិន នៅភូមិកំពង់ក្តី ឃុំកំពង់ចិនត្បូង ។ ភិនស្រលាញ់យាយ មឹន ដូចជាកូនបង្កើតរបស់គាត់ ។ មិនតែប៉ុណ្ណោះ ចាស់ទុំនៅក្នុងភូមិក៏ស្រលាញ់ពេញចិត្តយាយ មឹន ហើយក៏ចាត់ចែងឲ្យគាត់មានប្តីជាអ្នកស្រុកស្ទោង ។ យាយ មឹន បានរៀបការក្នុងអាយុ២៨ឆ្នាំ តាមការទុកដាក់របស់ចាស់ទុំ ។ ប្តីរបស់យាយឈ្មោះ ព្រំ ញ៉ែម កើតឆ្នាំរោងដែរ ប៉ុន្តែមានអាយុចាស់ជាងយាយ២៨ឆ្នាំ ។ នៅពេលដែលខ្ញុំសួរយាយថា ហេតុអ្វីក៏យាយព្រមរៀបការជាមួយបុរសដែលមានអាយុចាស់ជាងយាយច្រើនយ៉ាងនេះ? យាយរៀបរាប់ថា «កាលពីជំនាន់មុន រឿងរៀបការគឺចាស់ៗជាអ្នករៀបចំទុកដាក់ឲ្យ ។ បើចាស់ថាឲ្យរៀបការជាមួយអ្នកណាគឺ មិនដែលហ៊ានប្រកែកទេ ។ អ៊ីចឹងហើយបានជាមានពាក្យថា ទោះជាឲ្យឆ្កែឲ្យឆ្មាក៏យកដែរ» ។

ប្តីរបស់យាយធ្វើការងារស្រែចម្ការនិងទៅវត្តសុំសីល ។ ចំណែកយាយនៅផ្ទះដាំបន្លែបង្ការនិងចិញ្ចឹមសត្វ ។ យាយសន្សំប្រាក់កម្រៃដែលបានពីការលក់សត្វចិញ្ចឹម រហូតទិញបានដីធំទូលាយសង់ផ្ទះបិតមួយខ្នង ទិញដីស្រែជាច្រើនហិកតា និងទិញគោជាច្រើនក្បាល ទុកសម្រាប់ចែកកូនចៅទៅថ្ងៃអនាគត ។

ក្រោយពេលរៀបការបាន១ឆ្នាំ យាយមានកូនប្រុស

ម្នាក់ ។ ពេលនោះយាយចេះវិជ្ជាឆ្មប ។ នៅពេលដែលកូនច្បង មានអាយុ១០ឆ្នាំ ក្រុមមេព្រៃដែលបោះទីតាំងនៅក្នុងភូមិរបស់យាយ បានបើកបង្រៀនអក្ខរកម្មដល់ប្រជាជន ។ យាយក៏រៀនអក្ខរកម្មរហូតដល់ចេះអក្សរ ហើយក៏អានសៀវភៅពេទ្យបន្ថែមទៀត ។ ក្រោយមក យាយបានប្រឡងជាប់សញ្ញាប័ត្រពេទ្យឆ្មបនៅទីរួមខេត្តកំពង់ធំ ។ យាយ មីន មានកូន៤នាក់ៈ ប្រុស ៣នាក់ និងស្រីម្នាក់ ។

ឆ្នាំ១៩៦៨ ប្តីរបស់យាយបានទទួលអនិច្ចកម្មដោយជរាពាធ ។ ឆ្នាំ១៩៧១ កូនប្រុសច្បងរបស់យាយដែលមានអាយុ២០ឆ្នាំទើបនឹងលាចាកសិក្ខាបទ ក៏ស្ម័គ្រចិត្តចូលបម្រើក្នុងជួរកងទ័ពបដិវត្តន៍ខ្មែរក្រហម ។ យាយនិយាយថាៈ «*កាលហ្នឹងខាងគណៈស្រុកគណៈសង្កាត់មកហៅទៅ គេថាទៅធ្វើការនៅកន្លែងគេល្អ ធ្វើកងទ័ពចេះតែពូកខ្លាំង កូនខ្ញុំនៅក្មេងឈាមវាវជ្រួលជ្រើម វាឃើញការក្លែង វាចូលចិត្ត ចង់បាន ក៏ចូលកងទ័ពនឹងគេទៅ ។ ប៉ុន្តែទោះអ្នកណាចង់គេចមិនទៅធ្វើកងទ័ពក៏អត់បានដែរ ។ ផ្ទះណាមានកូនក្រមុំកំលោះនៅអត់បានទេ គេមកតាមហៅតាមដេញទៅទាំងអស់ បើមិនចូលកងទ័ពក៏ចូលក្នុងកងចល័តដែរ ។ ក្នុងភូមិសល់តែមនុស្សចាស់ៗនិងក្មេងតូចៗតែប៉ុណ្ណោះ*» ។ ឆ្នាំ១៩៧៣ កូនប្រុសរបស់យាយបានឆៀងចូលលេងផ្ទះម្តងក្នុងខណៈពេលដែលអង្គភាពរបស់ខ្លួនធ្វើដំណើរកាត់តាមភូមិកំណើត ។ យាយនិយាយថា «*កូនខ្ញុំមកផ្ទះមិនយូរទេ គ្រាន់តែមកថ្វាយបង្គំម៉ែសួរសុខទុក្ខម៉ែតែពីរបីម៉ោងក៏លាទៅវិញ ។ រត់ទៅមុខបណ្តើរ ងាកក្រោយលើកដៃសំពះលាម៉ែបណ្តើររហូតទាល់តែកំបាំងនឹងព្រៃ ។ ខ្ញុំបានជួបកូនតែម្តងហ្នឹង ហើយក៏បាត់ដំណឹងរហូត ។ បើកូនខ្ញុំនៅរស់ដល់ឥឡូវ វាមានអាយុ៤៩ឆ្នាំហើយ*» ។ កូនប្រុសច្បងរបស់យាយឈ្មោះ ព្រុំ ចេង ឈ្មោះបដិវត្តន៍ ផាញ ។

ឆ្នាំ១៩៧៤ ខ្មែរក្រហមបានជម្លៀសក្រុមគ្រួសាររបស់យាយនិងប្រជាជនទាំងអស់នៅទីប្រជុំជនស្ទោង ឲ្យទៅរស់នៅក្នុងព្រៃមួយឈ្មោះភូមិតាពេជ្រ ។ ការជម្លៀសប្រព្រឹត្តទៅនៅពេលយប់ ។ យាយបររទេះគោដឹកស្បៀងអាហារ សម្លៀកបំពាក់ មុងភួយ ចានឆ្នាំង ។ ចំណែកកូនទាំងបីនាក់របស់យាយរែកផងទូលផង ដឹកគោជាច្រើនក្បាលផង ។ យាយបានយកគោរបស់ខ្លួនដែលមានមាឌធំៗ ទៅដូរយកគោមាឌតូចៗល្មមដែលអាចឲ្យកូនដឹកនិងបញ្ឈរវាបាន ។

នៅភូមិតាពេជ្របានមួយរយៈ ខ្មែរក្រហមជម្លៀសឲ្យមកនៅព្រែកប៉ររស់វិញ ។ អំឡុងពេលរស់នៅព្រែកប៉ររស់ កូនស្រីរបស់យាយឈ្មោះ ព្រុំ សំអាន (ឈ្មោះបដិវត្តន៍ ព្រុំ សំអេន) ក៏ចូលក្នុងកងចល័តទៅធ្វើការនៅការដ្ឋានឆ្ងាយៗ រយៈពេល ១០ថ្ងៃឬកន្លះខែទើបឃើញមកជួបក្រុមគ្រួសារម្តង ។ បន្ទាប់ពីបានទទួលជ័យជម្នះលើរបបសាធារណរដ្ឋខ្មែរទូទាំងប្រទេសនៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ អង្គការខ្មែរក្រហមក៏បញ្ជូន សំអាន ទៅកាត់ដេរនៅភ្នំពេញ ហើយ យាយ មីន ក៏បាត់ដំណឹងកូនស្រីតាំងពីពេលនោះមក ។ នៅឆ្នាំ១៩៨៨ យាយបានទទួលដំណឹងថាកូនស្រីរស់នៅឯជំរំខាវអ៊ីដាងនៅព្រំដែនខ្មែរ-ថៃ ។

ក្រោយថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានជម្លៀសប្រជាជនពីព្រែកប៉ររស់ឲ្យមករស់នៅខាងលិចថ្នល់ជាតិលេខ៦វិញ ។ យាយក៏បានត្រឡប់ចូលផ្ទះដើម្បីយកឥវ៉ាន់មួយចំនួន ប៉ុន្តែរបស់របរនៅក្នុងផ្ទះទាំងប៉ុន្មានត្រូវកងទ័ពខ្មែរក្រហមរឹបអូស ហើយផ្ទះត្រូវរុះរើអស់នៅសល់តែសសរ៥ដើមប៉ុណ្ណោះ ។ យាយប្រាប់ថា «*គេអត់ឲ្យខ្ញុំយក គេថាខ្ញុំលះបង់មិនបាន*» ។

បន្ទាប់ពីជម្លៀសឲ្យមករស់នៅខាងលិចផ្លូវជាតិលេខ៦ ខ្មែរក្រហមដាក់ទិសឲ្យយាយ មីន ដកស្ទូង លើកប្រព័ន្ធភ្លឺស្រែ និងធ្វើជីរលាមក ក្រោយមកក៏ចាត់តាំងយាយឲ្យធ្វើជាប្រធានសហករណ៍ ។ យាយទទួលខុសត្រូវបែងចែកស្បៀងអាហារ ឧបករណ៍ប្រើប្រាស់និងសម្ភារផ្សេងៗ ដល់ភូមិនិងកងចល័តនានា ។ យាយនិយាយថា កាលយាយនៅក្តាប់សហករណ៍មិនទាន់មានគោលនយោបាយហូបរួមនៅឡើយទេ ។ ប្រជាជននៅដាំបាយហូបតាមផ្ទះរៀងៗខ្លួន ហើយសហករណ៍ផ្គត់ផ្គង់របបស្រូវឲ្យប្រជាជន ។ យាយតែងតែចែកស្រូវឲ្យប្រជាជនលើសពីចំនួនដែលបានចុះក្នុងបញ្ជី គឺធ្វើយ៉ាងណាឲ្យតែឆាប់អស់ស្រូវពីជង្រុក ព្រោះយាយដឹងថា ប្រសិនបើទុកពិតជាមាន

ឡានមកដឹកយកទៅទុកនៅសហករណ៍ធំអស់ជាមិនខាន។ កូនទីបីរបស់យាយដែលមានអាយុជាង១០ឆ្នាំ ចូលក្នុងកងចល័តទៅធ្វើការឆ្ងាយៗពីភូមិ យូរៗទើបឃើញមកលេងម្តង។ កូនប្រុសពៅរស់នៅក្នុងភូមិរៀនអក្សរនិងកើបអាចម៍គោធ្វើជីរដាក់ស្រែ ។

យាយ មីន ធ្វើជាប្រធានសហករណ៍បានរយៈពេលជិតមួយឆ្នាំ ថ្នាក់លើមានផែនការដកយាយចេញ ហើយដាក់អ្នកមកពីជនបទជំនួសវិញ ។ យាយបានដឹងដើងការមុន ក៏លួចចែកស្រូវប្រមាណ៦០០ថាំងដែលនៅសល់ក្នុងជង្រុកឲ្យប្រជាជនអស់ ។ លុះដល់វេលាយប់ គណៈសង្កាត់ចាត់មនុស្សឲ្យមកហៅយាយទៅទីស្នាក់ការ ។ យាយនិយាយថាៈ «កាលហ្នឹងប្រធាននារីពីរនាក់ ប្រធានបុរសបីនាក់ ហៅខ្ញុំទៅសួរ ខ្ញុំភ័យអើយភ័យ គិតថាមុខជាគេសម្លាប់ហើយ ។ គណៈសង្កាត់សួរខ្ញុំថា អ្នកណាមានវិធានការឲ្យចែកស្រូវ? ស្រូវហ្នឹងមានចំនួនប៉ុន្មាន? ខ្ញុំថាស្រូវហ្នឹងមានចំនួន២០០ថាំង (តាមពិតស្រូវមាន៦០០ថាំងឯណោះ) តែកាលដាក់ហ្នឹងស្រូវវាសើម ដល់ត្រូវក្តៅវាក៏ដុះពេញជង្រុក ខ្ញុំក៏ចែកប្រជាជនតាមផ្ទះទៅ ព្រោះយើងមិនទាន់ឲ្យរបបស្រូវប្រជាជនឯណា ។ ដល់ដេញដើងខ្ញុំមិនទាន់ គេក៏លែងថាអីទៅ» ។

ឆ្នាំ១៩៧៦ ខ្មែរក្រហមបានដកយាយពីតំណែងប្រធានសហករណ៍ ហើយចាត់តាំងឲ្យធ្វើជាប្រធានរោងបាយ ។ យាយនិយាយថា ពេលនោះអង្គការចេញគោលនយោបាយឲ្យហូបបាយរួមហើយ ។ ពេលធ្វើប្រធានរោងបាយ យាយតែងតែកើបកេងពីប្រធានភ័ស្តុភារបានស្រូវអង្ករម្ហូបអាហារលើសរបបយកមកដាំឲ្យប្រជាជនហូបបានឆ្អែត ។ យាយលើកឧទាហរណ៍ថា ប្រសិនបើថ្នាក់លើដាក់ទិសមកថាឲ្យហូបមួយកំប៉ុង៣នាក់ យាយលៃលកបន្ថែមបានមួយកំប៉ុង២នាក់ ។ ប្រសិនបើខាងភ័ស្តុភារបើកអំបិលឲ្យតិច យាយសូអត់បង់អំបិលឲ្យប្រធានហូបធ្វើម៉េចឲ្យបានរបបអំបិលបន្ថែមឲ្យច្រើន។ យាយតែងតែលួចផ្តល់អង្ករ អំបិល ស្ករ ឲ្យប្រជាជនដែលមកសុំគាត់ជានិច្ច មិនថាអ្នកមូលដ្ឋាន ឬអ្នក១៧មេសាឡើយ ។ ធ្វើការនៅរោងបាយបានប្រហែល១ឆ្នាំ អង្គការដកយាយទៅធ្វើប្រធានក្រុមនារីសង្គ្រោះ (ឆ្មប) ។ យាយនិយាយថា ក្រុមឆ្មបរបស់យាយមានតែឧបករណ៍កាត់ផ្ចិតប៉ុណ្ណោះ អង្គការគ្មានផ្តល់អ្វីឲ្យទេសូម្បីតែថ្នាំចែកឲ្យអ្នកជំងឺក៏គ្មានដែរ អ្នកជំងឺត្រូវរកថ្នាំដើមឈើសំបកឈើមកដាំទឹកហូបដោយខ្លួនឯង ។

យាយ មីន បានឲ្យដឹងថា តាំងពីឆ្នាំ១៩៧៦ ខ្មែរក្រហមសម្លាប់ប្រជាជនជាបណ្តើរៗ ។ មកដល់ឆ្នាំ១៩៧៧ ខ្មែរក្រហមកាត់បន្ថយរបបអាហារប្រជាជនឲ្យកាន់តែតិចទៅៗ និងអនុវត្តការសម្លាប់រង្គាលកាន់តែខ្លាំងក្លា ។ នៅក្នុងសហករណ៍ដែលយាយរស់នៅប្រជាជនស្លាប់ជាបន្តបន្ទាប់ដោយសារការអត់ឃ្លាន ធ្វើការបាក់កម្លាំងនិងត្រូវខ្មែរក្រហមសម្លាប់ ។



កូនប្រុសច្បងរបស់យាយ មីន នៅតែបាត់ខ្លួនមិនមានដំណឹងរហូតដល់បច្ចុប្បន្ន។ យាយនិយាយថា «ខ្ញុំអាល័យកូនណាស់ ខ្ញុំដេកមើលផ្លូវកូនរាប់ឆ្នាំ ទាល់តែរឹងរៃខូចសុខភាព ឥឡូវនេះខ្ញុំឈប់គិតហើយ បើកូននៅរស់ក៏ឃើញមកហើយបើមិនឃើញមកទេ ខ្ញុំក៏មិនដឹងជាធ្វើយ៉ាងម៉េចដែរ» ។ ចំណែកកូនស្រីទី២របស់យាយកំពុងរស់នៅឯប្រទេសស្វីស ពុំទាន់បានមកលេងស្រុកនៅឡើយទេ។ យាយ មីន អង្អែលរូបថត កូនស្រីបណ្តើរពោលបណ្តើរថាៈ «ខ្ញុំមានកូនស្រីតែមួយត្រូវឃ្លាតពីដើមទ្រូងម្តាយទៅនៅឆ្ងាយមើលមិនឃើញហៅមិនឮ ។

*អាណិតចៅដែលកើតមកមិនដែលឃើញមុខយាយ យាយមិនដែលឃើញមុខចៅ ។ ខ្ញុំដេកគិតយូរៗទៅ ហូរទឹកភ្នែកអាណិតខ្លួនចាស់ហើយ កូនចៅនៅឆ្ងាយ» ។ បច្ចុប្បន្ន យាយ មីន រស់នៅជាមួយកូនប្រុសពៅឈ្មោះ ព្រាំ នួន ដែលបម្រើការនៅសាលាស្រុកស្ទោង ។ ចំណែកកូនប្រុសទី៣ ឈ្មោះ ព្រាំ ដួន ប្រកបរបរនេសាទត្រីនៅតំបន់ទន្លេ ក្នុងខេត្តកំពង់ធំ ។*

*តាំងពីសម័យឥស្សរៈរហូតមកដល់បច្ចុប្បន្ន យាយ គីម មីន ចេះតែបន្តនៅស្ងៀមស្ងាត់ មានតែនិយាយរឿងរ៉ាវទាំងនេះប្រាប់កូនចៅឲ្យដឹងនិងអប់រំចៅឲ្យខិតខំរៀនសូត្រ ខិតខំកសាងចិត្តគំនិតឲ្យបានល្អ ស្លូតត្រង់ កាន់យុត្តិធម៌ កុំឲ្យប្រព្រឹត្តអំពើមិនល្អ ។ យាយ គីម មីន បាននិយាយថា «របបខ្មែរក្រហមកើតឬមិនកើតម្តងទៀត គឺអាស្រ័យលើអ្នកដឹកនាំប្រទេស ប្រជាជនអត់ដឹងទេ ប្រជាជនដឹងតែរស់ក្រោមម្ជប់ត្រជាក់តែប៉ុណ្ណោះ» ។*

**សាន់ កល្យាណ**




គីម មីន និងស្វាមី ព្រមទាំងសាច់ញាតិ ក្នុងពិធីដង្ហែកូនប្រុសច្បងបួសជាសង្ឃ

# បដិវត្តន៍ដែលគ្មានខ្លឹមសារ


សេង សារី

សេង សារី គឺជាយុវនារីក្លាហានម្នាក់ដែលបានចាកចេញពីស្រុកកំណើតចូលបម្រើបដិវត្តន៍ខ្មែរក្រហមនៅឆ្នាំ១៩៧៤។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ សារី ត្រូវបានអង្គការបញ្ជូនទៅលត់ដំនៅមន្ទីរព្រៃស ពីបទរត់ចោលសមរភូមិទៅផ្ទះ។

សារី មានស្រុកកំណើតនៅស្រុកកោះធំ ខេត្តកណ្តាល។ ឪពុករបស់ សារី ឈ្មោះ គ្រួច ម្តាយឈ្មោះ ជា។ សារី មានបងប្រុសម្នាក់។ សារី បានធំពេញវ័យក្នុងពេលដែលស្រុកកំពុងមានសង្គ្រាម។ ក្នុងវ័យ១៨ឆ្នាំ សារី បានស្ម័គ្រចិត្តចូលធ្វើជាកងទ័ពនៅក្នុងកងពលលេខ១២ ក្នុងតួនាទីជា «មេពួក»។ សារី បានប្រាប់ថា គាត់ចូលបម្រើកងទ័ពនេះមកពីគាត់គិតថា នៅផ្ទះគ្មានបានប្រយោជន៍អីដល់ក្រុមគ្រួសារ ទើបគាត់សម្រេចចិត្តចូលបម្រើបដិវត្តន៍ ដោយធ្វើជានារីក្រហម។ ដំបូង សារី គិតថា ធ្វើជាពេទ្យ ប៉ុន្តែនៅពេលទៅដល់មន្ទីរពេទ្យគាត់ក៏ប្តូរចិត្តធ្វើជាកងទ័ពវិញ ព្រោះថាវាមានប្រយោជន៍ជាង។ សារី បានរៀនវគ្គនយោបាយនិងវគ្គបច្ចេក-ទេស អស់រយៈពេល២ខែនៅទំនប់ទួលក្រសាំង។ នៅទីនោះ សារី បានធ្លាក់ខ្លួនឈឺ ហើយទៅសម្រាកព្យាបាលនៅមន្ទីរពេទ្យព្រែកតាវ៉ាអស់រយៈពេលបីខែ រួចបន្តទៅព្យាបាលនៅមន្ទីរពេទ្យតំបន់អស់ពេល៣ខែទៀតទើបជាសះស្បើយ។ ក្រោយពីចេញពីមន្ទីរពេទ្យ សារី ត្រូវបានចាត់តាំងឲ្យទៅសមរភូមិទន្លេបាសាក់និងទន្លេមេគង្គ ក្រោមការដឹកនាំរបស់សមមិត្ត ពីន ជាបញ្ជាការកងពលលេខ១២។

ឆ្នាំ១៩៧៥ សារី ត្រូវបានចាត់តាំងឲ្យទៅវាយនៅម្តុំក្តមសំណាអស់រយៈពេល២ខែ ដើម្បីជំនួយដល់កងកាំភ្លើងធំ១០៥ មីលីម៉ែត្រ។ ក្រោយមកទើប សារី ត្រឡប់មកវាយនៅទន្លេមេគង្គវិញ ដើម្បីបន្តវាយចូលទីក្រុងភ្នំពេញ។ បន្ទាប់ពីរំដោះទីក្រុងបាន សារី បានចូលរួមសម្អាតទីក្រុងនិងតាមរកខ្មាំងដែលនៅសេសសល់។ នៅចុងឆ្នាំ១៩៧៥ ប្រធានកងរបស់ សារី បានមកធ្វើជីវទស្សន៍ ហើយបែងចែកឲ្យទៅធ្វើការនៅកន្លែងផ្សេងៗរួមទាំងមន្ទីរស-២១(គុកទួលស្លែង) ដែលជាកន្លែងធ្វើទារុណកម្មនិងសម្លាប់មនុស្សអស់ជាង១ម៉ឺននាក់។ ចំណែក សារី ត្រូវអង្គការបញ្ជូនទៅលត់ដំនៅមន្ទីរស-២១យ ស្ថិតនៅព្រៃស ដែលជាសាខារបស់មន្ទីរស-២១ ពីបទរត់ចោលសមរភូមិមកផ្ទះ។ ក្រោយឆ្នាំ១៩៧៩ សារី បានត្រឡប់មកភូមិកំណើតវិញ ហើយដឹងតាមរយៈអ្នកភូមិរបស់គាត់ថាបងប្រុសគាត់ឈ្មោះ ធី ត្រូវបានអង្គការចោទថាជាភ្នាក់ងារសម្ងាត់ សេ.អ៊ី.អា ហើយត្រូវបានខ្មែរក្រហមយកទៅសម្លាប់នៅមន្ទីរ១៥ ម្តុំព្រែកឬស្សី ស្រុកកោះធំ ខេត្តកណ្តាល។


ខៀវ ខុម

មន្ទីរស-២១យ ឬមន្ទីរ២៤ គឺជាមន្ទីរឃុំឃាំងមួយស្ថិតនៅខាងលិចទីក្រុងភ្នំពេញ ក្នុងស្រុកដង្កោ ខេត្តកណ្តាល។ សារី បាននិយាយថា អ្នកដែលត្រូវបញ្ជូនទៅលត់នៅទីនោះភាគច្រើនគឺអ្នករត់ចោលសមរភូមិ ខុសសីលធម៌ និងមានបងប្អូនជាខ្មាំងបដិវត្ត។ ខៀវ ខុម ត្រូវជាបងស្រីរបស់ ខៀវ ខុន បាននិយាយថា មូលហេតុដែល ខៀវ ខុន ត្រូវបញ្ជូនមកមន្ទីរលត់ដំព្រៃសគឺដោយសារតែនាងបានលួចលាបថ្នាំសក់នៅពេលចូលសម្អាតទីក្រុង។ ចំណែក ណយ អ៊ិត ត្រូវបានបញ្ជូនមកលត់ដំនៅព្រៃសដោយសារតែគាត់រត់ចោលសមរភូមិមកផ្ទះ។

សុន សេន រដ្ឋមន្ត្រីក្រសួងការពារប្រទេសរបស់របបកម្ពុជាប្រជាធិបតេយ្យបានថ្លែងសុន្ទរកថា នៅក្នុងអង្គប្រជុំលេខាភស្តុការ



សុន សេន

កងពល និងវិរសេនាធំឯករាជ្យនៅពីឆ្នាំ១៩៧៦ថា “បដិវត្តន៍ត្រូវមានវិធានការក្តាប់ឲ្យជាប់អំពីបញ្ហាសម្រិតសម្រាំងកម្មាភិបាលដែលជាប់និន្នាការ ដោយយកចិត្តទុកដាក់តាមដាននូវបាតុភាពដែលទាក់ទងកុំឲ្យមានទស្សនៈថា វាជារឿងធម្មតាឲ្យសោះ ។ នៅក្នុងការតាមដាននេះ ត្រូវប្រជុំពិនិត្យគ្រប់បាតុភាពដែលកើតមានឡើងទាំងខ្មាំងខាងក្រៅនិងខ្មាំងខាងក្នុង” ។

នៅមន្ទីរព្រៃស សារី ធ្វើការងារបង្កបង្កើនផលនិងចិញ្ចឹមជ្រូក ។ សារី ត្រូវបានអង្គការចាត់តាំងឲ្យមើលការខុសត្រូវនិងបង្រៀនរបៀបធ្វើការងារដល់អ្នកទោសចំនួន៣៨នាក់ដែលទើបបញ្ជូនមកដល់ ។ អ្នកទោសទាំងអស់នោះរួមមាន ប្រពន្ធរបស់កម្មាភិបាលនិងកុមារ ។ ក្រោយមកមានអ្នកទោសចំនួនបីនាក់បានលួចរត់ចេញពីមន្ទីរ ហើយពេលនោះប្រធានកងឈ្មោះ មុយ បានស្តីបន្ទោសឲ្យគាត់យ៉ាងខ្លាំងថា “មិត្តនារីឯងខ្ជិលរត់ហើយនៅតែធ្វើមិនដឹងមិនឮទៀត” ។ មុយ បានលើកកាំបិតដែលកំពុងកាត់ដើមចេកបម្រុងនឹងកាប់គាត់ ។ សារី បានតបទៅវិញថា គាត់ជាអ្នកចិញ្ចឹមជ្រូក មិនមែនជាអ្នកការពារអ្នកទោសទេ ។ បីថ្ងៃក្រោយមក អ្នកទោសទាំងបីដែលបានលួចរត់ត្រូវបានកម្មាភិបាលខ្មែរ-ក្រហមចាប់មកវិញ ។ សារី បានដដីកសួរអ្នកទោសទាំងនោះថា នរណាជាអ្នកនាំរត់? អ្នកទោសទាំងបីបានឆ្លើយដាក់គ្នាទៅវិញទៅមក ។ ទីបំផុត សារី បានដាក់កំហុសទៅលើដើងថា ជាអ្នកនាំរត់ ។ សារី បានកាប់ដើមឫស្សីមួយកង់ប៉ុនៗមេដើងដើម្បីវាយអ្នកទោសទាំងអស់នោះបញ្ឈឺចិត្តមុយ ។ បន្ទាប់មកទៀត សារី បានធ្វើឲ្យបាត់គោចំនួន១ក្បាល ។ សារី ភ័យយ៉ាងខ្លាំងខ្លាចប្រធានមន្ទីរព្រៃស ឈ្មោះ ហ៊ុយ យកគាត់ទៅសម្លាប់ ។ ប៉ុន្តែដោយសារ ហ៊ុយ មានបំណងចង់ឲ្យប្អូនរបស់ខ្លួន ឈ្មោះ ហឿន រៀបការជាមួយ ទើប សារី បានរួចផុតពីសេចក្តីស្លាប់ ។



វ័ត្ន នឹម

ឆ្នាំ១៩៧៩ ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម សារី បានត្រឡប់មកស្រុកកំណើតវិញ ហើយយុវជន-យុវនារីនៅក្នុងស្រុកកោះធំមួយចំនួនបានត្រូវប្រជាជននិងអាជ្ញាធរឃុំស្រុកសង្ស័យថាបានសម្លាប់មនុស្សនៅក្នុងរបបខ្មែរក្រហម ។ នៅឆ្នាំ១៩៨០ សារី និង វ័ត្ន នឹម ដែលជាយុវនារីធ្វើការនៅមន្ទីរព្រៃសដែរ បានបបួលគ្នាមកមើលគុកទួលស្លែង ។ នៅមន្ទីរស-២១ ឬគុកទួលស្លែងមានតាំងរូបថតកម្មាភិបាលនិងអ្នកទោសជាច្រើន ដែលនៅក្នុងនោះមានរូបថត សារី និង វ័ត្ន នឹម ដែរ ។ ក្នុងខណៈដែលអ្នកទាំងពីរកំពុងសម្លឹងមើលរូបថត មានមនុស្សប្រមាណ៣-៤នាក់ឡោមព័ទ្ធគាត់ ប្រុងនឹងវាយ ហើយចោទគាត់ថា “បានសម្លាប់មនុស្ស” ។ ប៉ុន្តែអ្នកទាំងពីរបានគេចខ្លួនទៅផ្ទះបងប្អូននៅម្តុំផ្សារទួលទំពូង ។ សារី បានអះអាងបញ្ជាក់ថា “ខ្ញុំមិនបានសម្លាប់មនុស្សទេ ខ្ញុំឈឺចិត្តណាស់ដែលគ្មានអ្នករកយុត្តិធម៌ឲ្យបានត្រឹមត្រូវ ។ ធ្វើបដិវត្តន៍ គ្មានបានលទ្ធផលអ្វីទេបានត្រឹមតែទទួលការចោទប្រកាន់ថា “ជាមេឃាតករ” ។

**ប៉ាង ពីច័ន**

# ជោគវាសនារបស់អតីតយុទ្ធជននៅតំបន់៣១

នៅក្នុងឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧៥ ប្រជាជនដែលរស់នៅតាមជនបទនិងតំបន់ដាច់ស្រយាលតែងតែទទួលរងនូវការទម្លាក់គ្រាប់បែកនិងការរត់គេចចេញពីផ្ទះសម្បែងស្ទើរគ្មានលស់ថ្ងៃ បណ្តាលមកពីការប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងទាហាន លន់ ណុល (របបសាធារណរដ្ឋខ្មែរ) ។ នៅពេលជាមួយគ្នានោះ ខ្មែរក្រហមបានឆ្លៀតឱកាសអប់រំបំពាក់បំប៉នមនោគមវិជ្ជាបំផុសចលនាប្រជាជនឲ្យមានកំហឹងវណ្ណៈយ៉ាងស្រួចស្រាល់ដើម្បីឲ្យចូលរួមក្នុងចលនាតស៊ូរបស់ខ្លួន ។

នៅតាមតំបន់នីមួយៗដែលគ្រប់គ្រងដោយខ្មែរក្រហម កុមារដែលមានអាយុចាប់ពី១០-១៧ឆ្នាំត្រូវបានកម្មាភិបាលទាំងនោះឃោសនាឲ្យចូលបម្រើបដិវត្តន៍ដោយអះអាងថា «ធ្វើបដិវត្តន៍ដើម្បីរំដោះប្រទេសជាតិ រំដោះប្រជាជនឲ្យរួចផុតពីការជិះជាន់និងការឈ្លានពាន ។ កុមារមួយចំនួនដែលមិនបានស្ម័គ្រចិត្តចូលបម្រើបដិវត្តន៍ ត្រូវបានប្រធានភូមិ ប្រធានឃុំ គាបសង្កត់គ្រប់បែបយ៉ាងមិនឲ្យរស់នៅក្នុងភូមិនេះបានសុខស្រួលឡើយ ហើយមិនយូរមិនឆាប់កុមារទាំងនោះត្រូវតែបន្ទំចិត្តចូលបម្រើបដិវត្តន៍ស្ទើរគ្រប់គ្នា ។ បន្ទាប់ពីខ្មែរក្រហមបានទទួលជ័យជម្នះលើរបប លន់ ណុល កុមារមួយចំនួនដែលមានប្រវត្តិរូបជាកូនកសិករ ជាវណ្ណៈអធន ត្រូវបានខ្មែរក្រហម ជ្រើសរើសឲ្យទៅបម្រើការងារនៅតាមអង្គភាពនានានៅទីក្រុងភ្នំពេញរហូតដល់ឆ្នាំ១៩៧៩ ។

បន្ទាប់ពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ខ្មែរក្រហមបានបន្សល់ទុកឯកសារជាច្រើនប្រភេទ ដែលរួមមានទាំងឯកសារប្រវត្តិរូបកម្មាភិបាលខ្មែរក្រហមមួយចំនួនធំ ។ កាលពីពេលថ្មីៗនេះក្រុមស្រាវជ្រាវរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាបានជ្រើសរើសយកប្រវត្តិរូបចំនួន៥០ដែលសុទ្ធតែជាអតីតយុទ្ធជនខ្មែរក្រហមនៅខេត្តកំពង់ឆ្នាំង(តំបន់៣១) ដើម្បីស្វែងរកឲ្យដឹងថាក្រោយពីសង្គ្រាមចប់ តើអ្នកទាំងនោះអាចមានវាសនាត្រឡប់មកស្រុកកំណើតដែរឬទេ? ជាលទ្ធផល ក្រុមរបស់យើងបានរកឃើញអតីតយុទ្ធជនខ្មែរក្រហមដែលនៅរស់តែ៦នាក់ប៉ុណ្ណោះ ។ ចំណែកសាច់ញាតិភាគច្រើនរបស់អតីតយុទ្ធជនដែលបាត់ខ្លួន បានកំពុងបន្តទន្ទឹងរង់ចាំអ្នកទាំងនោះត្រឡប់មកផ្ទះវិញ ទោះបីជាសេចក្តីសង្ឃឹមនោះមានតិចតួចចំពោះគាត់យ៉ាងណាក៏ដោយ ។


តូច ដាត

តូច ដាត អាយុ៥០ឆ្នាំ សព្វថ្ងៃរស់នៅភូមិគាសុខ ឃុំសែប ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ។ តូច ដាត ជាបងស្រីរបស់ តូច សៃ បានឲ្យដឹងថា នៅអំឡុងឆ្នាំ១៩៧០ នៅក្បែរភូមិរបស់គាត់មានការប្រយុទ្ធគ្នាជាញឹកញាប់រវាងកងទ័ពរំដោះនិងទាហាន លន់ ណុល ហើយមេដឹកនាំនៅក្នុងភូមិគាសុខបានប្រកាសឲ្យប្រជាជនរុះរើផ្ទះសម្បែងមកធ្វើជាខ្ទមតូចៗនៅតាមវាលស្រែវិញ ។

តូច ដាត បានប្រាប់ថា នៅឆ្នាំ១៩៧៤ គណៈឃុំសែប ឈ្មោះ ខ្មៅ បានមកយកប្អូនរបស់គាត់ឈ្មោះ តូច សៃ ទៅធ្វើបដិវត្តន៍ដែលមូលដ្ឋាននៅភ្នំព្រះ ។ តូច សៃ បានយំស្រែកមិនព្រមទៅទេ ប៉ុន្តែ ខ្មៅ នៅតែបង្ខំ ។ ឪពុកម្តាយរបស់ តូច សៃ បាននិយាយថា គាត់មិនចង់ឲ្យកូនរបស់គាត់ទៅធ្វើបដិវត្តន៍ទេ ព្រោះកូនគាត់អាយុទើបតែ១២ឆ្នាំ ប៉ុន្តែគាត់គ្មានឥទ្ធិពលនឹងហាមឃាត់គណៈឃុំឈ្មោះ ខ្មៅ មិនឲ្យយកកូនរបស់គាត់ទៅបានទេ ។ នៅពេលដែល សៃ ចេញទៅធ្វើបដិវត្តន៍ សៃ បានលួចរត់ត្រឡប់មកផ្ទះពីរដង ប៉ុន្តែគណៈឃុំបានចាប់ សៃ យកទៅវិញទៀត ។ ចាប់តាំងពីពេលចាប់ខ្លួននៅលើកចុងក្រោយ សៃ មិនដែលបានត្រឡប់មកលេងផ្ទះទេ ។ នៅចុងឆ្នាំ១៩៧៥ បងស្រីរបស់ សៃ បានទទួលដំណឹងតាមរយៈប្អូនជីដូនមួយ(មកលេងស្រុកកំណើត)ថា សៃ ត្រូវអង្គការចាត់តាំងឲ្យទៅធ្វើការនៅភ្នំពេញ ។ រហូតមកដល់ពេលនេះក៏នៅតែមិនឃើញ សៃ ត្រឡប់

មកផ្ទះទៀត ។ នៅក្នុងប្រវត្តិរូបរបស់ តួច សែ ដែលបន្សល់ពីរបបខ្មែរក្រហមបញ្ជាក់ថា សែ បានចូលបដិវត្តន៍នៅឆ្នាំ១៩៧៤ ក្នុងអាយុ១២ឆ្នាំ តាមរយៈឈ្មោះ ខ្មៅ ជាគណៈឃុំ ។ សែ បានចូលធ្វើបដិវត្តន៍ដោយសារបានទទួលការអប់រំពីអង្គការមូលដ្ឋាន និងបានយល់ច្បាស់ពីការជិះជាន់ឈ្លានពានរបស់វណ្ណៈជិះជាន់គ្រប់ប្រភេទមកលើ ប្រជាជន កម្មករ កសិករក្រីក្រឲ្យរងទុក្ខវេទនា ។

ក្រោយពេលចូលបដិវត្តន៍ សែ បានស្នាក់នៅមន្ទីរឃុំចំនួន៨ថ្ងៃ បន្ទាប់មកទៅនៅមន្ទីរស្រុក១៨ គឺស្រុកកោះធំ (ខេត្តកណ្តាល) ប្រហែលមួយឆ្នាំ ទើបអង្គការបញ្ជូនមកមន្ទីរស-២១ខាងផ្នែកកុមារដែលមានឈ្មោះ ម៉ាន ជាប្រធាន ។ បន្ទាប់ពីស្នាក់នៅមន្ទីរស-២១អស់រយៈពេលកន្លះខែ តួច សែ ត្រូវបានគណៈមន្ទីរបញ្ជូនមករៀនបច្ចេកទេសយោធានៅសាលាកងពល៧០៣ រយៈពេល៣ខែ២៨ថ្ងៃទៀត ។ ក្រោយចប់វគ្គសិក្សា គណៈសាលាបានបញ្ជូន សែ មកនៅមន្ទីរស-២១ ក្នុងកងកុមារដដែល ក្រោមការដឹកនាំរបស់ គឿង ប្រធានកងអនុសេនាតូច ។ ឆ្នាំ១៩៧៦ ប្រធានកងបានបញ្ជូន សែ មកនៅព្រៃសក្នុងកងកុមារបន្ទាប់ទៀត ផ្លាស់មកនៅកងអនុសេនាតូច២៣ ដែលឈ្មោះ ផល ជាប្រធាន ។ ខែវិច្ឆិកា ឆ្នាំ១៩៧៧ សែ ត្រូវចាត់តាំងឲ្យមកធ្វើការនៅកងការពារមន្ទីរស-២១ ក្រោមការដឹកនាំរបស់ ប៉េង, ហ៊ុយ និង ស្រី ។


ថោង ថុន

ថោង ថុន អាយុ៤៨ឆ្នាំ សព្វថ្ងៃរស់នៅភូមិខ្នងទួល ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ត្រូវជាបងជីដូនមួយរបស់ ថន ថា បានប្រាប់ឲ្យដឹងថា ថន ថា មិនដែលបានរៀនសូត្រទេ ។ ថន ថា ស្ម័គ្រចិត្តធ្វើជាកងកុមារដាច់ខាតរបស់ឃុំក្រាំងស្គារ គឺដោយសារតែនៅភូមិរបស់គាត់ជាតំបន់រំដោះកើតមានការប្រយុទ្ធរវាងកងទ័ពរណសិរ្សរួបរួមជាតិកម្ពុជានិងទាហាន លន់ ណុល ជាញឹកញាប់ ហើយអ្នកដឹកនាំរណសិរ្សរួបរួមជាតិនៅតាមមូលដ្ឋានភូមិឃុំបានអប់រំផ្នែកមនោគមវិជ្ជាឲ្យកុមារចេះចងកំហឹងស្អប់ខ្ពើមពួកនាយទុន ពួកមូលធន និងពួកដែលជិះជាន់កេងប្រវ័ញ្ចប្រជាជនក្រីក្រ ។


ថន ថា ឆ្នាំ១៩៧៤

ត្រួបផ្សំនឹងជីវភាពគ្រួសារដុនដាបផង ថន ថា ក៏បានស្ម័គ្រចិត្តចូលតែម្តង ។ ចំណែក រ៉ាយ ថា ជាអ្នកជិតខាងរបស់ ថន ថា បានអះអាងថា គាត់និងមិត្តភក្តិនារីប្អូននាក់បានចូលជាសមាជិកសមាគមនារីឃុំ ហើយ ថន ថា ចូលបម្រើក្នុងកងដាច់ខាតរបស់ឃុំ ។ ក្រោយថ្ងៃ១៧ មេសា ១៩៧៥ គាត់បានជួប ថន ថា ម្តងទៀត នៅក្នុងខណៈដែល ថន ថា ហៀបនឹងឡើងរថយន្ត ។ ថន ថា បានផ្តាំគាត់ថា “បងអើយ បើសិនជាបងបានទៅស្រុក បងឯងប្រាប់ម្តាយខ្ញុំផង ខ្ញុំត្រូវគេបញ្ជូនទៅភូមិភាគហើយ” ។ នៅក្នុងប្រវត្តិរូប ថន ថា សរសេរថា ចូលបដិវត្តនៅថ្ងៃទី៩ ខែមីនា ឆ្នាំ១៩៧៤ អាយុ១៣ឆ្នាំ ក្រោមការខទ្ទេសនាមរបស់ចាម ។ ថន ថា ត្រូវបានអង្គការចាត់តាំងឲ្យនៅមន្ទីរ៣១ ដឹកនាំដោយឈ្មោះ វ៉ាត ។ ខែតុលា ឆ្នាំ១៩៧៥ ថន ថា បានមករៀននៅសាលាយោធា៧០៣ ក្រោមការដឹកនាំរបស់ ប៉េង, យ៉ែម និង ណៃ ។ បន្ទាប់ពីបានបញ្ចប់វគ្គ ថន ថា ត្រូវអង្គការ

បញ្ជូនមកកង១១(កងកុមារ) ដែលមានឈ្មោះ ផន, ខាត និង កុំ ជាអ្នកដឹកនាំ ។ ខែឧសភា ឆ្នាំ១៩៧៦ អង្គការបានផ្លាស់ ផន ផា ឲ្យមកបម្រើការជាយុទ្ធជនពេទ្យនៅមន្ទីរស-២១ ។


នួន និន

នួន និន អាយុ៦៥ឆ្នាំ រស់នៅភូមិស្វាយពក ឃុំស្វាយ ខេត្តកំពង់ឆ្នាំង ត្រូវជាម្តាយរបស់ ណេង អ៊ិន បានប្រាប់ថា កូនរបស់គាត់ឈ្មោះ ណេង អ៊ិន អាយុ១៣ឆ្នាំ ដែលបានចូលរៀនបានមួយឆ្នាំ ស្រាប់តែប្រធានកងឈ្លបឃុំស្វាយបង្ខំឲ្យចូលធ្វើឈ្លបឃុំតែម្តង ។ ណេង អ៊ិន និងកុមារ៣នាក់ទៀត ត្រូវគណៈឃុំស្វាយ បញ្ជូនឲ្យទៅធ្វើជាកងទ័ព ។ ណេង អ៊ិន បានស្រែកយំព្រោះតែមិនចង់ឃ្លាតពីម្តាយនិងបងប្អូន ។ នួន និន នៅតែទន្ទឹងមើលផ្លូវកូន ហើយព្រួយបារម្ភមិនដឹងថាសុខទុក្ខរបស់កូនយ៉ាងណាទេ ។ នៅក្នុងប្រវត្តិរូប ណេង អ៊ិន បានចូលបដិវត្តនៅខែកុម្ភៈ ឆ្នាំ១៩៧២ ។ ណេង អ៊ិន ចូលបដិវត្តដោយសារមានការណែនាំពីសំណាក់អង្គការបដិវត្តន៍ឲ្យមានកំហឹងឈឺចាប់ចំពោះខ្មាំងដែលជិះជាន់សង្កត់សង្កិនមកលើប្រជាជន ។

ក្រោយពេលចូលបដិវត្ត ណេង អ៊ិន ធ្វើជាកងឈ្លបឃុំស្វាយ ។ ក្រោយពីខ្មែរក្រហមរំដោះក្រុងភ្នំពេញ អង្គការបានផ្លាស់ឲ្យមកធ្វើការនៅឃុំមួយខែ ក្រោយមកក៏បញ្ជូនបន្តមកនៅមន្ទីរស្រុកកំពង់ត្រឡាចស្នាក់នៅបាន១យប់រួចក៏បញ្ជូនបន្តមកតំបន់៣១ ។ រយៈពេលមួយខែក្រោយមក អង្គការក៏បញ្ជូនមកទីក្រុងភ្នំពេញទៀតដោយស្នាក់នៅបឹងទំពុន ក្រោមការដឹកនាំរបស់ ម៉ាន ។ ស្នាក់នៅបឹងទំពុនរយៈពេល៧ថ្ងៃ អង្គការបានបញ្ជូនមករៀនសាលាបច្ចេកទេសយោធា៧០៣អស់រយៈ៣ខែ ២៨ថ្ងៃ ។ បន្ទាប់ពីបញ្ចប់វគ្គ ណេង អ៊ិន ត្រូវបានបញ្ជូនមកមន្ទីរស-២១ ក្រោមការដឹកនាំរបស់ ប៉េង, ហ៊ុយ និង ស្រី ។

បច្ចុប្បន្ននេះក្រុមគ្រួសាររបស់អ្នកទាំងនេះកំពុងតែរង់ចាំមើលផ្លូវកូន និងប្អូនជានិច្ច ព្រោះគាត់នៅមិនទាន់ទទួលបានពត៌មានច្បាស់លាស់ ។

**ឡុង ដានី**

# សេចក្តីជូនដំណឹង

មជ្ឈមណ្ឌលឯកសារកម្ពុជាសង្ឃឹមថា ប្រជាជនកម្ពុជាគ្រប់រូបដែលធ្លាប់ឆ្លងកាត់របបខ្មែរក្រហម បាននិងកំពុងសរសេរអត្ថបទ ឬសៀវភៅអំពីរឿងរ៉ាវផ្ទាល់ខ្លួន ហើយនឹងផ្ញើមកមជ្ឈមណ្ឌលឯកសារកម្ពុជា តាមអាសយដ្ឋានខាងក្រោមៈ

ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ

ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥

ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨

**ការសរសេរអត្ថបទនេះមានសារសំខាន់÷**

◆ ចូលរួមជាចំណែកមួយនៃប្រវត្តិសាស្ត្រ ទុកសម្រាប់ក្មេងៗជំនាន់ក្រោយបានដឹងនិងសិក្សារៀនសូត្រ ។

◆ ជាវិធីមួយដើម្បីរំងាប់អារម្មណ៍ ដោយយកហេតុការណ៍ សេចក្តីទុក្ខ ការខឹងគុំកួន មកតម្កល់ជាឯកសារប្រវត្តិសាស្ត្រ ដើម្បីបម្រើដល់ការស្រាវជ្រាវតទៅអនាគត ។

◆ ការចងចាំគឺជាសន្តិវិធីមួយក្នុងការទប់ស្កាត់មិនឲ្យអំពើប្រល័យពូជសាសន៍កើតឡើងបានជាថ្មីម្តងទៀតក្នុងសង្គមមនុស្ស ។

◆ ជួយដល់ការស្វែងរកយុត្តិធម៌ជូនដល់ប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតនៅក្នុងរបបខ្មែរក្រហមនិងជួយលើកកម្ពស់ការគោរពសិទ្ធិមនុស្ស ។

សូមអរគុណ ។

# កម្ពុជាៈ តុលាការដែលមានអំណាចក្នុងការជម្រះក្តីករណីឧក្រិដ្ឋសង្រ្គាម

***ទីក្រុងញូវយ៉ក ថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣***

សេចក្តីថ្លែងការណ៍របស់រដ្ឋាភិបាលកម្ពុជាកាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ បានបញ្ជាក់អំពីការបំអកដល់អង្គការសហប្រជាជាតិ រួមជាមួយមហាអំណាចលោកខាងលិចមួយចំនួនដែលបានទទួលស្គាល់និងការការពារដោយចំហចំពោះរបបប្រល័យពូជសាសន៍ខ្មែរក្រហមនៅពេញអំឡុងទសវត្សរ៍ឆ្នាំ១៩៨០ និងស្ទើរតែពេញអំឡុងទសវត្សរ៍ឆ្នាំ១៩៩០ ប៉ុន្តែនៅប៉ុន្មានឆ្នាំថ្មីៗនេះមានការចោទប្រកាន់តាមតែខ្លួនយល់ថាត្រឹមត្រូវមកលើរដ្ឋាភិបាលកម្ពុជាថាលេងល្បិចពន្យារពេលនិងរារាំងដល់ការចាប់ផ្តើមបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលនៅរស់ ។ ឯកសាររបស់ភាគីកម្ពុជាមិនត្រឹមតែវាយបកត្រឡប់មកលើការចោទប្រកាន់ទាំងនេះទេ ប៉ុន្តែមានផ្ទុកនូវបញ្ហាខ្ពស់ជាងនេះទៅទៀត ពោលគឺយុត្តិធម៌និងការផ្សះផ្សាជាតិមានទម្ងន់ ឬសារសំខាន់ជាងការចងពៀរឬសងសឹកគ្នាទៅវិញទៅមក ។ ឯកសារនេះក៏បានស្នើឡើងដែរថា សូមឲ្យបង្កើតនូវគំរូមួយដែលទាក់ទងដល់កិច្ចសហប្រតិបត្តិការរវាងស្ថាប័នសាធារណៈនានានិងរដ្ឋាភិបាលដែលមានអធិបតេយ្យភាព អាចបង្ហាញថា ពិតជាមានកម្រិតខ្ពស់ជាងតុលាការព្រហ្មទណ្ឌអន្តរជាតិដែលស្នើឡើងពីខាងក្រៅនិងមានរូបរាងរួចហើយ ។

នៅក្នុងអំឡុងពេល៣ឆ្នាំ ៨ខែ និង ២០ថ្ងៃ គិតចាប់ពីខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ប្រជាពលរដ្ឋកម្ពុជាម្នាក់ក្នុងចំណោម៤នាក់ត្រូវស្លាប់ ។ ភាគច្រើនត្រូវគេយកទៅសម្លាប់ដោយសារមនោគមវិជ្ជាមួយដែលស្អប់ខ្ពើមចំពោះអ្នកដែលចេះអាន ចេះសរសេរ ឬអ្នកដែលមានជំនាញអាចផ្ចាញ់គំនិតស្ងប់ស្ងៀមដូចគល់ឈើទាមទារដោយបងលេខ១ ឬ ប៉ុល ពត ដែលបានទៅបណ្តុះបណ្តាលនៅវិទ្យាល័យ Sorbonne និងអ្នកនៅជិតស្និទ្ធជាមួយខ្មែរក្រហម ។ តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានធ្វើឡើងនៅខែមករា ឆ្នាំ១៩៧៩ ក្រោយពីការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យដោយកងកម្លាំងមិនប្រក្រតីរួមគ្នានិងកងទ័ពវៀតណាម ។ ពេលនោះរដ្ឋាភិបាលថ្មីក៏កាត់ទោសមេដឹកនាំខ្មែរក្រហមដោយកំបាំងមុខក្នុងនាមសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ អង្គការសហប្រជាជាតិមិនត្រឹមតែបដិសេធមិនព្រមទទួលស្គាល់តុលាការនេះប៉ុណ្ណោះទេ ប៉ុន្តែបានបន្តទុកអាសនៈឲ្យខ្មែរក្រហមអង្គុយជាតំណាងស្របច្បាប់របស់កម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិរហូតដល់ឆ្នាំ១៩៩១ទៀតផង ។ នៅឆ្នាំដដែលនោះ កិច្ចចរចាសន្តិភាពទីក្រុងប៉ារីសកាន់តែមានអំណោយផលដល់ភាពស្របច្បាប់របស់ខ្មែរក្រហមថែមទៀត ដោយអនុញ្ញាតឲ្យមេឃាតករទាំងនេះអង្គុយនៅលើអង្គការដឹកនាំថ្មីរបស់កម្ពុជា ពោលគឺ អេស.អិន.ស៊ី ។

នៅខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រី ហ៊ុន សែន និងសម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ទ្រង់បានសរសេរសំបុត្រមួយច្បាប់ផ្ញើទៅកាន់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិសុំជំនួយក្នុងការវិនិច្ឆ័យទោសមេដឹកនាំខ្មែរក្រហម ។ កិច្ចចរចាចេះតែបន្តរហូតទៅដល់ខែកុម្ភៈ ឆ្នាំ២០០២ ស្តីអំពីការបង្កើតតុលាការពិសេសមួយ ដោយមានការចូលរួមពីអន្តរជាតិនិងកម្ពុជាខ្លួនឯងផ្ទាល់ ។

ប៉ុន្តែនៅថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០០២ អង្គការសហប្រជាជាតិដែលទាមទារឲ្យមានវិសោធនកម្មច្បាប់កម្ពុជាទាក់ទងនឹងតុលាការនេះ បានឲ្យសញ្ញាដកថយពីកិច្ចចរចា ។ កិច្ចចរចាចាប់ផ្តើមដំណើរការសាជាថ្មីនៅពេលដែលមហាសន្និបាតអង្គការសហប្រជាជាតិ

បោះឆ្នោតនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ដោយមានប្រទេសចំនួន១២៣គាំទ្រ និង៣៧អនុបវាទ ដែលទាមទារឲ្យលោកអគ្គលេខាធិការអង្គការសហប្រជាជាតិធ្វើការចរចាបន្តទៀត ។

នៅក្នុងបរិបទនេះហើយដែលគណៈប្រតិភូកម្ពុជាប្រចាំនៅអង្គការសហប្រជាជាតិបានចេញសេចក្តីថ្លែងការណ៍ជាផ្លូវការមួយនៅថ្ងៃទី១៣ ខែមករា ឆ្នាំ២០០៣ អំពី «ទាក់ទងនឹងការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីខក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ» ។ខាងក្រោមនេះគឺជាសេចក្តីដកស្រង់ចេញពីសេចក្តីថ្លែងការណ៍ដោយមានការបន្ថែមចំណងជើងតូច ។

## ហេតុផល បីលីខុន

នៅថ្ងៃទី៧ ខែមករា ឆ្នាំ២០០៣ កម្ពុជាបានប្រារព្ធខួបអនុស្សាវរីយ៍លើកទី២៤នៃការផ្តួលរំលំរបបខ្មែរក្រហមដែលធ្វើឲ្យប្រជាជនកម្ពុជាស្លាប់អស់ជាងមួយភាគបួន ។ កម្ពុជាបានទទួលយកកាតព្វកិច្ចក្រោមអនុសញ្ញាប្រល័យពូជសាសន៍ដើម្បីកាត់សេចក្តីជនទាំងឡាយណាដែលទទួលខុសត្រូវចំពោះការរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមក្នុងចន្លោះឆ្នាំ១៩៧៥-១៩៧៩ ។

ដើម្បីឈានដល់ការសម្រេចគោលដៅនេះ ដោយឆ្លើយតបទៅតាមការអញ្ជើញរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិឯកឧត្តម កូហ្វី អាណាន់ គណៈប្រតិភូកម្ពុជាដឹកនាំដោយ សុខ អាន ទេសរដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីបានអញ្ជើញមកដល់ទីក្រុងញូវយ៉ក ហើយបានចូលរួមប្រជុំចំនួនប្រាំពីរលើក ។ មួយលើកប្រជុំជាមួយលោកអគ្គលេខាធិការផ្ទាល់ និងប្រាំមួយលើកទៀតជាមួយតំណាងអគ្គលេខាធិការអង្គការសហប្រជាជាតិដែលដឹកនាំដោយឯកឧត្តម ហេន កូរែល ទីប្រឹក្សាច្បាប់ ។ កិច្ចប្រជុំទាំងនេះគឺជាការរៀបចំបន្តកិច្ចចរចាសាជាថ្មីអំពីបញ្ហាកាត់សេចក្តីខក្រិដ្ឋកម្មដែលប្រព្រឹត្តដោយខ្មែរក្រហម ដោយអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិលេខ៥៧,២២៨ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ។

គណៈប្រតិភូកម្ពុជាសូមឆ្លៀតឱកាសនេះដើម្បីបញ្ចប់កិច្ចចរចាដោះស្រាយបញ្ហាមួយចំនួននិងបញ្ហាពាក់ព័ន្ធដែលបានលើកឡើង ។

១) យើងសូមបញ្ជាក់សាជាថ្មីថារាជរដ្ឋាភិបាលកម្ពុជាបានតាំងចិត្តបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ ភាពត្រឹមត្រូវនិងទៅតាមគន្លងនីតិវិធីត្រឹមត្រូវតាមច្បាប់ ។ ចាប់តាំងពីឆ្នាំ១៩៧៩មក នៅពេលដែលយើងផ្តួលរំលំរបបខ្មែរក្រហម យើងបានខិតខំរិះរកគ្រប់មធ្យោបាយដើម្បីដោះស្រាយបញ្ហាខក្រិដ្ឋកម្មទាំងនេះ ។ យើងបានពុះពារដើម្បីស្វែងរកការពិត យុត្តិធម៌និងការបង្រួបបង្រួមនិងផ្សះផ្សាជាតិ ដែលជាការសំយោគមួយមានលក្ខណៈប្រទាំងប្រទើស ប៉ុន្តែមានលក្ខណៈចាំបាច់ ។ បើគ្មានការសំយោគបែបនេះទេ ប្រជាជនកម្ពុជាមិនអាចគេចផុតពីស្នាកស្នាមនៃអំពើប្រល័យពូជសាសន៍ ហើយមិនអាចកសាងសង្គមមួយប្រកបដោយសន្តិភាពទាញយកផលប្រយោជន៍ចេញពីធនធានធម្មជាតិដ៏សម្បូណ៍បែបនិងធនធានមនុស្សរបស់យើងទេ ។

នេះជាលើកទីមួយហើយក្នុងប្រវត្តិសាស្ត្រទំនើបដែលប្រទេសជាតិទាំងមូលមានសន្តិភាពនិងការរួបរួមគ្នា ដែលប្រការនេះគឺពិតជាសមិទ្ធផលដ៏ធំកំភួនមួយ ។

## ពិភពលោកមិនអើពើនឹងតុលាការឆ្នាំ១៩៧៩

សំណើរបស់សហនាយករដ្ឋមន្ត្រីកម្ពុជានៅខែមិថុនា ឆ្នាំ១៩៩៧ សុំជំនួយពីអង្គការសហប្រជាជាតិដើម្បីអនុវត្តកិច្ចការនេះគឺជាការចាប់ផ្តើមបើកឆាកចុងក្រោយ នៅក្នុងដំណើរដ៏វែងឆ្ងាយឆ្ពោះទៅរកការពិត យុត្តិធម៌និងការផ្សះផ្សាជាតិ ។ នៅឆ្នាំ១៩៧៩ យើងបានបង្កើតតុលាការប្រជាជនបដិវត្តដែលជាការជំនុំជម្រះក្តីពីបទប្រល័យពូជសាសន៍លើកទីមួយនៅលើពិភពលោកដែលក្នុងនោះយើងបានអញ្ជើញអ្នកច្បាប់អន្តរជាតិឲ្យមកចូលរួមដែរ ។ ជាអកុសល ដោយសារភាពខ្សោយក្នុងដំណើរការជំនុំជម្រះក្តីនោះ ជាពិសេសភាពឯកោខាងនយោបាយរបស់រដ្ឋាភិបាលយើងកាលពីពេលនោះកសិណសាក្សីនិងសាលក្រមមិនត្រូវបានអើពើពីពិភពខាងក្រៅឡើយ ។ ខ្មែរក្រហមត្រូវបានបន្តទទួលស្គាល់និងផ្តល់អាសនៈនៅអង្គការសហប្រជាជាតិ ចំណែកខាងកម្ពុជាគឺខិតខំរិះរកមធ្យោបាយដោះស្រាយបញ្ហានេះ ។ ឥឡូវនេះ

នៅពេលដែលយើងដុតដៃដុតជើងប្រឹងប្រែងស្វែងរកយុត្តិធម៌ ដោយសង្ឃឹមថា ធ្វើជាដៃគូជាមួយអង្គការសហប្រជាជាតិ យើងត្រូវចាំយ៉ាងច្បាស់ថា ការស្វែងរកយុត្តិធម៌នេះមិនត្រូវធ្វើឲ្យខូចខាតដល់ដំណើរការផ្សះផ្សាជាតិឡើយ ។

កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ១៩៩១ បានផ្តល់ភាពស្របច្បាប់ខាងនយោបាយដល់ខ្មែរក្រហម ហើយនៅពេលដែលអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិចាកចេញពីកម្ពុជានៅឆ្នាំ១៩៩៣ រដ្ឋាភិបាលចម្រុះថ្មីត្រូវគេទុកឲ្យប្រឈមមុខនឹងការបន្តនយោបាយសង្គ្រាមស៊ីវិល និងការបង្កអស្ថិរភាព ។ ពេលនោះយើងបានប្រើយុទ្ធសាស្ត្រចម្រុះទាំងផ្លូវនយោបាយ តាមផ្លូវច្បាប់ សេដ្ឋកិច្ច និងយោធា ក្នុងនោះមានច្បាប់ដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ដែលអនុម័តនៅឆ្នាំ១៩៩៤ និងកិច្ចខិតខំប្រឹងប្រែងជំរុញឲ្យសមាជិកខ្មែរក្រហមផ្តាច់ខ្លួនទៀតផង ដែលនយោបាយនេះ សម្តេចនាយករដ្ឋមន្ត្រីឲ្យឈ្មោះថានយោបាយឈ្នះ-ឈ្នះ ។

នៅចុងខែធ្នូ ឆ្នាំ១៩៩៨ យើងបានបញ្ចប់រចនាសម្ព័ន្ធនយោបាយនិងយោធារបស់ខ្មែរក្រហម ហើយដល់ដំណាក់កាលនោះគឺត្រូវប្រឈមមុខនឹងបញ្ហាផ្សះផ្សាជាតិនិងយុត្តិធម៌ ។ កម្ពុជាប្រហែលជាអាចជម្រាបជូនមេរៀនមួយចំនួនផ្សេងទៀតទាក់ទងនឹងបទពិសោធន៍ក្នុងដំណើរការផ្សះផ្សាជាតិ ។ សព្វថ្ងៃនេះអតីតមេដឹកនាំខ្មែរក្រហមបានទម្លាក់អាវុធចុះ ហើយបានចាប់ផ្តើមកសាងជីវិតសាជាថ្មីជាមួយសង្គមជាតិ ចំណែកអតីតភាគីបដិបក្ខបានចូលមកធ្វើការជាមួយគ្នាដើម្បីអភិវឌ្ឍប្រទេស ។

នៅពេលដែលសហនាយករដ្ឋមន្ត្រីធ្វើសំណើទៅអង្គការសហប្រជាជាតិសុំជំនួយរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមនោះគឺជាការសុំជំនួយមិនមែនជាការសុំឲ្យធ្វើការផ្លាស់ប្តូរគ្រឹះស្ថានរបស់យើងដែលយើងកំពុងតែខិតខំសម្រេចឲ្យបាននោះទេ ។

## យុត្តិធម៌ត្រូវពន្យារពេល

២) យើងត្រូវបានរិះគន់អំពីពេលវេលានៃការចរចា ។ យើងហួសពីដឹងទៅទៀតថា កាលណាយុត្តិធម៌ត្រូវពន្យារពេលគឺយុត្តិធម៌ក៏គ្មានរូបរាងដែរ ហើយយើងដឹងទៀតថា យើងបន្តខិតខំធ្វើការងារនេះជារៀងរាល់ថ្ងៃដើម្បីដោះស្រាយការពន្យារពេលដែលអូសបន្លាយអស់រយៈពេល២៤ឆ្នាំមកហើយនេះ ក្នុងគោលបំណងនាំយកមេគំនិតនិងចារីមកកាត់ទោសចំពោះមុខច្បាប់ ។ កម្ពុជាបានគាត់តែងច្បាប់បង្កើតអង្គជំនុំជម្រះវិសាមញ្ញដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហម ហើយច្បាប់នេះត្រូវបានប្រកាសឲ្យប្រើនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ពោលគឺពីរឆ្នាំក្រោយពីសេចក្តីព្រាងច្បាប់ត្រូវបានដាក់ឲ្យមានការពិភាក្សាដេញដោល ។ ចំណែកកិច្ចចរចាជាមួយអង្គការសហប្រជាជាតិគឺចាប់ផ្តើមនៅខែសីហា ឆ្នាំ១៩៩៩ ។ នេះគឺជារយៈពេលមួយដែលមិនធម្មតាសម្រាប់ប្រទេសមួយក្នុងការគាត់តែងច្បាប់ ជាពិសេសប្រភេទច្បាប់ដែលមិនធ្លាប់មានពីមុនមកដោយអនុញ្ញាតឲ្យមានការចូលរួមពីសំណាក់ជនបរទេសនៅក្នុងតុលាការជាតិនិងនៅក្នុងបញ្ហាមួយដែលស្ថិតក្នុងលក្ខណៈពិបាកដោះស្រាយ ។ សេចក្តីព្រាងច្បាប់ត្រូវបានលើកយកមកពិភាក្សានៅទីស្តីការគណៈរដ្ឋមន្ត្រីចំនួនបីលើកដាច់ដោយឡែកពីគ្នា ពិភាក្សាដេញដោល ដោយគណៈកម្មាធិការនីតិកម្មនិងសម័យប្រជុំពេញអង្គរបស់អង្គការនីតិបញ្ញត្តិទាំងពីររបស់យើង ត្រួតពិនិត្យធម្មនុញ្ញភាពដោយក្រុមប្រឹក្សាធម្មនុញ្ញ ហើយចុងបញ្ចប់សេចក្តីព្រាងនេះត្រូវបានឡាយព្រះហស្តលេខាដោយព្រះប្រមុខរដ្ឋព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាប្រកាសឲ្យប្រើប្រាស់ជាផ្លូវការ ។ ការពន្យារពេលប៉ុន្មានខែ គឺដោយហេតុថាក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថាសេចក្តីព្រាងនេះមិនសូវមានលក្ខណៈច្បាស់លាស់ ពោលគឺអតិបរមានៃទោសរហូតដល់មួយជីវិត ដូច្នេះវាផ្ទុយទៅនឹងរដ្ឋធម្មនុញ្ញដែលចែងមិនឲ្យមានទោសប្រហារជីវិត ។ ចុងបញ្ចប់រដ្ឋាភិបាលក៏បានធ្វើវិសោធនកម្មលើសេចក្តីព្រាងច្បាប់ រួចហើយដាក់ជូនសភានិងព្រឹទ្ធសភាពិភាក្សាដេញដោលម្តងទៀត ។ សំខាន់យើងត្រូវដឹងថា ប្រទេសយើងសព្វថ្ងៃកំពុងតែស្ថិតក្នុងដំណើរការប្រជាធិបតេយ្យនីយកម្ម ហើយក្រុមប្រឹក្សាធម្មនុញ្ញគឺជាស្ថាប័នទើបតែបង្កើតថ្មីដែលអំណាចនិងការសម្រេចចិត្តរបស់ខ្លួនគួរតែត្រូវគោរព ។ ម្យ៉ាងវិញទៀត យុត្តិធម៌ដែលយើងរកឃើញគឺជាយុត្តិធម៌ចង់ស្តារឲ្យមានឡើងវិញក្រោយពេលគេបំភ្លេចចោលអស់មួយរយៈ ដែលជាការរួមចំណែកដល់ការ

ស្ថាបនាឡើងវិញនិងការធ្វើប្រជាធិបតេយ្យនីយកម្មសង្គមជាតិយើងទាំងមូល ។ ដើម្បីប្រតិបត្តិដំណើរកាត់ទោសមេដឹកនាំខ្មែរក្រហមពីបទប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិពុំមែនមានន័យថាគ្មានគ្រោះថ្នាក់នោះទេ ។ ដូច្នេះហើយបានជាយើងសុខចិត្តធ្វើការលះបង់ជាច្រើនដើម្បីទទួលបាននូវការគាំទ្រពីសំណាក់ប្រជាជនយើងទៅលើបញ្ហានេះ ។

សំឡេងឆ្នោតឯកច្ឆន្ទនៅក្នុងសភាជាតិ និងព្រឹទ្ធសភាគាំទ្រដល់ច្បាប់នេះគឺច្រើនមិនដែលធ្លាប់មាន ហើយជាសក្ខីភាពបញ្ជាក់ពីលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងពង្រឹងនិងមិនឲ្យប៉ះពាល់ដល់សន្តិភាពដែលងាយនឹងប្រេះស្រាំ ។ ការប៉ាន់ស្មានអំពីការចំណាយពេលវេលានេះគឺពិតជាគំនិតរបស់បុគ្គល ប៉ុន្តែ៣ឆ្នាំចុងក្រោយនៃការចរចាត្រូវតែចាត់ទុកថា ជាផ្នែកមួយនៃដំណើរការជាប្រវត្តិសាស្ត្រអស់រយៈពេល២៤ឆ្នាំនេះ ហើយអាចយកទៅប្រៀបធៀបជាមួយប្រទេសដទៃៗទៀតដែលចំណាយពេលអស់រាប់ឆ្នាំ មានដល់ទៅរាប់ទសវត្សរ៍ទៀតផង ក្នុងការប៉ុនប៉ងដោះស្រាយបញ្ហាឧក្រិដ្ឋកម្មដែលមានលក្ខណៈបែបនេះ ។

## ឧក្រិដ្ឋកម្មនៅក្នុងប្រទេសយើង

៣) យើងពិតជាដឹងអំពីចំណុចខ្សោយខ្លះៗ នៅក្នុងប្រព័ន្ធតុលាការនិងប្រព័ន្ធច្បាប់របស់យើងដែលមួយផ្នែកធំបណ្តាលមកពីព្រៃផ្សៃដ៏សែនធ្ងន់របស់ខ្មែរក្រហមដែលវាយសំពងមកលើរចនាសម្ព័ន្ធសង្គមរបស់កម្ពុជា ។ មិនតែប៉ុណ្ណោះ នេះគឺជាមូលហេតុមួយក្នុងចំណោមមូលហេតុសំខាន់ៗដែលនាំឲ្យយើងស្នើសុំជំនួយពីអង្គការសហប្រជាជាតិនៅឆ្នាំ១៩៩៧ ។ ក៏ប៉ុន្តែយើងសូមបដិសេធនូវទស្សនៈដែលថាប្រព័ន្ធតុលាការរបស់យើងមិនគួរត្រូវបានប្រគល់នូវតួនាទីសកម្ម និងសំខាន់ក្នុងដំណើរការស្វែងរកយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុតនៅក្នុងប្រវត្តិសាស្ត្ររបស់យើង ។ យើងសូមបង្ហាញជូននូវកិច្ចខិតខំប្រឹងប្រែងសំខាន់ៗដែលរដ្ឋាភិបាលយើងបានធ្វើឈានទៅកែទម្រង់ផ្នែកច្បាប់និងតុលាការដែលលទ្ធផលនៃកំណែទម្រង់នេះឃើញជាបណ្តើរៗហើយ ។ កំណែទម្រង់ទាំងនេះធ្វើឲ្យយើងជឿជាក់ថា យើងមានអ្នកច្បាប់ជាអាជីពច្បាស់លាស់និងមានលក្ខណៈសម្បត្តិពេញលេញក្នុងការដើរតួក្នុងអង្គជំនុំជម្រះក្តីរឿងក្តីមេដឹកនាំខ្មែរក្រហមនាពេលខាងមុខ ដោយរួមជាមួយនឹងសមភាគីអន្តរជាតិ ។ យើងសូមបញ្ជាក់ថា នៅក្នុងដំណើរការក្តីនេះ យើងមិនត្រឹមតែបានស្នើសុំជំនួយអន្តរជាតិទេ ប៉ុន្តែយើងក៏បានសុំឲ្យមានការចូលរួមពីអន្តរជាតិដែរ ហើយយើងបានយល់ព្រមចូលរួមជាមួយសហគមន៍អន្តរជាតិក្នុងការចែករំលែកបន្ទុកដ៏ធ្ងន់ធ្ងរនៃការវិនិច្ឆ័យក្តីឧក្រិដ្ឋកម្មធ្ងន់ធ្ងរដែលប្រព្រឹត្តឡើងនៅក្នុងប្រទេសរបស់យើងនិងដោយប្រជាជនយើងផ្ទាល់ ។ គ្មានសេចក្តីសម្រេចណាមួយដែលធ្វើទៅបានដោយគ្មានការចូលរួមនិងការយល់ស្របពេញលេញនោះទេ ។

ចំណែកឯសមត្ថភាពក្នុងការរៀបចំរបស់យើងវិញ កម្ពុជានៅឆ្នាំនេះកំពុងតែធ្វើជាអធិបតីនៃសមាគមប្រជាជាតិអាស៊ី-អាគ្នេយ៍ ហើយថ្មីៗនេះទៀតសោត កម្ពុជាបានធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំកំពូលអាស៊ាននិងកិច្ចប្រជុំធំៗផ្សេងៗទៀតប្រកបដោយជោគជ័យរួមទាំងកិច្ចប្រជុំកំពូលមហាអនុតំបន់ទន្លេមេគង្គ ដែលមានការចូលរួមពីសំណាក់ប្រមុខរដ្ឋាភិបាល ប្រមុខរដ្ឋនិងរដ្ឋមន្ត្រីក្រសួងការបរទេសជាច្រើនប្រទេសទៀតផង ។

៤) មានអ្នកសង្កេតការណ៍មួយចំនួនបានចោទសួរអំពីបញ្ហានៃភាពគួរឲ្យទុកចិត្តបាននៃដំណើរការជំនុំជម្រះក្តីដូចដែលមានចែងនៅក្នុងច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ។

នៅក្នុងដំណើរការនេះយើងបានធ្វើការចរចា ហើយឈានដល់កិច្ចសម្របសម្រួលឈានទៅបង្កើតរូបមន្តមួយដែលឆ្លុះបញ្ចាំងអំពីការធ្វើការរួមគ្នា ដែលគ្មានភាគីណាគ្រប់គ្រងលើភាគីណាមួយឡើយ ប៉ុន្តែជាសមធម៌មួយដែលផ្តល់នូវការចូលរួមជាលក្ខណៈជាតិនិងអន្តរជាតិនៅគ្រប់ដំណាក់កាលទាំងអស់ តាំងពីការចោទប្រកាន់ ការស៊ើបអង្កេត និងការចេញសាលក្រម...។

## ព្រឹត្តិការណ៍សំខាន់នៅក្នុងច្បាប់មនុស្សធម៌

៥) កិច្ចចរចាធ្វើឡើងប៉ុន្មានឆ្នាំនេះបានបង្កើតចេញជាដែនសមត្ថកិច្ចតាមពេលវេលានិងសម្ភារនៃអង្គជំនុំជម្រះវិសាមញ្ញ...។ នៅពេលដែលយើងចាប់ផ្តើមការចរចានៅឆ្នាំ១៩៩៩ ជំហររបស់យើងគឺខុសគ្នាដាច់ស្រឡះ ។ វាមិនគួរឲ្យគិតដល់ទាល់តែសោះថា ឥឡូវនេះឈានដល់ជំហរយ៉ាងដូច្នេះ ហើយបោះបង់

បោលនូវសមិទ្ធផលដែលយើងបានមកដោយលំបាកនៅក្នុងបញ្ហាដែនសមត្ថកិច្ចនេះ ។ យើងប្រាកដក្នុងចិត្តថា គំរូរបស់កម្ពុជាមិនត្រឹមតែគួរឲ្យជឿទុកចិត្តបានទេ ប៉ុន្តែវាតំណាងឲ្យព្រឹត្តិការណ៍ប្រវត្តិសាស្ត្រនៅក្នុងច្បាប់មនុស្សធម៌អន្តរជាតិដែលឥឡូវនេះចេញពីតុលាការព្រហ្មទណ្ឌអន្តរជាតិដែលដំណើរការរួចទៅហើយដូចដែលបានឃើញស្រាប់កាលពីពាក់កណ្តាលសតវត្សរ៍កន្លងទៅនៅនូរិមប៊ឺកនិងតូក្យូ និងថ្មីៗនេះនៅទីក្រុងឡាអេនិងអារូហ្សាឆ្ពោះទៅកាន់ភាពបំពេញគ្នាទៅវិញទៅមកដោយជំរុញលើកទឹកចិត្តដល់ប្រទេសនីមួយៗឲ្យយកយុត្តិធម៌មកប្រើនៅក្នុងកម្រិតជាតិ នៅក្នុងលក្ខណៈដែលស្របគ្នាទៅនឹងគំរូអន្តរជាតិនិងស្របគ្នាទៅនឹងការទទួលខុសត្រូវរបស់យើងក្រោមលិខិតូបករណ៍សំខាន់ៗជាពិសេសអនុសញ្ញាប្រល័យពូជសាសន៍... ។

ក្រោយពីកិច្ចប្រជុំស៊ីជម្រៅដែលប្រព្រឹត្តទៅនៅទីក្រុងញូវយ៉កនេះ យើងបានអញ្ជើញលោកអគ្គលេខាធិការអង្គការសហប្រជាជាតិឲ្យបញ្ជូនគណៈប្រតិភូមកកាន់ទីក្រុងភ្នំពេញនៅពេលខាងមុខនេះដើម្បីធ្វើឲ្យត្រូវតាមទម្រង់នូវកិច្ចព្រមព្រៀងដែលនឹងត្រូវចុះហត្ថលេខាដោយភាគីទាំងពីរ រួចហើយចាប់ពិនិត្យធ្វើការងារដែលពន្យារពេលទុកជាយូរមកហើយក្នុងការនាំយកជនទាំងឡាយណាដែលទទួលខុសត្រូវខ្ពស់បំផុតមកកាត់ទោសចំពោះមុខច្បាប់ ។

យើងសូមថ្លែងអំណរគុណចំពោះប្រទេសទាំង១៥០ដែលបានបោះឆ្នោតគាំទ្រដល់សេចក្តីសម្រេចរបស់មហាសន្និបាតអង្គការសហប្រជាជាតិ ហើយសូមអំពាវនាវដល់សហគមន៍អន្តរជាតិឲ្យចូលរួមជាមួយយើងក្នុងការអនុវត្តនូវការងារជាប្រវត្តិសាស្ត្រនេះ ។

**សេចក្តីថ្លែងការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា**



លើកទំនប់ដីកប្រឡាយ នៅក្នុងរបបខ្មែរក្រហម

# ឱកាសចុងក្រោយសម្រាប់កម្ពុជា

*ព្រឹទ្ធសភាសហរដ្ឋអាមេរិក*
*ទីក្រុងវ៉ាស៊ីនតោនឌីស៊ី*
*ថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៣*
*លោក កូហ្វី អាណាន់*
*អគ្គលេខាធិការអង្គការសហប្រជាជាតិ*
*ជាន់ទី៣៨ ទីស្នាក់ការអង្គការសហប្រជាជាតិ*
*ទីក្រុងញូវយ៉ក, ញូវយ៉ក ១០០១៧*

***លោកអគ្គលេខាធិការជាទីគោរព***

យើងខ្ញុំយល់ថាអង្គការសហប្រជាជាតិស្វែងយល់ថា ការចរចាជាមួយរាជរដ្ឋាភិបាលកម្ពុជាស្តីអំពីការបង្កើតតុលាការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហមគឺជា“ឱកាសចុងក្រោយ”សម្រាប់កម្ពុជាក្នុងការស្វែងរកជំនួយពីអង្គការសហប្រជាជាតិលើបញ្ហានេះ ។ យើងខ្ញុំមានសេចក្តីរីករាយណាស់ដែលនៅក្នុងការចរចាថ្មីៗ អង្គការសហប្រជាជាតិបានបដិសេធមិនព្រមឈានដល់កិច្ចព្រមព្រៀងមួយដែលមិនអាចនាំមកនូវយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជាដែលជាជនរងគ្រោះនៃអំពើប្រល័យពូជសាសន៍ប្រព្រឹត្តឡើងដោយខ្មែរក្រហម ។

យើងខ្ញុំបានគាំទ្រដល់ការសម្រេចចិត្តដ៏សមហេតុសមផលរបស់អង្គការសហប្រជាជាតិក្នុងការដកខ្លួនថយពីកិច្ចចរចា នៅខែកុម្ភៈ ឆ្នាំ២០០២ ជាពេលដែលរដ្ឋាភិបាលកម្ពុជាមានឱកាសគ្រប់គ្រាន់ក្នុងការបង្ហាញនូវសុឆន្ទៈចង់បង្កើតតុលាការមួយដែលគួរឲ្យជឿជាក់បាន ។ ការដែលរដ្ឋាភិបាលកម្ពុជាមកកាន់ទីក្រុងញូវយ៉កដោយគ្មានការរៀបចំខ្លួនត្រឹមត្រូវដើម្បីឆ្លើយតបតាមការទាមទាររបស់អង្គការសហប្រជាជាតិគឺបានសបញ្ជាក់ឲ្យឃើញសាជាថ្មីនូវកង្វះភាពស្មោះត្រង់របស់នាយករដ្ឋមន្ត្រីកម្ពុជា ។

ក្រោយពីតាមដានការពិភាក្សាគ្នាសាចុះសាឡើងអស់រយៈពេលប៉ុន្មានឆ្នាំកន្លងមក ហើយដោយមានសម្ពាធដ៏ខ្លាំងក្លាពីសំណាក់បុគ្គលមួយចំនួននៅក្នុងសហគមន៍អន្តរជាតិឲ្យអង្គការសហប្រជាជាតិចរចាជាមួយនាយករដ្ឋមន្ត្រី ហ៊ុន សែន នោះ យើងខ្ញុំសូមស្នើឲ្យលោកអគ្គលេខាធិការបន្តធ្វើឲ្យ“តុលាការចម្រុះ”ដែលបានស្នើឡើងមានលក្ខណៈជាតុលាការមួយដែលផ្តល់នូវយុត្តិធម៌មានលក្ខណៈអន្តរជាតិអាចទទួលយកបាន ។

នាយករដ្ឋមន្ត្រី ហ៊ុន សែន ពុំមានឆន្ទៈនយោបាយដែលចាំបាច់ក្នុងការរៀបចំតុលាការមួយដែលយុត្តិធម៌និងមិនលម្អៀងឡើយ ។ ឥទ្ធិពលនិងការគ្រប់គ្រងរបស់លោក ហ៊ុន សែន ទៅលើតុលាការកម្ពុជាគឺមានលក្ខណៈខ្លាំងក្លាណាស់ ដែលជាការបំភិតបំភ័យនិងរំខានដល់ប្រជាជនកម្ពុជាដែលចូលរួមធ្វើការងារសម្រាប់តុលាការ ឬដែលនឹងបង្ហាញខ្លួននៅចំពោះមុខតុលាការ ។ ដោយគ្មានការគាំទ្រច្បាស់លាស់ជាក់លាក់ពីលោក ហ៊ុន សែន ទៅលើតុលាការមួយដែលមានឯករាជ្យភាពពិតប្រាកដ ហើយពុំមានការធានាតាមផ្លូវច្បាប់ដ៏សមរម្យដើម្បីធានានូវសុចរិតភាព និងភាពមិនលម្អៀងរបស់តុលាការ “តុលាការចម្រុះ” នេះនឹងត្រូវវិនាសឈានទៅបរាជ័យមិនខាន ។

ការដែលកម្ពុជាដោះស្រាយវិបត្តិនៃការកាប់ឈើខុសច្បាប់និងការរំខានដល់អង្គការ Global Witness ដែលជាអ្នកឃ្លាំមើលមានចរិតឯករាជ្យនេះគួរតែក្លាយជាការព្រមានដល់សហគមន៍អន្តរជាតិថាបញ្ហាច្រើនអនេកចេញពីភាគីកម្ពុជាដែលខ្លួនត្រូវប្រឈមមុខក្នុងការធានាឲ្យបាននូវយុត្តិធម៌សម្រាប់ជនរងគ្រោះដោយសារបទឧក្រិដ្ឋប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ វិបត្តិនៃការកាប់ឈើខុសច្បាប់សបញ្ជាក់អំពីកង្វះវិធាននៃច្បាប់នៅក្នុងប្រទេសកម្ពុជា និងភាពខ្វះចន្លោះនៅក្នុងប្រព័ន្ធតុលាការកម្ពុជា ព្រមទាំងអសមត្ថភាពរបស់សហគមន៍អន្តរជាតិក្នុងការត្រួតពិនិត្យទៅលើអំណាចផ្តាច់មុខរបស់លោក ហ៊ុន សែន ។

យើងខ្ញុំសូមគាំទ្រយ៉ាងពេញទំហឹង និងឥតរាថយដល់ការសម្រេចចិត្តជាថ្មីដ៏ត្រឹមត្រូវទៅលើបញ្ហាតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលស្នើឡើងនេះ ។ យើងខ្ញុំជឿជាក់ថាឱកាសកាន់តែប្រសើរអាចនឹងកើតមានជាមួយនឹងមេដឹកនាំកម្ពុជាថ្មី ប្រសិនបើប្រជាជនកម្ពុជាត្រូវបានអនុញ្ញាតឲ្យចូលរួមនៅក្នុងការបោះឆ្នោតជ្រើសរើសតំណាងរាស្ត្រប្រកបដោយសេរីនិងយុត្តិធម៌នៅប៉ុន្មានខែខាងមុខនេះ ។

សូមលោកអគ្គលេខាទទួលនូវការរាប់អានដ៏ស្មោះអំពីយើងខ្ញុំ ។

| | |
|---|---|
| ហត្ថលេខា | ហត្ថលេខា |
| មីត ម៉ែក ខូណែល | ប៉ាទ្រីក លៀហ៊ី |
| សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក | សមាជិកព្រឹទ្ធសភាសហរដ្ឋអាមេរិក |

# នីតិរដ្ឋ និង កេរដំណែលនៃជម្លោះ

## សុន្ទរកថាថ្លែងដោយឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធានក្រុមការងារសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេស និងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម

### ថ្ងៃទី១៦-១៩ ខែមករា ឆ្នាំ២០០៣

ឯកឧត្តម តំណាងទូតនានានិងអ្នកចូលរួមទាំងអស់ជាទីមេត្រី!

ជាបឋមសូមអនុញ្ញាតឲ្យខ្ញុំថ្លែងអំណរគុណចំពោះអ្នកដែលបានរៀបចំកិច្ចប្រជុំនេះ និងបានចាត់ចែងឲ្យគណៈប្រតិភូកម្ពុជាបានចូលរួមនៅក្នុងវេទិកានេះ ដែលជាការផ្តល់ឱកាសដ៏មានតម្លៃសម្រាប់យើងខ្ញុំក្នុងការជួបជុំគ្នានិងផ្លាស់ប្តូរមតិយោបល់ជាមួយអ្នកសិក្សាជាន់ខ្ពស់ អគ្គទូត និងអ្នកជំនាញការច្បាប់មកពីបណ្តាប្រទេសនានាជុំវិញពិភពលោក ។ អ្នករៀបចំដ៏ខ្ពង់ខ្ពស់ឧត្តមរួមមានសាកលវិទ្យាល័យហាវឺដ សមាគមសហប្រជាជាតិ និងសាកលវិទ្យាល័យបុតស្តុណ បានផ្តល់នូវការបម្រើដ៏ល្អតាមរយៈការសម្រេចចិត្តរៀបចំកិច្ចប្រជុំនេះ ហើយយើងមានកិត្តិយសណាស់ដែលទទួលបានការអញ្ជើញចូលរួមដើម្បីក្រេបជញ្ជក់បទពិសោធន៍ពីគ្នាទៅវិញទៅមក ។

នៅដើមសតវត្សរ៍ទី២១នេះ បញ្ហាដែលមានជុំវិញ “វិធាននៃច្បាប់និងកេរដំណែលនៃជម្លោះ” ដែលជាចំណងជើងនៃសន្និសីទនេះត្រូវគេមើលឃើញថាកំពុងតែផ្តល់នូវសំណួរជាច្រើនចំពោះយើងនៅក្នុងបណ្តាប្រទេសមួយចំនួននៃពិភពលោក ។ នៅពេលដែលយើងលើកយកព្រឹត្តិការណ៍ពីអតីតកាលមកពិភាក្សា ។ ប៉ុន្តែជាអកុសល ជម្លោះមិនមែនកើតឡើងតែក្នុងអតីតកាលនោះទេ ជម្លោះសព្វថ្ងៃនេះក៏វាកំពុងតែសាបព្រោះនូវកេរដំណែលនៃការឈឺចាប់និងភាពជូរចត់ សម្រាប់ថ្ងៃខាងមុខផងដែរ ។

ក្នុងការលើកយកសភាពការណ៍នៅកម្ពុជាមកចូលរួមពិភាក្សា យើងត្រូវសម្លឹងមើលទៅក្រោយអំពីសភាពការណ៍ដែលយើងបានជួបប្រទះនៅឆ្នាំ១៩៧៩ ក្រោយពីការផ្តួលរំលំរបបប្រល័យពូជសាសន៍ ប៉ុល ពត ដែលមានឈ្មោះថារបបកម្ពុជាប្រជាធិបតេយ្យ និងពិនិត្យមើលសម័យកាលបច្ចុប្បន្នចាប់តាំងពីខែកក្កដា ឆ្នាំ១៩៩៧ ដែលនៅឆ្នាំនោះរាជរដ្ឋាភិបាលកម្ពុជាបានស្នើសុំជំនួយនិងការចូលរួមពីសំណាក់អង្គការសហប្រជាជាតិ ។ ការលើកយកគំនិតជុយគ្នាស្រឡះពីរនេះមកបកស្រាយជាការចាំបាច់ណាស់ ពីព្រោះសំណួរទាំងឡាយដែលអ្នករៀបចំកម្មវិធីសន្និសីទរបស់យើងបានដាក់ជូនគឺមានចម្លើយផ្សេងៗគ្នា ប្រសិនបើការផ្តោតយកចិត្តទុកដាក់របស់យើងសំដៅទៅលើឆ្នាំ១៩៧៩ ឬ២០០៣ ។

គួរឲ្យស្តាយណាស់ កាលនោះមានតែសមាជិកប៉ុន្មាននាក់ប៉ុណ្ណោះនៅក្នុងសហគមន៍អន្តរជាតិ ដែលបានជួយយើងកសាងប្រទេសសាជាថ្មីក្រោយពីការផ្តួលរំលំរបបខ្មែរក្រហមនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ដោយសារតែសភាពការណ៍នយោបាយសង្គ្រាមត្រជាក់ និងឥទ្ធិពលនៃអ្វីដែលគេហៅជាទូទៅថា “សង្គ្រាមវៀតណាម” បេះតែអួសបន្ទាយ ។ ថ្ងៃនេះខ្ញុំសូមបញ្ជាក់សាជាថ្មីនូវការដឹងគុណមិនភ្លេចចំពោះអ្នកដែលបានជួយជំរុញកិច្ចប្រឹងប្រែងរបស់យើង ប៉ុន្តែអ្វីដែលធ្វើឲ្យយើងមានការឆ្ងើងឆ្ងល់ និងឈឺចាប់នោះគឺថាអ្នកដែលបានអនុវត្តនូវឧក្រិដ្ឋកម្មដ៏គួរឲ្យព្រឺព្រួចបេះតែទទួលបាននូវសិទ្ធិតំណាងឲ្យកម្ពុជានៅមហាសន្និបាតអង្គការសហប្រជាជាតិពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ហើយទទួលនូវ

ជំនួយទាំងផ្នែកនយោបាយ សេដ្ឋកិច្ច និងយោធាថែមទៀតផង សម្រាប់ការផ្តួលរំលំរដ្ឋាភិបាលពិតប្រាកដដែលកំពុងកាន់អំណាចរបស់ប្រទេសកម្ពុជា ។

ក្រោយពីខ្មែរក្រហមត្រូវកម្ចាត់ចេញពីប្រទេសភ្លាមក៏មានកិច្ចខិតខំប្រឹងប្រែងស្វែងរកនិងចងក្រងជាឯកសារការពិតទាក់ទងនឹងអ្វីដែលបានកើតឡើងនៅក្រោមអំណាចរបស់ខ្មែរក្រហមដែលមានប្រជាជនកម្ពុជាជាច្រើនលាននាក់ ពោលជាងមួយភាគបួននៃប្រជាជនទាំងអស់ដែលបានស្លាប់បាត់បង់ជីវិត ។ ប៉ុន្តែក្រៅពីចងក្រងជាឯកសារនិងរំឭកចងចាំព្រឹត្តិការណ៍នេះ យើងដឹងថាយើងត្រូវតែចាត់វិធានការដើម្បីបង្កឲ្យមានការទទួលខុសត្រូវពីជនទាំងឡាយដែលបានប្រព្រឹត្តបទឧក្រិដ្ឋទាំងនេះ ។ សារសំខាន់ផ្នែកនយោបាយនៃតុលាការនេះត្រូវបានគេយល់ ហើយមានធនធានស្ទួចស្ទើងណាស់ត្រូវបានចំណាយសម្រាប់ប្រមូលភ័ស្តុតាងនិងបង្កើតជាក្របខ័ណ្ឌមួយសម្រាប់ការជំនុំជម្រះក្តី ។ សារសំខាន់ដែលរដ្ឋាភិបាលពេលនោះដាក់មកលើដំណើរការនេះត្រូវបានបង្ហាញតាមរយៈ ក្រឹត្យច្បាប់លេខ១ អនុម័តនៅថ្ងៃទី១៥ ខែកក្កដា ឆ្នាំ១៩៧៩ ដែលជាមូលដ្ឋានសម្រាប់តុលាការប្រជាជនបដិវត្ត "ក្នុងការកាត់ទោសបន ប៉ុល ពត និង អៀង សារី ពីបទប្រល័យពូជសាសន៍" ។ វិសាលភាពនៃការជំនុំជម្រះក្តីត្រូវបានកំណត់តែទៅលើបុគ្គលពីររូបប៉ុណ្ណោះ ដែលត្រូវបានចាត់ទុកថាជា "មេក្រុម" ហើយក្រឹត្យច្បាប់បានចែងអំពី "នយោបាយអត់ឱនចំពោះបុគ្គលណាដែលបានចូលរួមនៅក្នុងជួរកងទ័ព ឬរដ្ឋបាលដឹកនាំរបស់បន ប៉ុល ពត និង អៀង សារី ករណីបុគ្គលនោះបង្ហាញនូវការសោកស្តាយដោយស្មោះ" ។

ដីកាត្រូវបានចេញសម្រាប់ ប៉ុល ពត និង អៀង សារី ព្រមជាមួយនឹងសេចក្តីអំពាវនាវសូមឲ្យចុះចូលជាមួយអាជ្ញាធរ ប៉ុន្តែអ្នកទាំងពីរមិនបានបង្ហាញមុខ ។ ពេលនោះការជម្រះក្តីក៏បន្តទៅមុខដោយគ្មានវត្តមានរបស់ជនជាប់ចោទទាំងពីរ ។ "តុលាការប្រជាជនបដិវត្តសម្រាប់កាត់ទោសបន ប៉ុល ពត និង អៀង សារី" ប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៥ ដល់ ថ្ងៃទី១៩ ខែសីហា ឆ្នាំ១៩៧៩ នៅសាលចតុមុខស្ថិតនៅទីប្រសព្វរវាងទន្លេមេគង្គនិងទន្លេសាប ។ តុលាការនេះបានរកឃើញថា ជនជាប់ចោទទាំងពីរមានទោសពីបទប្រល័យពូជសាសន៍ ហើយកាត់ទោសប្រហារជីវិតនិងរឹបអូសទ្រព្យសម្បត្តិទាំងអស់ ។

គួររំឭកថា តុលាការប្រជាជនបដិវត្តរបស់យើងដែលប្រព្រឹត្តទៅនៅខែសីហា ឆ្នាំ១៩៧៩ គឺជាតុលាការមុនគេបង្អស់នៅលើពិភពលោក ដែលកាត់ទោសទណ្ឌិតពីបទប្រល័យពូជសាសន៍ ប៉ុន្តែដំណើរការជម្រះក្តីនេះមាននៅលើទំព័រកាសែតបរទេសដ៏តិចតួចបំផុត ហើយដំណើរការជម្រះក្តីនេះទៀតសោតទើបតែបានបោះពុម្ពដោយពេញលេញនៅឆ្នាំ២០០០ប៉ុណ្ណោះ ។

លោកប្រធានក្រុមប្រឹក្សារដ្ឋ ហេង សំរិន មានប្រសាសន៍នាឱកាសបិទសវនាការថា "ជាតុលាការប្រវត្តិសាស្ត្រ តុលាការចេញពីមនសិការមនុស្សជាតិ...នឹងរួបរួមជាមួយប្រជាជនកម្ពុជាដើម្បីប្រកាសនូវសាលក្រមរបស់តុលាការនេះ" ។ ប៉ុន្តែ២៥ឆ្នាំក្រោយមកចំណុចនេះមិនទាន់បានកើតឡើងនៅឡើយទេ ។ ប្រព័ន្ធសារពត៌មានអន្តរជាតិពុំបានចាប់អារម្មណ៍នឹងតុលាការនេះហើយនិងសាលក្រមអំពើប្រល័យពូជសាសន៍នេះទេ ។ រដ្ឋាភិបាលលោកខាងលិចមួយភាគធំចាត់ទុកតុលាការនេះថាជា"តុលាការដែលធ្វើឲ្យតែមាន" ដោយពុំបានចំណាយកម្លាំងសូម្បីតែបន្តិចដើម្បីត្រួតពិនិត្យភ័ស្តុតាងដែលបានប្រើប្រាស់ ឬក៏តាមដានដំណើរការនៃការកាត់ទោសឡើយ ។ គួរឲ្យភ្ញាក់ផ្អើលណាស់ជនដែលត្រូវកាត់ទោសពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅតែទទួលបាននូវការទទួលស្គាល់និងជំនួយអន្តរជាតិយ៉ាងទូលំទូលាយ ។ កាលៈទេសៈរបស់យើងនៅពេលនោះ គឺប្រហាក់ប្រហែលគ្នាទៅនឹងអ្វីដែលបងប្អូនប្រជាជនអាហ្វ្រិកដែលកំពុងមានវត្តមានថ្ងៃនេះកំពុងជួបប្រទះ ។ ក្នុងចំណោមមេធាវីកម្ពុជារាប់រយនាក់នៅមុនឆ្នាំ១៩៧៥ មានតែ៩នាក់ប៉ុណ្ណោះ ដែលមានជីវិតរស់ពីរបបខ្មែរក្រហម ហេតុដូច្នេះហើយបានជាយើងស្វែងរកជំនួយពីបរទេស ។ មេធាវីបរទេសចំនួន៩រូបត្រូវបានអញ្ជើញឲ្យចូលរួមជាលក្ខណៈបុគ្គល ហើយមេធាវីទាំងនេះមកពីប្រទេសអាល់ហ្សេរី គុយបា ឥណ្ឌា ជប៉ុន ស៊ីរីយ៉ា សហភាពសូវៀតសហរដ្ឋអាមេរិកនិងវៀតណាម ។ អង្គការអន្តរជាតិដែលបានចូលរួមសង្កេតការណ៍មានទីប្រឹក្សាពិភពលោកសម្រាប់សន្តិភាពអង្គការសាមគ្គីភាពនៃប្រជាជនអាហ្វ្រិកនិងអាស៊ី អង្គការសាមគ្គី-

ភាពនៃប្រជាជនអាស៊ី អាហ្វ្រិក និងអាមេរិកឡាទីននិងទីប្រឹក្សាព្រះវិហារអាស៊ី ។

វាជាកាតព្វកិច្ចរបស់ខ្ញុំក្នុងការទទួលស្គាល់អំពីភាពខ្វះខាតរបស់តុលាការប្រជាជនបដិវត្តដែលបានប្រព្រឹត្តឡើងពុំមានការយកចិត្តទុកដាក់គ្រប់គ្រាន់ និងនៅក្នុងបរិយាកាសដ៏តានតឹងក្រោយពេលមានសង្គ្រាម ។ ខ្ញុំដឹងថាអស់លោកពិតជាបានដឹងយ៉ាងច្បាស់ ។ ជាក់ស្តែង ការការពារក្តីដែលបានលើកឡើងដោយមេធាវីចុងចោទ ជ្រើសតាំងដោយតុលាការផ្ទាល់ មានលក្ខណៈខ្សោយខ្លាំងណាស់ ទោះជាតាមផ្លូវយុត្តិធម៌ការការពារក្តីនេះអាចនឹងធ្វើឲ្យជននជាប់ចោទរួចទោស ។ គួរឲ្យភ្ញាក់ផ្អើលខ្លាំងណាស់ដែលនៅឆ្នាំ១៩៧៩ សហគមន៍អន្តរជាតិមិនបានផ្តល់នូវកម្រិតមួយនៃជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុដែលត្រូវការជាចាំបាច់ដើម្បីយកទៅដំណើរការតុលាការមួយឲ្យមានលក្ខណៈអន្តរជាតិ ។ យើងត្រូវចងចាំថា ក្នុងពេលនោះក្រុមមនុស្សដែលព្យាយាមប្រឹងប្រែងបង្កើនការអនុវត្តច្បាប់អន្តរជាតិដើម្បីបម្រើមនុស្សជាតិដូចបច្ចុប្បន្ននេះមិនទាន់មាននៅឡើយទេ ។

ជាផលវិបាកនៃការបន្តការគាំទ្រដល់ខ្មែរក្រហមប្រជាជនកម្ពុជារាប់សែននាក់បានបាត់បង់ជីវិត ហើយទទួលរងនូវគ្រោះថ្នាក់ដោយសារគ្រាប់មីនទោះបីជាប្រទេសកម្ពុជាត្រូវបានរំដោះឲ្យរួចផុតពីរបបប្រល័យពូជសាសន៍ហើយក៏ដោយ ។ មនោគមវិជ្ជា និងសេចក្តីត្រូវការរបស់ប្រទេសមហាអំណាចមួយចំនួនធំបានបណ្តាលឲ្យសហគមន៍អន្តរជាតិភ្លេចអំពីការពិត យុត្តិធម៌ និងសិទ្ធិមនុស្ស ហើយមិនអើពើនឹងការស្លាប់បាត់បង់ជីវិតរបស់ប្រជាជនកម្ពុជារាប់លាននាក់ ។ ជំនួសឲ្យយុត្តិធម៌វិន្ទាន់ដែលបានផ្តល់ឲ្យប្រទេសកម្ពុជា គឺជាសង្គ្រាមស៊ីវិលដែលអូសបន្លាយអស់រយៈពេលជាង១០ឆ្នាំ សេដ្ឋកិច្ចទិនថយ និងគ្រាប់មីនរាប់លានគ្រាប់ដែលកំពុងគំរាមកំហែងដល់ប្រជាជនក្រីក្រយើងនៅតាមតំបន់ជនបទ ។

កិច្ចព្រមព្រៀងសន្តិភាពនៅទីក្រុងប៉ារីសឆ្នាំ១៩៩១ បានបង្កើតធម្មានុរូបកម្មផ្នែកនយោបាយចំពោះខ្មែរក្រហម ហើយនៅពេលដែលអាជ្ញាធរបណ្តោះអាសន្នរបស់អង្គការសហប្រជាជាតិនៅកម្ពុជា (ហៅកាត់ថាអ៊ុនតាក់) ចាកចេញពីប្រទេសកម្ពុជានៅឆ្នាំ១៩៩៣ រដ្ឋាភិបាលចម្រុះដែលទើបតែបង្កើតឡើងថ្មីៗត្រូវតែទទួលបន្ទុកដោះស្រាយទប់ទល់ជាមួយនឹងការបន្តធ្វើសង្គ្រាមស៊ីវិល និងអស្ថិរភាពបង្កដោយខ្មែរក្រហម ។

ក្នុងសភាពការណ៍បែបនោះ យើងក៏បានអនុវត្តនូវវិធីសាស្ត្រមួយដែលមានមុខព្រួញច្រើនទាក់ទងដល់ការឃោសនាតាមផ្លូវនយោបាយ ច្បាប់ សេដ្ឋកិច្ច និងយោធា ។ នៅឆ្នាំ១៩៩៤ រដ្ឋសភាជាតិរបស់យើងបានអនុម័តច្បាប់មួយដើម្បីដាក់ខ្មែរក្រហមឲ្យនៅក្រៅច្បាប់ ហើយជំរុញឲ្យសមាជិករបស់ខ្មែរក្រហមផ្តាច់ខ្លួននិងសុំចុះចូលជាមួយរដ្ឋាភិបាល ។ ច្បាប់នោះមានរាប់បញ្ចូលទាំងការពន្យារពេលចំនួន៦ខែដើម្បីជំរុញឲ្យមានការចុះចូល ។ កងទ័ពខ្មែរក្រហមជាច្រើនកងបានសុំចុះចូលមកខាងរដ្ឋាភិបាលក្នុងអំឡុងពេលនោះ ប៉ុន្តែគ្មានមេបញ្ជាការកងទ័ពឬមេដឹកនាំនយោបាយជាន់ខ្ពស់ណាម្នាក់ឆក់យកឱកាសនេះដើម្បីចុះចូលឡើយ ។

ពេលនោះ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ក៏ចាប់ផ្តើមអនុវត្តនូវអ្វីដែលលោកពណ៌នាថាជា "នយោបាយឈ្នះ-ឈ្នះ" ដែលរួមមានប្រាំផ្នែកគឺ "បំបែក ធ្វើឲ្យឯកោ បញ្ចប់សមាហរណកម្ម និងអភិវឌ្ឍ" ។ នយោបាយថ្មីនេះបានបញ្ចប់នូវរចនាសម្ព័ន្ធនយោបាយ និងយោធារបស់ខ្មែរក្រហម ដោយរួមទាំងការប្រើប្រាស់ការវាយសម្រុក ប៉ុន្តែខ្មែរក្រហមណាដែលបានចុះចូលត្រូវបានធានាឲ្យមានសុវត្ថិភាពរូបរាងកាយ និងការរស់រានមានជីវិតសិទ្ធិធ្វើការងារនិងអនុវត្តមុខរបរប្រចាំថ្ងៃ និងសិទ្ធិកាន់កាប់ទ្រព្យសម្បត្តិ ។

មកដល់ចុងខែធ្នូ ឆ្នាំ១៩៩៨ ទីបំផុតយើងសម្រេចបាននូវការរំលាយអង្គការចាត់តាំងនយោបាយនិងយោធាខ្មែរក្រហម ហើយបានប្រឈមមុខនឹងកាតព្វកិច្ចពីរគឺការបង្រួបបង្រួមជាតិ និងយុត្តិធម៌ ។ ប្រទេសកម្ពុជាប្រហែលជាអាចផ្តល់ដល់ពិភពលោកនូវបទពិសោធន៍ការបង្រួបបង្រួមជាតិដ៏ស្មុគស្មាញនិងចំណាយពេលអស់យ៉ាងយូរនេះបាន ។ បច្ចុប្បន្នអតីតទាហានខ្មែរក្រហមបានទម្លាក់អាវុធចុះហើយចាប់ផ្តើមជីវិតថ្មីជាមួយប្រជាជនទូទៅ ចំណែកឯអតីតគូបដិបក្ខបានងាកមកចាប់ដៃគ្នាអភិវឌ្ឍប្រទេស ។

នៅក្នុងប្រទេសកម្ពុជាការបង្រួបបង្រួមជាតិមិនមែនមានន័យថាបំភ្លេចអតីតកាលចោលនោះទេ ។ រដ្ឋាភិបាលកម្ពុជាបានប្រមែប្រមូលវត្ថុតាងផ្សេងៗ និងកសិណសាក្សីពេញមួយទសវត្សរ៍ឆ្នាំ១៩៨០ ហើយទាមទារឲ្យមានការបង្កើតឡើងនូវតុលាការមួយដែលទទួលស្គាល់ដោយអន្តរជាតិ ។

ទោះជាយ៉ាងណាក៏ដោយ ក៏យើងត្រូវតែទទួលស្គាល់ថាជោគជ័យរបស់ប្រទេសកម្ពុជានៅក្នុងផ្នែកការពិតនិងការបង្រួបបង្រួមជាតិមិនមានទំនាក់ទំនងជាមួយនឹងការស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបប្រល័យពូជសាសន៍ទេ ។ ឥឡូវនេះពេលដែលយើងខំប្រឹងស្វែងរកយុត្តិធម៌សម្រាប់ជនរងគ្រោះនៃរបបប្រល័យពូជសាសន៍យើងចាំជាប់យ៉ាងមុតមាំនៅក្នុងចិត្តថាការធ្វើនេះត្រូវតែពុំអាចប៉ះពាល់ដល់ដំណើរការនៃការបង្រួបបង្រួមជាតិដែលខ្ញុំបាននិយាយពីខាងលើ ។ នៅប្រទេសកម្ពុជាយើងត្រូវការយុត្តិធម៌ដើម្បីព្យាបាលរបួសនៅក្នុងសង្គមរបស់យើងទាំងមូលក្នុងពេលជាមួយគ្នានៃការជួយបន់ស្រន់ឲ្យអ្នកដែលបានរៀបចំគម្រោងនិងដាក់បញ្ជា គឺអ្នកដែលបានអនុវត្តនូវបទឧក្រិដ្ឋទទួលខុសត្រូវចំពោះអ្វីដែលខ្លួនបានប្រព្រឹត្ត ។

នៅខែមិថុនា ឆ្នាំ១៩៩៧ សហនាយករដ្ឋមន្ត្រីកម្ពុជាបានស្នើសុំឲ្យអង្គការសហប្រជាជាតិផ្តល់ជាជំនួយដល់ការបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ប៉ុន្តែគួរឲ្យសោកស្តាយខ្លាំងណាស់ ជាងប្រាំឆ្នាំក្រោយមក យើងនៅតែស្ថិតនៅក្នុងដំណាក់កាលនៃការរៀបចំបែបបទនិងលក្ខខណ្ឌសម្រាប់ជំនួយនិងការចូលរួមជាអន្តរជាតិ ។ ទោះជាយ៉ាងណាក៏ដោយ ក៏ខ្ញុំសប្បាយចិត្តនឹងជម្រាបជូនអស់លោកលោកស្រីថាកម្ពុជាសង្ឃឹមថាកម្ពុជាកំពុងតែឈានជើងចូលទៅក្នុងដំណាក់កាលចុងក្រោយនៃការរៀបចំមុនពេលចាប់ដំណើរការការងារជាក់ស្តែងនៃការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលកម្ពុជាប្រជាធិបតេយ្យ ដោយយោងទៅលើច្បាប់ដែលបានអនុម័តដោយអង្គនីតិបញ្ញត្តិទាំងពីរដែលបានប្រកាសឡើងនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ ជាច្បាប់ដែលជាលទ្ធផលនៃការចរចាជាច្រើនលើកជាមួយអង្គការសហប្រជាជាតិ ។

នៅក្នុងការចរចាទាំងនេះយើងត្រូវបានដឹកនាំដោយគោលការណ៍ជាមូលដ្ឋានគ្រឹះចំនួនបីៈ

ទីមួយគឺ ជាការគោរពនិងការស្វែងរកយុត្តិធម៌ៈ យើងចោទប្រកាន់បទឧក្រិដ្ឋកម្មរបស់ខ្មែរក្រហមថា ជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ យើងទាមទាររកយុត្តិធម៌សម្រាប់ផ្តល់ឲ្យជនរងគ្រោះនិងប្រជាជាតិកម្ពុជាទាំងមូល ហើយក៏សង្ឃឹមដែរថាអាចចូលរួមដល់ការរីកលូតលាស់នៃគោលការណ៍មនុស្សធម៌អន្តរជាតិ ផ្តន្ទាទោសបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ហើយព្យាយាមការពារកុំឲ្យបទឧក្រិដ្ឋនេះកើតឡើងជាថ្មីម្តងទៀត ។ ប្រជាជនកម្ពុជាបានបង្ហាញនូវអំណរអរគុណយ៉ាងជ្រាលជ្រៅចំពោះសហគមន៍អន្តរជាតិដែលបានចូលរួមនៅក្នុងដំណើរការស្វែងរកយុត្តិធម៌នេះក្នុងរវាងបីបួនឆ្នាំចុងក្រោយនេះ ទោះបីជាប្រទេសទាំងនេះមិនបានចូលរួមនៅក្នុងសម័យ ប៉ុល ពត និងភ្លាមៗក្រោយសម័យនេះ ។

ទីពីរគឺ ការថែរក្សាសន្តិភាព ស្ថិរភាពនយោបាយ និងឯកភាពជាតិ ដែលប្រទេសកម្ពុជាទើបតែសម្រេចបាន ។ ទាំងនេះជាកត្តាដែលធ្វើឲ្យមានបរិយាកាសសុទិដ្ឋិនិយមគ្មានពីរ និងអវត្តមាននៃអំពើហិង្សាដែលមានលក្ខណៈផ្ទុយស្រឡះទៅនឹងស្ថានភាពពីមុនៗ ទោះជាយើងមិនទាន់សម្រេចបាននូវច្បាប់សង្គមនិងសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមឲ្យបាន១០០ភាគរយក៏ដោយ ។ កត្តានេះច្បាស់ជាពុំអាចកើតឡើងទៅរួចទេនៅក្នុងអតីតកាលគួរឲ្យរន្ធត់ដែលបានកន្លងទៅថ្មីៗនេះ ។ តែទោះជាយ៉ាងណាក៏ដោយ ក៏យើងនៅតែមានអំនួតក្នុងការដើរឆ្ពោះទៅមុខក្នុងដំណើរការពង្រឹងស្ថានភាពនយោបាយ សន្តិភាព និងសុវត្ថិភាពនៅក្នុងប្រទេសកម្ពុជា ហើយនេះគឺជាការសម្រេចបានយ៉ាងមានតម្លៃបំផុតសម្រាប់ទឹកដីកម្ពុជាជាទីស្រលាញ់របស់យើង ។ អ្វីៗដែលយើងធ្វើត្រូវតែចៀសវាងការប៉ះពាល់ដល់សន្តិភាពនិងស្ថិរភាព ហើយនៅក្នុងដំណើរការក្នុងរយៈពេលបួនឆ្នាំនៃការបង្កើតតុលាការខ្មែរក្រហមយើងតែងតែព្យាយាមធ្វើសម្បទានដោយផ្អែកទៅលើការគោរពប្រយោជន៍ជាតិ ។

មានមតិមួយចំនួនបានរិះគន់ថា ដំណើរការនេះធ្វើដំណើរទៅមុខគើមៗ ប៉ុន្តែការសម្រេចនូវការមូលមតិគ្នាពិតជាការពិបាក

ណាស់ ពោលគឺទាល់តែទទួលបាននូវសំឡេងឆ្នោតដាច់ខាតពីសំណាក់អង្គនីតិបញ្ញត្តិទាំងពីរ ទើបការសម្រេចមួយអាចយកជាការបាន ។ ច្បាប់កាត់ទោសមេដឹកនាំខ្មែរក្រហមត្រូវបានប្រកាសឲ្យប្រើប្រាស់ជាផ្លូវការនៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ គឺមានរយៈពេលពីរឆ្នាំគត់ បន្ទាប់ពីសេចក្តីព្រាងច្បាប់ត្រូវបានយកមកដាក់នៅលើតុចរចា ។ រយៈពេលនេះមិនយូរប៉ុន្មានទេក្នុងការបង្កើតច្បាប់ដែលមិនធ្លាប់មានពីមុនទាក់ទងនឹងបញ្ហាងាយនឹងប្រេះស្រាំនិងសំខាន់បែបនេះ ។

ទីប្រឹក្សាធម្មនុញ្ញបានចំណាយពេលអស់ជាច្រើនខែដើម្បីពិនិត្យដោយហ្មត់ចត់ឡើងវិញនូវច្បាប់ខ្មែរក្រហម ហើយសង្កេតឃើញថាទោសបញ្ញត្តិអតិបរមាមានកម្រិតត្រឹមការជាប់ពន្ធនាគារអស់មួយជីវិតប៉ុណ្ណោះ ដូច្នេះវាអាចមានភាពមិនស្របគ្នាជាមួយនឹងរដ្ឋធម្មនុញ្ញរបស់យើងដែលគ្មានទោសប្រហារជីវិត ។ ជាលទ្ធផលរាជរដ្ឋាភិបាលបានកែប្រែសេចក្តីព្រាង ហើយយកទៅពិភាក្សាគ្នានៅក្នុងរដ្ឋសភានិងព្រឹទ្ធសភាជាតិជាថ្មីម្តងទៀត ។ យើងត្រូវកត់សម្គាល់ថា ប្រទេសរបស់យើងកំពុងតែឆ្លងកាត់ដំណើរការនៃការប្រែក្លាយឲ្យទៅជាសង្គមប្រជាធិបតេយ្យ ហើយក្នុងន័យនេះ ទីប្រឹក្សាធម្មនុញ្ញជាស្ថាប័នថ្មីមួយដែលទើបតែត្រូវបានបង្កើតឡើងនិងមានអំណាចនិងការសម្រេចចិត្តគួរតែត្រូវគោរពជាផ្នែកមួយនៃដំណើរការនេះ ។

លើសពីនេះ យើងស្វែងរកយុត្តិធម៌ដែលរួមចំណែកទៅលើការកសាងនិងការអនុវត្តលទ្ធិប្រជាធិបតេយ្យនៃសង្គមទាំងមូល ។ ការកាត់ទោសបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ មិនមែនគ្មានការប្រថុយប្រថាននោះទេ ដូច្នេះហើយបានជាយើងចំណាយអស់កម្លាំងជាច្រើនដើម្បីសុំឲ្យមានការគាំទ្រពីប្រជាជន ។ ការបោះឆ្នោតជាឯកច្ឆន្ទនៅក្នុងរដ្ឋសភានិងព្រឹទ្ធសភាសម្រាប់ច្បាប់នេះគឺមិនធ្លាប់មានហើយសបញ្ជាក់ថា លទ្ធផលនៃកិច្ចប្រឹងប្រែងនេះជាការជំរុញឲ្យមានសន្តិភាព មិនមែនធ្វើឲ្យបាត់បង់សន្តិភាពទៅវិញនោះទេ ។ ការលើករយៈពេលដែលបានប្រើប្រាស់មកនិយាយពិតជាពុំត្រឹមត្រូវទេ ប៉ុន្តែរយៈពេលបីឆ្នាំនៃការចរចានេះត្រូវតែរាប់បញ្ចូលជាផ្នែកមួយនៃដំណើរការជាប្រវត្តិសាស្ត្ររយៈពេល៨ឆ្នាំនេះ ហើយអាចប្រៀបធៀបទៅនឹងប្រទេសដទៃទៀតដែលបានចំណាយពេលវេលាជាច្រើនឆ្នាំ ឬទសវត្សរ៍ក្នុងការស្វែងរកយុត្តិធម៌សម្រាប់បទឧក្រិដ្ឋប្រភេទនេះ ។

ទីបីគឺ ការគោរពអធិបតេយ្យជាតិដែលត្រូវបានលើកឡើងជាគោលការណ៍គ្រឹះនៅក្នុងរដ្ឋធម្មនុញ្ញនៃអង្គការសហប្រជាជាតិ ។ ការលើកឡើងនូវគោលការណ៍គោរពអធិបតេយ្យភាពជាតិរបស់យើងគឺមានហេតុផល ។ យើងបានពុះពារដោយឥតសំចៃដើម្បីឲ្យមានគោលការណ៍នេះ ។ រាជរដ្ឋាភិបាលកម្ពុជាមិនបានទទួលយកនូវអនុសាសន៍របស់ក្រុមអ្នកជំនាញការផ្តល់នៅឆ្នាំ១៩៩៩ ដែលស្នើឲ្យមានអង្គជំនុំជម្រះក្តីនៅក្រៅប្រទេសដោយគ្មានការចូលរួមពីសំណាក់ជនជាតិខ្មែរលើកលែងតែចុងចោទឬអ្នកចូលរួមមើលនោះ ។ ដូចសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានកត់សម្គាល់កាលពីពេលនោះដែរ កិច្ចការដែលលោកអគ្គលេខាធិការអង្គការសហប្រជាជាតិចង់ផ្តល់ឲ្យជនជាតិខ្មែរធ្វើគឺ "ឲ្យចូលព្រៃចាប់ខ្លា" និង "ធ្វើជាសុនខបម្រើរបស់អង្គការសហប្រជាជាតិតែប៉ុណ្ណោះ" ។

គំនិតរបស់យើងពីកន្លងមកក៏ដូចជាបច្ចុប្បន្ន គឺថាកម្ពុជាមានកាតព្វកិច្ចចម្បងក្នុងការរៀបចំការវិនិច្ឆ័យទោសតាមមាត្រា៦ នៃអនុសញ្ញាស្តីពីអំពើប្រល័យពូជសាសន៍ ហើយអាចចាប់ផ្តើមដំណើរការនៅក្នុងតុលាការនៅក្នុងស្រុកដែលមានស្រាប់ ។ អនុញ្ញាតឲ្យខ្ញុំរំឭកជូនអ្នករិះគន់ទៅលើគំនិតនេះថា គោលការណ៍ជួយបំពេញគ្នាទៅវិញទៅមកគឺជាគ្រឹះយ៉ាងសំខាន់ចំពោះតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលក្នុងនោះកម្ពុជាមានមោទកភាពបានក្លាយខ្លួនជារដ្ឋសមាជិកទី៦០ដើម្បីផ្តល់សច្ចាប័ន និងការអនុវត្តជាក់ស្តែងក្នុងរយៈពេល១០ឆ្នាំក្រោយមក ។

ក៏ប៉ុន្តែ ទោះបីជាយើងមានកាតព្វកិច្ចទាំងស្រុងនៅក្នុងការកាត់ទោសមេដឹកនាំខ្មែរក្រហមនៅក្នុងតុលាការក្នុងស្រុកយ៉ាងណាក៏ដោយ ក៏យើងបានស្វែងរកការចូលរួមពីសំណាក់អន្តរជាតិដែរជាពិសេសតាមរយៈអង្គការសហប្រជាជាតិតែម្តង ។ ហេតុអ្វី? ម្យ៉ាងគឺដោយសារយើងដឹងច្បាស់ណាស់អំពីចំណុចខ្សោយរបស់ប្រព័ន្ធតុលាការរបស់យើង ហើយយើងចង់បានជំនួយការដើម្បីឲ្យការជម្រះក្តីនេះចូលតាមបទដ្ឋានមួយដែលទទួលស្គាល់ដោយ

អន្តរជាតិ ។ ម៉្យាងទៀត ខ្ញុំសូមជម្រាបដោយត្រង់ទៅចុះថា យើងមានអារម្មណ៍ថា វាជាការសំខាន់សម្រាប់សហគមន៍អន្តរជាតិ ក្នុងការចូលរួមអនុវត្តកិច្ចការនេះប្រយោជន៍ដើម្បីឲ្យសហគមន៍នេះ មានការដាច់ស្រេចច្បាស់លាស់ទាំងអស់គ្នាទៅលើប្រវត្តិរបស់ ខ្លួនពីមុនមកដែលគាំទ្រខ្មែរក្រហម ។ នេះគឺជាការឲ្យហេតុផល របស់យើងនៅពេលដែលយើងសុំឲ្យមានជំនួយ នៅឆ្នាំ១៩៩៧ និងនៅពេលដែលយើងសម្រេចកិច្ចព្រមព្រៀងជាគោលការណ៍ ជាមួយអង្គការសហប្រជាជាតិក្នុងការរៀបចំអង្គជំនុំជម្រះជា លក្ខណៈជាតិដោយមានការចូលរួមពីសំណាក់អន្តរជាតិ ។ មកដល់ សព្វថ្ងៃនេះ យើងក៏នៅតែប្រកាន់យកហេតុផលនេះដដែល ទោះបីជានៅចំពោះមុខការសម្រេចដកខ្លួនចេញជាឯកតោភាគីពី ការចរចានៅខែកុម្ភៈ ឆ្នាំ២០០២ របស់អង្គការសហប្រជាជាតិ ក៏ដោយ ។

ពីឆ្នាំ១៩៩៩ ទៅឆ្នាំ២០០០ ប្រទេសកម្ពុជានិងអង្គការ សហប្រជាជាតិបានធ្វើការចរចាអំពី“គំរូរបស់ប្រទេសកម្ពុជា” ។ យើងបានរំកិលចេញពីសេចក្តីស្នើដំបូងរបស់អង្គការសហប្រជា ជាតិ (ដែលមានលក្ខណៈស្រដៀងគ្នាទៅនឹង“តុលាការពិសេស” សម្រាប់ប្រទេសសេរ៉ាឡេអូន) ទៅដល់រូបមន្តដ៏មានតុល្យភាព ដ៏ប្រុងប្រយ័ត្នមួយគឺៈ ចៅក្រមជាជនជាតិកម្ពុជាមានសមាជិក ច្រើនជាងជារបស់អង្គការសហប្រជាជាតិនៅក្នុងអង្គជំនុំជម្រះ នីមួយៗ ក៏ប៉ុន្តែរាល់ការសម្រេចចិត្តត្រូវការឲ្យមានមតិភាគច្រើន លើសលប់(ដែលក្នុងនោះទាល់តែមានចៅក្រមបរទេសយ៉ាងតិច ម្នាក់បោះឆ្នោតគាំទ្រ) ។ មានសហព្រះរាជអាជ្ញានិងសហចៅក្រម ស៊ើបអង្កេតទាំងពីរនេះមានសញ្ជាតិកម្ពុជាម្នាក់និងបរទេសម្នាក់) ដំណើរការរួមជាមួយអង្គបុរេជំនុំជម្រះដើម្បីដោះស្រាយការ ខ្វែងគំនិតគ្នា ។ រូបមន្តនេះមិនបានផ្តល់នូវអំណាចដល់ភាគីម្ខាង ណាឡើយ ប៉ុន្តែវាបង្កើតជាមូលដ្ឋានគ្រឹះសម្រាប់ការធ្វើការ រួមគ្នា ។

នៅពេលដែលរបាយការណ៍របស់ក្រុមអ្នកជំនាញការត្រូវ បានផ្តល់ឲ្យគោលជំហររបស់ភាគីទាំងពីរគឺនៅមានលក្ខណៈផ្ទុយ គ្នាស្រឡះ ។ អង្គការសហប្រជាជាតិទាមទារឲ្យមានតុលាការ អន្តរជាតិសុទ្ធសាធ ចំណែកឯកម្ពុជាទាមទារតុលាការដែលមាន ដំណើរការជាលក្ខណៈជាតិ ។ មកដល់ដំណាក់កាលនេះទៅហើយ យើងមិនអាចបោះបង់ចោលនូវការទទួលជោគជ័យដែលរកបាន ដោយលំបាកនេះ ហើយទៅចាប់ផ្តើមពីដំបូងវិញទេ ។ យើងជឿ ជាក់យ៉ាងមុតមាំថា “គំរូរបស់ប្រទេសកម្ពុជា” មិនត្រឹមតែគួរឲ្យ ជឿទុកចិត្តបានប៉ុណ្ណោះទេ វាជាគំរូជាប្រវត្តិសាស្ត្រនៅក្នុងច្បាប់ មនុស្សធម៌អន្តរជាតិ ដែលឥឡូវនេះកំពុងតែរំកិលចេញពីតុលាការ ឧក្រិដ្ឋកម្មអន្តរជាតិដែលបង្កើតឡើងនិងដំណើរការដោយអន្តរជាតិ ដូចដែលធ្លាប់មានជាងពាក់កណ្តាលសតវត្សរ៍នៅទីក្រុងនូរិមប៊ឺក និងតូក្យូ ហើយថ្មីៗនេះនៅទីក្រុងឡាអេនិងអារូស្សាទៅកាន់ ការប្រុបាច់បញ្ចូលគ្នាដែលជំរុញឲ្យប្រទេសនីមួយៗមានឱកាស អនុវត្តនូវការស្វែងរកយុត្តិធម៌នៅក្នុងកម្រិតជាតិក្នុងរបៀបមួយ ដែលបំពេញនូវបទដ្ឋានអន្តរជាតិ ហើយស្របទៅនឹងការទទួល ខុសត្រូវរបស់យើងចំពោះមុខឧបករណ៍ច្បាប់សំខាន់ៗ ពិសេសគឺ អនុសញ្ញាស្តីអំពីអំពើប្រល័យពូជសាសន៍ ។

បញ្ហាដែលប្រទេសកម្ពុជាបានឆ្លងកាត់នៅឆ្នាំ១៩៧៩ និងម្តងទៀតនៅឆ្នាំ២០០២ ទាក់ទិនទៅនឹងគោលជំហររបស់ សហគមន៍អន្តរជាតិចំពោះការដាក់ខ្មែរក្រហមឲ្យមានការទទួល ខុសត្រូវបង្ហាញថាស្ថានការណ៍ក្រោយជម្លោះគឺមានភាពស្មុគស្មាញ ហើយចំណុចខ្សោយមិនមែនមានតែលើភាគីម្ខាងប៉ុណ្ណោះទេ ។ ប្រទេសកម្ពុជាទទួលស្គាល់ដោយស្មោះស្ម័គ្រនូវ“ភាពអន់ថយនៃ ស្ថាប័នក្នុងស្រុក...និងធនធាន” ដែលបង្កជាហេតុផលមួយដែល នាំឲ្យយើងស្វែងរកជំនួយការពីមជ្ឈដ្ឋានអន្តរជាតិ “ដើម្បីដោះ ស្រាយនូវអំពើព្រៃផ្សៃទាំងឡាយកើតឡើងនៅក្នុងអំឡុងពេល កន្លងទៅថ្មីៗ” ។ ប៉ុន្តែ នៅក្នុងករណីនៃប្រទេសកម្ពុជាយ៉ាងហោច ណាស់ “ការខ្វះខាត...ផ្នែកឆន្ទៈនយោបាយ” បានកើតឡើង ខ្ញុំ ហ៊ាននិយាយថា មិនមែនមានចំពោះតែភាគីកម្ពុជាទេ ។

តាមការពិត ការពន្យារពេលរបស់សហគមន៍អន្តរជាតិ ទៅលើបញ្ហាការដាក់ឲ្យមានការទទួលខុសត្រូវតាមផ្លូវតុលាការ នៅប្រទេសកម្ពុជាជាកត្តាលេចធ្លោរមួយនៃស្ថានការរបស់ប្រទេស កម្ពុជាបើប្រៀបធៀបទៅនឹងប្រទេសដទៃដែលយើងបានដឹងឮ នៅលើតុពិភាក្សាក្នុងសន្និសីទនេះ ។ យុត្តាធិការពេលវេលា សម្រាប់តុលាការគឺពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ពោលគឺ

បទឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងស្ទើរ៣០ឆ្នាំទៅហើយ ។ សង្គមរបស់យើងបានសម្រេចបាននូវសន្តិភាពនិងភាពនឹងន ហើយតុលាការខ្មែរក្រហមមិនមែនជាផ្នែកដ៏សំខាន់នៃការបញ្ចប់ការវាយប្រយុទ្ធគ្នាក្នុងស្រុកនេះទេ ។ យើងកំពុងតែស្ថិតនៅក្នុងស្ថានការណ៍ក្រោយជម្លោះ មិនមែននៅក្នុងសំណល់នៃអំពើឧក្រិដ្ឋកម្មដែលទើបតែបានបញ្ចប់និងនៅក្នុងស្រមោលនៃជនដែលនិងការគំរាមកំហែងចង់វិលត្រលប់ទៅរកការប្រព្រឹត្តិបទឧក្រិដ្ឋរបស់ជនទាំងនេះម្តងទៀតនោះទេ ។ ក្នុងន័យនេះប្រទេសកម្ពុជាប្រហែលជាឈរនៅលើគោលជំហរកាន់តែរឹងមាំមួយក្នុងការប្រើប្រាស់សិទ្ធិនិងការទទួលខុសត្រូវរបស់ខ្លួនក្នុងនាមជា“ម្ចាស់” នៃដំណើរការដោយគោរពអញ្ជើញនិងប្រាថ្នាដោយស្មោះស្ម័គ្រនូវការចូលរួមពីសហគមន៍អន្តរជាតិនៅក្នុងកិច្ចការនេះ ។

គណៈប្រតិភូរបស់យើងទើបតែបានចំណាយពេលពេញមួយសប្តាហ៍មុនជាមួយលោកអនុលេខាធិការកិច្ចការច្បាប់ដោយចាប់ផ្តើមថា អ្វីដែលយើងសង្ឃឹមទុកមុននឹងក្លាយទៅជាដំណាក់កាលចុងក្រោយនៃការរៀបចំសម្រាប់អង្គជំនុំជម្រះវិសាមញ្ញ ។ ដំណាក់កាលនេះត្រូវបានចាប់ផ្តើមឡើងដោយការបោះឆ្នោតនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០០២ ទទួលស្វាគមន៍ច្បាប់ស្តីអំពីអង្គជំនុំជម្រះវិសាមញ្ញនិងសំណូមពរឲ្យលោកអគ្គលេខាធិការចាប់ផ្តើមការចរចាជាមួយប្រទេសកម្ពុជា ។ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះការគាំទ្ររបស់ប្រទេសជាច្រើនកាលពីឆ្នាំមុនក្នុងការព្យាយាមយ៉ាងលំបាកដើម្បីឲ្យអង្គការសហប្រជាជាតិវិលត្រឡប់មកតុចរចាវិញជាពិសេសគឺ ប្រទេសបារាំងនិងជប៉ុនដែលបានដាក់សេចក្តីព្រាងច្បាប់ថ្មីៗនេះទៅក្នុងរបៀបវារៈរបស់មហាសន្និបាត ក៏ដូចជាប្រទេសចំនួន១៥០ដែលបានបោះឆ្នោតគាំទ្រ ។

យើងសង្ឃឹមថា “គំរូរបស់ប្រទេសកម្ពុជា” នៃតុលាការជាតិដោយមានការចូលរួមពីអន្តរជាតិនឹងក្លាយទៅជាការពិតនៅក្នុងអនាគតកាលដ៏ខ្លីខាងមុខក្រោយពីឧក្រិដ្ឋកម្មត្រូវបានប្រព្រឹត្តឡើងជិត៣០ឆ្នាំកន្លងទៅ ។ “គំរូរបស់ប្រទេសកម្ពុជា” អាចយកទៅប្រើប្រាស់នៅក្នុងករណីផ្សេងទៀត ពីព្រោះថា តួនាទីរបស់សហគមន៍អន្តរជាតិគឺគាំទ្រដល់យុត្តាធិការជាតិ ប្រទេសទាំងឡាយ ជួយដល់ប្រទេសទាំងនេះក្នុងការអនុវត្តកាតព្វកិច្ចអន្តរជាតិរបស់ខ្លួន ដោយស្របទៅតាមបទដ្ឋានយុត្តិធម៌អន្តរជាតិ យុត្តិធម៌ និងដំណើរការដ៏ត្រឹមត្រូវនៃច្បាប់ ។

រាជរដ្ឋាភិបាលកម្ពុជា ជំនួសមុខឲ្យប្រជាជនកម្ពុជានិងមនុស្សជាតិទាំងមូល នៅតែតាំងចិត្តស្វែងរកយុត្តិធម៌នៃអំពើឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងដោយខ្មែរក្រហម ។ ការតាំងចិត្តដ៏មុតមាំនេះត្រូវបានបង្ហាញឲ្យឃើញតាមរយៈការចំណាយពេលវេលានិងថាមពលដ៏ច្រើនដែលយើងបានធ្វើអស់រយៈពេល៣ឆ្នាំកន្លះចាប់តាំងពីសម្តេចនាយករដ្ឋមន្ត្រីបានបង្កើតក្រុមការងារសម្រាប់ប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេស និងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហមដែលរូបខ្ញុំផ្ទាល់ត្រូវបានតែងតាំងជាប្រធាន ។ ខ្ញុំសូមបញ្ជាក់ឲ្យច្បាស់ថា នេះជាពេលវេលានិងថាមពលដែលត្រូវបានបង្វែរចេញពីការងារបន្ទាន់មួយចំនួនទាក់ទងនឹងការស្តាបនាជាតិឡើងវិញ ប៉ុន្តែយើងខ្ញុំរៀបចំខ្លួនរួចជាស្រេចក្នុងការធ្វើពលិកម្មដើម្បីឈានទៅសម្រេចបាននូវយុត្តិធម៌ពិតប្រាកដមួយ ។ ច្បាប់ដែលត្រូវបានប្រកាសជាធរមាននៅថ្ងៃទី១០ ខែសីហា ឆ្នាំ២០០១ បានលេចចេញពីការពិភាក្សា និងការសម្របសម្រួលគ្នាយ៉ាងយកចិត្តទុកដាក់រវាងអង្គការសហប្រជាជាតិនិងប្រទេសកម្ពុជាដែលជាលទ្ធផលនៃការដាក់បញ្ចូលអ្នកជំនាញការជាច្រើនរូបមកពីប្រទេសផ្សេងៗឲ្យចូលរួម ។ ច្បាប់នេះបានបង្កើតជាមូលដ្ឋានគ្រឹះយ៉ាងរឹងមាំ ហើយយើងសង្ឃឹមថា នៅទីបញ្ចប់អង្គការសហប្រជាជាតិនឹងចូលរួមជាមួយយើងក្នុងការអនុវត្តច្បាប់នេះ ។

## ពន្យល់ពាក្យខ្មែរក្រហម

**ឯកភាព:** *ការបង្រួបបង្រួមបញ្ចូលគ្នាធ្វើតែមួយ ។*

**សមាសភាព:** *ភាវៈផ្តុំគ្នាប្រជុំគ្នាជាក្រុម ។*

**សេរីភាព:** *ភាវៈធ្វើបានតាមចំណង់ តាមចិត្ត ។*

**អព្យាក្រឹត្យ:** *ភាវៈនៅជាកណ្តាលឥតចូលគំនិតខាងណា ។*

*សៀវភៅកំណត់ហេតុ ប៊ុន ធឿន (ប៊ុន)*

# កម្ពុជាត្រូវតែបង្ហាញនូវការតាំងចិត្តរបស់ខ្លួន

**ព្រឹទ្ធសភាសហរដ្ឋអាមេរិក**

**ទីក្រុងវ៉ាស៊ីនតោនឌីស៊ី ២០៥១០-៦០២៥**

ថ្ងៃទី៦ ខែមីនា ឆ្នាំ ២០០៣

លោកកូហ្វី អាណាន់ អគ្គលេខាធិការអង្គការសហប្រជាជាតិ

ជាន់ទី៣៨ ទីស្នាក់ការអង្គការសហប្រជាជាតិ

ទីក្រុងញូវយ៉ក ញូវយ៉ក ១០០១៧

លោកអគ្គលេខាធិការជាទីគោរព

យើងខ្ញុំមានការចាប់ការចាប់អារម្មណ៍ដោយដឹងថាលោកអគ្គលេខាធិការរបស់អង្គការសហប្រជាជាតិ និងជាទីប្រឹក្សាច្បាប់គ្រោងនឹងធ្វើដំណើរមកទីក្រុងភ្នំពេញសប្តាហ៍ក្រោយ ដើម្បីបន្តការចរចាជាមួយរដ្ឋាភិបាលកម្ពុជាស្តីអំពីការបង្កើតតុលាការខ្មែរក្រហម ។ នៅក្នុងពេលដែលរដ្ឋាភិបាលកម្ពុជានៅតែបន្តធ្វើមិនអើពើចំពោះវិធាននៃច្បាប់ ដំណើរមកកាន់ទីក្រុងភ្នំពេញនេះគឺធ្វើឡើងមិនចំពេល និងជាការធ្វេសប្រហែសមួយ ។

ប៉ុន្មានសប្តាហ៍កន្លងទៅរដ្ឋាភិបាលកម្ពុជាបានពន្យារឲ្យមានកុប្បកម្មនៅទីក្រុងភ្នំពេញដែលបណ្តាលឲ្យមានការខូចខាតដល់ផលប្រយោជន៍សាធារណៈនិងឯកជនរបស់ថៃ គិតជាទឹកប្រាក់ប្រមាណ ៥០លានដុល្លា ។ នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលគាំទ្រដោយចំហដល់អណ្តាតភ្លើង កំហឹងជាតិនិយមនៅតាមដងវិថី ខកខានមិនបានការពារស្ថានទូតថៃ និងក្រុមហ៊ុនថៃ។ ផ្ទុយទៅវិញ រដ្ឋាភិបាលកម្ពុជាបែរជាចាប់ខ្លួន និងយាយីដល់សកម្មជនប្រឆាំង និងសកម្មជនប្រជាធិបតេយ្យទៅវិញ ធ្វើឲ្យសកម្មជនមួយចំនួនត្រូវតែបង្ខំចិត្តធ្វើយ៉ាងណាឲ្យតែមានសុវត្ថិភាពដល់ខ្លួន។ មកទល់ពេលនេះ មិនទាន់មានការទទួលខុសត្រូវចំពោះមុខច្បាប់នៅឡើយទេ ចំពោះអ្នកដែលពន្យារ គាំទ្រ ឬផ្តល់សេចក្តីយល់ព្រមឲ្យមានកុប្បកម្មនេះឡើង ។

មិនតែប៉ុណ្ណោះសោត ការធ្វើឃាតដោយហេតុផលនយោបាយក៏បានកើតឡើងនៅកម្ពុជាផងដែរ ទាំងនៅទីក្រុងភ្នំពេញ និងទាំងនៅតាមជនបទ។ ក្រោយពេលដែលអតីតសមាជិកសភា ឱម រដ្ឋសាឌី ត្រូវបានបាញ់សម្លាប់ទាំងកណ្តាលថ្ងៃត្រង់ នៅក្នុងទីក្រុងភ្នំពេញ ក្រសួងមហាផ្ទៃ និងនាយករដ្ឋមន្ត្រី ហ៊ុន សែន និយាយថាករណីនេះគឺជាបទល្មើសប្លន់យកទូរស័ព្ទ ។ ប្រការនេះធ្វើឲ្យឃាតកម្មទៅលើរូបលោក សាឌី កាន់តែមានសេចក្តីខ្លោចផ្សាថែមទៀត ។ ជាការពិតណាស់មិនបាច់និយាយក៏ដឹងដែរថាគ្មានការទទួលខុសត្រូវចំពោះមុខច្បាប់ឡើយ ចំពោះឃាតកម្មទៅលើសកម្មជននយោបាយនៅក្នុងប្រទេសកម្ពុជា ។

លោកជ្រាបហើយអំពីការព្រួយបារម្ភរបស់យើងខ្ញុំដែលថាប្រព័ន្ធច្បាប់ដែលល្បីខាងពុករលួយអាចនាំដល់ភាពគ្មានសុចរិតនៅក្នុងតុលាការ និងជ្រាបអំពីជំនឿរបស់យើងខ្ញុំថា លោកនាយករដ្ឋមន្ត្រីហ៊ុន សែន គ្មានឆន្ទៈនយោបាយដែលជាការចំបាច់នាំដល់សាលាក្តីដែលមានលក្ខណៈយុត្តិធម៌មិនលម្អៀងបានទេ ។ ព្រឹត្តិការណ៍កន្លងទៅប៉ុន្មានសប្តាហ៍មុន ពិតជាបញ្ជាក់ឱយឃើញនូវភាពគ្មានច្បាប់ទម្លាប់នៅក្នុងប្រទេសកម្ពុជា ។

សួរដោយត្រឹមត្រូវថា តើប្រជាជនកម្ពុជាអាចសង្ឃឹមថានឹងទទួលបានយុត្តិធម៌ពីរដ្ឋាភិបាលរបស់ខ្លួនចំពោះឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងដោយខ្មែរក្រហមដែរឬទេ បើមិនទាន់ទាំងដោះស្រាយ និងផ្តន្ទាទោសចារីនៃបទល្មើសឃាតកម្មដែលប្រព្រឹត្តកាលពីខែមុនផងនោះ ។

លោក កូហ្វី គួរតែពន្យារដំណើរទស្សនៈកិច្ចរបស់ខ្លួនមកកាន់ទីក្រុងភ្នំពេញ រហូតដល់ពេលណារដ្ឋាភិបាលកម្ពុជាបង្ហាញនូវការតាំងចិត្តរបស់ខ្លួនចំពោះបញ្ហាសិទ្ធិមនុស្ស ប្រជាធិបតេយ្យនិងនីតិរដ្ឋ ។ របៀបដោះស្រាយ "ធ្វើការតាមធម្មតាដូចជាគ្មានអ្វីកើតឡើង" របស់នាយករដ្ឋមន្ត្រី ក្រោយពីមានខបទ្វវហេតុទាំងនេះកើតឡើង ជាការបញ្ជូនសារខុសស្រឡះមួយទៅកាន់ប្រជាជនកម្ពុជាដែលផ្តល់ការគោរព និងក្តីសង្ឃឹមចំពោះសហគមន៍អន្តរជាតិដើម្បីធ្វើឲ្យរដ្ឋាភិបាលរបស់ខ្លួនទទួលខុសត្រូវ និងអនុវត្តតាមគោលការណ៍លទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ។

សូមលោកអគ្គលេខាធិការមេត្តាពិចារណានូវមតិយោបល់របស់យើងខ្ញុំផងចុះ ។

សូមលោកអគ្គលេខាធិការទទួលនូវការរាប់អានដ៏ស្មោះអំពីយើងខ្ញុំ ។

| | |
|---|---|
| ហត្ថលេខា | ហត្ថលេខា |
| មីត ម៉ែក ខូណែល | ប៉ាទ្រីក លេហ៊ី |
| ប្រធានអនុគណៈកម្មាធិការ | សមាជិកអនុកម្មាធិការប្រតិបត្តិ |
| ប្រតិបត្តិហិរញ្ញវត្ថុក្រៅប្រទេស | ការហិរញ្ញវត្ថុក្រៅប្រទេស |

# សន្តិភាពនិងការផ្សះផ្សាជាតិ

### *សេចក្តីផ្តើម*

បទពិសោធន៍របស់ខ្ញុំដែលធ្វើការជាមួយនឹងគ្រឹះស្ថានកសាងសន្តិភាពដែលមានឈ្មោះថា មជ្ឈមណ្ឌលឯកសារកម្ពុជា និងចំណេះដឹងរបស់ខ្ញុំដែលបានមកពីការចូលរួមសន្និសីទទាក់ទងនឹងដំណោះស្រាយជម្លោះនិងជំរុញឲ្យមនុស្សជាតិរស់នៅនិងធ្វើការជាមួយគ្នា ព្រមជាមួយនឹងការសន្ទនារបស់ខ្ញុំ ការពិភាក្សាវែកញែកទៅលើវិធីនានាដើម្បីបង្កើតបានសន្តិភាពនិងការបង្រួបបង្រួមផ្សះផ្សាជាតិ គឺស្តែងចេញនៅក្នុងអត្ថបទសិក្សានេះតែម្តង ។ ជាងនេះទៅទៀត ដំណើរការផ្សះផ្សាគឺជាបញ្ហាដ៏ពិបាកក្នុងខណៈពេលនេះជាបញ្ហាដែលសង្គមមិនទាន់មានការអភិវឌ្ឍន៍ភាគច្រើនកំពុងតែពិភាក្សាវែកញែក ។ ខ្ញុំមានកិត្តិយសណាស់ដែលបានចូលរួមនិងផ្តល់ជាវិភាគទានតាមរយៈគំនិតរបស់ខ្ញុំផ្តោតទៅលើអនាគតរបស់ប្រទេសកំណើតខ្ញុំ ។

ខ្ញុំសម្រេចចិត្តជ្រើសយកប្រធានបទនេះសម្រាប់សរសេរពីព្រោះថា វាជាបញ្ហាសំខាន់សម្រាប់រូបខ្ញុំផ្ទាល់ និងសម្រាប់ប្រទេសខ្ញុំដែលទើបតែងើបពីការបែកបាក់ និងទើបងើបផុតពីសង្គមមួយដែលមានលក្ខណៈហិង្សាអូសបន្លាយអស់មួយរយៈ ។ ការសម្រេចថាតើត្រូវដោះស្រាយជាមួយនឹងមរតកនៃការរំលោភសិទ្ធិមនុស្សដែរឬទេ និងដោះស្រាយដោយរបៀបណាគឺជាបញ្ហាចម្បងក្នុងការលើកកម្ពស់ការផ្សះផ្សានិងការអភិវឌ្ឍន៍សេដ្ឋកិច្ចប្រកបដោយនិរន្តភាព ។ ខ្ញុំជឿជាក់ថា លើកកម្ពស់ការផ្សះផ្សាមានន័យថាលើកកម្ពស់សន្តិភាពនិងលទ្ធិប្រជាធិបតេយ្យ ។ នៅពេលដែលប្រជាជនរស់នៅជាមួយនឹងគំនិតថា ជាតិរបស់ខ្លួនកំពុងស្ថិតនៅក្រោមនីតិរដ្ឋ អហិង្សា សមភាព និងសុខដុមរមនាពេលនោះគេនឹងមានសេរីភាពឈានជើងទៅមុខ និងធ្វើឲ្យគ្រួសាររបស់ខ្លួនព្រមទាំងប្រទេសជាតិរបស់ខ្លួនសម្បូណ៌សប្បាយជាមិនខាន ។ តើមានលក្ខណៈសម្បត្តិអ្វីខ្លះដែលធ្វើឲ្យមានការផ្សះផ្សា? ពិតជាគ្មានចម្លើយសាមញ្ញចំពោះសំណួរនេះឡើយ ហើយសំណួរនេះក៏ពិតជាមិនអាចឆ្លើយបានដោយងាយៗដែរ ។ ក៏ប៉ុន្តែមេរៀនដែលបានមកពីប្រទេសនានាពិតជាមានប្រយោជន៍ណាស់ ។

ខ្ញុំនឹងពិនិត្យទៅលើបីចំណុចដែលមានដូចខាងក្រោមនេះ÷ ចំណុចទី១ ខ្ញុំពិនិត្យទៅលើភាពតានតឹងនិងមធ្យោបាយនានាដែលបានអនុវត្តនៅក្នុងប្រទេសមួយចំនួនរួចមកហើយក្នុងការដោះស្រាយជាមួយនឹងភាពតានតឹងដែលជាមូលដ្ឋានសម្រាប់ការផ្សះផ្សានាពេលអនាគត ។ ចំណុចទី២ ខ្ញុំនឹងរុករកករណីជាក់ស្តែងស្តីអំពីដំណើរការផ្សះផ្សាជាតិនៅក្នុងប្រទេសកម្ពុជា ។ ចំណុចចុងក្រោយគឺនៅក្នុងសេចក្តីសន្និដ្ឋាន ខ្ញុំនឹងទាញហេតុផលថា យុត្តិធម៌គ្រាន់តែជាតំណាង គឺជាវិធីសាស្ត្រដ៏ល្អបំផុតនៅក្នុងការជំរុញឲ្យមានសន្តិភាពនិងការផ្សះផ្សាជាតិនៅកម្ពុជា ។

ពាក្យថា “ការផ្សះផ្សា” ជាភាសាឡាតាំងសរសេរថា “reconcilare” ។ ពាក្យថា “re” គឺបានន័យថា ជាថ្មីម្តងទៀតឡើងវិញ ។ ចំណែកឯពាក្យថា “reconcilare” មានន័យថា “ឲ្យជួបជុំគ្នា” ។ ចំពោះលោក ចនប៉ូល លីឌើរ៉ាច់ យល់ថា ពាក្យ “re” គឺមិនសំដៅទៅលើការត្រឡប់មកធាតុដើមវិញទេ ប៉ុន្តែសំដៅទៅលើការកសាងឡើងនូវទំនាក់ទំនងថ្មីមួយ ។ លោកមានប្រសាសន៍ថា ការផ្សះផ្សាបង្កើតនូវកន្លែងមួយដែល “ការពិតនិងការប្រោសប្រណីប្រសព្វគ្នា ។ យុត្តិធម៌និងសន្តិភាពប្រសព្វគ្នា ។ អែនទ្រូរីកបាយ និយាយថា “ការផ្សះផ្សាសំដៅទៅលើអនាគត ហើយតម្រូវឲ្យមានការចូលរួមយ៉ាងសកម្មពីសំណាក់អ្នកដែលបានបែកបាក់នឹងគ្នាតាមរយៈភាពអមិត្ត ។ ចំណុចសំខាន់នៃដំណើរការផ្សះផ្សា គឺការរៀបចំខ្លួនរួចជាស្រេចរបស់មនុស្សក្នុងការប្រមើលមើលទៅអនាគតមួយរួមគ្នា ។ ដើម្បីឲ្យមានអនាគតមួយរួមគ្នាមនុស្សទាំងនោះមិនត្រូវបំភ្លេច ប៉ុន្តែត្រូវចេះអត់ឱនចំពោះអតីតកាលដូច្នេះត្រូវស្ថិតក្នុងជំហរមួយចង់ធ្វើដំណើរទៅមុខរួមគ្នា” ។

ស្រដៀងគ្នានេះដែរ ហ៊ីស្សគីអាស អាសេហ្វា និយាយថាទ្រឹស្តីនៃការផ្សះផ្សា «មិនមែនត្រឹមតែព្យាយាមរកដំណោះស្រាយចំពោះបញ្ហានានាដែលជាដើមហេតុនៃជម្លោះប៉ុណ្ណោះទេ តែត្រូវផ្តើការដើម្បីផ្លាស់ប្តូរទំនាក់ទំនងរបស់ភាគីជម្លោះ ពីការមិនពេញចិត្ត និងប្រទូសរ៉ាយមកជាមិត្តភាព និងសុខដុមរមនា ។ ពិតណាស់ដើម្បីឲ្យគុណសម្បត្តិនេះកើតឡើងភាគីទាំងសងខាងត្រូវចំណាយពេល និងចូលរួមស្មើៗគ្នាយ៉ាងអស់ពីចិត្តនៅក្នុងដំណើរការឈានទៅរកដំណោះស្រាយ ។

### ភាពតានតឹង

យោងតាមនិយមន័យខាងលើយើងអាចមើលឃើញថាការផ្សះផ្សាជាទូទៅគឺនិយាយអំពីការពិត ការប្រោសប្រណីសន្តិភាព និងយុត្តិធម៌ ។ និយាយឲ្យកាន់តែច្បាស់ថែមទៀតដំណើរការផ្សះផ្សាគឺនិយាយអំពីពេលដែលគំនិតទាំងបួនប្រសព្វគ្នាព្រមៗគ្នា ។ និយមន័យទាំងនេះ គឺពិតជាមិនទាន់គ្រប់គ្រាន់ដើម្បីយល់ពីដំណើរការផ្សះផ្សាឡើយ ។ ដូចជាថា និយមន័យទាំងនេះមិនបានលើកបញ្ហាដែលបានកើតឡើងនៅក្នុងដំណើរការផ្សះផ្សា ហើយថាតើបញ្ហាទាំងនោះបានដោះស្រាយបន្ថែមនូវលទ្ធផលដែលចេញពីដំណោះស្រាយនោះដែរឬទេ ។ ទាក់ទងនឹងបញ្ហានេះ ចនប៉ូល លីឌឺរ៉ាច បានផ្តល់នូវការស្វែងយល់បន្ថែមទៀតទៅលើដំណើរការផ្សះផ្សាថា «ដំណើរការផ្សះផ្សាតំណាងឲ្យលំហឬភាពតានតឹង ដែលភាពតានតឹងប្រកបដោយប្រឌិតញាណដែលក្តោបនូវភាពចាំបាច់និងថាមពលទាំងនេះដែលធ្វើឲ្យដើរទាំងអស់គ្នា» ។ ដើម្បីឲ្យសន្តិភាពនិងការផ្សះផ្សាលេចចេញជារូបរាងឡើងតម្លៃទាំងអស់នេះត្រូវតែដាក់បញ្ចូលគ្នាចេញជាតម្លៃមួយប្រឆាំងនឹងតម្លៃមួយទៀត ។ លោកពន្យល់បន្ថែមទៀតថាៈ ការពិត គឺការចង់បាននូវការទទួលស្គាល់នូវកំហុស ការខាតបង់ និងបទពិសោធន៍ដ៏គួរឲ្យឈឺចាប់ ប៉ុន្តែជាគូនឹងការប្រោសប្រណី ដែលបញ្ចេញច្បាស់នូវការទទួលយកការផ្តេចផ្តែកធ្វើមិនដឹងមិនឮនិងការចាប់ផ្តើមសាជាថ្មី ។ យុត្តិធម៌តំណាងឲ្យការស្វែងរកសិទ្ធិរបស់បុគ្គលនិងរបស់ក្រុម ដើម្បីកសាងរចនាសម្ព័ន្ធសង្គមឡើងវិញ និងដើម្បីប៉ះប៉ូវការខូចខាត ប៉ុន្តែត្រូវភ្ជាប់នឹងសន្តិភាពដែលសង្កត់ធ្ងន់ទៅលើតម្រូវការចាំបាច់នូវសន្តិភាព សន្តិសុខនិងសុខុមាលភាព ។

អែនឌ្រូ រីកប៊ី ពិពណ៌នាថា ការផ្សះផ្សាតម្រូវឲ្យមានគំនិតធំៗបួន គឺការពិត យុត្តិធម៌ ការអត់ឱន និងសន្តិភាព ហើយគោលគំនិតទាំងបួននេះអាស្រ័យគ្នាទៅវិញទៅមក ។ គំនិតទាំងបួនត្រូវតែកើតមានព្រមៗគ្នា ដូចជានៅពេលដែលការពិតយុត្តិធម៌ និង ការអត់ឱនបំពេញបន្ថែមទៅលើសន្តិភាព នៅពេលមានសន្តិភាពហើយ នឹងមានការផ្សះផ្សាមួយប្រកបដោយចីរភាព ប៉ុន្តែដំណើរការនេះមិនអាចយកមកដាក់ប្រសព្វគ្នាបានដោយងាយៗនោះទេ ។ អែនឌ្រូ និយាយថា «តម្លៃទាំងនេះគឺមានភាពតានតឹងជាមួយគ្នាទៅវិញទៅមកជានិច្ច» ។ ហាក់ មៀល អូលីវីរ៉ាមបូថាម និង ថម វូដហៅ សុទ្ធតែបានយល់ស្របទាំងអស់គ្នាទៅលើភាពតានតឹងដែលកើតឡើងនៅក្នុងដំណើរការផ្សះផ្សា ។ ភាពតានតឹងដែលអ្នកស្រាវជ្រាវខាងលើអាចមើលឃើញច្បាស់គឺរវាងសន្តិភាព និងយុត្តិធម៌ដោយហេតុថាសន្តិភាពនាំដល់ការសម្រេចនូវតម្លៃផ្សេងទៀត ចំណែកឯយុត្តិធម៌វិញធានាឲ្យមានការបញ្ឈប់ការរំលោភ ។ អ្នកស្រាវជ្រាវខាងលើនិយាយថា «បន្ថែមទៅលើការលំបាកនានា ដែលនៅជាប់ជាមួយនឹងការលំបាកទៅលើគ្នាទៅវិញទៅមករវាងតម្លៃទាំងពីរនេះ ក៏នៅមានការលំបាកមួយទៀតដែរគឺពិបាកនឹងជៀសឲ្យផុតពីភាពតានតឹងរវាងតម្លៃទាំងពីរនៅពេលដែលតម្លៃទាំងពីរនេះត្រូវបានយកមកផ្គុំគ្នា» ។

សម្តេចព្រះ សុគន្ធាធិបតី បួរ គ្រី ព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជាមានគំនិតដូចគ្នានេះដែរ ។ ទាក់ទងទៅនឹងភាពតានតឹងរវាងការពិតនិងយុត្តិធម៌ សម្តេចមានសង្ឃដីកាថា «អាត្មាជ្រាបរួចហើយពាក្យខ្មែរថា កាត់ទឹកមិនដាច់កាត់សាច់វាឈឺ ។ មួយទៀតថា យល់ញាតិឃាតច្បាប់» ។

ស្រដៀងគ្នានេះដែរ ម៉ាតា មីណូ ពិពណ៌នាថា ការពិតនិងយុត្តិធម៌គឺជាគោលគំនិតពីរសំខាន់ដែលធ្វើការឆ្លើយតបទៅនឹងហិង្សាជារួម ។ អ្នកស្រីទាញហេតុផលថា «ការធ្វើឲ្យមានភាពដូចដើមឡើងវិញនូវភាពថ្លៃថ្នូរចំពោះជនរងគ្រោះអាចជាផ្នែកមួយនៃដំណើរការនេះ ប៉ុន្តែក៏គួរតែដោះស្រាយជាមួយអ្នកដែលបាន

ជួយជ្រោមជ្រែង ឬដែលបានចូលរួមនៅក្នុងអំពើឃោរឃៅនោះ ។ បើពុំនោះសោត ការបែកបាក់និងការតូចចិត្តប្រហែលជានឹងកើតឡើងហើយចេះតែវិវឌ្ឍជាលំដាប់» ។ ក៏ប៉ុន្តែបញ្ហានៅត្រង់ថាតើគោលបំណងណាមួយក្នុងចំណោមគោលបំណងទាំងពីរដែលគួរតែមានអាទិភាព?

លោក ម៉ៃឃើល ប៉ាឡេវៀត អះអាងថា ទោះជាតាមផ្លូវណាក៏ដោយក្នុងការដោះស្រាយការរំលោភកាលពីអតីតកាល កត្តាសីលធម៌និងនយោបាយចាំបាច់ត្រូវតែមានតុល្យភាពៈ មានន័យថា ការទាមទារចង់បានយុត្តិធម៌ត្រូវតែថ្លឹងឲ្យស្មើនឹងអ្វីដែលអាចធ្វើបានតាមផ្លូវនយោបាយ ។ ពេលនោះភាពតានតឹងតែងតែត្រូវបានចាត់ទុកថាបានកើតឡើងរវាងការចង់បានយុត្តិធម៌និងសន្តិភាព ដោយសារសារជាតិមិនទៀងនៃនយោបាយអន្តរកាល ។ ជាការច្បាស់ណាស់ថា យុត្តិធម៌អាចប៉ះពាល់ដល់សន្តិភាពនៅពេលដែលលទ្ធិប្រជាធិបតេយ្យឬកិច្ចព្រមព្រៀងសន្តិភាពនៅតែងាយប្រេះស្រាំនៅឡើយ» ។

ឥឡូវនេះចូរយើងក្រឡេកមើលភាពតានតឹងជាក់ស្តែងដែលកើតមានឡើងនៅក្នុងដំណាក់កាលអន្តរកាល និងរបៀបដោះស្រាយផ្សេងៗគ្នានៅបណ្តាប្រទេសមួយចំនួន ។ សាមូអែល ហាន់ទីងតុន បានបែងចែកដំណាក់កាលអន្តរកាលនៃលទ្ធិប្រជាធិបតេយ្យភាវូបនីយកម្មទៅជាបីប្រភេទធំៗ ។ ទីមួយៈ ការប្រែធាតុ គឺនៅពេលដែលភាគីក្នុងជម្លោះទាំងសងខាងមានការព្រមព្រៀងគ្នាតាមរយៈការចរចា និងនាំមកនូវការផ្លាស់ប្តូរ ។ ទីពីរៈ ការជំនួស គឺនៅពេលដែលរបបមួយត្រូវបានផ្តួលរំលំដោយកម្លាំងឬសម្ពាធ ។ ទីបីៈ ការផ្លាស់ប្តូរខ្សែគ្នា គឺនៅពេលដែលរបបមួយត្រូវបានបង្ខំឲ្យចរចាជាមួយនឹងភាគីបដិបក្ខ រួចហើយឈានទៅរកការផ្លាស់ប្តូរ ។

វិធីនៃដំណើរការឆ្លងកាត់(អន្តរកាល)ក្នុងដំណោះស្រាយជាមួយនឹងកេរដំណែលនៃការរំលោភនានាគឺការយកការពិតមកដាក់ខ្សែងជាមួយនឹងយុត្តិធម៌ ។ ឧទាហរណ៍ វិធីក្នុងការដោះស្រាយបញ្ហាអំពើឃោរឃៅអតីតកាលនៅប្រទេសអាហ្វ្រិកខាងត្បូង អេស្បាញ អាហ្សង់ទីន និង ប្រទេសឈីលី ។ គណៈកម្មការផ្សះផ្សានិងស្វែងរកការពិតត្រូវបានបង្កើតឡើងនៅក្នុងខែខសភា ឆ្នាំ១៩៩៥ នៅប្រទេសអាហ្វ្រិកខាងត្បូង ដែលជាកិច្ចសម្រុះសម្រួលរបស់អតីតប្រធានាធិបតី ឌឺក្លឹក នៃរបប អាប៉ាថេត ដែលត្រូវបរាជ័យដោយការបោះឆ្នោតចាញ់ លោកប្រធានាធិបតី ណេលសិន ម៉ែនឌីឡា នៅឆ្នាំ១៩៩៤ ។ គណៈកម្មការផ្សះផ្សានិងស្វែងរកការពិតបង្កើតឡើងដើម្បីព្យាបាលការឈឺចាប់របស់ជនរងគ្រោះតាមរយៈការធ្វើការស៊ើបអង្កេតស្វែងរកការពិតដែលបានកើតឡើង ។ គណៈកម្មការនេះបង្កើតជាចំណងផ្ទាល់រវាងការផ្តល់ការលើកលែងទោស និងការបរិយាយការពិតៈ ពោលគឺការលើកលែងទោសដើម្បីការពិត ។ ការលើកលែងទោសនឹងផ្តល់ទៅអ្នកដែលមកនិយាយការពិត ហើយនិងសុំការលើកលែងទោស ។ នៅក្នុងដំណាក់កាលនេះ មានមនុស្សចំនួន២ម៉ឺននាក់មកធ្វើជាកសិណ ទន្ទឹមពេលនោះដែរ មានមនុស្សចំនួន៧ពាន់នាក់មកសុំការលើកលែងទោស ។ រួចហើយ ម្នាក់ៗត្រឡប់ទៅលំនៅដ្ឋានរៀងៗខ្លួនវិញ ។ អ្វីៗគ្រប់យ៉ាងត្រូវបានបញ្ចប់ ។ ស្រដៀងគ្នានេះ នៅប្រទេសអាហ្សង់ទីន និងឈីលី មេដឹកនាំរបបដែលមានអំពើឃោរឃៅកើតឡើងបានទទួលនូវការលើកលែងទោសដែលផ្តល់ដោយប្រធានាធិបតីដែលទើបជាប់ឆ្នោតថ្មីដោយរដ្ឋាភិបាលថ្មីចាត់ទុកវិធីលើកលែងទោសនេះជាមធ្យោបាយសម្រាប់ដោះស្រាយការរំលោភបំពានកើតឡើងពីអតីតកាល ។

អ្នកគាំទ្រដំណោះស្រាយនេះឲ្យហេតុផលថា ខ្លួនទើបតែងើបផុតពីសង្គ្រាមបែកបាក់ ហើយខ្លួនមានសារសំខាន់ណាស់ក្នុងការជំរុញឲ្យមានការផ្សះផ្សាឡើងវិញ ។ វិសុទ្ធកម្មនិងការជំនុំជម្រះក្តីនាំជំរុញឲ្យសហគមន៍របស់គេដែលទើបតែស្តាបនាថ្មីសន្ទាងពីមានសន្តិភាពទៅភាពចលាចល ឬរហូតដល់មានសង្គ្រាមថែមទៀតក៏ថាបាន ។ ហ៊ុសគៀស អាសេហ្វ និយាយថា បញ្ហាសំខាន់ក្នុងការផ្សះផ្សា គឺមិនមែនអំពីការស្វែងរកយុត្តិធម៌ទេ ប៉ុន្តែអំពី «ទំនាក់ទំនងសុខដុមរមនានិងទំនាក់ទំនងវិជ្ជមាន» ដើម្បីការផ្សះផ្សា ។ យុត្តិធម៌មានសារសំខាន់ណាស់ប៉ុន្តែមិនគ្រប់គ្រាន់ទេ» ។

មិនមែនប្រជាជនអាហ្វ្រិកខាងត្បូងទាំងអស់សុទ្ធតែពេញចិត្តនឹងគណៈកម្មការស្វែងរកការពិតនិងផ្សះផ្សានោះទេ ។ អ្នកដែលមានវាសនារស់រានមានជីវិត និងជាពិសេសអតីតជនរងគ្រោះកំពុងតែបដិសេធមិនទទួលយកនូវវិធីដែលគណៈកម្មការ

ស្វែងរកការពិតនិងផ្សះផ្សាបានធ្វើ គឺអ្វីដែលប្រជាជនមួយចំនួនហៅថាការផ្សះផ្សាតាមបែប«រឿងលួចកង់» ។ ម៉ាថា មីណូ កត់សម្គាល់នូវភាពតានតឹងរវាងការពិតនិងយុត្តិធម៌នៅក្នុងបរិបទនេះថា «តើមានប្រយោជន៍អ្វីនឹងដឹងពុ្ក បើគ្មានយុត្តិធម៌ផងនោះ?» ។

គិតចាប់ពីការយកការពិតនិងសន្តិភាពមកដាក់ប្រសព្វជាមួយនឹងយុត្តិធម៌គឺជាការរកយុត្តិធម៌ក្នុងការដោះស្រាយជាមួយនឹងអ្នកដែលមានកំហុសនៃការរំលោភសិទ្ធិមនុស្សកាលពីអតីតកាល ។ វិធីនេះត្រូវបានចាត់ចែងលែលករួចទៅហើយនៅអឺរ៉ុបខាងកើតនិងអឺរ៉ុបកណ្តាលក្នុងអំឡុងឆ្នាំ១៩៨៩ ហើយដំណាក់កាលឆ្លងកាត់គឺច្បាស់ណាស់ថា ជាការដាក់ជំនួស(មេដឹកនាំថ្មី) ដែលរបបចាស់ត្រូវបានផ្តួលរំលំតាមរយៈការគាបសង្កត់ពីក្រោមនិងកម្លាំងមកពីខាងក្រៅ ។ ឧទាហរណ៍ វិធីរកយុត្តិធម៌សម្រាប់ចារីនៃបទល្មើសនៅនូរិមប៊ឺកដែលជម្រះក្តីឧក្រិដ្ឋជនសង្គ្រាមណាហ្ស៊ីនិងនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនៅអតីតយូហ្គោស្លាវីនិងរ៉ាន់ដា ។

លោក រ៉យ លីកលីដឌ័រ យល់ថា ការចង់បានយុត្តិធម៌នឹងលែងធ្វើឲ្យមានឧក្រិដ្ឋកម្មនាពេលអនាគត ហើយបើនិយាយអំពីចិត្តសាស្ត្រវិញ ទាំងជនរងគ្រោះនិងចារីនៃបទល្មើសនឹងមិនអាចរស់ជាមួយអ្នកផ្សេងបានទេ លុះត្រាណាតែបទល្មើសត្រូវបានទទួលស្គាល់ថា បានកើតមានមែន និងមានការផ្តន្ទាទោសសំណងការខូចខាត ឬការសម្តែងនូវវិប្បដិសារី ។

ក៏ប៉ុន្តែជាទូទៅតែងតែមានការលំបាកក្នុងការបែងចែកឲ្យដាច់រវាងជនរងគ្រោះនិងជនដៃដល់ ។ ពីព្រោះនៅក្នុងសង្គ្រាមស៊ីវិលម្នាក់ៗសុទ្ធតែមានកំហុសពីការចូលរួមជាមួយភាគីណាមួយមិនខាននៅពេលផ្សេងៗគ្នា ។ អ៊ីចឹងតើអ្នកណាជាអ្នកញែកឲ្យដាច់ថា អ្នកណាជាជនរងគ្រោះ អ្នកណាជាជនដៃដល់? ដើម្បីឲ្យដឹងការពិត និងអ្វីដែលបានកើតឡើងនៅក្នុងអតីតកាល គួរតែមានការស៊ុខចិត្តបន្តិចម្នាក់ៗទៅលើបញ្ហាយុត្តិធម៌ ។ នេះគឺជាសំណួរពីរទាក់ទងនឹងតម្លៃទាំងពីរនេះ ។ សំណួរទីមួយៈ ថាតើធ្វើដូចម្តេចទើបបុគ្គលម្នាក់ចេញមុខឆ្លើយនូវការពិតអំពីអំពើអាក្រក់ដែលខ្លួនបានធ្វើកាលពីអតីតកាល ប្រសិនបើគេត្រូវប្រឈមមុខនឹងវិសុទ្ធកម្មនិងការកាត់ទោស? សំណួរទីពីរៈ តើការផ្តន្ទាទោសតាមរយៈប្រព័ន្ធតុលាការព្រហ្មទណ្ឌជាមធ្យោបាយសមស្របសម្រាប់ឈានទៅរកការពិតដែរឬទេ? សម្រាប់ ម៉ាថា មីណូ យល់ថា គ្មានចម្លើយថាត្រូវឬខុសឡើយ ។ ម៉ាថា យល់ថា «ម្នាក់សុំឲ្យមានការពិតនិងយុត្តិធម៌ច្រើនតាមតែអាចធ្វើបាន ។ ឯម្នាក់ទៀតចង់សង្កត់ធ្ងន់ទៅលើការប្រព្រឹត្តិខុសច្បាប់ ជាពិសេសការប្រព្រឹត្តិអំពើដែលមិនប្រពៃគួរឲ្យរន្ធត់» ។

## សិក្សាករណីជាក់ស្តែងនៅកម្ពុជា

ប្រហែលជាឧទាហរណ៍ដ៏ច្បាស់នៃភាពតានតឹងរវាងការពិតនិងយុត្តិធម៌អាចរកឃើញនៅកម្ពុជា ដែលរាជរដ្ឋាភិបាលកម្ពុជាព្យាយាមយកការពិតប្រសព្វជាមួយនឹងយុត្តិធម៌ក្នុងខណៈដែលប្រជាជនមួយចំនួន ជាពិសេសថ្នាក់ដឹកនាំសង្គមស៊ីវិលព្យាយាមសុំយុត្តិធម៌ចេញពីផ្លូវច្បាប់ដើម្បីដោះស្រាយការរំលោភបំពានសិទ្ធិមនុស្សពីសំណាក់ខ្មែរក្រហម ។

១) ប្រវត្តិនៃជម្លោះ

ក្រោយពីសាធារណរដ្ឋខ្មែរដឹកនាំដោយលោក លន់ ណុល ដែលគាំទ្រដោយសហរដ្ឋអាមេរិកត្រូវបានផ្តួលរំលំនៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានអនុវត្តនូវនយោបាយកុម្មុយនិស្តនៅក្នុងប្រទេសកម្ពុជាដែលជាលទ្ធផលបណ្តាលឲ្យប្រជាជនកម្ពុជាស្លាប់អស់យ៉ាងហោចណាស់១លាន៧សែននាក់ តាមរយៈការសម្លាប់ ជំងឺនិងការអត់អាហារដោយធ្វើពលកម្មហួសកម្លាំង ។

កងទ័ពវៀតណាមបានដេញខ្មែរក្រហមចេញពីអំណាចហើយបានលើកបន្តុបលោក ហេង សំរិន និងសម្តេច ហ៊ុន សែន ឲ្យគ្រប់គ្រងប្រទេសនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ។ ខ្មែរក្រហមបានដកថយដល់ជាយដែនថៃ ។ ការគាំទ្រជាអន្តរជាតិទៅលើភាគីម្ខាងៗបានឆ្លុះបញ្ចាំងពីការបែងចែកមនោគមវិជ្ជានៅសម័យសង្គ្រាមត្រជាក់ ។ រដ្ឋាភិបាលភ្នំពេញត្រូវបានគាំទ្រដោយសហភាពសាធារណរដ្ឋសង្គមនិយមសូវៀត ចំណែកឯរដ្ឋាភិបាលចម្រុះត្រីភាគីដែលរួមមានក្រុមខ្មែរក្រហម រណសិរ្សរួបរួមជាតិ ដើម្បីឯករាជ្យនិងរណសិរ្សរំដោះប្រជាពលរដ្ឋខ្មែរដែលដឹកនាំសម្តេចសីហនុ និងលោក សឺន សាន បានទទួលការគាំទ្រពីសហរដ្ឋអាមេរិកចិន និងប្រជាជាតិអាស៊ីអាគ្នេយ៍ ។ រដ្ឋាភិបាលចម្រុះគ្រប់គ្រងទឹកដី

កម្ពុជាពី១០ទៅ២០ភាគរយ ។ រដ្ឋាភិបាលចម្រុះបានរួមកម្លាំងគ្នាធ្វើប្រតិបត្តិការពីប្រទេសថៃនិងភាគពាយ័ព្យនៃប្រទេសកម្ពុជាប្រយុទ្ធប្រឆាំងនឹងរដ្ឋាភិបាលកម្ពុជា ។ នៅឆ្នាំ១៩៨៩ រដ្ឋាភិបាលភ្នំពេញដែលមានសម្តេច ហ៊ុន សែន ជានាយករដ្ឋមន្ត្រី បានបោះបង់ចោលនូវលទ្ធិកុម្មុយនិស្ត ហើយបានផ្លាស់ប្តូរឈ្មោះប្រទេសទៅជា "រដ្ឋកម្ពុជា" ចំណែកឯកងទ័ពវៀតណាមវិញក៏បានដកពីប្រទេសកម្ពុជាទាំងស្រុងដែរ ។ ការចរចាសន្តិភាពដែលរ៉ាប់រងដោយអង្គការសហប្រជាជាតិបាននាំដល់កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសនៅខែតុលា ឆ្នាំ១៩៩១ ហើយបន្ទាប់មកមានការបោះឆ្នោតជាតិនៅខែឧសភា ឆ្នាំ១៩៩៣ ក្រោមការត្រួតពិនិត្យមើលពីសំណាក់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិនៅប្រទេសកម្ពុជា(ហៅកាត់ថា អ៊ុនតាក់) ។

អង្គការសហប្រជាជាតិបានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកសាងសន្តិភាពលទ្ធិប្រជាធិបតេយ្យ និងសិទ្ធិមនុស្សនៅកម្ពុជា ប៉ុន្តែបញ្ហាយុត្តិធម៌និងការផ្សះផ្សាត្រូវបរាជ័យទាំងស្រុងនៅ


ព្រះសង្ឃនិងប្រជាជនកំពុងធ្វើពិធីបង្សុកូលឧទ្ទិសជូនជនរងគ្រោះដែលបានស្លាប់ក្នុងរបបខ្មែរក្រហម

ដំណាក់ចុងក្រោយនៃកិច្ចព្រមព្រៀងសន្តិភាព ។ កិច្ចព្រមព្រៀងសន្តិភាពមិនបានរារាំងខ្មែរក្រហមមិនឲ្យចូលរួមនៅក្នុងការបោះឆ្នោតឆ្នាំ១៩៩៣ឡើយ ហើយក៏មិនបានបង្ការមិនឲ្យមេដឹកនាំខ្មែរក្រហមដែលបានចូលរួមនៅក្នុងការសម្លាប់មនុស្សមិនឲ្យកាន់មុខដំណែងនៅក្នុងរដ្ឋាភិបាលកម្ពុជានាពេលអនាគតដែរ ។ នៅឆ្នាំ១៩៩៦ អតីតមេដឹកនាំខ្មែរក្រហមធំៗបានចុះចូលជាមួយនឹងរដ្ឋាភិបាលកម្ពុជានិងកងយោធពលខេមរភូមិន្ទជាបន្តបន្ទាប់ ។ ដើម្បីប្រយោជន៍នៃការផ្សះផ្សាជាតិ រដ្ឋាភិបាលបានទទួលយកអតីតខ្មែរក្រហម ហើយបានសន្យាថានឹងផ្តល់នូវការលើកលែងទោស ។

(២) ដំណើរការសន្តិភាពនៅកម្ពុជា

ក្រោយពីរបបខ្មែរក្រហមដួលរលំ គ្មានដំណើរការជាផ្លូវការនិងសាធារណៈដើម្បីទទួលស្គាល់ ការសុំអភ័យទោស ឬរកយុត្តិធម៌តាមផ្លូវច្បាប់ឡើយ ។ ការកាត់ទោសប្រហារជីវិតដោយកំបាំងមុខនូវមេដឹកនាំខ្មែរក្រហម ប៉ុល ពត, អៀង សារី ពីសំណាក់សាធារណរដ្ឋប្រជាមានិតកម្ពុជានៅឆ្នាំ១៩៧៩ មិនត្រូវបានទទួល

យកជាអន្តរជាតិឡើយ ដោយសារការជំទាស់នានាថា មិនមានលក្ខណៈត្រឹមត្រូវតាមច្បាប់និងភាពឯកោខាងការទូតនៃរបបសាធារណរដ្ឋប្រជាមានិតកម្ពុជា ។ កាលពីពេលនោះខ្មែរក្រហមនៅតែជាគ្រោះគំរាមកំហែងដល់សន្តិសុខជាតិរហូតដល់ថ្ងៃដែលគេមកចុះចូលនិងទទួលបាននូវការលើកលែងទោស ។

នយោបាយផ្សះផ្សាជាតិរបស់រដ្ឋាភិបាលកម្ពុជាបានបញ្ឈប់សង្គ្រាមស៊ីវិល ហើយនាំមកនូវសន្តិភាពនិងផ្តល់ឱកាសល្អសម្រាប់គ្រួសារកម្ពុជាឲ្យរួមរស់ជាមួយគ្នាទៀត ។ នេះគឺជាសមាហរណកម្មផ្នែកនយោបាយមិនមែនសមាហរណកម្មផ្នែកសង្គមទេ ។ នៅពេលដែលអតីតកម្មាភិបាលខ្មែរក្រហមចូលមករួមរស់នៅក្នុងសង្គមជាតិនិងសង្គមគ្រួសារវិញ គេមិនត្រឹមតែបានជួបឪពុកម្តាយនិងបងប្អូនសាច់ញាតិប៉ុណ្ណោះទេ ថែមទាំងបានជួបជាមួយអ្នកដែលបានរស់រានមានជីវិតចាកផុតពីរបបខ្មែរក្រហមទៀតផង ដែលកូនចៅនិងឪពុកម្តាយរបស់ជនរងគ្រោះខ្លះនៅតែបាត់ខ្លួន ខ្លះមិនដែលឃើញស្រមោលជារៀងរហូតមក ។ នៅក្នុងស្ថានភាពបែបនេះពិតជាការច្បាស់ណាស់ថាភាពតានតឹងរវាងយុត្តិធម៌និងការពិត គឺជាដំណើរការផ្សះផ្សាដែលមិនអាចចៀសវាងបាន ។

តើធ្វើយ៉ាងដូចម្តេចទើបឲ្យប្រជាជនកម្ពុជាចាកផុតពីភាពប៉ះទង្គិចផ្លូវចិត្តបាន? តើដំណើរការផ្សះផ្សាត្រូវសម្រេចបានដោយរបៀបណាដែលល្អបំផុតនោះ បើឧក្រិដ្ឋកម្មមានលក្ខណៈឃោរឃៅហើយពិបាកនឹងឲ្យអ្នករស់រានមានជីវិតលើកលែងទោសឲ្យនោះ? តើយើងនឹងត្រូវដោះស្រាយយ៉ាងដូចម្តេចចំពោះកំហុសដែលបានកើតឡើង ហើយធ្វើយ៉ាងដូចម្តេចទើបសម្រេចបាននូវយុត្តិធម៌និងជំរុញឲ្យមានសន្តិភាពផងនោះ? ដំណើរការផ្សះផ្សានៅប្រទេសកម្ពុជាពិតជាស្មុគស្មាញណាស់ ។ នៅក្នុងខណៈដែលខ្ញុំកំពុងសរសេរអត្ថបទនេះ យន្តការសន្តិភាពដើម្បីស្វែងរកការពិតនិងយុត្តិធម៌កំពុងតែត្រូវបានពិភាក្សាវែកញែកយ៉ាងក្តៅគគុកដោយសង្គមកម្ពុជានិងអ្នកសិក្សាស្រាវជ្រាវជាន់ខ្ពស់នៅទូទាំងពិភពលោក ។ វិធីដោះស្រាយនីមួយៗសុទ្ធតែបង្កើតនូវភាពតានតឹង ។

*៣) ភាពតានតឹងរវាង ការពិត សន្តិភាព និង យុត្តិធម៌*

មានទស្សនៈពីរផ្សេងគ្នាទាក់ទងនឹងការផ្សះផ្សាប្រកបដោយនិរន្តរភាពនៅក្នុងប្រទេសកម្ពុជា ។ ទស្សនៈទីមួយគឺចង់ឲ្យមានគណៈកម្មការស្វែងរកការពិតដែលជារបស់រដ្ឋាភិបាលកម្ពុជានិងមេដឹកនាំខ្មែរក្រហមដែលនៅរស់ ។ និយាយឲ្យកាន់តែច្បាស់ថែមទៀតនោះគឺគណៈកម្មការនេះ ជារបស់នាយករដ្ឋមន្ត្រី ហ៊ុន សែន ដែលបានស្នើគំនិតនេះឡើងនៅឆ្នាំ១៩៩៦ ។ លោកក៏បានបញ្ជូនគណៈប្រតិភូកម្ពុជាទៅរៀនសូត្រយកបទពិសោធន៍ថែមទៀតសម្រាប់គណៈកម្មការរបស់ខ្លួនកាលពីពេលថ្មីៗនេះ ។ លោកបានហៅវិធីបង្កើតគណៈកម្មការស្វែងរកការពិតថាជាវិធី "ឈ្នះ-ឈ្នះ" ។ សម្តេច ហ៊ុន សែន គូសបញ្ជាក់ថា សន្តិភាពគឺជាបញ្ហាដ៏សំខាន់បំផុតទោះជាដំណោះស្រាយអ្វីក៏មិនត្រូវធ្វើឲ្យប៉ះពាល់ដល់សន្តិភាពនិងស្ថិរភាពបានដែរ ។

យោងតាមទស្សនៈរបស់សម្តេច ហ៊ុន សែន កម្ពុជាគឺជារដ្ឋមួយដែលទើបតែបានងើបផុតពីការបែកបាក់ និងជាសង្គមមួយដែលហែកហួរដោយសង្គ្រាម ដូច្នេះសន្តិភាពនិងការកាត់បន្ថយភាពក្រីក្រគឺជាកិច្ចការអាទិភាព ។ ការបែងចែកច្បាស់លាស់រវាងមានកំហុសនិងគ្មានកំហុស ជនដៃដល់និងជនរងគ្រោះនៃរបបខ្មែរក្រហមគឺមិនសមស្របទេ ហើយវាមិនផ្តល់នូវផលប្រយោជន៍ណាមួយទាល់តែសោះសម្រាប់អតីតកាល បច្ចុប្បន្នកាលនិងអនាគតកាល ។ ទន្ទឹមគ្នានេះ សម្តេច ហ៊ុន សែន ជឿជាក់ថាការកាត់ទោសខ្មែរក្រហម ជាពិសេសអតីតមេដឹកនាំលេខ២ ប្អូន អៀង សារី នឹងបំផ្លាញដល់សន្តិភាពដែលកំពុងមានសព្វថ្ងៃ និងប៉ះពាល់ដល់សង្គមសព្វថ្ងៃដែលងាយនឹងប្រេះស្រាំនៅឡើយ ។ សម្តេចមានប្រសាសន៍ថា "កាត់ទោស អៀង សារី (ខ្មែរក្រហម) នឹងបង្កជាបញ្ហាដល់កម្ពុជា" ។ គឺដោយសារបញ្ហានេះហើយបានជាសម្តេច ហ៊ុន សែន មិនអនុវត្តការដាក់ឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ដោយគំហុកយកតែមែនទែននោះ ។ មេដឹកនាំខ្មែរក្រហមដែលនៅរស់ដូចជា ខៀវ សំផន និង នួន ជា ដែលរស់នៅក្បែរទល់ដែនថៃ ក៏គាំទ្រដល់គំនិតបង្កើតគណៈកម្មការស្វែងរកការពិតដែរ ។ ខៀវ សំផន សន្យាថា ខ្លួនរួមជាមួយនឹងមេដឹកនាំខ្មែរក្រហមដទៃទៀតនឹងរីករាយក្នុងការផ្តល់ជាកសិណទៅលើការសម្លាប់ដែលកើតឡើងនៅចន្លោះឆ្នាំ១៩៧៥-៧៩ ប្រសិនបើគណៈកម្មការ

ស្វែងរកការពិតរបៀបប្រទេសអាហ្វ្រិកខាងត្បូងត្រូវបានបង្កើតឡើង ។ ខៀវ សំផន បន្ថែមទៀតថា «ហើយក៏គ្មានការសងសឹកតទៅទៀតដែរ» ។

ប្រជាជនកម្ពុជាទាំងអស់មិនមែនសុទ្ធតែពេញចិត្តនិងយល់ស្របជាមួយសម្តេច ហ៊ុន សែន និងនយោបាយផ្សះផ្សាជាតិរបស់រដ្ឋាភិបាលកម្ពុជា និងគំនិតចង់បង្កើតគណៈកម្មការស្វែងរកការពិតដើម្បីដោះស្រាយអំពើឃោរឃៅដែលប្រព្រឹត្តដោយខ្មែរក្រហមនោះទេ ។ អ្នកដែលជំទាស់ភាគច្រើនជាអ្នកប្រជាធិបតេយ្យ អ្នកដឹកនាំសង្គមស៊ីវិល ជាពិសេសលោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលបានចងក្រងនិងថែរក្សាប្រវត្តិសាស្ត្រនៃរបបខ្មែរក្រហមដើម្បី «ការចងចាំនិងយុត្តិធម៌» ហើយដែលបានធានាថាមជ្ឈមណ្ឌលឯកសារកម្ពុជាមានឯកសារគ្រប់គ្រាន់សម្រាប់តុលាការដែលនឹងត្រូវបង្កើតឡើងខាងមុខ ដែលឯកសារទាំងនេះទាក់ទងនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិប្រព្រឹត្តឡើងដោយរបបខ្មែរក្រហម ។ បុគ្គលិកដែលធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជាកំពុងតែសុំឲ្យមានយុត្តិធម៌តាមផ្លូវច្បាប់ក្នុងការដោះស្រាយបញ្ហាអំពើឃោរឃៅរបស់ខ្មែរក្រហម ។ និយាយឲ្យកាន់តែប្រត្យក្សជាងនេះទៅទៀតអ្នកទាំងអស់ចង់ឲ្យមានយុត្តិធម៌នៅលើការពិតនិងសន្តិភាព ។ បុគ្គលិកទាំងនេះចង់ឃើញការបង្កើតនូវនីតិរដ្ឋនិងការបញ្ចប់នូវវប្បធម៌និទណ្ឌភាព ព្រោះថានីតិរដ្ឋនិងការបញ្ចប់នូវវប្បធម៌និទណ្ឌភាពគឺជាមូលដ្ឋានសំខាន់សម្រាប់យុត្តិធម៌ ។ កាលណាមានយុត្តិធម៌ហើយសន្តិភាពនឹងមានជាមិនខាន ។

ក្រុមការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជាជឿថា សង្គមសុខសាន្ត គឺសង្គមដែលមានយុត្តិធម៌ ។ សន្តិភាពពិតជាមិនអាចមាននៅកម្ពុជាទេប្រសិនបើយុត្តិធម៌ពិតប្រាកដនៃឧក្រិដ្ឋកម្មប្រព្រឹត្តដោយខ្មែរក្រហមនិងវប្បធម៌និទណ្ឌភាពមិនត្រូវបានកម្ចាត់ចោលនោះ ។ ប្រជាជនកម្ពុជានៅតែព្រួយបារម្ភក្នុងចិត្ត ពីព្រោះរាល់ថ្ងៃគាត់ឃើញអ្នកដែលប្រព្រឹត្តអំពើប្រល័យពូជសាសន៍ធ្វើដំណើរដោយសេរីនៅក្បែរៗខ្លួនរបស់គាត់ ។ ដូច្នេះតុលាការកម្ពុជាត្រូវតែនាំជនដៃដល់ទាំងអស់មកកាត់ទោស ។ លោក ឆាំង យុ បានមានប្រសាសន៍ថា រដ្ឋាភិបាលកម្ពុជាបានផ្តល់រំលំរបបប្រល័យពូជសាសន៍នៅក្នុងដោយសង្គ្រាមមិនមែនផ្តល់រំលំដោយច្បាប់ទេ ។ លោកជឿថា ប្រសិនបើគ្មាននីតិរដ្ឋប្រទេសកម្ពុជាមិនអាចរីកចម្រើនទៅមុខទេ ។ លោកមានប្រសាសន៍ថា «ដើម្បីឲ្យមានសន្តិភាព ដើម្បីឲ្យមានការបង្រួបបង្រួមផ្សះផ្សាជាតិ ការអភិវឌ្ឍន៍ និងស្ថិរភាពពិតប្រាកដ កម្ពុជាត្រូវតែប្រឈមមុខនឹងការពិតនិងរកយុត្តិធម៌...មានតែពេលនោះទេទើបកម្ពុជាលែងវិលវល់នឹងអតីតកាលនិងចាប់ផ្តើមកសាងអនាគតថ្មីមួយ...» ។

លោក ឆាំង យុ ពន្យល់ថាគំនិតគណៈកម្មការស្វែងរកការពិតគឺជាដំណើរការដោះស្រាយទំនាស់ដែលផ្តោតសំខាន់ទៅលើដំណោះស្រាយសម្រាប់រយៈពេលខ្លី ដោះស្រាយព្រឹត្តិការណ៍ដែលមានគ្រោះថ្នាក់ដែលនាំឲ្យមានជម្លោះ ។ សំខាន់ជាងនេះទៅទៀតគណៈកម្មការនេះរិះរកការបញ្ចប់ជម្លោះតាមរយៈវិធីដែលឆាប់និងងាយស្រួល ។ ក៏ប៉ុន្តែទោះជាយ៉ាងណាក៏ដោយលោក ឆាំង យុ មានប្រសាសន៍ថា «វិធីដោះស្រាយតាមរយៈគណៈកម្មការស្វែងរកការពិតមិនមានលក្ខណៈសមស្របសម្រាប់ប្រទេសកម្ពុជាទេ ។ មេដឹកនាំខ្មែរក្រហមដូចជា អៀង សារី, ខៀវ សំផន, នួន ជា និង អៀង ធីរិទ្ធ មិនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ទទួលយកនូវការប្រណីទោសពីគណៈកម្មការស្វែងរកការពិតទេ» ។

មកទល់សព្វថ្ងៃនេះមិនទាន់មានការសិក្សាបែបវិទ្យាសាស្ត្រដែលបញ្ជាក់ឲ្យច្បាស់ថា វិធីណាមួយដែលប្រជាជនកម្ពុជាចង់បានជាងគេនោះទេ មានតែអត្ថបទមួយចំនួនដែលសរសេរដោយអ្នកដឹកនាំសង្គមស៊ីវិលតាមរយៈកាសែតដើម្បីសម្តែងនូវទស្សនៈការយល់ឃើញរបស់ខ្លួន ឬតាមរយៈការពិភាក្សាជាក្រុមតូចៗទៅលើបញ្ហាបង្កើតតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមប៉ុណ្ណោះ ។ នៅពេលខ្ញុំបម្រើការជាអ្នកសិក្សាស្រាវជ្រាវនៅមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានសម្ភាសមនុស្សរាប់រយនាក់អំពីបញ្ហាបង្រួបបង្រួមនិងផ្សះផ្សាជាតិ ។ មុនពេលខ្ញុំចាកចេញពីប្រទេសកម្ពុជាមកសិក្សានៅទីនេះ(សាកលវិទ្យាល័យខាវរទ្រីចក្រភពអង់គ្លេស) ខ្ញុំបានចំណាយពេលពីរខែធ្វើការជាមួយអ្នកស្រុកអ្នកភូមិ៦០០នាក់នៅទូទាំងប្រទេសស្តីអំពីបញ្ហានេះម្តងទៀត ។

លទ្ធផលនៃការសិក្សាបង្ហាញថា វិធីដោះស្រាយតាមរយៈ

សន្តិភាពនិងតាមរយៈយុត្តិធម៌សុទ្ធតែជាដំណោះស្រាយសមហេតុសមផល និងមានលក្ខណៈជាក់ស្តែងនៅក្នុងការបង្រួបបង្រួមផ្សះផ្សាជាតិនៅកម្ពុជា ។ ទស្សនៈដែលអាចទទួលយកនូវផ្លូវកណ្តាលគឺជាវិធីល្អបំផុត ។ ទស្សនៈកណ្តាលនេះសុំឲ្យមានយុត្តិធម៌ ប៉ុន្តែយុត្តិធម៌ក្នុងកម្រិតមួយដែលជាផ្លូវនឹងសន្តិភាព ការទទួលស្គាល់ និងការពិត ។ និយាយឲ្យចំជាងនេះមានន័យថា ទស្សនៈកណ្តាលនេះ គឺប្រហាក់ប្រហែលគ្នានឹងទស្សនៈរកយុត្តិធម៌តាមផ្លូវច្បាប់ និងការពិត ។ ទស្សនៈនេះមានលក្ខណៈប្រហាក់ប្រហែលគ្នាទៅនឹងទស្សនៈរកយុត្តិធម៌តាមផ្លូវច្បាប់នៅត្រង់ថា មេដឹកនាំខ្មែរក្រហមនឹងត្រូវតែប្រឈមមុខនឹងការជម្រះក្តីនៅចំពោះមុខតុលាការ ។ ចំណែកឯទស្សនៈដែលខុសពីទស្សនៈរកយុត្តិធម៌តាមផ្លូវច្បាប់គឺត្រង់ថា តុលាការនឹងមិនវិនិច្ឆ័យទោសកម្មាភិបាលខ្មែរក្រហមទាំងអស់នោះទេ ។ ទន្ទឹមគ្នានេះដែរ ទស្សនៈទទួលយកផ្លូវកណ្តាល គឺប្រហាក់ប្រហែលគ្នានឹងគណៈកម្មាធិការស្វែងរកការពិតនៅត្រង់ថា កម្មាភិបាលខ្មែរក្រហមថ្នាក់ក្រោមមកឆ្លើយសារភាពអំពីកំហុសរបស់ខ្លួន រួចហើយសុំការប្រណីទោស ។ ប៉ុន្តែ ការឆ្លើយសារភាពនិងការប្រណីទោសមិនមែនសម្រាប់មេដឹកនាំខ្មែរក្រហមធំៗនោះទេ ។

អ្នកគាំទ្រទស្សនៈបែបនេះភាគច្រើនគឺជាអ្នកដែលមានវាសនារស់រានមានជីវិតពីរបបខ្មែរក្រហមដែលរស់នៅតាមជនបទ និងបាត់បង់សមាជិកគ្រួសារព្រមទាំងបាត់កូនដែលបានចូលបម្រើក្នុងជួរបដិវត្តន៍របស់ខ្មែរក្រហម ។ បងប្អូនអ៊ំពូមីងទាំងនោះជាពុទ្ធសាសនិកដែលជឿលើ "កម្មនិងផល" ហើយគាត់គាំទ្រទស្សនៈផ្លូវកណ្តាលរបស់ព្រះសម្មាសម្ពុទ្ធក្នុងការដោះស្រាយទំនាស់ ។

ព្រះសុមេធាធិបតី ទេព វង្ស សម្តេចព្រះសង្ឃរាជគណៈមហានិកាយនៃព្រះរាជាណាចក្រកម្ពុជាមានសង្ឃដីកាពន្យល់ថា ការជ្រើសរើសផ្លូវកណ្តាលគឺជាការលើកទឹកចិត្តឲ្យបញ្ឈប់ការចងពៀរមិនចេះចប់មិនចេះហើយ ។ សម្តេចព្រះសង្ឃរាជបានលើកជាឧទាហរណ៍ថា ការវិនិច្ឆ័យត្រូវតែធ្វើឡើងដោយមានយុត្តិធម៌ផង ។ "មេដឹកនាំខ្មែរក្រហមគួរតែត្រូវផ្តន្ទាទោសទៅតាមកំហុសដែលខ្លួនបានប្រព្រឹត្ត ។ ប៉ុន្តែមិនត្រូវបំភិតបំភ័យអ្នកដទៃទៀត ឬបង្ខំជនស្លូតត្រង់ឲ្យទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នោះទេ" ។ ព្រះភិក្ខុ យស ហ៊ុត ខេមចារោសុំឲ្យមានការ "និរទោស"សម្រាប់ជាការផ្តន្ទាទោសមេដឹកនាំខ្មែរក្រហម ។ ព្រះភិក្ខុមានសង្ឃដីកាបញ្ជាក់ថា "យើងមើលរឿងព្រះវេស្សន្តរ ត្រូវប្រជារាស្ត្រនិរទេសឲ្យទៅរស់នៅក្នុងព្រៃ ដោយសារព្រះអង្គបានដាក់ទានដំរីនាគដេន្រ្ទទៅឲ្យនគរផ្សេង គឺព្រះអង្គធ្វើដុយនឹងឆន្ទៈរបស់រាស្ត្រ ប៉ុន្តែមួយរយៈក្រោយព្រះអង្គត្រូវបានយាងឲ្យត្រឡប់មកវិញ ។ ដូច្នេះការសងសឹកអត់មានចំណេញទេ ។ សំខាន់យើងចង់ដឹងការពិតចង់ឲ្យមានការទទួលខុសត្រូវដើម្បីជាមេរៀនដល់អ្នកដទៃកុំធ្វើដូច្នោះទៀត" ។

ទស្សនៈអំពីផ្លូវកណ្តាលគឺ វាទូទៅទៅហើយសម្រាប់អ្នកកាន់ព្រះពុទ្ធសាសនា ជាពិសេសប្រជាជនកម្ពុជាតែម្តង ។ តាមន័យច្បាប់ទស្សនៈផ្លូវកណ្តាល វេនឌី ឡេមប៊ិន បានឲ្យយោបល់ថា "យុត្តិធម៌គ្រាន់តែជានិមិត្តរូប"ប៉ុណ្ណោះ ។ នៅក្នុងសំណេររបស់វេនឌី ដែលមានចំណងជើងថា "យុត្តិធម៌និងការបង្រួបបង្រួមផ្សះផ្សាជាតិៈ ការកសាងសន្តិភាពក្រោយពេលមានជម្លោះនៅក្នុងប្រទេសកម្ពុជានិងរ៉ាន់ដា" អ្នកស្រីបានពន្យល់ថា យុត្តិធម៌គ្រាន់តែនិមិត្តរូបដែលមានការខុសប្លែកពី "យុត្តិធម៌ពិតប្រាកដ ឬយុត្តិធម៌សគ្គម" អាចសម្រេចទៅបានលុះត្រាណាតែជនរងគ្រោះដឹងថា អ្នកណាបានធ្វើអ្វីខ្លះមកលើអ្នកដែលខ្លួនស្រលាញ់ ។ ជាមួយគ្នានេះដែរ សហគមន៍និងជនដែលទទួលស្គាល់ភាពអយុត្តិធម៌ដែលខ្លួនបានឆ្លងកាត់ ចំណែកឯជនដែលសម្តែងការសោកស្តាយចំពោះកំហុសដែលខ្លួនបានធ្វើ ទោះជាគ្មាន "យុត្តិធម៌ពិតប្រាកដ ឬយុត្តិធម៌តាមបែបសំណងការខាតបង់" ក៏ដោយ ។

ដើម្បីឈានទៅសម្រេចបាននូវយុត្តិធម៌គ្រាន់តែជានិមិត្តរូប កម្ពុជាត្រូវតែវិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យនិងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងអំឡុងថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ការកាត់ទោសមេដឹកនាំខ្មែរក្រហមមិនត្រឹមតែជាព្រានវ៉ាយសំពងយ៉ាងដំណំទៅលើនិទណ្ឌភាពប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងជាការចាប់ផ្តើមដ៏ប្រពៃក្នុងការកសាងនីតិរដ្ឋនៅកម្ពុជាផង ។ ការជំនុំជម្រះក្តីនឹងផ្តល់នូវការធូរស្បើយក្នុងអារម្មណ៍ចំពោះជនរងគ្រោះ

ខ្មែរក្រហមមួយចំនួនធំ ហើយលាតត្រដាងព័ត៌មានជាច្រើនឲ្យសាធារណជនដឹងអំពីការប្រល័យពូជសាសន៍ជាព័ត៌មានដែលប្រជាជនមិនបានដឹងពីមុនមក ។ ការទទួលបានផ្សេងៗទៀតដែលអាចជាលទ្ធផលចេញពីតុលាការនេះអាចជាការធូរស្បើយខាងផ្លូវចិត្តសាស្ត្រចំពោះអ្នកដែលកំពុងតែរងការឈឺចាប់អំពីការប្រល័យពូជសាសន៍ ។ ប្រការនេះនឹងក្លាយទៅជាករណីដែលថាការពិតអាចធ្វើឲ្យជនរងគ្រោះមានសេរីភាពផុតទុក្ខកង្វល់ ហើយចាប់ផ្តើមកសាងជីវិតនៅក្នុងសហគមន៍ដ៏សុខដុមរមនា ។

ក្រោយពីតុលាការរកឃើញថាមានកំហុស ឧក្រិដ្ឋជនត្រូវតែសុំការអភ័យទោស ហើយប្រជាជនត្រូវតែអត់ឱនឲ្យតាមរយៈការមិនយកទៅដាក់ពន្ធនាគារ ប៉ុន្តែត្រឹមតែដាក់ឃុំនៅក្នុងផ្ទះ ។ ការសុំខមាទោសជាសាធារណៈនឹងធ្វើឲ្យមានការទទួលយកផលនៃការរំលោភនានា ហើយធ្វើឲ្យជនរងគ្រោះមានឱកាសមានសេរីភាពដើរទៅមុខក្នុងន័យថា ភាពអយុត្តិធម៌ដែលកើតឡើងចំពោះខ្លួនត្រូវបានទទួលស្គាល់ហើយ ចំណែកឯកូនចៅ ឬឪពុកម្តាយរបស់ជនរងគ្រោះដែលបានបាត់បង់ទៅត្រូវបានទទួលស្គាល់និងយកមកឲ្យពិចារណា ។ គួរឲ្យចាប់អារម្មណ៍ជាងនេះទៅទៀត ការទទួលស្គាល់នេះនឹងធ្វើឲ្យអ្នកស្រុក អ្នកភូមិ អភ័យទោសឲ្យកម្មាភិបាលថ្នាក់ក្រោមនិងរួមរស់ជាមួយគ្នានៅក្នុងមូលដ្ឋានរបស់ខ្លួន ។

តាមវិធីនេះយុត្តិធម៌ដែលគ្រាន់តែជានិមិត្តរូបបង្កើតបានជាកន្លែងមួយផ្តល់នូវយុត្តិធម៌ ប្រសព្វគ្នាជាមួយនឹងសន្តិភាព ហើយពេលវេលាសុំខមាទោសប្រសព្វគ្នាជាមួយការប្រោសប្រណីតាមរយៈការយល់ព្រមនឹងគ្នាទៅលើភាពយុត្តិធម៌ក្នុងកម្រិតណាមួយដើម្បីបម្រើផលប្រយោជន៍ សន្តិភាព និងសន្តិសុខ ។

## សេចក្តីសន្និដ្ឋាន

ដើម្បីសម្រេចលទ្ធផលល្អបំផុត ការជ្រើសរើសយកយន្តការផ្សះផ្សានៅកម្ពុជាត្រូវតែផ្អែកទៅលើតម្រូវការចាំបាច់របស់អ្នកដែលមានវាសនារស់រានមានជីវិតចាកផុតពីរបបខ្មែរក្រហម និងទស្សនៈវិស័យទៅលើអនាគតរបស់កម្ពុជាជាជាងផ្អែកលើកាលានុវត្តន៍ និងអាទិភាពនយោបាយ ។ មានអ្នកខ្លះចង់បានយុត្តិធម៌តាមផ្លូវច្បាប់ អ្នកខ្លះទៀតចង់បានដំណើរសុំខមាទោសជាសាធារណៈនិងការប្រណីទោស ចំណែកឯអ្នកផ្សេងទៀតចង់បានការដាក់ទណ្ឌកម្ម ឬការកាត់ទោស ។ ដូច្នេះ ការផ្សះផ្សាចាំបាច់ត្រូវតែពិចារណាទៅលើភាពចាំបាច់ទាំងអស់នេះដូចដែល អ្នកស្រី វេនឌី លើកឡើងថា “ដំណើរការផ្សះផ្សាដែលមានន័យទូលំទូលាយចាំបាច់ត្រូវគិតគូរពិចារណាទៅលើភាពចាំបាច់ទាំងនេះ” ។ ខ្ញុំពិតជាគាំទ្រដល់ដំណើរការផ្សះផ្សាដែលយកកត្តាទាំងអស់នេះចេញពីភាគីទាំងអស់ទៅគិតពិចារណា ពីព្រោះដំណើរការផ្សះផ្សាមិនត្រឹមតែមានគោលបំណងធ្វើឲ្យភាគីទាំងអស់នៅក្នុងជម្លោះយល់ស្របគ្នា និងចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការស្វែងរកដំណោះស្រាយប៉ុណ្ណោះទេ ប៉ុន្តែគឺសំដៅកសាងទំនាក់ទំនងថ្មីក្រោយពីមានជម្លោះថែមទៀត ។

ទាំងយុត្តិធម៌តាមផ្លូវច្បាប់ ទាំងសន្តិភាព គឺមិនមែនជាដំណោះស្រាយដ៏ល្អសម្រាប់អនាគតនៃការផ្សះផ្សានៅកម្ពុជាទេ ។ ចាំបាច់ត្រូវធ្វើឲ្យស៊ីគ្នារវាងយុត្តិធម៌តាមផ្លូវច្បាប់និងសន្តិភាព ។ ដូចដែលការសិក្សាស្រាវជ្រាវរបស់ខ្ញុំបានបង្ហាញស្រាប់ មានតែយុត្តិធម៌ជានិមិត្តរូបទេ ទើបអាចសម្រេចទៅបាន ។ ប្រសិនបើដើម្បីផលប្រយោជន៍សង្គមកម្ពុជានិងប្រជាជនកម្ពុជា ដូច្នេះសំឡេងរបស់ប្រជាជនកម្ពុជាត្រូវតែស្តាប់ឮនិងយកទៅពិចារណា ។ និយាយម្យ៉ាងទៀត ដំណោះស្រាយតាមយុត្តិធម៌គ្រាន់តែជានិមិត្តរូបត្រូវតែបានពិចារណានៅក្នុងដំណើរការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ពីព្រោះប្រការនេះនឹងធ្វើឲ្យភាគីទាំងអស់មានឆន្ទៈចង់ចូលមកធ្វើការជាមួយគ្នា ។ ក្រៅពីនោះ យុត្តិធម៌មិនត្រឹមតែជានិមិត្តរូបដែលធ្វើឲ្យអ្នកនៅរស់ចាកផុតពីរបបខ្មែរក្រហម(ទាំងជនរងគ្រោះនិងជនដៃដល់) មានភាពសម្បូណ៌សប្បាយរស់នៅក្នុងភូមិជាមួយគ្នាយ៉ាងសុខសាន្តប៉ុណ្ណោះទេ ថែមទាំងពង្រឹងបន្ថែមនូវទស្សនាទានរបស់ព្រះពុទ្ធសាសនានៅក្នុងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជាទៀតផង ។ វិធីនេះនឹងធ្វើឲ្យព្រះពុទ្ធទ្រង់រីករាយ ក្នុងន័យថាគំរូរបស់ព្រះអង្គត្រូវបានយកមកអនុវត្ត ដើម្បីជួយឲ្យពុទ្ធបរិស័ទចាកផុតពីការមួហ្មង អំពើហិង្សា និងការសម្លាប់ ដើម្បីឈានទៅរួមរស់នៅក្នុងសុខសន្តិភាព និងភាពសុខដុមរមនា ។

**អៀ ម៉េងទ្រី**

# កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិនិងកម្ពុជា

អង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាបានឈានដល់កិច្ចព្រមព្រៀងមួយមុននឹងឈានទៅបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃរបបកម្ពុជាប្រជាធិបតេយ្យ។ កិច្ចព្រមព្រៀងជាប្រវត្តិសាស្ត្រនេះធ្វើឡើងនៅទីក្រុងភ្នំពេញ ចាប់ពីថ្ងៃទី១៣ដល់១៧ ខែមីនា ឆ្នាំ២០០៣ រវាងលោកអគ្គលេខាធិការរងអង្គការសហប្រជាជាតិ ហេន កូរែល និងឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធានក្រុមការងារសម្រាប់សហប្រតិបត្តិការជាមួយអ្នកជំនាញការច្បាប់បរទេសនិងការរៀបចំដំណើរការកាត់ទោសមេដឹកនាំខ្មែរក្រហម។

ការចម្លុះភាពទ័លច្រកដែលមតិភាគច្រើនមិនដែលរំពឹងថានឹងអាចកើតមានឡើងនោះគឺជាលទ្ធផលនៃការចរចាចំនួន១១លើក និងប្រើរយៈពេលជាងប្រាំឆ្នាំគិតចាប់ពីឆ្នាំ១៩៩៧-៩៨មកដល់ឆ្នាំ២០០៣ ហើយកិច្ចចរចាគំហុកចុងក្រោយនេះគឺធ្វើឡើងតាមសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិដែលផ្តល់អាណត្តិដល់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិបន្តការចរចាក្រោយពេលអង្គការសហប្រជាជាតិបានដកថយនៅខែកុម្ភៈ ឆ្នាំ២០០២។

សេចក្តីព្រាងថ្មីនេះមាន៣២មាត្រា ហើយទទួលស្គាល់យុត្តាធិការទៅលើសាច់រឿងដែលជាប់វិវាទនិងយុត្តាធិការទៅលើរូបបុគ្គលដូចដែលចែងនៅក្នុងច្បាប់ស្តីអំពី "ការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ដែលមាន១៨ជំពូក និង៤៨មាត្រា។ សេចក្តីព្រាងកិច្ចព្រមព្រៀងនេះគ្រប់គ្រងតាមច្បាប់ទៅលើកិច្ចសហប្រតិបត្តិការរវាងអង្គការសហប្រជាជាតិនិងរាជរដ្ឋាភិបាលកម្ពុជាក្នុងការជំនុំជម្រះក្តីមេដឹកនាំខ្មែរក្រហម រួមទាំងបញ្ហាបច្ចេកទេស រដ្ឋបាល ការស៊ើបអង្កេត ការតែងតាំង ការប្រើភាសាក្នុងតុលាការ ការលើកលែងទោស ការរកដំណោះស្រាយនៅពេលគ្មានមតិឯកច្ឆន្ទក្នុងការសម្រេចចិត្ត ជាពិសេសបញ្ហាថវិកានិងជំនួយផ្សេងៗរបស់អង្គការសហប្រជាជាតិផង។ បញ្ហាសំខាន់មួយទៀតគឺ នៅមាត្រា២៨ដែលចែងពីការរក្សាសិទ្ធិដកថយពីដំណើរការជំនុំជម្រះ ប្រសិនបើមានបញ្ហាបច្ចេកទេសផ្លាស់ប្តូររចនាសម្ព័ន្ធគ្រប់គ្រងដែលអង្គការសហប្រជាជាតិយល់ថានឹងប្រាសចាកពីកិច្ចព្រមព្រៀងនេះ។ "ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជាធ្វើការផ្លាស់ប្តូររចនាសម្ព័ន្ធ ឬអង្គការលេខនៃអង្គជំនុំជម្រះវិសាមញ្ញ ឬធ្វើអ្វីផ្សេងពីនេះដែលជាហេតុបង្កឲ្យអង្គជំនុំជម្រះមិនអាចធ្វើបំពេញតួនាទីទៅតាមកិច្ចព្រមព្រៀង បច្ចុប្បន្ននេះអង្គការសហប្រជាជាតិរក្សាសិទ្ធិឈប់ផ្តល់ជំនួយ ទោះជំនួយជាថវិកា ឬជំនួយផ្សេងៗទៀតដូចដែលមានចែងក្នុងកិច្ចព្រមព្រៀងនេះ"។ ចំណុចសំខាន់ចុងក្រោយមួយទៀតគឺ ការបញ្ជាក់បន្ថែមនូវមាត្រា២៦និង២៧នៃអនុសញ្ញាទីក្រុងវីយែន ស្តីអំពីច្បាប់នៃសន្ធិសញ្ញា។ តាមខ្លឹមសារនៃមាត្រាទាំងពីរនេះគឺថា រាល់សន្ធិសញ្ញាដែលនៅជាធរមានគឺតម្រូវឲ្យភាគីនៃសន្ធិសញ្ញាត្រូវតែអនុវត្តដោយសុទ្ធចិត្ត ហើយភាគីនោះមិនត្រូវអនុវត្តបទបញ្ញត្តិក្នុងស្រុក ដោយលើកហេតុផលថាខ្លួនមិនអាចអនុវត្តតាមបទបញ្ញត្តិនៅក្នុងអនុសញ្ញាអន្តរជាតិបានទេ។ កម្ពុជាបានក្លាយជាភាគីហត្ថលេខីនៃអនុសញ្ញាទីក្រុងវីយែន នាថ្ងៃទី៤ ខែកញ្ញា ឆ្នាំ១៩៦៩។ បទបញ្ញត្តិជាច្រើននៃអនុសញ្ញានេះត្រូវបានទទួលស្គាល់ថាបង្កើតបានជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ។

សេចក្តីព្រាងកិច្ចព្រមព្រៀងនេះនឹងត្រូវអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិនិងសភាជាតិកម្ពុជា មុនពេលចាប់ផ្តើមដំណើរការអង្គជំនុំជម្រះក្តីវិសាមញ្ញនេះ។ មេដឹកនាំខ្មែរក្រហមដែលនៅរស់មានដូចជា នួន ជា, ខៀវ សំផន, អៀង សារី, តាម៉ុក និង ឌុច ។

**សួ ប៊ុនស៊ី**

# នៅតែមិនអស់ចិត្ត




តាំងពីខ្ញុំដឹងក្តីមក ខ្ញុំមិនដែលបានឃើញជីដូនជីតារបស់ខ្ញុំទេ ។ ខ្ញុំឃើញតែម៉ាក់និងប៉ារបស់ខ្ញុំតែប៉ុណ្ណោះ ។ ក្រុមគ្រួសាររបស់ខ្ញុំរស់នៅក្នុងទីរួមស្រុកស្វាយស៊ីសុផុន ខេត្តបាត់ដំបង (បច្ចុប្បន្នខេត្តបន្ទាយមានជ័យ) ។ គាត់ទាំងពីរគឺជាអាជីវករលក់ដូរនៅក្នុងទីរួមខេត្តនេះ ។ គាត់ទាំងពីរត្រូវដើបទៅផ្សារតាំងពីព្រលឹមទល់ព្រលប់ទើបត្រឡប់មកផ្ទះវិញ ។ ហេតុដូចនេះខ្ញុំនិងបងប្អូនស្រីបីនាក់ត្រូវតែមានជំហររឹងមាំក្នុងការមើលថែរក្សាគ្នាទៅវិញទៅមក ។ នៅក្នុងអំឡុងឆ្នាំ១៩៨០ ស្ថានភាពស្រុកទេសមិនទាន់មានស្ថិរភាពនៅឡើយ ។ ឆ្នាំនោះខ្ញុំរៀនថ្នាក់ដំបូង ហើយបន្ទប់រៀននីមួយៗមិនទាន់មានតុកៅអីទេ ខ្ញុំនិងមិត្តរួមថ្នាក់ត្រូវយកក្រណាត់កៅស៊ូមួយផ្ទាំង(ល្មមអាចអង្គុយបាន) ដើម្បីក្រាលអង្គុយរៀន ។ ដោយសារមានការរំខានរបស់ពួកខ្មែរក្រហមនិងពួកទ័ពព្រៃធ្វើឲ្យការសិក្សារបស់ខ្ញុំត្រូវអាក់ខានជាញឹកញាយ ។ ស្ទើរតែរាល់ថ្ងៃមិនថាថ្ងៃឬយប់ខ្ញុំតែងតែឮស្នូរកាំភ្លើងប្រយុទ្ធគ្នារវាងកងទ័ពខ្មែរក្រហមនិងកងទ័ពរបស់រដ្ឋា-ភិបាលនៅតាមស្រុកឆ្ងាយៗ ។ ជួនកាលគ្រាប់ទាំងនោះបានហោះមកធ្លាក់នៅកណ្តាលទីរួមស្រុកបណ្តាលឲ្យមនុស្សដែលកំពុងដើរឬអង្គុយនៅផ្ទះស្លាប់ឬត្រូវរបួសក៏មាន ។ ម៉ាក់ត្រឡប់មកពីផ្សារហើយរូតរះដាំស្ល ដើម្បីឲ្យកូនៗញាំឲ្យបានទាន់ពេលវេលា ខ្លាចក្រែងកងទ័ពខ្មែរក្រហមវាយប្រហារចូលមក ធ្វើឲ្យពួកយើងរត់ចូលលេណដ្ឋានទាំងពោះទទេ ។ ខ្ញុំនៅចាំបានថា មានយប់មួយពួកខ្មែរក្រហមបានបាញ់ផ្លោងគ្រាប់បែកជាច្រើនគ្រាប់ ហើយសម្រុកចូលមកដុតផ្សារដែលនៅក្បែរផ្ទះរបស់ខ្ញុំ ។ ខ្មែរក្រហមស្រែកហ៊ោកញ្ជ្រៀវពីជ័យជម្នះរបស់ខ្លួនពេញផ្សារ ក្នុងខណៈដែលប្រជាជនកម្ពុជាកំពុងពួនសម្ងំនៅក្នុងលេណដ្ឋាន ។ នៅពេលណាដែលប្រធានភូមិប្រាប់ថានឹងមានហេតុការណ៍កើតឡើង នៅយប់នោះក្រុមគ្រួសារខ្ញុំនិងគ្រួសារដទៃទៀតមិនហ៊ានដេកនៅក្នុងផ្ទះទេ គឺមកដេកនៅក្បែរលេណដ្ឋាន ។

មុនពេលព្រលប់ខ្ញុំត្រូវយកចង្កៀងចូលទៅត្រួតពិនិត្យ ឬយកសំបកក្រូចដុតបង្ហុយនៅក្នុងលេណដ្ឋានដើម្បីការពារសត្វល្អិតដែលសម្ងំនៅក្នុងនោះ ។ រាល់ពេលដែលហេតុការណ៍កើតឡើងនៅក្នុងលេណដ្ឋានខ្ញុំតែងតែសួរម៉ាក់ប៉ាថា ពួកណាជាអ្នកបាញ់ផ្លោង? ពួកវាមកពីណា? គាត់ទាំងពីរបានប្រាប់ថា ពួកខ្មែរក្រហមជាពួកព្រៃ កាលណោះខ្ញុំមិនដឹងថា "ខ្មែរក្រហម" ជាមនុស្សប្រភេទណានោះទេ ។ អស់រយៈពេលជាង១០ឆ្នាំ វាស៊ាំទៅហើយសម្រាប់ក្រុមគ្រួសាររបស់ខ្ញុំក្នុងការរស់នៅក្នុងតំបន់អសន្តិសុខ ។ ទោះបីជាមានសេចក្តីអំពាវនាវរបស់រដ្ឋាភិបាលសុំឲ្យពួកខ្មែរក្រហមឬកងទ័ពព្រៃចុះចូលដើម្បីរួបរួមខ្មែរតែមួយក៏ដោយ ក៏ខ្ញុំនៅតែឮសំឡេងគ្រាប់ទាំងយប់ទាំងថ្ងៃនៅឯជាយទីរួមខេត្តជានិច្ច ។ ប្រហែលជាឆ្នាំ១៩៨៨-៨៩ នៅវេលាយប់រំលងអធ្រាត្រពួកខ្មែរក្រហមមួយក្រុមបានចូលមកដុតឃ្លាំងផ្ទុកគ្រាប់នៅក្បែរសាលារៀនខ្ញុំបណ្តាលឲ្យអគាររោងជាងដែលនៅក្បែរនោះត្រូវខូចខាតនិងអគារសិក្សាខ្លះត្រូវធ្លុះដំបូលដោយអន្ទើ ។ ព្រឹត្តិការណ៍នៅយប់នោះប៉ាគិតថាសង្គ្រាមកើតមានម្តងទៀតហើយ ចំណែកនៅក្នុងផ្ទះរបស់ខ្ញុំកញ្ចក់និងរបស់របរដែលនៅលើធ្នើរនិងព្យួរនៅជញ្ជាំងផ្ទះត្រូវធ្លាក់មកក្រោមទាំងអស់ ។ ប៉ាបានកន្ត្រាក់ដៃខ្ញុំឲ្យភ្ញាក់ពីដេកដើម្បីរត់ចូលលេណដ្ឋានឲ្យទាន់ ។ គ្រាប់កាំភ្លើងបានហោះកាត់កន្លែងដែលក្រុមគ្រួសារខ្ញុំឆ្លងកាត់ ប៉ុន្តែសំណាងល្អក្រុមគ្រួសាររបស់ខ្ញុំពុំមាននរណាម្នាក់គ្រោះថ្នាក់ទេ ។ ម៉ាក់និងប៉ាភ័យខ្លាចជាងពេលណាៗទាំងអស់ ។

ដើម្បីសុវត្ថិភាពនិងអនាគតកូនៗ នៅឆ្នាំ១៩៩០ ម៉ាក់និងប៉ាបានសម្រេចចិត្តមករស់នៅទីក្រុងភ្នំពេញវិញ ។ ខ្ញុំនិងបងប្អូនរបស់ខ្ញុំក៏បានមកបន្តការសិក្សាទាំងពាក់កណ្តាលឆ្នាំនៅវិទ្យាល័យសន្ធរម៉ុក ។ នៅអនុវិទ្យាល័យ ខ្ញុំបានសិក្សាមេរៀនអំពីបនប្រល័យពូជសាសន៍ ដែលមាននៅក្នុងសៀវភៅរៀនអាននិងរូបភាពអំពើ

ព្រៃផ្សៃនិងបទឧក្រិដ្ឋរបស់ពួកខ្មែរក្រហមមកលើប្រជាជន ។ ប៉ុន្តែខ្ញុំមិនទាន់បានគិតអំពីប្រភពរបស់ខ្មែរក្រហមកើតមកពីទីណាឡើយ ។ ខ្ញុំគ្រាន់តែដឹងសើៗនិងទន្ទេញមេរៀនទាំងនោះឲ្យចាំមាត់ដើម្បីទទួលបានពិន្ទុល្អតែប៉ុណ្ណោះ ។ "ខ្មែរក្រហម" ស្ទើរតែរសាយអស់ពីអារម្មណ៍របស់ខ្ញុំបាត់ទៅហើយ ខ្ញុំមិនដែលនឹកឃើញពីសកម្មភាពរបស់ខ្មែរក្រហមទៀតទេ ។

បន្ទាប់ពីពេលដែលខ្ញុំបានមកធ្វើការនៅមជ្ឈមណ្ឌលឯកសារកម្ពុជា"ខ្មែរក្រហម"បានរស់ក្នុងអារម្មណ៍ខ្ញុំឡើងវិញ ។ ខ្មែរក្រហមគឺជាសសរទ្រូងរបស់របបកម្ពុជាប្រជាធិបតេយ្យ ដែលគ្រប់គ្រងដោយ ប៉ុល ពត, អៀង សារី, ខៀវ សំផន និងមេដឹកនាំមួយចំនួនទៀត ហើយខ្មែរក្រហមក៏ជាអ្នកបំផ្លាញសសរគ្រឹះប្រទេសកម្ពុជាដែរ ។ មជ្ឈមណ្ឌលបានតម្រូវឲ្យបុគ្គលិកម្នាក់ៗសរសេរអត្ថបទអំពីការរងចាំរបស់ខ្លួននៅថ្ងៃ១៧ មេសា ១៩៧៥ ។ ខ្ញុំអាចសរសេររឿងទាំងនេះបានតាមតែការអធិប្បាយរបស់ម៉ាក់និងប៉ាប៉ុណ្ណោះ ។

មុនរបបសាធារណរដ្ឋខ្មែរដួលរលំបន្តិច ក្រុមគ្រួសាររបស់ខ្ញុំបានចាកចេញពីភ្នំពេញទៅរស់នៅស្រុកស្វាយស៊ីសុផុន ខេត្តបាត់ដំបង ដើម្បីគេចឲ្យផុតពីការចាប់ទាហានរបស់របប លន់ ណុល ។ មិនទាន់បាន២ឆ្នាំផងរបបខ្មែរក្រហមបានចូលមកដល់ ។

ខែមេសា ឆ្នាំ១៩៧៥ បន្ទាប់ពីពិធីបុណ្យចូលឆ្នាំបានរំលងផុត២ថ្ងៃ កងទ័ពខ្មែរក្រហមដែលមានឯកសណ្ឋានពណ៌ខ្មៅបង់កក្រមាក្រហមបាននាំចូលមករាំច្រៀងជាមួយប្រជាជនក្នុងពិធីបុណ្យឆ្លងព្រះវិហារមួយ ។ ស្អែកឡើងខ្មែរក្រហមបានចូលពាសពេញទីរួមស្រុកស្វាយស៊ីសុផុន ហើយបានប្រកាសជាបន្ទាន់ហៅមន្ត្រី ទាហានធំៗ អ្នកមានស័ក្តិយសគ្រប់ជាន់ថ្នាក់ទាំងអស់និងកងទ័ពមកចូលរួមប្រជុំនៅបន្ទាយស៊ុប (ផ្សារបន្ទាយមានជ័យ) ហើយទុកអាវុធនៅទីនោះ ។ ក្រោយមកអាវុធទាំងនោះត្រូវពួកខ្មែរក្រហមដឹកយកទៅបាត់អស់មិនដឹងយកទៅទីណាឡើយ ។

ប្រហែលជាម៉ោង៩ទៅម៉ោង១០យប់ រថយន្តហ្ស៊ីបមួយគ្រឿងដែលមានដាក់មេក្រូនៅពីលើបានបើកពាសពេញផ្លូវប្រកាសខ្លាំងៗថា"ប្រជាជនទាំងអស់ត្រូវចូលរួមប្រជុំដើម្បីដោះស្រាយ" ។ កងទ័ពខ្មែរក្រហមបានស្រែកប្រកាសឲ្យប្រជាជនចូលរួមស្តាប់ការប្រជុំនៅសាលាបឋមសិក្សាស៊ីសុផុននៅវេលាថ្ងៃស្អែក ។ ប៉ានិងអ្នកភូមិបានទៅកាន់កន្លែងប្រជុំតាំងពីម៉ោង៦ព្រឹក អង្គុយចាំរហូតដល់ថ្ងៃត្រង់ ទើបឃើញរថយន្តមួយគ្រឿងបើកចូលមក ។ ក្នុងរថយន្តនោះមានតែមនុស្សពីរនាក់ គឺអ្នកបើកបរម្នាក់និងកម្មាភិបាលម្នាក់ ។ កម្មាភិបាលម្នាក់នោះសម្តែងទឹកមុខមាំ ហើយស្រែកតាមមេក្រូយ៉ាងខ្លីថា "អង្គការចាត់តាំងមកថា ឲ្យបងប្អូនចាកចេញពីទីប្រជុំជនទៅនៅជនបទដើម្បីបង្កបង្កើនផល" និយាយតែប៉ុណ្ណឹង ក៏បត់ក្បាលរថយន្តត្រឡប់ទៅក្រោយវិញ ។ ពេលនោះប្រជាជនស្រឡាំងកាំងគ្រប់គ្នា ។

កងទ័ពអាវខ្មៅ ហៅថាខ្មែរក្រហមដែលមានទឹកមុខគួរឲ្យខ្លាច ប្រដាប់ដោយអាវុធគ្រប់ដៃកំពុងឈរយាមល្បាតតាមផ្លូវព្រោងព្រាតស្រែកបង្ខំឲ្យប្រជាជនចាកចេញឲ្យផុតពីទីប្រជុំជនក្នុងអំឡុងពេលបីថ្ងៃដើម្បីសម្អាតទីក្រុង ។ ប្រជាជនភាគច្រើនពុំបានគិតវែងឆ្ងាយ ព្រោះយល់ថាចេញតែបីថ្ងៃ និងថាកម្ពុជាសន្តិភាពហើយទើបមិនបានប្រមូលអីវ៉ាន់យកទៅតាមខ្លួនឲ្យបានច្រើន ។ ក្រុមគ្រួសាររបស់ខ្ញុំបានកំពុងធ្វើដំណើររំកិលសន្សឹមកណ្តាលហ្វូងមនុស្ស ខ្លះធ្វើដំណើរដោយម៉ូតូ រទេះគោ កង់និងទេះដឹកដែលរុញដោយកម្លាំងមនុស្សតាមផ្លូវឆ្ពោះទៅសៀមរាប ។ នៅតាមផ្លូវមានភាពរញ៉េរញ៉ៃខ្លាំងណាស់ សំឡេងស្រែករបស់កុមារតូចៗនិងសំឡេងស្រែកហៅប្អូនដែលកំពុងវង្វេងក្នុងហ្វូងមនុស្សធ្វើឲ្យទ្រហឹងអឺងអាប់ ។ អ្នកខ្លះធ្វើដំណើរទៅតាមផ្លូវខេត្តបាត់ដំបង ខ្លះទៅតាមផ្លូវអូរជ្រៅ ។ ប៉ាបានប្រាប់ខ្ញុំថា ពេលកំពុងជម្លៀសចេញនោះប្រហែលជាម៉ោង១២ថ្ងៃត្រង់ ហើយចំខែចេត្រទៀត អាកាសធាតុក្តៅហួតហែង តាមផ្លូវគ្មានទឹកគ្រប់គ្រាន់សម្រាប់បំពេញសេចក្តីស្រេកឃ្លានទេ ។ មនុស្សម្នាធ្វើដំណើរទាំងញើសហូររហាម ខ្លះស្ពាយបង្វេច ខ្លះបររទេះ ជិះម៉ូតូ បណ្តើរកង់ដាក់របស់របរពីលើតាមលទ្ធភាពដែលអាចយកបាន ។ ប៉ាមានកង់មួយ សម្រាប់ដាក់ប្រដាប់ប្រដាប្រើប្រាស់មួយចំនួនដូចជា ចាន ឆ្នាំងនិងគ្រឿងដាំស្ល ហើយបងស្រីនិងខ្ញុំអង្គុយនៅរាបកង់ខាងក្រោយ ។ ម៉ាក់មានផ្ទៃពោះប្អូនស្រីទី៣ ។

ដំណើរជម្លៀសក្រោមអាកាសធាតុក្តៅហួតហែង គ្មានទឹក គ្មានអាហារគ្រប់គ្រាន់ដើម្បីបំពេញក្រពះ ម្យ៉ាងពុលនឹងមនុស្សផងនោះ បានបណ្តាលឲ្យអ្នកធ្វើរដំណើរខ្លះត្រូវស្លាប់និងសន្លប់ ។ ប៉ា

និយាយប្រាប់ថាគាត់បានឃើញមនុស្សប្រុសកន្ទាត់ម្នាក់ដើររហូតដល់ដង្ហក់ខ្យល់ដួលស្លាប់មួយរំពេច ។ គ្រាន់តែចេញផុតពីទីរួមស្រុកភ្នាម កងទ័ពខ្មែរក្រហមបានដាក់ខ្សែត្រៀមការពារមិនឲ្យប្រជាជនត្រឡប់មកក្រោយវិញឡើយ ប្រសិនបើនរណាម្នាក់ហ៊ានប្រឆាំងពួកវានឹងសម្លាប់ចោល ។ គ្រួសាររបស់ខ្ញុំបានធ្វើដំណើររហូតមកដល់ភូមិមួយចម្ងាយប្រហែលជា៧គីឡូម៉ែត្រពីស្រុកស្វាយសុីសុផុន ឈ្មោះភូមិថ្មី ។ ប្រជាជនជម្លៀសដែលបានទៅដល់ទីនោះមិនត្រូវបានអ្នកស្រុកទទួលរាប់អានទេ ។ ពួកយើងបានសម្រាកនៅទីនោះពីរយប់ រួចក៏បន្តដំណើរអស់រយៈពេលពីរថ្ងៃទៀតទើបទៅដល់ភូមិមួយទៀតឈ្មោះភូមិគោកទ្រាស ដោយសារថាប្រធានសហករណ៍ដែលនៅភូមិនោះធ្លាប់មានទំនាក់ទំនងជាមួយមារបស់ម៉ាក់(បាល័ដ្ឋស្រុកស្វាយសុីសុផុន) ទើបប្រធានសហករណ៍ទទួលគាត់ឲ្យនៅទីនោះ ហើយចែកជង្រុកស្រូវមួយឲ្យធ្វើជាខ្ទម ។ បីថ្ងៃបានក្លាយទៅបីឆ្នាំប្រាំបីខែម្ភៃថ្ងៃ ក្រុមគ្រួសាររបស់ខ្ញុំមានទម្លាប់នឹងការរស់នៅជាមួយអ្នកភូមិទៅហើយ ។

នៅភូមិគោកទ្រាស ម៉ាក់ត្រូវប្រធានសហករណ៍តម្រូវឲ្យទៅធ្វើស្រែ ដកសំណាប តាំងពីម៉ោង៧រហូតដល់ម៉ោង៥ល្ងាចទើបត្រឡប់មកផ្ទះវិញ ហើយនៅយប់ម៉ោងប្រហែល១១យប់ម៉ាក់ប៉ានិងអ្នកភូមិត្រូវទៅលើកទំនប់បន្តទៀត ។ ពេលថ្ងៃប៉ាត្រូវបានចាត់តាំងឲ្យទៅឃ្វាលគោ ដឹកសំណាប ស្រូវ និងកាប់ឈើនៅឯភូមិឆ្ងាយៗ ។ ដូច្នេះប៉ាគឺជាចំណែកមួយក្នុងការថែទាំគោរបស់សហករណ៍ដែរ ។ ប៉ាបានប្រាប់ថា ធ្វើការច្រើនមែនប៉ុន្តែ ពួកយើងសម្បូណ៌ហូប ព្រោះប្រធានសហករណ៍ចិត្តល្អ គ្មានអ្នកភូមិណាម្នាក់ត្រូវអត់បាយក្រោមការគ្រប់គ្រងរបស់គាត់ឡើយ ។ មានពេលតិចតួចណាស់ដែលយើងត្រូវដាច់បាយ គឺនៅពេលដែលពួកនិរតីចូលមកកាន់កាប់ ប្រធានសហករណ៍ ឃុំ ភូមិ ចាស់(ពួកពាយ័ព្យ) ត្រូវចាប់យកទៅសម្លាប់ចោលទាំងអស់ ។ ក្រោមការគ្រប់គ្រងរបស់ពួកនិរតីក្រុមគ្រួសាររបស់ខ្ញុំនិងអ្នកភូមិត្រូវដាច់


ត្រូវ ហាក់ (ឪពុក) ត្រូវ ពួយថុង(ប្អូន)

បាយមានតែបបរនិងដំឡូងមីជំនួសវិញ ។ ប៉ុន្តែ ប៉ាបានប្រាប់ថា អ្នកភូមិដែលនៅឆ្ងាយពីភូមិគាត់ ១០គីឡូម៉ែត្ររស់វេទនាជាងភូមិដែលយើងរស់នៅទៅទៀត ។ ពួកយើងបានរស់នៅទីនោះរហូតដល់ថ្ងៃរំដោះ៧មករា ឆ្នាំ១៩៧៩ ។ កងទ័ពខ្មែរក្រហមដែលបាក់ទ័ពបាននាំគ្នារត់ប្រាសអាយុឆ្ពោះទៅខេត្តសៀមរាប ពេលនោះអ្នកទទួលខុសត្រូវខាងអ្វីអាចយករបស់នោះបាន ។ ប៉ាយកបានរទេះគោមួយគ្រឿងនិងគោមួយនឹម រួចប្រញាប់

ប្រញាប់ចាកចេញពីភូមិនោះទាំងយប់ដើម្បីត្រឡប់មកផ្ទះនៅឯស្រុកស្វាយស៊ីសុផុនវិញ ។

ទោះបីជាគ្រួសារខ្ញុំមិនបានឆ្លងកាត់ការលំបាកវេទនាដូចប្រជាជនដទៃទៀតក្នុងរយៈពេលនៃការគ្រប់គ្រងរបស់ខ្មែរក្រហមក៏ដោយ ក៏ម៉ាក់និយាយថា ដោយសារតែខ្មែរក្រហមទើបធ្វើឲ្យឪពុក (ត្រូវ ហាក់) និង ប្អូនប្រុស (ត្រូវ ពួយថុង) របស់គាត់បាត់ខ្លួន ឪពុកមា ម្តាយមីង និងបងប្អូនប្រុសស្រីជីដូនមួយប្រហែលជាង១០នាក់ត្រូវស្លាប់ ។ ចំណែកប៉ាវិញបានប្រាប់ថា ខ្មែរក្រហមបានយកម្តាយរបស់គាត់និងប្អូន៣នាក់ទៅសម្លាប់ចោលដោយចោទថាជា«ក្មាក់ងារយួន» ។ ប្អូនស្រីរបស់ប៉ាបានឃើញឈ្លបខ្មែរក្រហមបណ្តើរម្តាយនិងប្អូនៗរបស់គាត់នៅចំពោះមុខ តែគាត់មិនហ៊ានងើបមុខសម្លឹងមើលទេ ។ ប្អូនថ្លៃស្រីជីដូនមួយរបស់ប៉ាម្នាក់ក៏បានត្រូវកងទ័ពខ្មែរក្រហមចាប់យកទៅវះពោះច្រកស្មៅដែរ ព្រោះថាគាត់ជាស្ត្រីជនជាតិវៀតណាម ។ ខ្ញុំរន្ធត់ចិត្តយ៉ាងខ្លាំង ព្រោះពីមុនមកខ្ញុំមិនដែលនឹកនាថាបងប្អូនរបស់ម៉ាក់និងប៉ាស្លាប់ច្រើនយ៉ាងនេះសោះ ។

រាល់ពេលដែលម៉ាក់និងប៉ាមើលខ្សែភាពយន្តឯកសារស្តីពីព្រឹត្តិការណ៍ក្នុងរបបខ្មែរក្រហមតាមកញ្ចក់ទូរទស្សន៍ គាត់ទាំងពីរតែងរំឭកឡើងវិញថា គាត់នៅតែមិនអស់ចិត្ត ស្តាយអំពីការស្លាប់និងបាត់ខ្លួនរបស់ឪពុកម្តាយនិងប្អូនគាត់ណាស់ ។ ខ្ញុំមិនដឹងថាតើត្រូវធ្វើយ៉ាងណាដើម្បីម៉ាក់និងប៉ាស្ងប់ចិត្តបានទេ ។

ខ្ញុំរីករាយណាស់ដែលបានមកធ្វើការនេះនៅមជ្ឈមណ្ឌលនេះ ដែលជាកន្លែងផ្ទុកនូវឯកសារខ្មែរក្រហមរាប់ម៉ឺនសន្លឹក ។ ខ្ញុំបាននិយាយរឿងរ៉ាវខ្មែរក្រហមប្រាប់ម៉ាក់និងប៉ារបស់តាមរយៈឯកសារជាច្រើនដែលខ្ញុំបានអានអំពីបទឧក្រិដ្ឋខ្មែរក្រហមដែលបានចាប់មនុស្សមកដាក់ទោស រួចធ្វើទារុណកម្ម និងវិស្វរចម្លើយអ្នកទោសឲ្យសារភាព និងការខិតខំប្រឹងប្រែងរបស់មជ្ឈមណ្ឌលដើម្បីជំរុញមានតុលាការអន្តរជាតិមួយក្នុងការនាំយកមេដឹកនាំខ្មែរក្រហមធំៗមកកាត់ទោស ។ ប៉ានិងម៉ាក់សប្បាយចិត្តណាស់នៅពេលឮថានឹងមានតុលាការអន្តរជាតិ ។ ប៉ាតែងតែសួរខ្ញុំថាដំណើរការឲ្យមានតុលាកាអន្តរជាតិដល់ណាហើយ? ។ ប៉ាចង់ឲ្យតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំងអ្នកនៅរស់និងអ្នកស្លាប់ ដើម្បីរកយុត្តិធម៌ឲ្យឪពុកម្តាយបងប្អូនរបស់គាត់ ជនរងគ្រោះកម្ពុជាទាំងអស់ និងព្រលឹងអ្នកដែលបានស្លាប់ក្រោមការគ្រប់គ្រងរបស់ខ្មែរក្រហម ។

**លី សុផល**

## សូមចំរើនពរជូន

លោក ឆាំង យុ នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា

លោកប្រធានជាទីមេត្រី!

អាត្មាបានទទួលព្រឹត្តិបត្រ «ស្វែងការពិត» ចំនួន៨ក្បាលពីលេខ៣០ដល់លេខ៣៨ និងលិខិតរបស់លោករួចហើយ ។

ឯកសារទាំងនេះជាគុណប្រយោជន៍យ៉ាងធំធេងចំពោះសហព័ន្ធសមណនិស្សិតដើម្បីអភិវឌ្ឍសីលធម៌សង្គម ក៏ដូចជាអាត្មាភាពសម្រាប់ចែករំលែកដល់សិស្សនិស្សិត សមណសិស្សសមណនិស្សិត បានអាននិងសិក្សាស្រាវជ្រាវស្វែងយល់ការពិតពីរបបប្រល័យពូជសាសន៍ប៉ុលពត ។ ជាឯកសារផ្តល់នូវចំណេះដឹងខាងសង្គមប្រវត្តិដែលកូនខ្មែរត្រូវតែយល់ដឹង ហើយផ្សព្វផ្សាយទូទៅដល់មនុស្សជំនាន់ក្រោយឲ្យបានដឹងនិងចៀសវាង ។

អាត្មាភាពសូមអរគុណក្រៃលែងចំពោះការផ្តល់នូវឯកសារតាមសំណើនិងការសន្យាផ្តល់នូវព្រឹត្តិបត្រនៅលេខបន្តបន្ទាប់ទៅមុខទៀតរបស់លោក ។ សូមជូនពរលោកនិងសហការីទាំងអស់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា សូមប្រកបតែនឹងពុទ្ធពរគឺ អាយុ វណ្ណៈ សុខៈ ពលៈនិងបដិភាណៈកុំបីឃ្លៀងឃ្លាតឡើយ ។

សូមលោកប្រធានទទួលនូវសេចក្តីស្រឡាញ់អាប់អានដ៏ជ្រាលជ្រៅពីអាត្មាភាពនិងសហព័ន្ធ ។

ភ្នំពេញ,ថ្ងៃទី១០កើត ខែផល្គុន ឆ្នាំមមី ចត្វាស័ក ព.ស ២៥៤៦ត្រូវនឹងថ្ងៃទី១២ ខែមីនា ស.គ ២០០៣

**ជ័យ សុខគ្គិ**

# ខៀវ សំផន បានធ្វើអ្វីខ្លះ?

ខ្ញុំទើបតែបានស្គាល់ទស្សនាវដ្តីរបស់លោកតាមរយៈមិត្តភក្តិម្នាក់ ។ ខ្ញុំបានអានទស្សនាវដ្តីរបស់លោក "ស្វែងរកការពិត" លេខ ២១ ខែកញ្ញា ឆ្នាំ២០០១ ទំព័រ៣៩ ដែលនិពន្ធដោយលោក ហ៊ុយ វណ្ណៈ ។ ត្រង់អត្ថបទមួយ "ប្រវត្តិសង្ខេបរបស់ ខៀវ សំផន ដែលមានថ្ងៃ-ខែ-ឆ្នាំ មិនស្របនឹងព្រឹត្តិការណ៍នៃជីវិតរបស់គាត់ពីឆ្នាំ១៩៥៨ដល់ឆ្នាំ១៩៦០ ។

បើតាមអត្ថបទនេះអ្នកនិពន្ធ ហ៊ុយ វណ្ណៈ សរសេរថា "ឆ្នាំ១៩៥៩ លោក ខៀវ សំផន បញ្ចប់ការសិក្សារបស់គាត់នៅក្រុងប៉ារីស" ។ ដូច្នេះខ្ញុំមានចម្ងល់ពី-បីវគ្គខាងក្រោម÷ ១) នៅឆ្នាំ១៩៥៨ គាត់ (ខៀវ សំផន) ពុំទាន់បានទទួលសញ្ញាប័ត្រនៅឡើយទេ ហើយគាត់នៅរៀនឯប៉ារីស តើគាត់អាចបង្រៀនភាសាបារាំងនិងបង្កើតកាសែត"អុបសែវ៉ាទ័រ"នៅភ្នំពេញបានដែរឬ? ។ ២) ពីឆ្នាំ១៩៥០ដល់ឆ្នាំ១៩៦០ អ្នកនិពន្ធសរសេរថា លោក ខៀវ សំផន ធ្វើជារដ្ឋមន្ត្រីរបស់រាជការសម្តេច នរោត្តម សីហនុ ។ ដូច្នេះគាត់មានឱកាសឯណាមករៀន បើគាត់នៅធ្វើរដ្ឋមន្ត្រី? ឬធ្វើរដ្ឋមន្ត្រីឥតមានសញ្ញាប័ត្រ?

ដូច្នេះខ្ញុំយល់ថា អ្នកនិពន្ធអត្ថបទនេះមានការភ័ន្តច្រឡំខ្លះអំពីថ្ងៃ-ខែ-ឆ្នាំនេះ ឬអ្នកនិពន្ធប្រើឃ្លាប្រយោគពុំច្បាស់ធ្វើឲ្យអ្នកអានឯទៀត(ឬរូបខ្ញុំជាអាទិ៍) យល់ច្រឡំទៅវិញ ។

**សំណូមពររបស់ខ្ញុំ:** សូមឲ្យលោកចាងហ្វាងមេត្តាពិនិត្យដូចតទៅ÷ ក) សំណូមពររបស់ខ្ញុំ សូមឲ្យអ្នកនិពន្ធពិនិត្យ"ឆ្នាំ"នេះសាជាថ្មី ។ ខ) ធ្វើសេចក្តីកែតម្រូវឲ្យបានត្រឹមត្រូវដើម្បីកុំឲ្យអ្នកអានយល់ច្រឡំឬយល់ពុំច្បាស់ ។ គ) ក្នុងឋានៈលោកជាចាងហ្វាងការផ្សាយត្រូវធ្វើការពិនិត្យពិច័យគ្រប់អត្ថបទមុននឹងចុះផ្សាយ ។ ឃ) ខ្ញុំសូមទាញអារម្មណ៍របស់លោកចាងហ្វាងនាយកដែរថា រណ្តៅនិងធាតុដែលជីករកឃើញទាំងប៉ុន្មាននោះពុំមែនសុទ្ធតែធាតុនិងរណ្តៅនិងឆ្អឹងអ្នកដែលត្រូវគេសម្លាប់ពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ទាំងអស់នោះទេ ។ ពីព្រោះសង្គ្រាមនៅស្រុកយើងមានយុគផ្សេងគ្នា និងអ្នកដែលសម្លាប់ខ្មែរឃាតករមានមុខផ្សេងៗគ្នា ។ ដូច្នេះគឺយើងត្រូវចែកជាបីយុគដូចតទៅ÷

**យុគទី១:** ក)ឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ ជាចម្បាំងរវាងសាធារណរដ្ឋជាមួយពួកយួនយៀកមិញ រួមជាមួយពួករំដោះ ។ ឧទាហរណ៍ ទួលល្បៀប(ខេត្តកំពង់ស្ពឺ) ក្អមសំណ ព្រះកន្លង វត្តព្រះវិហារសួគ៌ (ខេត្តកណ្តាល)ព្រៃទទឹង, ស្គន់ (ខេត្តកំពង់ចាម) បារាយណ៍(ខេត្តកំពង់ធំ) តាំងគោក(កំពង់ធំ) ទឹកឆា..(កំពង់សោម)...។ល។ ត្រូវតែមានរណ្តៅខ្មោចដែរ ។

ខ) ឆ្នាំ១៩៧០ដល់ឆ្នាំ១៩៧៥ដែរ តែនៅក្នុងតំបន់រំដោះត្រួតត្រា កាន់កាប់ ក្តោបក្តាប់ដោយពួករំដោះ (ពួករំដោះក្នុងកងរំដោះ ត្រួតត្រាដោយពួកយួនយៀកមិញ យួនយៀកកុង ក្រុមរំដោះនិយមសម្តេចឪ ពួកក្រុមខ្មែរយៀកមិញនិងពួកក្រុមខ្មែរក្រហម ។ ឬស្បៀង សេដ្ឋកិច្ចនិងអាវុធយុទ្ធភ័ណ្ឌទទួលពីយៀកមិញនិងចិនតាមរយៈយួនកុម្មុយនិស្ត ។ ពួកខ្មែរយៀកមិញ ខ្មែរក្រហមជាអ្នកដឹកជញ្ជូនសម្ភារ ឲ្យពួកយៀកមិញ យៀកកុងទេ ។ ជ័យជម្នះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺយៀកមិញ យៀកកុងគេច្បាំងឲ្យ) ។ ពួកក្រុមរំដោះបានចាប់ប្រជារាស្ត្រឃុំឃាំងក្នុងមន្ទីរស្រុកឬឃុំរបស់គេសម្រាប់លត់ដំ ។ ក្នុងមន្ទីរឃុំឃាំងនីមួយៗគេសម្លាប់ប្រជារាស្ត្រស្លូតត្រង់ ឬប្រជារាស្ត្រស្លូតត្រង់ឬប្រជាជនដែលគេចោទប្រកាន់ថា វណ្ណៈជិះជាន់ វណ្ណៈមូលធន ឬសក្តិភូមិ ឬអ្នកលត់ដំពុំបានល្អ ពុំលះបង់កម្មែលសង្គមចាស់...។ល។ ពួកបូព៌ានិយមយួនកុម្មុយនិស្ត គេមិនចូលចិត្តកុម្មុយនិស្ត (យៀកមិញ-យៀកកុង) បានធ្វើបាបរុកគួនសម្លាប់ពួកខ្មែរដែលមានដើមកំណើតចិននិងពួកកូនចៅចិនប្រមាណពីរភាគបីទៅហើយ ព្រោះពេលនោះយួនកុម្មុយនិស្តគេមិនចូលចិត្តកុម្មុយនិស្តបែបលទ្ធិចិនទេ គឺគេទុកតែកុម្មុយនិស្តយួនគ្នាគេ ។ ឧទាហរណ៍រណ្តៅធាតុ(ចេតិយ៍)នៅភូមិពោធិ៍ទន្លេសង្កាត់កោះថ្មី ស្រុកកោះធំ ខេត្តកណ្តាល ទោះជារណ្តៅខ្មោចនិងឆ្អឹងដែលគេសម្លាប់មុនឆ្នាំ១៩៧៥ (ជាស្រុកកំណើតរបស់ខ្ញុំ) ។

គ) ឆ្នាំ១៩៧០-១៩៧៥ដែរ តែក្នុងតំបន់រំដោះ ពួកយួនយៀកមិញ យួនយៀកកុងគេជាសាសន៍តែមួយ ជាតិតែមួយ

ប្រយោជន៍គេតែមួយ ទិសដៅរបស់គេដូចគ្នា គេកម្ចាត់ក្រុមរំដោះសម្តេចឪ ។ (ឧទាហរណ៍ សាស្ត្រាចារ្យរបស់ខ្ញុំ អ៊ុង ឯម មិត្តរបស់ខ្ញុំ នន្ទ ហ៊ុយ, ស៊ុយ ផល...) ក្រុមរំដោះខ្មែរយៀកមិញពួកខ្មែរក្រហមណាដែលស្នេហាជាតិពិតៗ ប្រឆាំងនឹងប្រយោជន៍កុម្មុយនិស្តរបៀបយួនខាងជើង ។ លោកអាចពិចារណាបានហើយថា ខ្មោចទាំងនេះគេកប់នៅទីណា(ក្នុងដីខ្មែរ) តើសម័យណា? ពេលណាដែលគេកកាយរកឃើញ? ក្រោយឆ្នាំ១៩៩១ ? ចន្លោះឆ្នាំ១៩៧៥ឆ្នាំ១៩៩១ ? ។

**យុគទី២:** ឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ក្រោមរបបកម្ពុជាប្រជាធិបតេយ្យខ្មែរក្រហម រណ្តៅខ្មោចដែលសម្លាប់ដោយពួកអង្គការ ។

**យុគទី៣:** ឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៩១ (សន្និសីទនៅក្រុងប៉ារីស) ជាការទទួលខុសត្រូវទាំងអស់របស់បក្សប្រជាជន(ទោះជាប្តូរឈ្មោះយ៉ាងណាក៏ដោយ) និងកងទ័ពឈ្លានពានរបស់កុម្មុយនិស្តយៀកណាមទាំងស្រុងបានសម្លាប់ប្រជារាស្ត្រខ្មែរដោយប្រយោលឬដោយចេញមុខ ។ ឧទាហរណ៍ ផែនការ«ក៥» សូមអានសៀវភៅរបស់អ្នកនិពន្ធឈ្មោះ (Esuiéralda Lucciolli Le Mur de bambou, Régime Deforge ១៩៨៦) រួមសំយោគសេចក្តីហៅថា តើអ្នកឯកទេសណាដែលអាចពិនិត្យឲ្យដឹងថា ធាតុនោះត្រូវស្លាប់មុនឆ្នាំ ១៩៧៥ ធាតុដែលរកឃើញមនុស្សនោះបានស្លាប់មុនឆ្នាំ១៩៧៥ ធាតុរកឃើញមនុស្សនោះស្លាប់ក្រោយឆ្នាំ១៩៧៩ (១៩៧៩) ? ? ? ។ ហើយបើតាមយុគដែលយើងខ្ញុំបានចែកនេះឃើញថា អង្គការខ្មែរក្រហមត្រួតត្រាកម្ពុជាតែ៣ឆ្នាំ៨ខែទេ ។ តែយើងឃើញហើយថាតាំងពីឆ្នាំ១៩៧០ដល់៧៥ ហើយពីឆ្នាំ១៩៧៩ដល់សព្វថ្ងៃ តើនរណាដែលកាន់ខ្វែងរងមុខ និងលោកម្ចាស់ណាបានសោយរាជ្យនៅក្រោមចុងកាណុងរបស់គេយូរជាងគេ គឺអ្នកនោះនិងលោកម្ចាស់នោះមានដៃប្រឡាក់ឈាមខ្មែរច្រើនជាងគេ ។ ខ្ញុំពុំមែនជាអ្នកគាំទ្រអំពើមនុស្សឃាតរបស់ពួកក្រុមខ្មែរក្រហមឬក្រុមណាមួយទៀតទេ ។ ខ្ញុំដាក់ទណ្ឌកម្មយ៉ាងខ្លាំងលើសកម្មភាពទាំងនេះ ព្រោះដើម្បីការពារមនុស្សជាតិ ។ ម្យ៉ាងទៀតខ្ញុំត្រូវរែកញែកឲ្យឃើញការពិតខ្លះដូចក្នុងបំណងនៃទស្សនាវដ្តីរបស់លោកថា «ស្វែងរកការពិត»ដែរ ។ យោបល់បញ្ចប់យើងអាចសួរថាៈ តើនរណាជាអ្នកទទួលទណ្ឌកម្មច្រើនជាងគេក្នុងឃាតកម្មលើប្រជារាស្ត្រខ្មែរ? តើកំហុសទាំងអស់មកពីណា? តើហេតុអ្វីបានជាអ្នកដឹកនាំប្រទេសតូចតាចដទៃទៀត(ដែលតូចជាងប្រទេសកម្ពុជាផង) ហេតុអ្វីបានជាគេគេចចេញរួចអំពីខ្យល់កំបុតត្បូងនេះ (មនោគមវិជ្ជាកុម្មុយនិស្ត និងសេរីនិយម ប្រជាធិបតេយ្យនិយម) បាន ។

ក) យើងគួរក្រឡេកមើលកំហុសរបស់យើងសិន ។ ក្រោយពីសតវត្សរ៍ទី១៨មក រាជានិយមត្រូវរង្គោះរង្គើអស់ ។ មហាក្សត្រីយ៍និងអ្នកដឹកនាំខ្មែរក្រោយសតវត្សរ៍ទី១៨ ច្រើនតែតែងតាំងដោយបរទេស(សៀម យួន)... ។ ក្រោយមកទៀតឆ្នាំ ១៨៦៣ រហូតដល់សព្វថ្ងៃអ្នកដឹកនាំខ្មែរពុំដែលបានឡើងដឹកនាំដោយស្របច្បាប់ខ្មែរ ឬតាមឆន្ទៈខ្មែរប្រជារាស្ត្រខ្មែរជ្រើសរើសនោះទេ គឺសុទ្ធសឹងតែបន្តុប តម្លើង ដំទើត កាន់ខ្វែងរងមុខដោយបរទេស ។ ហើយអ្នកដឹកនាំនោះឯងសុទ្ធសឹងជាអ្នកដែលត្រូវ «គ្រាសកន្ទេល» ដូច្នេះហើយទើបគ្រប់ៗជំនាន់អ្នកដឹកនាំដែលបរទេសបន្តុបកាន់ខ្វែងរងមុខដោយបរទេសនោះ «ហុចដាវតែពីខាងដងឲ្យទៅចោរ» ... ។ ខ) នរណាគេការពារយើងបាន បើយើងមិនចេះ ការពារប្រទេស រៀបចំប្រទេស ។ នរណាគេយកទ័ពទីគេមកស្លាប់ជំនួសយើង ។ យើងមានច្បាប់អន្តរជាតិការពារមែនតែដល់ពេលមានវិបត្តិយើងឥតហៅពឹងច្បាប់នេះយកមកអះអាងជាសក្ខីភាពផងទេ ។ ឧទាហរណ៍ សន្និសីទថ្ងៃ២៣ ខែតុលា ឆ្នាំ១៩៩១ នៅប៉ារីស ឬកម្ពុជាជាសមាជិកសមាគមអាស៊ានដែរ តែយើងឥតប្តឹងផ្តល់ដល់សមាគមនេះទេ នៅពេលមានវិបត្តិរវាងសមាជិកនិងសមាជិក ។ យើងបង់តម្លៃចូលសមាជិករាប់លានដុល្លារនេះ តើប្រយោជន៍អ្វី? ។ គ) ប្រាកដមែនហើយ តាមច្បាប់ធម្មជាតិម្លប់ឈើធំតែងតែគ្របដណ្តប់មកលើឈើតូចតាច ។ តែយើងឈើតូចតាចឥតលូតលាស់ ឥតរំដោះឥតរើបម្រះពីម្លប់សោះដើម្បីរកសន្សើមដោយខ្លួនឯងឡើយ ។ ដូច្នេះប្រជារាស្ត្រខ្មែរគ្នាឥតមានទទួលខុសត្រូវក្នុងរឿងជាតិសោះទេ ។ ប្រជារាស្ត្រខ្មែរចាំតែទទួលរងកម្មតែប៉ុណ្ណោះ ។ គឺអ្នកដឹកនាំប្រជារាស្ត្រខ្មែរដែលទទួលខុសត្រូវខ្លួនឯងមួយរយភាគរយ ។

សូមលោកចាងហ្វាងទទួលរងនូវការរាប់អាននិងមេត្រីភាពដ៏ស្មោះត្រង់អំពីខ្ញុំ ។

**ហម ឆាយលី**

# ខៀវ សំផន បានធ្វើកិច្ចការមួយចំនួន

*ខៀវ សំផន គឺជាអតីតគណៈប្រធានរដ្ឋនៃរបបកម្ពុជាប្រជាធិបតេយ្យធ្លាប់និយាយដោយផ្ទាល់ តាមរយៈសារពត៌មានក្នុងស្រុកថា ខ្លួនគាត់បានអានទស្សនាវដ្តី“ស្វែងរកការពិត”របស់មជ្ឈមណ្ឌលឯកសារកម្ពុជាជាច្រើនលេខ ។ ក្នុងនោះគាត់ក៏បានអានអត្ថបទរបស់ខ្ញុំដែលសរសេរអំពីប្រវត្តិរូបសង្ខេបរបស់គាត់ដែរ ។ ខ្ញុំសូមធ្វើអត្ថាធិប្បាយទាក់ទងសំណួររបស់លោកដោយចាប់ផ្តើមករណីរបស់ ខៀវ សំផន ។*

*នៅឆ្នាំ១៩៥០ ខៀវ សំផន បានសិក្សាផ្នែកសេដ្ឋកិច្ចនៅសាកលវិទ្យាលម៉ុងប៉ែលលីយេ* Montpellier *ប្រទេសបារាំង ហើយបន្ទាប់មកគាត់ត្រូវបានគាត់ផ្តាច់អាហាររូបករណ៍វិញដោយសារតែទាក់ទិនបញ្ហានយោបាយ ។ នៅឆ្នាំ១៩៥៤ ខៀវ សំផន បានធ្វើជាចាងហ្វាងកាសែត អ៊ុបស៊ែរវ៉ាទ័រ* L'observateur *ដែលមានទីស្នាក់ការនៅទីក្រុងភ្នំពេញ ។*

*គោលបំណងនៃការបង្កើតកាសែតនេះ ខៀវ សំផន បានគូសបញ្ជាក់នៅក្នុង “សំបុត្រចំហជូនបងប្អូនជនរួមជាតិទាំងអស់” ដែលផ្សាយចេញពីទីក្រុងប៉ៃលិននាថ្ងៃទី១៦ ខែសីហា ឆ្នាំ២០០១ថា “ដើម្បីខិតខំឆ្លុះបញ្ចាំងនូវមតិរបស់បញ្ញាជន គ្រូបង្រៀន និងអ្នករាជការមួយចំនួនធំដែលគាំទ្រពេញទំហឹងចំពោះនយោបាយអព្យាក្រិត្យរបស់សម្តេចព្រះ នរោត្តម សីហនុ តែព្រមជាមួយនេះក៏គេយល់ឃើញថា ចាំបាច់មានវិធានការប្រជាធិបតេយ្យមួយចំនួនសំដៅឲ្យមានតុល្យភាពសង្គម ដើម្បីពង្រឹកមូលដ្ឋាននយោបាយអព្យាក្រិត” ។ សេចក្តីពិស្តារបន្ថែមទៀតនោះ លោកអាចមើលនៅក្នុងទំព័រទស្សនាវដ្តីស្វែងរកការពិតលេខ២១ ខែកញ្ញា ឆ្នាំ២០០១ ។*

*នៅថ្ងៃទី១៣ ខែឧសភា ឆ្នាំ១៩៥៩ ខៀវ សំផន បានបញ្ចប់និក្ខេបបទថ្នាក់បណ្ឌិតដែលមានចំណងជើងថា* “The Economy of Cambodia and Its Problems with Industrialzation” *។ នៅឆ្នាំ១៩៦០ ខៀវ សំផន បានវិលត្រឡប់ពីប្រទេសបារាំងវិញរួមជាមួយ ហ៊ូ យន់, ហ៊ូ នឹម, ភោគ ឆាយ និងមនុស្សមួយចំនួនទៀត ។ ខ្ញុំមាននិក្ខេបនេះ ហើយខ្ញុំក៏ធ្លាប់បានអានដែរ ។ សេចក្តីពិស្តារបន្ថែមទៀតនោះ លោកអាចមើលនៅក្នុងអ៊ីនធឺណែតស្តីអំពីទិន្នន័យអំពើប្រល័យពូជសាសន៍នៅកម្ពុជា* www.dccam.org(database section) *។*

*ទាក់ទិននឹងសំណួរអំពីតួលេខរណ្តៅសាកសពនិងអដ្ឋិធាតុជនរងគ្រោះនៅក្នុងរបបខ្មែរក្រហម ខ្ញុំសូមបញ្ជាក់ថា ទម្រាំឈានដល់ការសម្រេចយកទិន្នន័យនៃទីតាំងនីមួយៗ បុគ្គលិកស្រាវជ្រាវត្រូវបានណែនាំឲ្យផ្ទៀងផ្ទាត់ពត៌មានយ៉ាងហ្មត់ចត់បំផុត ។ ពត៌មានស្តីពីទីតាំងនីមួយៗបានមកពីការសម្ភាសន៍សាក្សីដែលបានរកឃើញផ្ទាល់និងធ្លាប់បានដឹងឮយ៉ាងហោចប្រាំនាក់ អាជ្ញាធរមូលដ្ឋានយ៉ាងហោចពីរនាក់ដើម្បីបញ្ជាក់ថា ទីតាំងទាំងនេះពិតជាទីតាំងឧក្រិដ្ឋកម្មរបស់ខ្មែរក្រហម ។*

*ក្រៅអំពីការសម្ភាសន៍សាក្សីដែលបានឃើញនិងដឹងឮយ៉ាងហេតុការណ៍ផ្ទាល់ ទិន្នន័យនៃទីតាំងនីមួយៗត្រូវយកមកផ្ទៀងផ្ទាត់ជាមួយរបាយការណ៍ទីតាំងរណ្តៅសាកសពរបបខ្មែរក្រហមដែលស្រាវជ្រាវដោយអ្នកស្រាវជ្រាវមុនៗ ។ ជាមួយគ្នានេះ ទីតាំងនីមួយៗត្រូវកំណត់ដោយម៉ាស៊ីនកំណត់ទីតាំងភូមិសាស្ត្រពិភពលោកហៅកាត់ថា ជីភីអេស* (GPS: Global Position System) *ថែមទៀត ដើម្បីធានាទីតាំងច្បាស់លាស់តាមប្រព័ន្ធផ្កាយរណប ។*

*ក្នុងការស្រាវជ្រាវទីតាំងរណ្តៅសាកសពនេះទៀតសោត ក្រុមស្រាវជ្រាវនៃមជ្ឈមណ្ឌលឯកសារកម្ពុជាបានសហការជាមួយវេជ្ជបណ្ឌិតជំនាញចំនួនបួនរូបមក ដែលអ្នកទាំងនោះធ្លាប់បានធ្វើកោសល្យវិច័យឆ្អឹងសាកសពសម្រាប់តុលាការនៅប្រទេសទីម័រខាងកើត ។ ចំពោះពត៌មានពិស្តារនោះលោកអាចមើលនៅក្នុងអ៊ិនធឺណែត ។ ខ្ញុំសូមអរគុណចំពោះលោកដែលបានអាននិងចូលរួមយោបល់ចំពោះទស្សនាវដ្តីស្វែងរកការពិតនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ព្រមទាំងផ្តល់ឯកសារដ៏មានសារប្រយោជន៍ដល់មជ្ឈមណ្ឌល ។ ប្រសិនបើលោកមានចម្ងល់បន្ថែមចំពោះពត៌មានដទៃទៀតដែលបានចុះផ្សាយនៅក្នុងទំព័រទស្សនាវដ្តីស្វែងរកការពិត សូមទំនាក់ទំនងតាមទូរស័ព្ទលេខ (៨៨៥)២៣ ២១១ ៨៧៥ឬ* Email: dccam@online.com.kh *។ សូមអរគុណ ។*

**ហ៊ុយ វណ្ណៈ**




ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា
ទស្សនាវដ្ដីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល

មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្ដីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន ។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្ដីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

**A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 39, March 2003.**
**Funded by Norway, Sweden, Switzerland, the Netherlands and USA.**